អភិបាលកិច្ចដីធ្លី សម្រាប់ ស្ត្រី និងបុរស

សេចក្តីណែនាំបច្ចេកទេស ដើម្បីគាំទ្រដល់ការសម្រេចអភិបាលកិច្ចលើការកាន់កាប់ដី ប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ

សេចក្ដីណែនាំបច្ចេកទេសស្ដីពីអភិបាលកិច្ចលើការកាន់កាប់ដី លេខ១

អភិបាលកិច្ចដីធ្លី
សម្រាប់ ស្ត្រី និងបុរស

សេចក្ដីណែនាំបច្ចេកទេស ដើម្បីគាំទ្រដល់ការសម្រេចអភិបាលកិច្ចលើការកាន់កាប់ដី
ប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ
ទីក្រុងរ៉ូម ២០១៣

បោះពុម្ពឡើងវិញលើកទី១៖ មករា ២០១៣
បោះពុម្ពឡើងវិញលើកទី២៖ មិថុនា ២០១៣

ការហៅឈ្មោះទាំងឡាយ និង ការបង្ហាញឯកសារនៅក្នុងផលិតផលព័ត៌មាននេះ មិនមែនមានន័យថាជាការសម្តែងមតិណាមួយរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់ ឬ ស្ថានភាពអភិវឌ្ឍន៍របស់ប្រទេស ដែនដី ទីក្រុង ឬ តំបន់ណាមួយ ឬ អាជ្ញាធរនៃប្រទេស ដែនដី ទីក្រុង ឬ តំបន់ ឬ ពាក់ព័ន្ធនឹងការកំណត់ព្រំដែនរបស់ប្រទេស ដែនដី ទីក្រុង ឬ តំបន់ទាំងនេះឡើយ។ ការលើកឡើងអំពីក្រុមហ៊ុន ឬ ផលិតផលរបស់ម្ចាស់កម្មន្តសាលជាក់លាក់ណាមួយ ទោះបីជាក្រុមហ៊ុន ឬ ផលិតផលទាំងនេះមាន ឬ គ្មានប៉ាតង់ក្តី មិនមែនមានន័យថាក្រុមហ៊ុន ឬ ផលិតផលទាំងនេះត្រូវបានគាំទ្រ ឬ ណែនាំដោយ FAO ថាមានការពេញចិត្តជាងក្រុមហ៊ុន ឬ ផលិតផលស្រដៀងគ្នាដទៃទៀតដែលមិនបានលើកឡើងនោះទេ។

ទស្សនៈដែលបានស្តែងចេញនៅក្នុងផលិតផលព័ត៌មាននេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងពុំចាំបាច់ត្រូវឆ្លុះបញ្ចាំងអំពីទស្សនៈ ឬគោលនយោបាយរបស់អង្គការ FAO ឡើយ។

ISBN 978-92-5-107403-9 (print)
E-ISBN 978-92-5-107724-5 (PDF)

© FAO 2013

FAO លើកទឹកចិត្តដល់ការប្រើប្រាស់ ការផលិតឡើងវិញ និងការផ្សព្វផ្សាយឯកសារនៅក្នុងផលិតផលព័ត៌មាននេះ។ លើកលែងតែមានការហាមឃាត់បើពុំនោះសោតទេ គេអាចថតចម្លង ដោនឡូត និងបោះពុម្ពឯកសារនេះសម្រាប់គោលបំណងសិក្សាស្រាវជ្រាវលក្ខណៈឯកជន និងការបង្រៀន ឬសម្រាប់ប្រើប្រាស់នៅក្នុងផលិតផល ឬ សេវាកម្មដែលពុំមានលក្ខណៈជាការធ្វើអាជីវកម្ម ឱ្យតែមានការទទួលស្គាល់សមស្របថា អង្គការ FAO គឺជាប្រភពព័ត៌មាន និងជាម្ចាស់សិទ្ធិអ្នកនិពន្ធ ហើយការអនុម័តរបស់អង្គការ FAO ទៅលើទស្សនៈ លទ្ធផល ឬ សេវារបស់អ្នកប្រើប្រាស់ មិនត្រូវបានបកស្រាយក្នុងលក្ខណៈណាមួយ។

រាល់សំណើសុំសិទ្ធិធ្វើការបកប្រែ និងការយកលំនាំតាម ព្រមទាំងការស្នើសុំសិទ្ធិលក់ដូរ និងសិទ្ធិប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្មដទៃទៀត គួរធ្វើឡើងតាមរយៈ www.fao.org/contact-us/ licencerequest ឬ ផ្ញើទៅកាន់ copyright@fao.org. ។

រាល់ផលិតផលព័ត៌មានរបស់អង្គការ FAO អាចរកបាននៅក្នុងវ៉ិបសាយរបស់អង្គការ FAO (www.fao.org/ publications) និងអាចទិញបានតាមរយៈអ៊ីម៉ែល publications-sales@fao.org.

សេចក្តីថ្លែងអំណរគុណ

សេចក្តីណែនាំបច្ចេកទេសស្តីពី *អភិបាលកិច្ចលើការកាន់កាប់ដីធ្លី សម្រាប់ស្ត្រី និង បុរស* ត្រូវបានរៀបចំឡើងដោយក្រុមការងារមួយក្រុម ដែលដឹកនាំដោយ Elizabeth Daley និងរួមមានសមាជិកក្រុមការងារដូចជា Clara Mi Young Park, Francesca Romano, Leila Shamsaifar, Ting-Hui Lau និង Babette Wehrmann។ សេចក្តីណែនាំនេះ ត្រូវបានរៀបចំជាសេចក្តីព្រាងដោយ Elizabeth Daley និង Clara Mi Young Park ជាមួយនិងអ្នករួមចំណែកផ្តល់ឯកសារ និងមាតិកាដទៃទៀត ដូចជា Judy Adoko, Dalal Alnaggar, Marianna Bicchieri, Patricia Costas, Kate Dalrymple, Nigel Edmead, Debra Anne Fletcher, Seema Gaikwad, Catherine Gatundu, Renée Giovarelli, Paolo Groppo, Nora Heil, Adriana Herrera-Garibay, Rachael Knight, Annalisa Mauro, Eliane Najros, Esther Obaikol, Martha Osorio, Sabine Pallas, Neil Pullar, Peter Rabley, Rebecca Sittie, Elizabeth Stair, Josephine Stowers-Fiu, Mika- Petteri Törhönen, Margret Vidar និង Babette Wehrmann។

សេចក្តីណែនាំនេះ ទទួលបានការផ្តល់មតិយោបល់ពី Dubravka Bojic, Paolo Groppo, Paul Munro-Faure, Ana Paula de la O Campos, Martha Osorio, David Palmer, Neil Pullar, Francesca Romano, Margret Vidar និង Babette Wehrmann។ សេចក្តីណែនាំនេះ ក៏ត្រូវបានត្រួតពិនិត្យពីជំនាញការខាងក្រៅ ដូចជា Bayarmaa Byambaa, Catherine Gatundu, Renée Giovarelli, Susana Lastarria-Cornhiel, Sabine Pallas, Siraj Sait, Agatha Wanyonyi និងក្រុមការងារអាល្លឺម៉ង់ទទួលបន្ទុកការងារដីធ្លី ដែលត្រូវបានរៀបចំឡើងដោយទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (GIZ) ។ សេចក្តីណែនាំនេះ ត្រូវបានពិនិត្យកែសម្រួលដោយ Jane Shaw និងរៀបចំរចនាបទដោយ Luca Feliziani ។

អង្គការ FAO សូមថ្លែងអំណរគុណចំពោះមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម (IFAD) សម្រាប់ការផ្តល់មូលនិធិគាំទ្រដល់ការអភិវឌ្ឍន៍ និង ការរៀបចំសេចក្តីណែនាំបច្ចេកទេសនេះ។

បុព្វកថា

នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ គណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក បានអនុម័តទៅ*លើគោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ* (គោលការណ៍ណែនាំ)។ ផ្អែកលើការគោលណែនាំនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងដោយទទួលស្គាល់អំពីសារៈសំខាន់នៃដីចំពោះការអភិវឌ្ឍន៍ គោលការណ៍ណែនាំទាំងនេះមានបំណងរួមចំណែកដល់កិច្ចខិតខំកម្រិតសកល និងកិច្ចខិតខំនៅកម្រិតថ្នាក់ជាតិ សំដៅលុបបំបាត់ភាពអត់ឃ្លាន និងភាពក្រីក្រ តាមរយៈការលើកកម្ពស់សិទ្ធិកាន់កាប់ដីធ្លី និងលទ្ធភាពប្រើប្រាស់ដី ជលផល និងព្រៃឈើប្រកបដោយសមធម៌។

សេចក្តីណែនាំបច្ចេកទេសស្តីពី*អភិបាលកិច្ចដីធ្លីសម្រាប់ស្ត្រី និង បុរស* នេះ មានគោលបំណងជួយដល់ការអនុវត្តន៍គោលការណ៍សមធម៌យេនឌ័រ នៃគោលការណ៍ណែនាំ តាមរយៈការសម្រេចឱ្យបាននូវអភិបាលកិច្ចលើការកាន់កាប់ដី ប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ។

ការរៀបចំសេចក្តីណែនាំនេះ រួមមានការស្រាវជ្រាវ និងការពិគ្រោះយោបល់ជាច្រើន ដែលនាំឱ្យឈានទៅដល់ការផលិតឯកសារការងារមួយរបស់អង្គការ FAO ក្នុងខែកុម្ភៈ ឆ្នាំ២០១១ *អភិបាលកិច្ចដីធ្លីសម្រាប់ស្ត្រី និងបុរស - គោលការណ៍ណែនាំអំពីយេនឌ័រ និង គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ និងធនធានធម្មជាតិដទៃទៀត* (FAO, 2011a)។ ឯកសារការងារនេះបានធ្វើការវិភាគ និងកំណត់រកប្រធានបទ និងបញ្ហាចម្បងៗដែលត្រូវគ្របដណ្តប់នៅក្នុងសេចក្តីណែនាំនេះ។

ដើម្បីជួយកំណត់រកការអនុវត្តន៍ល្អ សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ សិក្ខាសាលាបច្ចេកទេសមួយត្រូវបានរៀបចំឡើង ក្នុងខែឧសភា ឆ្នាំ២០១១ នៅឯការិយាល័យកណ្តាលរបស់អង្គការ FAO ក្នុងទីក្រុងរ៉ូម។ "អភិបាលកិច្ច ដីធ្លីសម្រាប់ស្ត្រី និងបុរស - សិក្ខាសាលាស្តីពីអភិបាលកិច្ចលើការកាន់កាប់ដី ប្រកបដោយសមធម៌យេនឌ័រ" បានពាំនាំអ្នកអនុវត្តការងារលើវិស័យដីធ្លីពីភាគីរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនទូទាំងពិភពលោក ដើម្បីចែករំលែកបទពិសោធន៍ និង អភិក្រមជាក់ស្តែង ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រ នៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។ លទ្ធផលនៃសិក្ខាសាលានេះ បានរួមចំណែកយ៉ាងខ្លាំងចំពោះការធ្វើឱ្យមាតិកានៃសេចក្តីណែនាំនេះ កាន់តែមានភាពសម្បូរបែប។

ក្រោយពេលអនុម័តទៅលើគោលការណ៍ណែនាំ ក្រុមការងាររៀបចំសេចក្តីព្រាងបានពិនិត្យសម្រេចទៅលើសេចក្តីណែនាំបច្ចេកទេសនេះ តាមរយៈដំណើរការមួយដែលអនុញ្ញាតឱ្យមានការត្រួតពិនិត្យដោយសហការីដទៃទៀត។

Alexander Müller
ជំនួយការអគ្គនាយក

មាតិកា

iii
សេចក្តីថ្លែងអំណរគុណ

iv
បុព្វកថា

សេចក្តីផ្តើម

3
តើសេចក្តីណែនាំនេះ និយាយអំពីអ្វី?

5
តើសេចក្តីណែនាំនេះ មានវិសាលភាព និង
ដែនកំណត់ដូចម្តេចខ្លះ?

6
ហេតុអ្វីចាំបាច់ត្រូវមានសេចក្តីណែនាំបច្ចេកទេស
ស្តីពីអភិបាលកិច្ចលើការកាន់កាប់ដី ប្រកបដោយ
សមធម៌យេនឌ័រ?

7
តើម៉ូឌុលទាំងអស់គ្របដណ្តប់លើបញ្ហាសំខាន់ៗ
អ្វីខ្លះ?

8
សេចក្តីណែនាំនេះ សម្រាប់នរណា និង
តើគួរប្រើប្រាស់សេចក្តីណែនាំនេះយ៉ាងដូចម្តេច?

10
ឯកសារយោង

ម៉ូឌុល១ ៖ ការបង្កើតគោលនយោបាយ

13
សេចក្តីផ្តើម

14
ភាពខុសគ្នារវាងគោលនយោបាយដីធ្លី និង
អភិបាលកិច្ចនៅក្នុងការបង្កើតគោលនយោបាយ
ស្តីពីដីធ្លី

15
ការកសាងឱ្យមានការចូលរួមប្រកបដោយសមធម៌
យេនឌ័រ នៅក្នុងដំណើរការបង្កើតគោលនយោបាយ
ស្តីពីដីធ្លី

22
តួនាទីរបស់អ្នកពាក់ព័ន្ធនៅក្នុងការបង្កើតគោលនយោបាយស្តីពីដីធ្លី ប្រកបដោយសមធម៌យេនឌ័រ
29
ការបង្កើតគោលនយោបាយស្តីពីដីធ្លីនៅថ្នាក់មូលដ្ឋាន
30
ការសង្ខេបអំពីសារសំខាន់ៗស្តីពីការបង្កើតគោលនយោបាយ
32
ឯកសារយោង

ម៉ូឌុល២ ៖ បញ្ហាច្បាប់

35
សេចក្តីផ្តើម
37
ទិដ្ឋភាពផ្នែកច្បាប់ផ្សេងៗគ្នាពីទស្សនៈវិស័យយេនឌ័រ
46
ការរៀបចំសេចក្តីព្រាងច្បាប់ និយ័តកម្ម និងនីតិវិធី
53
អភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយសមធម៌យេនឌ័រ និងការអនុវត្តន៍សិទ្ធិចំពោះដីធ្លី
70
ការសង្ខេបអំពីសារសំខាន់ៗស្តីពីបញ្ហាច្បាប់
72
ឯកសារយោង

ម៉ូឌុល៣ ៖ ស្ថាប័ន

75
សេចក្តីផ្តើម
76
ស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី
79
ស្ថាប័នដែលទាក់ទងទៅនឹងដីធ្លី
82
ស្ថាប័នដទៃទៀត
87
ការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ
89
ភាពជាតំណាងប្រកបដោយសមធម៌យេនឌ័រនៅក្នុងវិជ្ជាជីវៈបច្ចេកទេស
94
សង្ខេបអំពីសារសំខាន់ៗស្តីពីស្ថាប័ន
96
ឯកសារយោង

ម៉ូឌុល ៤ ៖ បញ្ហាបច្ចេកទេស

99
សេចក្តីផ្តើម
100
បញ្ហាទូទៅទាក់ទងនឹងរដ្ឋបាលដីធ្លី និងការគ្រប់គ្រងដីធ្លី
105
ការចុះបញ្ជីសិទ្ធិកាន់កាប់
106
ការអង្កេត ការផ្តល់ប្លង់ និងការចុះបញ្ជីដីធ្លី
114
ការវាយតម្លៃ
115
ការកំណត់ពន្ធ
116
ការធ្វើផែនការប្រើប្រាស់ដី
119
ការច្របាច់បញ្ចូលគ្នា និងការកែសម្រួលដីឡើងវិញ
121
ការបែងចែកដីឡើងវិញ និងបដិទាន
123
កំណែទម្រង់លើការបែងចែកដីឡើងវិញ
125
សំណង
127
សង្ខេបអំពីសារសំខាន់ៗ ស្តីពីបញ្ហាបច្ចេកទេស
129
ឯកសារយោង

ម៉ូឌុល ៥ ៖ ការបញ្ជូនសារ

132
សេចក្ដីផ្ដើម
133
ការលើកកម្ពស់ការយល់ដឹង ការបញ្ជ្រាបយេនឌ័រ និងការតស៊ូមតិ
140
អក្ខរកម្មផ្នែកច្បាប់
142
យុទ្ធសាស្ត្រ និងវិធីសាស្ត្រប្រាស្រ័យទាក់ទង និងលើកកម្ពស់ការយល់ដឹង
150
ការផ្លាស់ប្ដូរគុណតម្លៃ និងឥរិយាបថ
152
សង្ខេបអំពីសារសំខាន់ៗស្ដីពីការបញ្ជូនសារ
154
ឯកសារយោង

ធនធាន និងឯកសារយោង
155
សេចក្ដីផ្ដើម
155
បទបង្ហាញនៅឯសិក្ខាសាលាបច្ចេកទេស ដែលប្រព្រឹត្តធ្វើឡើងនៅ ខែឧសភា ឆ្នាំ២០១១
157
ឯកសារយោង និងអំណានបន្ថែម
162
ធនធានបន្ថែមទៀត សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយសមធម៌យេនឌ័រ
164
លិខិតុបករណ៍អន្តរជាតិ ដើម្បីគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ



សេចក្ដីផ្ដើម

បញ្ជីរាយនាមប្រអប់ និង តារាងរូបភាព

ប្រអប់

3
ប្រអប់ទី១ ៖ គោលការណ៍អនុវត្ត នៃគោលការណ៍ណែនាំដែលពាក់ព័ន្ធទៅនឹងសមភាព និងសមធម៌យេនឌ័រ
6
ប្រអប់ទី២ ៖ បទប្បញ្ញត្តិរបស់អនុសញ្ញា CEDAW ដែលគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ

តារាង និង រូបភាព

4
តារាងទី១ ៖ និយមន័យ
7
តារាងទី២ ៖ មាតិកានៃសេចក្ដីណែនាំនេះ
9
រូបភាពទី១ ៖ ម៉ូឌុល និង អ្នកពាក់ព័ន្ធនានា

សេចក្តីផ្តើម

អភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយសមធម៌យេនឌ័រ

"រដ្ឋគប្បីពិចារណាអំពីឧបសគ្គដោយឡែកដែលស្ត្រី និងកុមារីជួបប្រទះ ទាក់ទងទៅនឹងការកាន់កាប់ និងសិទ្ធិកាន់កាប់ដែលពាក់ព័ន្ធ ព្រមទាំងចាត់វិធានការនានា ដើម្បីធានាឱ្យបានថាក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ផ្តល់កិច្ចការពារគ្រប់គ្រាន់ជូនស្ត្រី និង ធានាថាច្បាប់ដែលទទួលស្គាល់សិទ្ធិកាន់កាប់របស់ស្ត្រី ត្រូវបានអនុវត្ត និងប្រតិបត្តិ..... រដ្ឋគប្បីអភិវឌ្ឍគោលនយោបាយ ច្បាប់ និង នីតិវិធីពាក់ព័ន្ធនានា តាមរយៈកិច្ចដំណើរការដោយមានការចូលរួម ដែលពាក់ព័ន្ធភាគីរងផលប៉ះពាល់ទាំងអស់ ដោយធានាឱ្យបានថា ទាំងបុរស និងស្ត្រីត្រូវបានរាប់បញ្ចូលតាំងពីដំបូង"។

*(គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និង ព្រៃឈើ ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ **កថាខ័ណ្ឌ ៥.៤ និង ៥.៥**)។*

តើសេចក្តីណែនាំនេះ និយាយអំពីអ្វី?

សេចក្តីណែនាំបច្ចេកទេស ស្តីពី*អភិបាលកិច្ចដីធ្លី សម្រាប់ស្ត្រី និងបុរស* នេះ មានគោលបំណងជួយដល់ការអនុវត្តន៍ *គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និង ព្រៃឈើ ក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ* (FAO 2012b) តាមរយៈការផ្តល់ការណែនាំ ដែលគាំទ្រដល់គោលការណ៍សមភាពយេនឌ័ររបស់គោល-ការណ៍ណែនាំ នៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដី។ នៅផ្នែកដំបូងនៃម៉ូឌុលនីមួយៗ គេបានសំដៅយោងចំពោះបទប្បញ្ញត្តិពាក់ព័ន្ធ នៅក្នុងគោលការណ៍ណែនាំ។

សេចក្តីណែនាំនេះ ផ្តោតលើបញ្ហាសមធម៌ និង របៀបដែលការកាន់កាប់ដីធ្លីអាចត្រូវបានគ្រប់គ្រង ក្នុងលក្ខណៈមួយដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងអាទិភាពផ្សេងៗគ្នារបស់ស្ត្រី និងបុរស។ សេចក្តីណែនាំនេះ ដកចេញឆ្ងាយពីការពិភាក្សាយូរអង្វែងអំពីសមភាពយេនឌ័រ ក្នុងការទទួលបានដីធ្លី សំដៅឆ្ពោះទៅរកការបញ្ជ្រាបអំពីបញ្ហាយេនឌ័រ ដើម្បីសម្រេចឱ្យបាននូវការចូលរួមប្រកបដោយសមធម៌យេនឌ័រកាន់តែប្រសើរជាងមុន នៅក្នុងដំណើរការ និងស្ថាប័ននានា ដែលធ្វើសេចក្តីសម្រេចចិត្តអំពីបញ្ហាដីធ្លី។

ប្រអប់ទី១ ៖

គោលការណ៍អនុវត្ត នៃគោលការណ៍ណែនាំដែលពាក់ព័ន្ធទៅនឹង សមភាព និងសមធម៌យេនឌ័រ

ប្រភព ៖ FAO 2012b

៣.ខ.១ សេចក្តីថ្លៃថ្នូររបស់មនុស្ស៖ ទទួល ស្គាល់សេចក្តីថ្លៃថ្នូរពីកំណើត និង សិទ្ធិមនុស្សស្មើភាពគ្នា និងមិនអាចផ្តាច់បានរបស់បុគ្គលគ្រប់រូប។
៣.ខ.២ មិនមានការរើសអើង៖ មិនមានអ្នកណាម្នាក់គប្បីទទួលរងការរើសអើងឡើយ បើយោងតាមច្បាប់ និងគោលនយោបាយ ក៏ដូចជាក្នុងការអនុវត្តន៍ជាក់ស្តែង។
៣.ខ.៣ សមធម៌ និងយុត្តិធម៌៖ ការទទួល ស្គាល់សមភាពរវាងបុគ្គល អាចតម្រូវឱ្យមានការទទួលស្គាល់ភាពខុសគ្នារវាងបុគ្គល និង ការធ្វើសកម្មភាពវិជ្ជមាន រួមទាំងការផ្តល់អំណាច ដើម្បីជំរុញសិទ្ធិកាន់កាប់ប្រកបដោយសមធម៌ និង លទ្ធភាពប្រើប្រាស់ដី ជលផល និង ព្រៃឈើ សម្រាប់មនុស្សទាំងអស់គ្នា ពោលគឺ ស្ត្រី និងបុរស យុវជន និង ប្រជាជនងាយរងគ្រោះ និងប្រជាជនដែលរមែងតែងត្រូវបានគេមើលរំលង ក្នុងបរិបទជាតិ។
៣.ខ.៤ សមភាពយេនឌ័រ៖ ធានាសិទ្ធិស្មើភាពគ្នារបស់ស្ត្រី និងបុរស ដើម្បីការទទួលបានរាល់សិទ្ធិមនុស្សទាំងអស់ ទន្ទឹមគ្នានឹងការទទួលស្គាល់អំពីភាពខុសគ្នារវាងស្ត្រី និងបុរស និង ចាត់វិធានការជាក់លាក់សំដៅពន្លឿនសមភាពជាក់ស្តែង នៅពេលដែលចាំបាច់។ រដ្ឋគប្បីធានាឱ្យបានថាស្ត្រី និងកុមារីមានសិទ្ធិកាន់កាប់ និង មានលទ្ធភាពប្រើប្រាស់ដី ជលផល និងព្រៃឈើស្មើភាពគ្នា មិនចំពោះថាពួកគេមានស្ថានភាពពលរដ្ឋ និងស្ថានភាពអាពាហ៍ពិពាហ៍ ដូចម្តេចឡើយ។

សមភាពយេនឌ័រ គឺជាគោលការណ៍ស្នូលមួយ ក្នុងចំណោមគោលការណ៍ស្នូល ទាំង ១០ សម្រាប់អនុវត្តគោលការណ៍ណែនាំ និង មានទំនាក់ទំនងជិតស្និទ្ធទៅនឹងគោលការណ៍ស្នូល ចំនួន ៣ ដទៃទៀត ដែលរួមមានជាអាទិ៍ សេចក្តីថ្លៃថ្នូររបស់មនុស្ស មិនមានការរើសអើង ព្រមទាំង សមធម៌ និង យុត្តិធម៌ (ប្រអប់ទី១)។

ទំនាក់ទំនងយេនឌ័រ គឺជាកត្តាកំណត់អំពីភាពខុសគ្នានៃស្ថានភាព និងអំណាចរបស់ស្ត្រី និងបុរស។ យេនឌ័រ និងតួនាទីយេនឌ័រ គឺជាកត្តាកំណត់លើកាលានុវត្តភាព និងឧបសគ្គដែលស្ត្រី និង បុរស ជួបប្រទះ ក្នុងការធានាចំពោះជីវភាពរស់នៅរបស់ពួកគេ ដែលរួមមានជាអាទិ៍ លទ្ធភាពរបស់ ពួកគេក្នុងការប្រើប្រាស់ដីធ្លី ការធ្វើ សេចក្តីសម្រេចចិត្តអំពីដីធ្លី និង ស្ថាប័នដែលផ្តល់ដីធ្លី និងធនធានផលិតផលដទៃទៀត (FAO, 2003a)។

អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ ធានាថាស្ត្រី និងបុរស អាចចូលរួមដោយស្មើភាពគ្នានៅក្នុងទំនាក់ទំនងរបស់ពួកគេ ចំពោះបញ្ហាដីធ្លី តាមរយៈស្ថាប័នផ្លូវការ និង ការរៀបចំមិនផ្លូវការ សម្រាប់រដ្ឋបាលដីធ្លី និង ការគ្រប់គ្រងដីធ្លី (តារាងទី១)។

តារាងទី១៖ **និយមន័យ**

វាក្យស័ព្ទ	និយមន័យ
យេនឌ័រ	អត្តសញ្ញាណសង្គម និង នយោបាយ ដែលភ្ជាប់ទៅនឹងភេទ និង រាងកាយរបស់បុគ្គលម្នាក់ ដែលសំដៅចំពោះកត្តាកំណត់ជាស្ត្រី ឬ បុរស ដែលអាចមានភាពខុសគ្នានៅកន្លែងផ្សេងៗគ្នា។ ទំនាក់ទំនងយេនឌ័រ គឺជាទំនាក់ទំនងរវាងស្ត្រី និង បុរស ផ្អែកលើអត្តសញ្ញាណសង្គមដែលភ្ជាប់ទៅនឹងពាក្យនីមួយៗនៅក្នុងសង្គម (Mackinnon, 1987; Moore, 1994)។
ការកាន់កាប់ដីធ្លី	ទំនាក់ទំនងរវាងប្រជាជន និងដី ដែលត្រូវបានកំណត់និយមន័យតាមផ្លូវច្បាប់ ឬ តាមលក្ខណៈប្រពៃណី - វិធានដែលសង្គមបានបង្កើតឡើង ដើម្បីបែងចែកសិទ្ធិអចលនទ្រព្យទៅលើដី ផ្តល់លទ្ធភាពប្រើប្រាស់ និង គ្រប់គ្រងដី និង

	កំណត់អំពីការទទួលខុសត្រូវ និង ការហាមឃាត់ដែលពាក់ព័ន្ធ។ ប្រព័ន្ធកាន់កាប់ដីធ្លី កំណត់ថាតើនរណាអាចប្រើប្រាស់ធនធានអ្វី សម្រាប់រយៈពេលប៉ុន្មាន និងក្រោមល័ក្ខខ័ណ្ឌអ្វីខ្លះ (FAO, 2002b; 2007)។
អភិបាលកិច្ច	ដំណើរការអភិបាលកិច្ច - ការគ្រប់គ្រងសង្គម និង ការសម្រុះសម្រួលទៅលើអាទិភាព និង ប្រយោជន៍ផ្សេងៗគ្នារបស់ក្រុមខុសៗគ្នា។ ដំណើរការនេះរាប់បញ្ចូលស្ថាប័នរដ្ឋាភិបាលផ្លូវការ និង ការរៀបចំមិនផ្លូវការ ព្រមទាំងពាក់ព័ន្ធទៅនឹង របៀបដែលប្រជាពលរដ្ឋចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត របៀបដែលរដ្ឋាភិបាលមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងរបៀបដែលសង្គមកំណត់កាតព្វកិច្ចទៅលើសមាជិករបស់ខ្លួន ឱ្យឃ្លាំមើលទៅលើវិធាន និងច្បាប់របស់សង្គម (FAO, 2007; 2009b)។

តើសេចក្ដីណែនាំនេះ មានវិសាលភាព និង ដែនកំណត់ដូចម្ដេចខ្លះ?

ការវិភាគយេនឌ័រ ជួយដល់ការកំណត់អំពីសេចក្ដីត្រូវការ និង អាទិភាពរបស់ស្ត្រី និងបុរស បញ្ជាក់អំពីភាពពាក់ព័ន្ធនៃយេនឌ័រ ក្នុងចំណោមក្រុមដែលមានអាយុ ទ្រព្យសម្បត្តិ វណ្ណៈ ជនជាតិ ជាតិពន្ធុ សាសនាផ្សេងៗគ្នា និងក្រុមដទៃទៀត (FAO, 2003a)។ បើទោះជាដូច្នេះក្ដី ការវិភាគលម្អិតក្នុងកម្រិតនេះ មិនអាចធ្វើទៅបានឡើយក្នុងលក្ខណៈជាប្រព័ន្ធនៅក្នុងសេចក្ដីណែនាំបែបនេះ ដែលមានគោលបំណងដើម្បីឱ្យអាចយកមកអនុវត្តបានទូលំទូលាយ និង មានភាពពាក់ព័ន្ធចំពោះមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋានទាំងអស់ ក្រុមសង្គមស៊ីវិល មន្ត្រីរដ្ឋបាល អ្នកបច្ចេកទេស និង អ្នកវិជ្ជាជីវៈដែលធ្វើការងារនៅក្នុងវិស័យដីធ្លីទូទាំងសកលលោក។

សេចក្ដីណែនាំនេះ ផ្ដោតទៅលើអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយសមធម៌យេនឌ័រ ដូច្នេះ វាពុំបានគ្របដណ្ដប់ទៅលើវិសាលភាពទាំងស្រុងនៃគោលការណ៍ណែនាំឡើយ អាស្រ័យដោយគោលការណ៍ណែនាំគ្របដណ្ដប់ផងដែរ ទៅលើអភិបាលកិច្ចលើការកាន់កាប់ជលផល និងព្រៃឈើ។ យ៉ាងណាមិញ គោលការណ៍ទូលំទូលាយនៃការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងដំណើរការអភិបាលកិច្ច អាចអនុវត្តបានចំពោះជលផល និងព្រៃឈើផងដែរ (ជាពិសេស អាស្រ័យដោយវិស័យទាំងពីរនេះ មានទំនាក់ទំនងជាមួយវិស័យដីធ្លី) ហើយគេអាចធ្វើការដកស្រង់មេរៀនបទពិសោធន៍គួរឱ្យចាប់អារម្មណ៍មួយចំនួន សម្រាប់ការប្រើប្រាស់ឱ្យបានកាន់តែទូលំទូលាយជាងនេះ។

សេចក្ដីណែនាំនេះ ផ្ដល់ដំបូន្មានអំពីយន្តការ យុទ្ធសាស្ត្រ និង សកម្មភាពនានា ដែលអាចយកមកប្រើប្រាស់ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រនៅក្នុងដំណើរការ ស្ថាប័ន និងសកម្មភាពនានានៃអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។ សេចក្ដីណែនាំនេះ មិនរាប់បញ្ចូលការពិភាក្សាស៊ីជម្រៅអំពីរាល់លទ្ធផលនៃដំណើរការ និងស្ថាប័នទាំងនោះឡើយ ប៉ុន្តែ វាផ្ដល់នូវអនុសាសន៍ដ៏មានសារៈប្រយោជន៍សម្រាប់ប្រើប្រាស់ជាការណែនាំមូលដ្ឋាន។

ហេតុអ្វីចាំបាច់ត្រូវមានសេចក្តីណែនាំបច្ចេកទេស ស្តីពីអភិបាលកិច្ចលើការកាន់កាប់ដី ប្រកបដោយសមធម៌យេនឌ័រ?

សមធម៌យេនឌ័រ ត្រូវបញ្ជ្រាបទៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ដើម្បីធានាថាប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋគ្រប់រូប ទាំងស្ត្រី និង បុរស ត្រូវបានដោះស្រាយ ព្រមទាំងធានាថាដំណើរការ និងស្ថាប័នទទួលបន្ទុកការងារកាន់កាប់ដីធ្លី មានតម្លាភាព មានការពិគ្រោះយោបល់ និង មានការចូលរួម។

ការបញ្ជ្រាបសមធម៌យេនឌ័រ ទៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ក៏មានសារៈសំខាន់ផងដែរ ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (MDGs) ទី៣ ៖ ការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី និង គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ទី១៖ ការលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន។ យោងតាមអំណះអំណាងពីទល្លីករណ៍នៃស្ថានភាពស្បៀងអាហារ និង កសិកម្ម ឆ្នាំ២០១០-២០១១ គេត្រូវធ្វើការដោះស្រាយបញ្ហាវិសមភាពយេនឌ័រ ដើម្បីបង្កើនសមត្ថភាពបំពេញការងារនៃវិស័យកសិកម្មជារួម នៅកម្រិតសកល (FAO, 2011b)។ ការបញ្ជ្រាបយេនឌ័រ ទទួលបានការគាំទ្រពីគោលការណ៍មិនរើសអើងយេនឌ័រ ដែលត្រូវបានអនុម័តយ៉ាងពេញទំហឹងនៅកម្រិតអន្តរជាតិ ដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់បំផុត នៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ឆ្នាំ១៩៧៩ (CEDAW) (ប្រអប់ទី២)។

ប្រអប់ទី២ ៖ **បទប្បញ្ញត្តិរបស់អនុសញ្ញា CEDAW ដែលគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយសមធម៌យេនឌ័រ**

មាត្រា១៣-១៥ ៖ ស្ត្រីមានសិទ្ធិស្មើបុរស ក្នុងការចុះកិច្ចសន្យា និងការគ្រប់គ្រងទ្រព្យ រាប់បញ្ចូលសិទ្ធិស្មើភាពគ្នាក្នុងការខ្ចីប្រាក់ពីធនាគារ និងសមភាពក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ និងសាលាជម្រះក្តី ដោយការរិតត្បិតឋានៈនីត្យានុកូលរបស់ស្ត្រី ត្រូវចាត់ទុកជាមោឃៈ។
មាត្រា១៤ ៖ ស្ត្រីត្រូវទទួលបានការប្រព្រឹត្តស្មើភាពគ្នានៅក្នុងកំណែទម្រង់ដីធ្លី និងកសិកម្ម ព្រមទាំងគម្រោងតាំងទីលំនៅឡើងវិញ និងលំនៅឋាន។
មាត្រា១៦ ៖ ស្ត្រីត្រូវមានសិទ្ធិស្មើភាពគ្នាទៅនឹងសហព័ទ្ធរបស់ពួកគេនៅក្នុងជីវិតអាពាហ៍ពិពាហ៍ ទាក់ទងទៅនឹងកម្មសិទ្ធិភាព ការគ្រប់គ្រង ការទទួលបាន និង ការបោះបង់ទ្រព្យសម្បត្តិ រាប់បញ្ចូលទាំងការលែងលះផងដែរ។

លិខិតុបករណ៍សំខាន់ៗដទៃទៀត នៅកម្រិតអន្តរជាតិ និងកម្រិតតំបន់ ដែលលើកកម្ពស់គោលការណ៍មិនរើសអើងយេនឌ័រ និងមានភាពពាក់ព័ន្ធទៅនឹងការសម្រេចឱ្យបាននូវអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយសមធម៌យេនឌ័រ អាចរកបាននៅក្នុងផ្នែក*ធនធាន និង ឯកសារយោង* នៅចុងបញ្ចប់នៃសេចក្តីណែនាំនេះ។

តើម៉ូឌុលទាំងអស់គ្របដណ្តប់លើបញ្ហាសំខាន់ៗអ្វីខ្លះ?

សេចក្តីណែនាំនេះ រួមមានម៉ូឌុលចំនួន៥ បូករួមទាំងសេចក្តីផ្តើម និង សេចក្តីសន្និដ្ឋាន ដែលរាយនាមអំពីធនធាន និង ឯកសារយោង។ តារាងទី២ គូសបញ្ជាក់អំពីប្រធានបទ និង មាតិកា នៃម៉ូឌុលទាំងនេះ។

ការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងដំណើរការបង្កើតគោលនយោបាយស្តីពីដីធ្លី គឺជាជំហានដំបូងមួយឆ្ពោះទៅរកអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ។ ដូច្នេះ រាល់សកម្មភាពអនុវត្តទាំងអស់ គួរមានមូលដ្ឋានផ្អែកលើគោលការណ៍ស្នូលនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស មិនមានការរើសអើង សមធម៌ យុត្តិធម៌ និងសមភាពយេនឌ័រ។ *ម៉ូឌុល១* ឆ្លើយតបទៅនឹងបញ្ហាការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងដំណើរការបង្កើតគោលនយោបាយស្តីពីដីធ្លី ដោយពិចារណាទៅលើបញ្ហានានាសម្រាប់ក្រុមអ្នកពាក់ព័ន្ធផ្សេងៗគ្នា និងកម្រិតអភិបាលកិច្ចផ្សេងៗគ្នា។

ជំហានទី២ គឺជាការប្រែក្លាយគោលនយោបាយទៅជាច្បាប់។ នៅក្នុងប្រទេសជាច្រើន វត្តមាននៃប្រព័ន្ធកាន់កាប់ដីធ្លីផ្សេងៗគ្នា បង្កើតឱ្យមាននូវការភាន់ច្រឡំ នៅពេលដែលច្បាប់ និង បទដ្ឋាន ព្រមទាំងការអនុវត្តន៍ប្រពៃណីផ្សេងៗគ្នា មានភាពផ្ទុយគ្នា។ នៅក្នុងករណីដទៃទៀត ច្បាប់ភូមិបាលមួយដ៏ល្អ មិនអាចយកមកអនុវត្តបាន អាស្រ័យដោយខ្វះលិខិតបទដ្ឋានក្រោមច្បាប់ សៀវភៅនីតិវិធី និងយុទ្ធសាស្ត្រអនុវត្ត។ ម៉ូឌុល២ ឆ្លើយតបទៅនឹងបញ្ហាច្បាប់ ដែលរួមមានជាអាទិ៍ ការរៀបចំសេចក្តីព្រាងច្បាប់ ការទទួលបានយុត្តិធម៌ ការដោះស្រាយវិវាទដីធ្លី និងកិច្ចគាំទ្រផ្នែកច្បាប់។

តារាងទី២៖ **មាតិកានៃសេចក្តីណែនាំនេះ**

ម៉ូឌុល	ប្រធានបទ	ខ្លឹមសារសង្ខេប
១	**ការបង្កើតគោលនយោបាយ**	ការរៀបចំកសាងឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រ ទៅក្នុងដំណើរការបង្កើតគោលនយោបាយស្តីពីដីធ្លី
២	**បញ្ហាច្បាប់**	ទិដ្ឋភាពនានាផ្នែកច្បាប់ ការរៀបចំសេចក្តីព្រាងច្បាប់ ការទទួលបានយុត្តិធម៌ ការដោះស្រាយវិវាទដីធ្លី កិច្ចគាំទ្រផ្នែកច្បាប់
៣	**ស្ថាប័ន**	ការចូលរួម និងភាពជាតំណាងប្រកបដោយសមធម៌យេនឌ័រនៅក្នុងស្ថាប័នទទួលបន្ទុកការងារអភិបាលកិច្ចលើការកាន់កាប់ដីធ្លី
៤	**បញ្ហាបច្ចេកទេស**	សមធម៌យេនឌ័រនៅក្នុងសកម្មភាព បច្ចេកវិទ្យា និង ប្រព័ន្ធរដ្ឋបាលដីធ្លី ព្រមទាំងចូលរួមរបស់ស្ត្រី នៅក្នុងរដ្ឋបាលដីធ្លី
៥	**ការបញ្ជូនសារ**	យុទ្ធសាស្ត្រ និងវិធីសាស្ត្រប្រាស្រ័យទាក់ទង ដើម្បីគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ។

ស្ត្រីមែងតែងត្រូវបានផាត់ចេញពីការចូលរួមនៅក្នុងដំណើរការប្រចាំថ្ងៃ នៃអភិបាលកិច្ចលើការកាន់កាប់ដីធ្លី នៅគ្រប់កម្រិត ព្រមទាំងមានសមត្ថភាពមានកម្រិត ក្នុងការជះឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចចិត្ត។ *ម៉ូឌុល៣* ឆ្លើយតបចំពោះយុទ្ធសាស្ត្រសម្របសម្រួលឱ្យមានភាពជាតំណាង និង ការចូលរួមរបស់ស្ត្រី និង បុរសគ្រប់រូប នៅក្នុងស្ថាប័នទទួលបន្ទុកការងារអភិបាលកិច្ចលើការកាន់កាប់ដីធ្លី រាប់បញ្ចូលទាំងស្ថាប័នបែបប្រពៃណីផងដែរ និង ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នទាំងនោះ។

បញ្ហាបច្ចេកទេស របស់រដ្ឋបាលដីធ្លី ក៏ត្រូវការផងដែរនូវអភិក្រម វិធីសាស្ត្រ និងបច្ចេកវិទ្យា ដែលយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ។ *ម៉ូឌុល៤* ឆ្លើយតបទៅនឹងបញ្ហាចំនួន២ ៖ *១)* តើសកម្មភាពរដ្ឋបាលដីធ្លីត្រូវបានរៀបចំឡើងបានគ្រប់គាន់ដល់កម្រិតណា ដើម្បីពិចារណា និង ដោះស្រាយចំពោះសេចក្តីត្រូវការ ប្រយោជន៍ និង បញ្ហាកង្វល់របស់ស្ត្រី និង *២)* តើស្ត្រីអាចចូលរួមដោយស្មើភាពជាមួយនឹងបុរស នៅក្នុងសកម្មភាពរដ្ឋបាលដីធ្លីក្នុងនាមជាក្រុមគោលដៅ និង ជាអតិថិជន បានដោយរបៀបណា។

ទំនាក់ទំនងល្អ មានសារៈសំខាន់ខ្លាំងណាស់ចំពោះអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ។ *ម៉ូឌុល៥* ពិចារណាទៅលើយុទ្ធសាស្ត្រ និងវិធីសាស្ត្រប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាពបំផុត ព្រមទាំងឆ្លើយតបទៅនឹងបញ្ហាសំខាន់ៗក្នុងការបញ្ជូនសារ ក្នុងនោះរួមមានជាអាទិ៍ ការផ្សព្វផ្សាយអំពីយេនឌ័រ ការលើកកម្ពស់ការយល់ដឹង ការតស៊ូមតិ អន្តរកម្មផ្នែកច្បាប់ និង ការផ្លាស់ប្តូររយៈពេលវែងទៅលើគុណតម្លៃ និង ឥរិយាបថ។

ផ្នែកដែលនិយាយអំពីសេចក្តីសន្និដ្ឋានផ្តល់នូវប្រភពនៃការណែនាំ និង ព័ត៌មានបន្ថែម។ អ្នកប្រើប្រាស់សេចក្តីណែនាំនេះ ដែលមានបំណងធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងរបស់ខ្លួនអំពីបញ្ហាវិភាគ ត្រូវបានលើកទឹកចិត្តឱ្យរកមើលឯកសារអំពីយេនឌ័រ និងដីធ្លី ដែលមានលក្ខណៈទូលំទូលាយជាងនេះ។ *ឯកសារស្តីពីអភិបាលកិច្ចដីធ្លីសម្រាប់ស្ត្រី និង បុរស ៖ គោលការណ៍ណែនាំអំពីយេនឌ័រ និង គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត ស្តីពីអភិបាលកិច្ចលើការកាន់កាប់ដីធ្លី និង ធនធានធម្មជាតិដទៃទៀតប្រកបដោយការទទួលខុសត្រូវ* របស់អង្គការ FAO ផ្តល់នូវការវិភាគមួយអំពីសាវតានៃរាល់គ្រប់ប្រធានបទ និង បញ្ហាដែលគ្របដណ្តប់នៅក្នុងសេចក្តីណែនាំនេះ រាប់បញ្ចូលទាំងឧបសគ្គ និងបញ្ហារាំងស្ទះ ក្នុងការសម្រេចឱ្យបាននូវអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ (FAO, 2011a)។

សេចក្តីណែនាំនេះ សម្រាប់នរណា និង តើគួរប្រើប្រាស់សេចក្តីណែនាំនេះយ៉ាងដូចម្តេច?

សេចក្តីណែនាំនេះ គឺជាឧបករណ៍ឯកសារយោងមួយដែលផ្តល់ឱ្យមន្ត្រីរដ្ឋបាល អ្នកបច្ចេកទេស និងអ្នកវិជ្ជាជីវៈដែលធ្វើការងារនៅក្នុងវិស័យដីធ្លីនូវការណែនាំ និង ឧទាហរណ៍នៃការអនុវត្តន៍ល្អ ដូចជា អ្វីដែលមានដំណើរការប្រព្រឹត្តទៅបានល្អ ទីកន្លែង មូលហេតុ និង របៀបអនុវត្ត ដើម្បីសម្រេចឱ្យបាននូវអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ដែលមានសមធម៌យេនឌ័រ។

សេចក្តីណែនាំនេះ ក៏មានគោលបំណងជម្រុញឱ្យមានអ្នកប្រើប្រាស់កាន់តែទូលំទូលាយផងដែរ រាប់បញ្ចូលទាំងជនទាំងឡាយណាដែលធ្វើការងារក្រោមសមាសភាពណាមួយលើបញ្ហាដែលទាក់ទងទៅនឹងយេនឌ័រ និង/ឬ ដីធ្លី។

បើទោះបីជាម៉ូឌុល នៅក្នុងសេចក្ដីណែនាំនេះ អនុវត្តតាមលំដាប់លំដោយសមស្របមួយ ចាប់ពីការបង្កើតគោលនយោបាយ ច្បាប់ រហូតដល់ការអនុវត្តន៍ក៏ដោយ ប៉ុន្តែ អ្នកប្រើប្រាស់ផ្សេងៗគ្នា នៅក្នុងស្ថានភាពខុសៗគ្នា អាចប្រើប្រាស់ម៉ូឌុលផ្សេងៗគ្នាជាចំណុចចាប់ផ្ដើមរបស់ពួកគេ សម្រាប់ណែនាំអំពីការផ្លាស់ប្ដូរ ហើយម៉ូឌុលនីមួយៗអាចមានទំនាក់ទំនងច្រើន ឬ តិច ទៅនឹងប្រភេទអ្នកពាក់ព័ន្ធផ្សេងៗគ្នា។

ដូច្នេះ ម៉ូឌុលនីមួយៗត្រូវបានរៀបចំឡើងក្នុងលក្ខណៈជាផ្នែកមួយដាច់ដោយឡែកតែឯង ដែលអាចយកមកធ្វើការពិគ្រោះយោបល់ និងប្រើប្រាស់ដាច់ដោយឡែក ឬ រួមគ្នាជាមួយម៉ូឌុលដទៃទៀត។ រូបភាពទី១ បង្ហាញថាតើម៉ូឌុលណាមួយក្នុងចំណោមម៉ូឌុលទាំង៥ អាចមានភាពពាក់ព័ន្ធខ្លាំងបំផុត សម្រាប់ប្រភេទអ្នកពាក់ព័ន្ធផ្សេងៗគ្នា។

រូបភាពទី១៖ ម៉ូឌុល និង អ្នកពាក់ព័ន្ធនានា

ឯកសារដែលបង្ហាញជូន ត្រូវបានដកស្រង់ចេញពីឯកសារដែលមានស្រាប់ និងអតិក្រម ព្រមទាំងបទពិសោធន៍ពីមូលដ្ឋាន។ ប្រភពព័ត៌មានដែលត្រូវបានយកមកប្រើប្រាស់ក្នុងការរៀបចំម៉ូឌុលនីមួយៗ មានរាយនាមនៅក្នុងឯកសារយោង នៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ។ បញ្ជីរាយនាមគ្រប់ជ្រុងជ្រោយមួយអំពីឯកសារយោង ក៏ត្រូវបានផ្ដល់ជូននៅក្នុងផ្នែក *ធនធាន និង ឯកសារយោង* ផងដែរ។

ឯកសារយោង

FAO. 2002b. *Land tenure and rural development. Land Tenure Studies 3*. Rome. ftp://ftp.fao.org/docrep/fao/005/y4307e/y4307e00.pdf

FAO. 2003a. *SEAGA Socio-Economic and Gender Analysis Programme macro level handbook*. Rome. www.fao.org/docrep/012/ak229e/ak229e00.pdf

FAO. 2007. *Good governance in land tenure and administration*. *Land Tenure Studies No. 9*. Rome. ftp://ftp.fao.org/docrep/fao/010/a1179e/a1179e00.pdf

FAO. 2009b. *Towards voluntary guidelines on re- sponsible governance of tenure of land and other natural resources – discussion paper*. Land Tenure Working Paper No. 10. Rome. ftp://ftp.fao.org/docrep/fao/012/i0955e/i0955e00.pdf

FAO. 2011a. *Governing land for women and men – gender and voluntary guidelines on responsible governance of tenure of land and other natural resources*, E. Daley and C.M. Park. *Land Tenure Working Paper No. 19*. Rome. http://www.fao. org/docrep/014/ma811e/ma811e00.pdf

FAO. 2011b. *State of Food and Agriculture 2010–11: Women in agriculture, closing the gender gap for development*. Rome. www.fao.org/docrep/013/ i2050e/i2050e.pdf

FAO. 2012b. *Voluntary Guidelines on the Responsible Governance of Tenure of Land, Fisheries and Forests in the Context of National Food Security*. Rome. http://www.fao.org/docrep/016/i2801e/ i2801e.pdf

MacKinnon, **C.** 1987. *Feminism unmodified: Discourses on life and law.* Cambridge, Massachusetts, USA, Harvard University Press.

Moore, **H.** 1994. The divisions within: sex, gender and sexual difference. *In A passion for difference – essays in anthropology and gender*. Oxford, UK, Polity Press.

ម៉ូឌុល

១



ការបង្កើតគោលនយោបាយ

បញ្ជីរាយនាមប្រអប់ និង តារាងរូបភាព

ប្រអប់

11
ប្រអប់ ១.១ ៖ ការបង្កើតគោលនយោបាយ និងគោលការណ៍ណែនាំ
16
ប្រអប់ ១.២ ៖ ភាពស្រដៀងគ្នាថ្នាក់តំបន់ នៅក្នុងបរិបទនៃការបង្កើតគោលនយោបាយឌីជីថល
19
ប្រអប់ ១.៣ ៖ មេរៀនបទពិសោធន៍សម្រាប់ការបង្កើតគោលនយោបាយឌីជីថលប្រកបដោយសមធម៌យេនឌ័រ
23
ប្រអប់ ១.៤ ៖ កិច្ចគាំទ្ររបស់រដ្ឋាភិបាល សម្រាប់ការបង្កើតគោលនយោបាយឌីជីថល ប្រកបដោយសមធម៌យេនឌ័រ
25
ប្រអប់ ១.៥ ៖ កិច្ចគាំទ្ររបស់សង្គមស៊ីវិលសម្រាប់ការបង្កើតគោលនយោបាយឌីជីថល ប្រកបដោយសមធម៌យេនឌ័រ
27
ប្រអប់ ១.៦ ៖ រដ្ឋាភិបាល និងសង្គមស៊ីវិលធ្វើការងារជាមួយគ្នា

បញ្ជីផ្ទៀងផ្ទាត់

17
បញ្ជីផ្ទៀងផ្ទាត់ ១.១ ៖ ការវិភាគបរិបទ
18
បញ្ជីផ្ទៀងផ្ទាត់ ១.២ ៖ ការតស៊ូមតិ
21
បញ្ជីផ្ទៀងផ្ទាត់ ១.៣ ៖ ការធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រ នៅក្នុងការបង្កើតគោលនយោបាយឌីជីថល
23
បញ្ជីផ្ទៀងផ្ទាត់ ១.៤ ៖ សកម្មភាពសម្រាប់រដ្ឋាភិបាល
27
បញ្ជីផ្ទៀងផ្ទាត់ ១.៥ ៖ សកម្មភាពសម្រាប់សង្គមស៊ីវិល
31
សូចនាករជាអនុសាសន៍សម្រាប់ត្រួតពិនិត្យការបង្កើតគោលនយោបាយ

តារាង និង រូបភាព

15
រូបភាព ១.១ ៖
ការកសាងដំណើរការបង្កើតគោលនយោបាយឌីជីថលប្រកបដោយសមធម៌យេនឌ័រ

ម៉ូឌុល១ ៖ ការបង្កើតគោលនយោបាយ

ការចូលរួមនៅក្នុងការបង្កើតគោលនយោបាយស្តីពីដីធ្លីប្រកបដោយសមធម៌យេនឌ័រ

សេចក្តីផ្តើម[១]

គន្លឹះក្នុងការធានាឱ្យមាននូវអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ គឺត្រូវចាប់ផ្តើមជាមួយនឹងដំណើរការបង្កើតគោលនយោបាយមួយដែលមានសមធម៌យេនឌ័រ ដែលគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងស្ត្រី និង បុរស ត្រូវបានរាប់បញ្ចូលដោយស្មើភាពគ្នានៅក្នុងការរៀបចំបង្កើត និងការអនុវត្តន៍គោលនយោបាយដីធ្លី។

ប្រអប់ ១.១ ៖ ការបង្កើតគោលនយោបាយ និង គោលការណ៍ណែនាំ

បើទោះជាដូច្នេះក្តី ភាពខុសគ្នានៃអំណាច រវាងស្ត្រី និង បុរស ព្រមទាំងកត្តាដទៃទៀត ដូចជា វណ្ណៈ ជនជាតិ ជាតិពន្ធុ ឬ អាយុ រមែងតែងបង្កើតឱ្យនូវឋានានុក្រមដែលកំណត់ ថាតើនរណាអាចចូលរួមនៅក្នុងការបង្កើតគោលនយោបាយដែលបង្កឱ្យផលប៉ះពាល់ទៅលើដំណើរការ និងលទ្ធផលការងារដែលមានសមធម៌យេនឌ័រ។ ការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងការបង្កើតគោលនយោបាយដីធ្លី អនុវត្តដោយផ្ទាល់ពីគោលការណ៍អនុវត្តមួយ ក្នុងចំណោមគោលការណ៍អនុវត្តសំខាន់ៗទាំង១០ នៃគោលការណ៍ណែនាំដែលនោះ គឺជាគោលការណ៍ស្តីពីការពិគ្រោះយោបល់ និងការចូលរួម (ប្រអប់ ១.១)។

ក) បទប្បញ្ញត្តិស្តីពីការបង្កើតគោលនយោបាយដីធ្លី ទាក់ទងទៅនឹងបញ្ហាយេនឌ័រ

3.B.6 ការពិគ្រោះយោបល់ និង ការចូលរួម ៖ ការចូលរួម និងការស្វែងរកកិច្ចគាំទ្រពីអ្នកដែលមានសិទ្ធិកាន់កាប់ស្របច្បាប់ ដែលអាចទទួលរងផលប៉ះពាល់ពីសេចក្តីសម្រេចចិត្ត មុនពេលដែលសេចក្តីសម្រេចចិត្តត្រូវបានធ្វើឡើង និង ការឆ្លើយតបទៅនឹងវិភាគទានរួមចំណែករបស់ពួកគេ ដោយពិចារណាទៅលើអតុល្យភាពអំណាចដែលមានស្រាប់ រវាងភាគីផ្សេងៗគ្នា និងការធានាឱ្យមានការចូលរួមសកម្ម ដោយសេរី ប្រកបដោយប្រសិទ្ធភាព ប្រកបដោយអត្ថន័យ និង ផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយរបស់បុគ្គល និងក្រុមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលពាក់ព័ន្ធ។
5.5 រដ្ឋគួរអភិវឌ្ឍន៍គោលនយោបាយ ច្បាប់ និងនីតិវិធីដែលពាក់ព័ន្ធ តាមរយៈដំណើរការដែលមានការចូលរួមពីគ្រប់ភាគីទាំងអស់ដែលទទួលរងផលប៉ះពាល់ ដោយធានាថា ទាំងបុរស និងស្ត្រី ត្រូវបានរាប់បញ្ចូលតាំងពីដំបូង។ គោលនយោបាយ ច្បាប់ និងនីតិវិធី គួរពិចារណាអំពីសមត្ថភាពក្នុងការអនុវត្តន៍។ គោលនយោបាយ ច្បាប់ និងនីតិវិធីទាំងនោះ គួរបញ្ចូលអភិក្រមដែលផ្តោតយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ ដែលអភិក្រមនេះ គួរបញ្ជាក់ឱ្យបានច្បាស់លាស់ជាភាសាសមស្រប និង ផ្សព្វផ្សាយឱ្យបានទូលំទូលាយ។
9.10 ក្នុងករណីចាំបាច់ តួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ គួរខិតខំធ្វើការងាររួមគ្នាជាមួយស្ថាប័នតំណាងរបស់សហគមន៍ ដែលទទួលរងផលប៉ះពាល់ និងសហការជាមួយសហគមន៍ទទួលរងផលប៉ះពាល់ ដើម្បីចូលរួមនៅក្នុងការអភិវឌ្ឍន៍គោលនយោបាយ ច្បាប់ និងគម្រោងកាន់កាប់ដីធ្លី ក្នុងលក្ខណៈមួយដែលមិនរើសអើង និង ផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ។

ភាពខុសគ្នារវាងគោលនយោបាយដីធ្លី និងអភិបាលកិច្ចនៅក្នុងការបង្កើតគោលនយោបាយស្តីពីដីធ្លី

មុនពេលពិចារណាអំពី ដំណើរការបង្កើតគោលនយោបាយ ចាំបាច់ត្រូវកត់សម្គាល់ថា ដំណើរការនេះមានភាពខុសគ្នាពីមាតិកានៃគោលនយោបាយស្តីពីដីធ្លី ដែលទទួលបានពីដំណើរការបង្កើតគោលនយោបាយ ដែលមាតិកាអាចពុំមានសមធម៌យេនឌ័រ ក្នុងកម្រិតដូចគ្នាទាំងស្រុងទៅនឹងដំណើរការ។

បើទោះជាដូច្នេះក្តី នៅក្នុងប្រទេសណាក៏ដោយ ដំណើរការបង្កើតគោលនយោបាយដីធ្លីមួយ ដែលមានសមធម៌យេនឌ័រ ដោយមានការចូលរួមពីស្ត្រី និង បុរស ពីគ្រប់ស្រទាប់វណ្ណៈ ជាតិពន្ធុ ជនជាតិ និង សាសនា អនុញ្ញាតឱ្យទទួលបានទស្សនៈវិស័យផ្សេងៗគ្នា ទៅលើគ្រប់បញ្ហាដីធ្លី ដើម្បីយកមកពិភាក្សា និងពិចារណា។

ខ) បទប្បញ្ញត្តិស្តីពីមាតិកានៃគោលនយោបាយដីធ្លី ទាក់ទងទៅនឹងបញ្ហាយេនឌ័រ

5.3 រដ្ឋគួរធានាថា ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌរចនាសម្ព័ន្ធ សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លី ទទួលស្គាល់ និងគោរពសិទ្ធិកាន់កាប់ស្របច្បាប់ ដោយយោងទៅតាមច្បាប់ជាតិរាប់បញ្ចូលសិទ្ធិកាន់កាប់ស្របច្បាប់បែបប្រពៃណី ដែលបច្ចុប្បន្នពុំមានកិច្ចការពារពីច្បាប់ និង សម្របសម្រួល លើកកម្ពស់ និងការពារសិទ្ធិកាន់កាប់... រដ្ឋគួរផ្តល់ក្របខ័ណ្ឌការងារមួយចំនួន ដែលមិនរើសអើង និង លើកកម្ពស់សមធម៌សង្គម និងសមភាពយេនឌ័រ។

10.1 ក្នុងករណីដែលមានវត្តមាននៃការកាន់កាប់ដី ជលផល និងព្រៃឈើក្នុងលក្ខណៈមិនផ្លូវការ រដ្ឋគួរទទួលស្គាល់ចំពោះការកាន់កាប់បែបនេះ ក្នុងលក្ខណៈមួយដែលគោរពដល់សិទ្ធិជាផ្លូវការដែលមានស្រាប់ ក្រោមច្បាប់ជាតិ និង ក្នុងលក្ខណៈមួយដែលទទួលស្គាល់ អំពីតថភាពជាក់ស្តែងនៃស្ថានភាព និងលើកកម្ពស់សុខុមាលភាពផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន។ រដ្ឋគួរលើកកម្ពស់គោលនយោបាយ និងច្បាប់ ដើម្បីផ្តល់ការទទួលស្គាល់ចំពោះការកាន់កាប់មិនផ្លូវការបែបនេះ។ ដំណើរការបង្កើតគោលនយោបាយ និងច្បាប់ទាំងនេះ គួរមានលក្ខណៈបែបចូលរួម ផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ និង ខិតខំរៀបចំបង្កើតបទប្បញ្ញត្តិស្តីពីកិច្ចគាំទ្រផ្នែកបច្ចេកទេស និង កិច្ចគាំទ្រផ្នែកច្បាប់ សម្រាប់សហគមន៍ និង បុគ្គលដែលទទួលរងផលប៉ះពាល់។

គោលនយោបាយស្តីពីដីធ្លី អាចគ្របដណ្តប់ទៅលើកម្រងបញ្ហាមួយដ៏ទូលំទូលាយ ដែលទាក់ទងទៅនឹងដីធ្លី ដែលកម្រងបញ្ហាទាំងអស់នោះ បង្កប់នូវសញ្ញាណប្រកបដោយសក្តានុពល សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយការទទួលខុសត្រូវ។ គោលនយោបាយដីធ្លី ប្រកបដោយសមធម៌យេនឌ័រ មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត អាស្រ័យទៅតាមរបៀបនៃការឆ្លើយតបចំពោះបញ្ហាសិទ្ធិដីធ្លី។ សកម្មភាពគោលនយោបាយ ដើម្បីសម្រេចឱ្យបាននូវអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយសមធម៌យេនឌ័ររួមមានជាអាទិ៍ ៖

- ការអនុវត្តន៍អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស្ត្រី
- ការទទួលស្គាល់សិទ្ធិប្រពៃណីរបស់ស្ត្រីចំពោះបញ្ហាដីធ្លី
- ការធានាថាស្ត្រីអាចចុះបញ្ជីសិទ្ធិដីធ្លីរបស់ពួកគេ ក្រោមល័ក្ខខ័ណ្ឌដូចគ្នាទៅនឹងបុរស

- ការជានាថាអ្នកពាក់ព័ន្ធទាំងអស់ អាចចូលរួមប្រកបដោយសមធម៌នៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី រាប់បញ្ចូលទាំងនៅក្នុងរដ្ឋបាលដីធ្លីថ្នាក់មូលដ្ឋាន និង ស្ថាប័នគ្រប់គ្រង
- ការណែនាំអំពីវិធានការវិជ្ជមានលើបញ្ហាការរើសអើង។

ការកសាងឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងដំណើរការបង្កើតគោលនយោបាយស្តីពីដីធ្លី

ការកសាងឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រ គឺជាដំណើរការមួយរយៈពេលវែង ដែលទាមទារឱ្យមានការរៀបចំផែនការ និង អន្តរាគមន៍នៅកម្រិតផ្សេងៗគ្នា ព្រមទាំងមានការចូលរួមពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗគ្នាផងដែរ។ គេត្រូវការឱ្យមាននូវឆន្ទៈនយោបាយពីភាគីរដ្ឋាភិបាល ព្រមជាមួយនឹងការចូលរួម និង កិច្ចគាំទ្រពីអ្នកពាក់ព័ន្ធភាគីសង្គមស៊ីវិល វិស័យឯកជន និងអង្គការអន្តរជាតិ។

រូបភាព ១.១ បង្ហាញអំពីធាតុផ្សំជាក់ស្តែងចំនួន៥ នៅក្នុងការកសាងដំណើរការមួយ ដែលមានមូលដ្ឋានផ្អែកលើការចូលរួមស្មើភាពគ្នារបស់ស្ត្រី និង បុរស។ ធាតុផ្សំទាំងនេះ មានអន្តរទំនាក់ទំនងគ្នាទៅវិញទៅមក ហើយជាធម្មតា គេតែងអនុវត្តធាតុផ្សំទាំងនេះ ស្របពេលជាមួយគ្នា។

រូបភាព ១.១ ៖ ការកសាងដំណើរការបង្កើតគោលនយោបាយដីធ្លីប្រកបដោយសមធម៌យេនឌ័រ

ការវិភាគបរិបទ

ប្រទេសនីមួយៗមានកម្រងលក្ខណៈពិសេសផ្ទាល់ខ្លួន ទាក់ទងទៅនឹងលក្ខណៈភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ចសង្គម និងវប្បធម៌ ព្រមទាំងប្រព័ន្ធនយោបាយ និងទម្រង់នៃការប្រើប្រាស់ដី ព្រមទាំងការកាន់កាប់ដី។ គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ត្រូវយល់អំពីបរិបទក្នុងស្រុកនេះ ដើម្បីឱ្យពួកគេអាចចូលរួមនៅក្នុងដំណើរការបង្កើតគោលនយោបាយប្រកបដោយប្រសិទ្ធភាពបំផុតដូចដែលអាចធ្វើទៅបាន។ ឧទាហរណ៍ នៅក្នុងប្រទេសជាច្រើន ទិដ្ឋភាពនានានៃច្បាប់ គឺជាផ្នែកមួយនៃបរិបទ។ ចំណុចនេះ មានន័យថា អ្នកបង្កើតគោលនយោបាយគួរពិចារណាអំពីការរៀបចំកាន់កាប់បែបសមូហភាព និង បែបប្រពៃណី ទំនាក់ទំនងរវាងការកាន់កាប់ដីធ្លី និងវិធាននានាដែលគ្របដណ្តប់ទៅលើសិទ្ធិអចលនទ្រព្យ នៅក្នុងចំណងអាពាហ៍ពិពាហ៍ និងការស្នងមរតក ព្រមទាំងឋានានុក្រមនៃអំណាចដែលបង្កឱ្យមានផលប៉ះពាល់ទៅលើការធ្វើសេចក្តីសម្រេចចិត្ត ទាក់ទងទៅនឹងបញ្ហាដីធ្លី។

ជួនកាល មានភាពស្រដៀងគ្នាមួយចំនួននៅក្នុងបរិបទរបស់បណ្តាប្រទេសនានាក្នុងតំបន់ ដូចជា នៅក្នុងតំបន់

អាស៊ី និងអាហ្វ្រិក (ប្រអប់ ១.២)។ ភាពស្រដៀងគ្នាបែបនេះ អនុញ្ញាតឱ្យមានការចែករំលែកអំពីមេរៀន បទពិសោធន៍ដែលបានរៀនសូត្រដោយផ្ទាល់ រវាងប្រទេសនានា ឬ តាមរយៈការផ្តួចផ្តើមកម្រិតតំបន់មួយចំនួន ដូចជាក្របខ័ណ្ឌសហជីពអាហ្វ្រិក និង គោលការណ៍ណែនាំស្តីពីគោលនយោបាយដីធ្លីនៅអាហ្វ្រិក ដែលមានរៀបរាប់នៅក្នុងប្រអប់ ១.៥។

ប្រអប់ ១.២ ៖ ភាពស្រដៀងគ្នាថ្នាក់តំបន់ នៅក្នុងបរិបទនៃការបង្កើតគោលនយោបាយដីធ្លី

ប្រភព ៖ Seema Gaikwad's presentation on "Asian experiences of civil society engagement with land policy processes" and Catherine Gatundu's presentation on "Africa experiences of civil society involvement in land policy process" at the May 2011 workshop; IPC, 2010; FAO, 2008b.

អាស៊ី

សម្ព័ន្ធនៃអង្គការសង្គមស៊ីវិលមួយ បានបង្កើតយន្តការឃ្លាំមើលដីធ្លីនៅអាស៊ី ដើម្បីគាំទ្រ ត្រួតពិនិត្យ និង តស៊ូមតិ សម្រាប់លទ្ធភាពប្រើប្រាស់ដី កំណែទម្រង់កសិកម្ម និង ការអភិវឌ្ឍន៍នៅតំបន់ជនបទប្រកបដោយសមធម៌ និង និរន្តរភាពទូទាំងតំបន់អាស៊ី។ យន្តការឃ្លាំមើលដីធ្លីនៅអាស៊ី ពង្រឹងបន្ថែមទៅលើភាពស្រដៀងគ្នាថ្នាក់តំបន់ ចំពោះ ៖

- ការធ្លាក់ចុះនៃចំនួនដីដែលមានសម្រាប់ការងារកសិកម្ម
- ប្រវត្តិនៃជម្លោះក្រោយពេលអាណានិគម និង សង្គ្រាមស៊ីវិល
- ផលប៉ះពាល់ទៅលើសិទ្ធិរបស់ស្ត្រីចំពោះបញ្ហាដីធ្លីដែលបណ្តាលមកពីបន្ទុកជាច្រើន ដែលរួមមានជាអាទិ៍ ស្រទាប់វណ្ណៈ និង ការរើសអើងយេនឌ័រ ការរំលោភបំពានផ្លូវភេទ និងអំពើហិង្សា ៖
  - ច្បាប់ស្តីពីគ្រួសារចែងខុសគ្នាអំពីសិទ្ធិរបស់ស្ត្រី ចំពោះទ្រព្យសម្បត្តិបុគ្គល និងទ្រព្យរួមក្រោយអាពាហ៍ពិពាហ៍ និងការស្នងមរតក ដោយអាស្រ័យទៅលើជាតិពន្ធុ សាសនា ឬ វណ្ណៈ
  - ជាទូទៅ សិទ្ធិដីធ្លីរបស់ស្ត្រីមានចំនួនតិចតួច និង គ្មានការទទួលស្គាល់ ហើយពួកគេ រមែងតែងត្រូវបានផាត់ចេញពីដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងដំណើរការអភិបាលកិច្ច
  - កន្លងមក វិសមភាព និងភាពលម្អៀងយេនឌ័រ បានបង្កការរាំងស្ទះចំពោះលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការផ្តួចផ្តើមរបស់រដ្ឋាភិបាល ដើម្បីចុះបញ្ជីដីធ្លី និងធ្វើសនិទានកម្មទៅលើសិទ្ធិអចលនទ្រព្យ។

អាហ្វ្រិក

បណ្តាញដីធ្លីអាហ្វ្រិកអាលិច រួមមានសមាសធាតុចូលរួមពីអង្គការសង្គមស៊ីវិល និងសកម្មជននានា ដែលចូលរួមនៅក្នុងដំណើរការបង្កើតគោលនយោបាយដីធ្លីនៅក្នុងប្រទេសរបស់ពួកគេរៀងៗខ្លួន។ បណ្តាញនេះ ពង្រឹងបន្ថែមទៅលើភាពស្រដៀងគ្នានៅថ្នាក់តំបន់ ចំពោះ ៖

- សារៈសំខាន់របស់វិស័យកសិកម្មនៅក្នុងសេដ្ឋកិច្ចជាតិ
- តួនាទីដ៏សំខាន់របស់ស្ត្រីនៅក្នុងការផលិតស្បៀងអាហារ
- សម្ពាធនៃវាលរហោស្ថាននីយកម្ម គ្រោះរាំងស្ងួត និងកំណើនប្រជាជន
- ការបន្សល់ទុកពីអាណានិគមនូវច្បាប់ភូមិបាលជាច្រើន ប៉ុន្តែមានគោលនយោបាយណែនាំតិចតួច
- ការគ្របដណ្តប់នៃការរៀបចំកាន់កាប់ដីធ្លីបែបប្រពៃណី
- អសន្តិសុខនៃការកាន់កាប់ដីធ្លីដែលស្ត្រីជាច្រើនជួបប្រទះ ៖

- ស្ថាប័ន និងរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន រមែងតែងស្ថិតក្រោមការគ្រប់ដណ្តប់ពីបុរស ហើយវិធានប្រពៃណីស្តីពីដីធ្លី រមែងតែងត្រូវបានបកស្រាយក្នុងលក្ខណៈមួយដែលមើលរំលងចំពោះស្ត្រី
- ស្ត្រីបានបាត់បង់ប្រយោជន៍ដោយសារតែភាពក្រីក្ររបស់ពួកគេ ដែលមានកម្រិតខ្ពស់ជាងបុរស កម្រិតអក្ខរកម្មទាបជាងបុរស និងខ្វះចំណេះដឹងអំពីប្រព័ន្ធច្បាប់
- ការអនុវត្តន៍រដ្ឋបាលដីធ្លី រមែងតែងធ្វើឱ្យបាត់បង់ប្រយោជន៍ចំពោះស្ត្រី រាប់បញ្ចូលទាំងការចុះបញ្ជីដីធ្លីគ្រួសារ និង ការទទួលបានសិទ្ធិបុគ្គលរឹងមាំចំពោះបញ្ហាដីធ្លី។

- ភាពខុសគ្នានៃសិទ្ធិជាពលរដ្ឋ ដែលបុរស និងស្ត្រីទទួលបាន ជាពិសេសស្ត្រីដែលរៀបការរួច ដែលបង្កឱ្យមានផលប៉ះពាល់ទៅលើទំនាក់ទំនងរបស់ស្ត្រី ចំពោះទ្រព្យសម្បត្តិគ្រប់ប្រភេទ។ ជួនកាល ស្ត្រីត្រូវការឱ្យមានការយល់ព្រមពីឪពុករបស់ពួកគេ ឬ ស្វាមីរបស់ពួកគេ ដើម្បីចុះបញ្ជីដីធ្លីដែលពួកគេទទួលបានដោយខ្លួនឯង។

✎បញ្ជីផ្ទៀងផ្ទាត់ ១.១ ៖
ការវិភាគបរិបទ

- ✓ តើក្រុមស្ត្រី និង បុរសផ្សេងៗគ្នា រមែងតែងត្រូវបានបញ្ចូលនៅក្នុងការពិភាក្សានយោបាយក្នុងសហគមន៍មូលដ្ឋាន និង នៅកម្រិតថ្នាក់ជាតិ ដោយរបៀបណា?
- ✓ តើបទដ្ឋានវប្បធម៌ និងសង្គម តម្រូវឱ្យដំណើរការបែបចូលរួមមានភាពដាច់ដោយឡែក សម្រាប់ក្រុមស្ត្រី និង ក្រុមបុរស ព្រមទាំងក្រុមដទៃទៀតដែរឬទេ? ឧទាហរណ៍ តើក្រុមស្ត្រី ឬ យុវជន មានអារម្មណ៍ថាមានការរាំងស្ទះចំពោះការនិយាយដោយបើកចំហរនៅក្នុងកិច្ចប្រជុំដែលមានវត្តមានបុរសពេញវ័យ ដែរឬទេ? តើគេអាចទទួលយកបានដែរឬទេនៅក្នុងមូលដ្ឋាន ចំពោះការលាយបញ្ចូលគ្នារវាងក្រុមស្ត្រី និងបុរសដោយបើកចំហរនៅក្នុងកិច្ចប្រជុំសាធារណៈ?
- ✓ តើស្ត្រី និងបុរស គឺជាសមាជិករបស់ស្ថាប័ន និង វេទិកាសង្គមដោយឡែកពីគ្នា ដែលគេអាចទាញបញ្ចូលគ្នា ដើម្បីធ្វើការពិគ្រោះយោបល់លើបញ្ហាគោលនយោបាយដីធ្លីបានដែរឬទេ?
- ✓ តើបទដ្ឋានវប្បធម៌ និងសង្គមបង្កប់អត្ថន័យថា ស្ត្រី និងបុរសមានប្រភេទ និងប្រធានបទនៃចំណេះដឹងផ្សេងៗគ្នាអំពីបញ្ហាដីធ្លីដែរឬទេ?

ចូរចងចាំ!

ការវិភាគបរិបទសមស្របតាំងពីដំបូងនៃដំណើរការមួយ នឹងធានាឱ្យមានការជ្រើសរើសយកអភិក្រមដែលមានប្រសិទ្ធភាពបំផុត និង ការប្រថាប់បញ្ចូលគ្នានូវយុទ្ធសាស្ត្រសម្រាប់បរិបទនោះ។ អ្វីដែលមានដំណើរការប្រព្រឹត្តទៅបានល្អក្នុងប្រទេសមួយ អាចពុំមានដំណើរការល្អដូចគ្នានៅក្នុងប្រទេសដទៃទៀតឡើយ បើទោះជាគេអាចរៀនសូត្រ និងចែករំលែកអំពីមេរៀនមួយចំនួនក៏ដោយ។

ការតស៊ូមតិ

ការតស៊ូមតិដែលមានមូលដ្ឋានផ្អែកលើភស្តុតាងបង្ហាញអំពីតម្លៃនៃដំណើរការមួយ ប្រកបដោយសមធម៌យេនឌ័រ ដែលទទួលបានប្រយោជន៍ពីវិភាគទាន និងការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងបុរស និងស្ត្រី ដែលធ្វើឱ្យការតស៊ូមតិនេះ ទំនងនឹងទទួលបានលទ្ធផលនូវការឯកភាព និងការគាំទ្រចំពោះគោលនយោបាយ។ គេត្រូវធ្វើការកំណត់អត្តសញ្ញាណ ទាក់ទងនឹងបញ្ចូលជនគោលដៅសក្តានុពលសម្រាប់ការងារតស៊ូមតិ ដូចជាអ្នកបង្កើតគោលនយោបាយ អ្នកស្រាវជ្រាវ និងប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន ទៅក្នុងការអភិវឌ្ឍន៍ និងការផ្សព្វផ្សាយផលិតផល យុទ្ធសាស្ត្រ និងវិធីសាស្ត្រទំនាក់ទំនង ដូចមានរៀបរាប់នៅក្នុង *ម៉ូឌុល៥*។

✎បញ្ជីផ្ទៀងផ្ទាត់ ១.២ ៖
ការតស៊ូមតិ

ប្រភព ៖ Sabine Pallas's presentation on "Developing communication and advocacy tools through action-oriented research in Africa" at the May 2011 technical workshop.

✓ ប្រមូលភស្តុតាងឱ្យបានច្រើនបំផុតដូចដែលអាចធ្វើទៅបាន ដើម្បីជាមូលដ្ឋានគាំទ្រដល់អំណះអំណាងដែលបានលើកឡើង។

✓ កំណត់ថាតើនរណាទំនងនឹងទទួលរងផលប៉ះពាល់ពីការស្រាវជ្រាវ និង បញ្ចូលពួកគេទៅក្នុងដំណើរការ។

✓ ជម្រុញឱ្យមានការចូលរួមពីតួអង្គក្នុងស្រុក ទាំងស្ត្រី និងបុរស ដោយពិចារណាទៅលើភាពខុសគ្នានៃឋានៈ និងអំណាច ដែលអាចបង្កឱ្យមានផលប៉ះពាល់ទៅលើការចូលរួមរបស់ពួកគេ។

✓ បង្ហាញភស្តុតាងក្នុងលក្ខណៈមួយ ដែលអ្នកបង្កើតគោលនយោបាយអាចយល់ដោយពុំផ្លាស់ប្តូរទៅលើគំហើញ ដើម្បីឱ្យស្របទៅតាមរបៀបវារៈគោលនយោបាយដែលមានស្រាប់របស់អ្នកពាក់ព័ន្ធផ្សេងៗគ្នា។

✓ កំណត់ថាតើនរណាកំពុងធ្វើការតស៊ូមតិជំនួសឱ្យនរណា និង នរណាត្រូវបានកំណត់អាណត្តិការងារដោយនរណា ដើម្បីជៀសវាងស្ថានភាពដែលអង្គការមួយធ្វើការតស៊ូមតិជូនប្រជាជន ដោយពុំបានធ្វើការពិគ្រោះយោបល់ជាមួយពួកគេឱ្យបានគ្រប់គ្រាន់អំពីសេចក្តីត្រូវការ និងការទាមទាររបស់ពួកគេ។

ចូរចងចាំ!

តួអង្គដែលអនុវត្តធ្វើការងារតស៊ូមតិនៅកម្រិតថ្នាក់ជាតិ អាចមានរបៀបវារៈផ្សេងគ្នាពីតួអង្គដែលធ្វើការងារនៅថ្នាក់មូលដ្ឋាន។ ការតម្រឹម និងការធ្វើសុខដុមនីយកម្ម ទៅលើគោលដៅតស៊ូមតិមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានាថាការងារតស៊ូមតិបម្រើឱ្យប្រយោជន៍របស់ជនគ្រប់រូប។

អង្គការសង្គមស៊ីវិល រមែងតែងមានតួនាទីមួយដ៏សំខាន់នៅក្នុងការងារតស៊ូមតិ (បញ្ជីផ្ទៀងផ្ទាត់ ១.៥)។

ការផ្សព្វផ្សាយ និង ការបណ្តុះបណ្តាល

ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយអំពីបញ្ហាយេនឌ័រ និងដីធ្លី នឹងមានផលិតភាពខ្ពស់ជាងការបណ្តុះបណ្តាលអំពីបញ្ហាដីធ្លីរបស់ស្ត្រីតែម្យ៉ាង ហើយវានឹងជួយឱ្យជៀសវាងបាននូវការមើលរំលង និងការយល់ខុសចំពោះបញ្ហាយេនឌ័រ ថាផ្តោតយកចិត្តទុកដាក់តែម្យ៉ាងចំពោះស្ត្រី។ អ្នកនយោបាយ និងមន្ត្រីរដ្ឋាភិបាល ទាំងស្ត្រី

និងបុរស ត្រូវការឱ្យមានការបណ្តុះបណ្តាលដើម្បីឱ្យពួកគេក្លាយខ្លួនទៅជាអ្នកបង្កើតគោលនយោបាយដីធ្លីប្រកបដោយប្រសិទ្ធភាព ដែលតំណាងឱ្យបញ្ហារបស់ស្ត្រី និងបុរស ដោយស្មើភាពគ្នា។

ស្ត្រី និងបុរសធម្មតា អាចត្រូវការការបណ្តុះបណ្តាល និងកិច្ចគាំទ្រពិសេស ដើម្បីឱ្យពួកគេអាចចូលរួមនៅក្នុងដំណើរការបង្កើតគោលនយោបាយដីធ្លី។ គេគួរផ្តោតការយកចិត្តទុកដាក់ជាពិសេស ចំពោះការសម្របសម្រួលឱ្យមានការចូលរួមរបស់ស្ត្រី នៅពេលដែលទំនាក់ទំនងយេនឌ័រនៅក្នុងប្រទេស គឺជាបញ្ហាប្រឈម។ ឧទាហរណ៍ កិច្ចប្រជុំសម្រាប់តែស្ត្រី បង្កលក្ខណៈឱ្យស្ត្រីអាចពិភាក្សាអំពីបញ្ហាដីធ្លីដែលមានលក្ខណៈរសើប ក្នុងចំណោមពួកគេ មុនពេលលើកឡើងអំពីបញ្ហាទាំងនោះ នៅក្នុងដំណើរការបង្កើតគោលនយោបាយដីធ្លីដែលមានលក្ខណៈទូលំទូលាយជាងនេះ។ អង្គការសង្គមស៊ីវិល ជាពិសេស គឺក្រុមស្ត្រីមានតួនាទីពិសេសក្នុងការសម្របសម្រួលដល់ការបង្កើតបណ្តាញស្ត្រីចម្រុះ ហើយរដ្ឋាភិបាលមូលដ្ឋាន និងស្ថាប័នប្រពៃណីនៅថ្នាក់មូលដ្ឋាន អាចដាក់បញ្ចូលនូវវេទិកាសម្រាប់តែស្ត្រី។

កិច្ចសន្ទនាពហុភាគីអ្នកពាក់ព័ន្ធ

ការបង្កើតគោលនយោបាយ គឺជាមុខងារស្នូលមួយក្នុងចំណោមមុខងារស្នូលនានារបស់រដ្ឋាភិបាល ដូច្នេះទីបំផុត គោលនយោបាយដីធ្លី និងដំណើរការបង្កើតគោលនយោបាយដីធ្លី ត្រូវតែស្ថិតក្រោមភាពជាម្ចាស់របស់រដ្ឋាភិបាល។ ដើម្បីសម្របសម្រួលឱ្យមានការចូលរួមប្រកបដោយភាពស្ថាបនា និង ការកសាងសម្ព័ន្ធភាពអ្នកពាក់ព័ន្ធដទៃទៀតត្រូវទទួលយកជាភាពជាម្ចាស់នេះ និងយល់អំពីតម្រូវការផ្សេងៗគ្នាចំពោះបញ្ហាដីធ្លី និងជំហរជារួមរបស់រដ្ឋាភិបាលលើបញ្ហាគោលនយោបាយដីធ្លី និងយេនឌ័រ។ បើទោះជាដូច្នេះក្តី កិច្ចសហប្រតិបត្តិការ និងការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ គួរចាប់ផ្តើមតាំងពីដំបូងនៃដំណើរការបង្កើតគោលនយោបាយ និងបន្តរហូតដល់ដំណាក់កាលអភិវឌ្ឍ អនុម័ត និង អនុវត្ត រាប់បញ្ចូលទាំងនៅក្នុងការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីយេនឌ័រ និង ការរៀបចំកម្មវិធី។

អនិក្រមរយៈពេលវែង

ដំណើរការបង្កើតគោលនយោបាយភាគច្រើនមានរយៈពេលវែងគ្រប់គ្រាន់ ល្មមនឹងអនុញ្ញាតឱ្យគេអាចរៀនសូត្រអំពីមេរៀនបទពិសោធន៍នានា ក្នុងអំឡុងពេលនៃដំណើរការទាំងនោះបាន។ ប្រអប់ ១.៣ ផ្តល់នូវឧទាហរណ៍មួយពីប្រទេសយូហ្គាន់ដា។

ប្រអប់ ១.៣ ៖
មេរៀនបទពិសោធន៍សម្រាប់ការបង្កើតគោលនយោបាយដីធ្លីប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ WLLA, 2010a; Esther Obaikal, personal communication.

> រដ្ឋធម្មនុញ្ញរបស់ប្រទេស*យូហ្គាន់ដា* ឆ្នាំ១៩៩៥ ចែងអំពីសមភាពរវាងស្ត្រី និងបុរស រាប់បញ្ចូលសមភាពក្នុងការទទួលបាន និង ការកាន់កាប់ដីធ្លី ព្រមទាំងសកម្មភាពវិជ្ជមាន ដើម្បីដោះស្រាយបញ្ហាការរើសអើងដែលធ្លាប់មានកន្លងមក ដែលស្ត្រី និងក្រុមដែលត្រូវបានគេមើលរំលងដទៃទៀតជួបប្រទះ។ បើទោះជាដូច្នេះក្តី ការភាន់ច្រឡំក្នុងអំឡុងពេលនៃការរៀបចំច្បាប់ភូមិបាល ឆ្នាំ១៩៩៨ បាននាំឱ្យមានការលុបចោលនូវខចែងមួយដ៏សំខាន់ ស្តីពីសហកម្មសិទ្ធិភាពដីធ្លីរវាងស្ត្រី និងបុរស។ ក្នុងឆ្នាំ២០០៤ ច្បាប់នេះ ត្រូវបានធ្វើវិសោធនកម្មដើម្បីទាមទារឱ្យមានការយល់ព្រមពីសហព័ទ្ធទាំងពីរសម្រាប់ប្រតិបត្តិការទាំងឡាយណា ដែលពាក់ព័ន្ធទៅនឹងដីរបស់គ្រួសារ ប៉ុន្តែ

សកម្មជនសង្គមស៊ីវិល នៅតែមានអារម្មណ៍ថា បទប្បញ្ញត្តិច្បាប់ដើម្បីឱ្យស្រ្តីមានលទ្ធភាពទទួលបាន គ្រប់គ្រង និង មានកម្មសិទ្ធិភាពលើដីធ្លី នៅពុំទាន់មានភាពគ្រប់គ្រាន់។

គេបានរៀនសូត្រមេរៀនបទពិសោធន៍មួយចំនួន ហើយនៅចំពោះមុខខុទ្ទកាល័យរបស់យូហ្គាន់ដា ក្នុងខែកក្កដា ឆ្នាំ២០១១ គោលនយោបាយស្តីពីដីធ្លីថ្មីរបស់យូហ្គាន់ដាបានដាក់បញ្ចូលក្រុមស្រ្តី នៅក្នុងដំណើរការបង្កើតគោលនយោបាយ ក្រោមឆ័ត្រនៃសម្ព័ន្ធភាពដីធ្លីរបស់យូហ្គាន់ដា។ ក្រុមទាំងនេះ បានចូលរួមនៅក្នុងការត្រួតពិនិត្យឡើងវិញទៅលើច្បាប់ចំនួន ១៦ ដែលទាក់ទងទៅនឹងបញ្ហាដីធ្លី ដើម្បីធានាថា បញ្ហាយេនឌ័រត្រូវបានបញ្ជ្រាបទៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃកម្មសិទ្ធិភាពដីធ្លី ការទទួលបាន ការប្រើប្រាស់ រដ្ឋបាល និងការគ្រប់គ្រងដីធ្លី ក្នុងប្រទេសយូហ្គាន់ដា។

ជំហានជាក់ស្តែងសម្រាប់ដំណើរការបង្កើតគោលនយោបាយដីធ្លីប្រកបដោយសមធម៌យេនឌ័រ[២]

ជំហាននីមួយៗក្នុងចំណោមជំហានទាំង៤ ខាងក្រោម រួមមានទិដ្ឋភាពដែលទាក់ទងទៅនឹងធាតុផ្សំសំខាន់ៗទាំង៥ ដូចមានបញ្ជាក់នៅក្នុងរូបភាព ១.១ ៖ ការវិភាគបរិបទ ការតស៊ូមតិ ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាល កិច្ចសន្ទនាពហុភាគីអ្នកពាក់ព័ន្ធ និង អភិក្រមរយៈពេលវែង។

នៅក្នុងជំហានទី១ អាណត្តិការងារផ្ទៃក្នុងមួយរបស់រដ្ឋាភិបាល ដើម្បីគាំទ្រដល់ដំណើរការបង្កើតគោលនយោបាយមួយដែលមានលក្ខណៈបែបចូលរួម និងមានសមធម៌យេនឌ័រ ត្រូវបានអភិវឌ្ឍ និងបន្តអនុវត្តដោយនាយកដ្ឋាន និងក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាល។ អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិ អាចផ្តល់ព័ត៌មានការលើកកម្ពស់ការយល់ដឹង និង ការអភិវឌ្ឍន៍សមត្ថភាព ជូនដល់មន្រ្តីរដ្ឋាភិបាលសំខាន់ៗ ជាពិសេស "បុគ្គលផ្ទើមនៅក្នុងស្ថាប័ន" ដែលប្រកបដោយសក្តានុពល (សូមមើលជំហានទី៤) និង អាចជួយប្រែក្លាយអាណត្តិការងារផ្ទៃក្នុងឱ្យក្លាយទៅជាសកម្មភាព។ វាមានសារៈសំខាន់ខ្លាំងណាស់ ដែលរដ្ឋាភិបាលត្រូវមានភាពបើកចំហចំពោះការពិគ្រោះយោបល់ជាមួយស្រ្តី និងបុរស ប៉ុន្តែ បរិបទប្រទេសក៏មានសារៈសំខាន់ផងដែរ។ ក្នុងករណីដែលសមភាពយេនឌ័រត្រូវបន្តវឌ្ឍនភាពទៅមុខទៀត គេអាចត្រឹមតែធានាឱ្យមាននូវការចូលរួមរបស់ស្រ្តីដែលពាក់ព័ន្ធនៅក្នុងរដ្ឋាភិបាល។ ការកសាងឱ្យមាននូវអាណត្តិការងារផ្ទៃក្នុងមួយ និងសកម្មភាពអនុវត្តដែលទាក់ទងទៅនឹងអាណត្តិការងារផ្ទៃក្នុងនោះ ត្រូវចំណាយពេលវេលាមួយចំនួន ហើយការងារនេះត្រូវទទួលបានធនធានឱ្យបានគ្រប់គ្រាន់។

នៅក្នុងជំហានទី២ សម្ព័ន្ធភាពពហុភាគីអ្នកពាក់ព័ន្ធចំនួន ៤ ភាគី ដែលរួមមាន រដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងអង្គការអន្តរជាតិ ត្រូវបានអភិវឌ្ឍដើម្បីលើកកម្ពស់ការចូលរួមប្រកបដោយសមធម៌យេនឌ័រនៅក្នុងការបង្កើតគោលនយោបាយស្តីពីដីធ្លី។ សកម្មភាពនេះ ពាក់ព័ន្ធទៅនឹងការច្របាច់បញ្ចូលគ្នានូវការចូលរួមពីលើមកក្រោម និងពីក្រោមទៅលើ សកម្មភាព និងព្រឹត្តិការណ៍នានានៅក្នុងដំណើរការបង្កើតគោលនយោបាយទាំងមូល ដោយបញ្ចូលទាំងស្រ្តី និងបុរស។ អង្គការសង្គមស៊ីវិល និងក្រុមស្រ្តី អាចរៀបចំបង្កើតឱ្យមាននូវសម្ព័ន្ធភាពដោយផ្ទាល់ជាមួយអ្នកពាក់ព័ន្ធវិស័យឯកជន (ដូចជា រដ្ឋបាលដីធ្លី និងអ្នក

បច្ចេកទេសជីផ្លី) និងធ្វើការងារជាមួយអង្គការអន្តរជាតិដើម្បីបញ្ចុះបញ្ចូលរដ្ឋាភិបាល។ គោលដៅចុងក្រោយគឺដើម្បីសម្រេចឱ្យបាននូវសម្ព័ន្ធភាពពហុភាគីអ្នកពាក់ព័ន្ធមួយដ៏ទូលំទូលាយ និងមានការឯកភាពគ្នា ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់។

នៅក្នុងដំណាក់ទី៣ សម្ព័ន្ធភាពពហុភាគីអ្នកពាក់ព័ន្ធ ស្វែងរកធ្វើការបង្កើត និងបណ្តុះបណ្តាលក្រុម "អ្នកត្រួសត្រាយផ្លូវ" ដើម្បីដឹកនាំកិច្ចពិភាក្សាអំពីគោលនយោបាយនៅកម្រិតមូលដ្ឋាន ដោយពិចារណាអំពីបរិបទផ្សេងៗគ្នានៅទូទាំងប្រទេស។ ក្រុមត្រួសត្រាយផ្លូវនេះ នឹងមានឥទ្ធិពលទ្វេឡើងនៅពេលដែលដំណើរការបង្កើតគោលនយោបាយជីផ្លី ត្រូវបានគេស្គាល់កាន់តែទូលំទូលាយ។ ក្រុមនេះ គួរយកលំនាំតាមសកម្មភាព និងព្រឹត្តិការណ៍ក្នុងមូលដ្ឋាន ដើម្បីធ្វើឱ្យសកម្មភាព និងព្រឹត្តិការណ៍ទាំងនោះមានសមធម៌យេនឌ័រ ដោយពិចារណាលើបញ្ហាមួយចំនួនដូចជា ភាសា ពេលវេលានៃកិច្ចប្រជុំ និងទម្រង់នៃការចូលរួមដែលសមស្របបំផុត។ ក្រុមត្រួសត្រាយផ្លូវនេះ គួររួមមាន អនុក្រុមស្ត្រី និងបុរស នៅក្នុងផ្នែកនីមួយៗនៃប្រទេស។ ក្រុមស្នូលមួយគួរចុះធ្វើទស្សនៈកិច្ចតាមខេត្ត ភូមិភាគ ស្រុក និងឃុំ ដើម្បីកសាងសម្ព័ន្ធភាពក្នុងមូលដ្ឋាន ដែលមានការចូលរួមពីស្ត្រី និងបុរស និងផ្តល់ភាពអង់អាចដល់ពួកគេ ដើម្បីអភិវឌ្ឍសមត្ថភាព និងសម្ព័ន្ធភាពផ្ទាល់ខ្លួនរបស់ពួកគេនៅកម្រិតមូលដ្ឋាន។ សម្ព័ន្ធភាពទាំងនេះ នឹងមានតម្លៃយ៉ាងខ្លាំងសម្រាប់ការបង្កើតគោលនយោបាយជីផ្លីថ្នាក់មូលដ្ឋាន។

នៅក្នុងដំណាក់ទី៤ "បុគ្គលឆ្នើម" ពីរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ត្រូវបានកំណត់អត្តសញ្ញាណ និងជម្រុញឱ្យចូលរួមដើម្បីធានាថា ការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅតែបន្តនៅក្នុងដំណើរការបង្កើតគោលនយោបាយជីផ្លីទាំងមូល។ សកម្មភាពវិជ្ជមាន និងកូតាសម្រាប់ស្ថាប័នបង្កើតគោលនយោបាយ និងរចនាសម្ព័ន្ធ អាចត្រូវបានយកមកធ្វើការពិចារណា ព្រមជាមួយនឹងវិធីធ្វើឱ្យការបង្កើតគោលនយោបាយ កាន់តែមានការពិគ្រោះយោបល់ និងមានការចូលរួមសម្រាប់សាធារណជនគ្រប់រូប។ ប្រព័ន្ធផ្សព្វផ្សាយដើរតួនាទីមួយដ៏សំខាន់ក្នុងការផ្តល់ព័ត៌មាន និងការលើកកម្ពស់ការយល់ដឹង។

បញ្ជីផ្ទៀងផ្ទាត់ ១.៣ ៖

ការធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រនៅក្នុងការបង្កើតគោលនយោបាយជីផ្លី

- ✓ កិច្ចខិតខំក្នុងការបញ្ចូលស្ត្រីទៅក្នុងដំណើរការបង្កើតគោលនយោបាយជីផ្លី និងដើម្បីដោះស្រាយការព្រួយបារម្ភ និងបញ្ហាជាក់លាក់របស់ពួកគេ គួរត្រូវបានកំណត់គោលដៅឱ្យបានច្បាស់លាស់ និងផ្តល់ធនធានគាំទ្រឱ្យបានគ្រប់គ្រាន់។
- ✓ ស្ត្រី និងក្រុមដែលត្រូវបានគេមើលរំលងដទៃទៀត រមែងតែងតែជាអ្នកចូលរួមដែលខ្សត់ខ្សោយធនធាន និង ខ្វះខាតពេលវេលាបំផុត នៅក្នុងការបង្កើតគោលនយោបាយជីផ្លី។ ក្នុងករណីដែលឧបសគ្គផ្នែកវប្បធម៌ រារាំងស្ត្រីពីការនិយាយដោយបើកចំហ ពួកគេគួរទទួលបានការពិគ្រោះយោបល់ដោយឡែកពីបុរស។
- ✓ រចនាសម្ព័ន្ធ និងទម្រង់នៃដំណើរការបង្កើតគោលនយោបាយ ត្រូវមានភាពបត់បែនទន់ភ្លន់ឱ្យបានគ្រប់គ្រាន់ ដើម្បីសម្របទៅតាមបញ្ហាកង្វះពេលវេលារបស់ស្ត្រី និងកាតព្វកិច្ចគ្រួសារ/វប្បធម៌។
- ✓ បើទោះបីជាក្នុងករណីដែលការចូលរួមរបស់ស្ត្រី ត្រូវបានបញ្ចូលដោយស្របច្បាប់ ឬ ជាផ្លូវការទៅក្នុងដំណើរការបង្កើតគោលនយោបាយជីផ្លីក៏ដោយ គេក៏គួរផ្តោតការយកចិត្តទុកដាក់ ដើម្បីធានាឱ្យមានការចូលរួមពិតប្រាកដរបស់

ពួកគេផងដែរ។

✓ កូតា ឬ យន្តការស្រដៀងគ្នា ដើម្បីធានាការចូលរួមរបស់ស្ត្រីនៅក្នុងការបង្កើតគោលនយោបាយ គឺជាចំណុចចាប់ផ្តើមមួយដ៏សំខាន់ ប៉ុន្តែ ស្ត្រីក៏អាចត្រូវការការបណ្តុះបណ្តាល និងកិច្ចគាំទ្រសម្រាប់ការចូលរួមសកម្ម និងប្រកបដោយភាពស្ថាបនា ព្រមទាំងជំនួយដើម្បីឱ្យក្លាយជាអ្នកបង្កើតគោលនយោបាយ។

ចូរចងចាំ!

វាអាចមានការលំបាកក្នុងការវាស់ស្ទង់ទៅលើវឌ្ឍនភាពនៃការចូលរួមប្រកបដោយសមធម៌យេនឌ័រនៅក្នុងការបង្កើតគោលនយោបាយដីធ្លី។ ដោយឡែក គេអាចមាននិន្នាការត្រួតពិនិត្យចំពោះតែគោលនយោបាយដីធ្លី ដែលជាលទ្ធផលសម្រេចបាន។ បើទោះជាដូច្នេះក្តី វាមានសារៈសំខាន់ដែលត្រូវធានាថា ស្ត្រី និងបុរសបានចូលរួមស្មើភាពគ្នានៅក្នុងដំណើរការបង្កើតគោលនយោបាយ។

តួនាទីរបស់អ្នកពាក់ព័ន្ធនៅក្នុងការបង្កើតគោលនយោបាយស្តីពីដីធ្លីប្រកបដោយសមធម៌យេនឌ័រ

រដ្ឋាភិបាល

ក្នុងការផ្តល់ដំណើរការបង្កើតគោលនយោបាយដីធ្លីប្រកបដោយសមធម៌យេនឌ័រ រដ្ឋាភិបាលគួរមានភាពសកម្មនៅក្នុងវិស័យចំនួន២ ៖

- មន្ត្រីរដ្ឋាភិបាលត្រូវទទួលបានការបញ្ជ្រាបអំពីបញ្ហាយេនឌ័រ រាប់បញ្ចូលការចូលរួមប្រកបដោយសមធម៌យេនឌ័រនៅក្នុងការបង្កើតគោលនយោបាយដីធ្លី ក្នុងលក្ខណៈជាផ្នែកមួយនៃការបណ្តុះបណ្តាលណែនាំការងារសម្រាប់បុគ្គលិកថ្មីៗគ្រប់រូប នៅក្នុងក្រសួង និង នាយកដ្ឋានពាក់ព័ន្ធ។ ក្នុងករណីដែលអ្នកនយោបាយចូលរួមដោយផ្ទាល់នៅក្នុងរដ្ឋបាលរបស់រដ្ឋាភិបាល ពួកគេក៏គួរទទួលបានការបញ្ជ្រាបអំពីបញ្ហានេះផងដែរ។

- រដ្ឋាភិបាលអាចលើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធដទៃទៀត នៅក្នុងដំណើរការបង្កើតគោលនយោបាយដីធ្លី និងកំណត់អំពីរបៀបវារៈរួម ព្រមទាំងអាណត្តិការងារសម្រាប់ដំណើរការមួយដែលមានការចូលរួមពីគ្រប់ភាគី និងមានសមធម៌យេនឌ័រ។ ប្រអប់ ១.៤ ផ្តល់នូវឧទាហរណ៍មួយចំនួនអំពីការដឹកនាំរបស់រដ្ឋាភិបាល នៅក្នុងប្រទេសហ្គាណា នេប៉ាល់ និង ឥណ្ឌា។

នៅក្នុង*ប្រទេសហ្គាណា* គម្រោងរដ្ឋបាលដីធ្លីរបស់រដ្ឋាភិបាល (LAP) បានដាក់បញ្ចូលយុទ្ធសាស្ត្រយេនឌ័រមួយ សម្រាប់ឆ្លើយតបទៅនឹងបញ្ហាកង្វល់ផ្នែករដ្ឋបាលដីធ្លីរបស់ស្ត្រី និងបុរស តាមរយៈការប្រមូលទិន្នន័យដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ និងការចូលរួមនៅក្នុងដំណើរការរៀបចំ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ។ យុទ្ធសាស្ត្រនេះ មានសកម្មភាពចំនួន៥ ដើម្បីសម្រេចឱ្យបាននូវគោលបំណងយេនឌ័ររបស់គម្រោងរដ្ឋបាលដីធ្លី ៖ ការអប់រំសាធារណៈ ការកសាងសមត្ថភាព ដំណើរការស្ថាប័ន ការតស៊ូមតិ និងកិច្ចសហការ និងការតភ្ជាប់បណ្តាញ។
នៅក្នុង*ប្រទេសនេប៉ាល់* តំណាងមួយរូបនៃវេទិកាជាតិ ស្តីពីសិទ្ធិដីធ្លី ដែលរួមមានសមាសភាពចូលរួមពីកសិករជាស្ត្រី និងបុរស អង្គការស្ត្រី និងអង្គការដែលធ្វើការងារលើបញ្ហាកំណែទម្រង់ដីធ្លី ចូលរួមជាសមាជិកមួយរូបនៃគណៈកម្មការកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាលប្រទេសនេប៉ាល់ ដែលមានសមាជិក ៧រូប។
នៅក្នុង*ប្រទេសឥណ្ឌា* ក្នុងឆ្នាំ២០០៨ រដ្ឋាភិបាលបានរៀបចំបង្កើតគណៈកម្មាធិការទំនាក់ទំនងដីធ្លីរបស់រដ្ឋមួយទទួលបន្ទុកការងារកំណែទម្រង់ដីធ្លីដែលនៅសេសសល់ ដើម្បីត្រួតពិនិត្យទៅលើស្ថានភាពនៃកំណែទម្រង់ដីធ្លីនានា រាប់បញ្ចូលវិធានការដើម្បីធានាឱ្យមានការចូលរួមរបស់ស្ត្រី នៅក្នុងដំណើរការអភិបាលកិច្ចដីធ្លី និងការទទួលបានដីធ្លីកាន់តែប្រសើរជាងមុន។ អនុសាសន៍ជាក់លាក់ បានបញ្ចូលភាពជាតំណាងរបស់ស្ត្រីនៅក្នុងទីភ្នាក់ងារដែលត្រូវបានរៀបចំឡើង ដើម្បីត្រួតពិនិត្យទៅលើកំណែទម្រង់ដីធ្លី។

ប្រអប់ ១.៤ ៖
កិច្ចគាំទ្ររបស់រដ្ឋាភិបាលសម្រាប់ការបង្កើតគោលនយោបាយដីធ្លីប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ Seema Gaikwad's presentation on "Asian experiences of civil society engagement with land policy processes" and Rebecca Sittie's presentation on "Gender issues in managing and implementing land registration in Ghana" at the May 2011 technical workshop; India Ministry of Rural Development, 2009; Ghana Land Administration Project, no date.

✎បញ្ជីផ្ទៀងផ្ទាត់ ១.៤ ៖
សកម្មភាពសម្រាប់រដ្ឋាភិបាល

✓ ប្រើប្រាស់សកម្មភាពវិជ្ជមាន ដូចជាកូតា ដើម្បីធានាថាស្ត្រីទទួលបានភាពជាតំណាងប្រកបដោយសមធម៌នៅក្នុងស្ថាប័ន និង រចនាសម្ព័ន្ធនយោបាយ និងអភិបាលកិច្ចដែលពាក់ព័ន្ធនៅក្នុងការបង្កើតគោលនយោបាយដីធ្លី។ ពិចារណាទៅលើការអភិវឌ្ឍន៍សមត្ថភាព និងភាពបត់បែនទន់ភ្លន់ ដើម្បីគាំទ្រដល់ស្ថាប័ន និងរចនាសម្ព័ន្ធទាំងនេះ។

✓ បង្កើតក្រុមអ្នកពាក់ព័ន្ធ ឬ ទីភ្នាក់ងាររដ្ឋាភិបាលឯកទេសមួយ ដើម្បីដោះស្រាយបញ្ហាយេនឌ័រ តាមរយៈ ៖
- ការលើកកម្ពស់ការយល់ដឹងអំពីដំណើរការបង្កើតគោលនយោបាយដីធ្លី និងបញ្ហាគោលនយោបាយដីធ្លី ក្នុងចំណោមស្ត្រី និងបុរស
- ការប្រមូលការអនុវត្តន៍ និង មេរៀនល្អៗពីអន្តរជាតិ សម្រាប់ការចូលរួមប្រកបដោយសមធម៌យេនឌ័រ ក្នុងការបង្កើតគោលនយោបាយដីធ្លីពីប្រទេសជិតខាង។

✓ បង្កើត និង បណ្តុះបណ្តាលក្រុមមន្ត្រីរដ្ឋាភិបាលដែលជាអ្នកត្រួសត្រាយផ្លូវ រាប់បញ្ចូលទាំងស្ត្រី ដើម្បីដឹកនាំដំណើរការបង្កើតគោលនយោបាយដីធ្លីនៅថ្នាក់មូលដ្ឋាន តាមរយៈការចុះធ្វើទស្សនៈកិច្ចតាមបណ្តាស្រុកនានា និងស្ថាប័នរដ្ឋាភិបាលថ្នាក់ក្រោមជាតិដទៃទៀត ដើម្បី ៖
- កំណត់រកភាពខុសគ្នានៃបរិបទសម្រាប់ស្ត្រី និងបុរសទូទាំងប្រទេស
- បង្កើត និងបណ្តុះបណ្តាលក្រុមស្ត្រី និងបុរសក្នុងមូលដ្ឋាន ដើម្បីជម្រុញ

ដំណើរការនេះទៅថ្នាក់មូលដ្ឋាន

✓ ដឹកនាំក្នុងការយកលំនាំតាមសកម្មភាពគោលនយោបាយ ព្រឹត្តិការណ៍ ដំណើរការ និងឧបករណ៍នានា ដើម្បីធានាឱ្យមានសមធម៌យេនឌ័រ ឧទាហរណ៍ តាមរយៈការធ្វើសវនកម្មផ្ទៃក្នុងទៅលើការចូលរួមប្រកបដោយសមធម៌យេនឌ័រ។

ចូរចងចាំ!

រដ្ឋាភិបាលដើរតួនាទីឈានមុខ នៅក្នុងការបង្កើតគោលនយោបាយប្រកបដោយសមធម៌យេនឌ័រ ប៉ុន្តែ ពួកគេត្រូវធ្វើការងារជាមួយអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីធានាថាគោលនយោបាយឆ្លុះបញ្ចាំងអំពីសេចក្តីត្រូវការរបស់មនុស្ស និង ដើម្បីជួយបង្កលក្ខណៈឱ្យមានការឯកភាពគ្នា និងកិច្ចគាំទ្រសម្រាប់លទ្ធផលគោលនយោបាយ។

សង្គមស៊ីវិល

អ្នកពាក់ព័ន្ធសង្គមស៊ីវិល អាចជួយធ្វើឱ្យប្រជាជន និងក្រុមដែលត្រូវបានគេមើលរំលង កាន់តែត្រូវបានគេមើលឃើញតាមរយៈ ៖ ការតស៊ូមតិសម្រាប់បញ្ហារបស់ពួកគេ និងការគាំទ្រឱ្យមានការចូលរួមដោយផ្ទាល់របស់ពួកគេនៅក្នុងកិច្ចពិភាក្សាអំពីគោលនយោបាយ ការត្រួតពិនិត្យ និងការផ្តល់របាយការណ៍អំពីដំណើរការបង្កើតគោលនយោបាយ ដើម្បីធ្វើឱ្យដំណើរការនេះកាន់តែមានគណនេយ្យភាពចំពោះសមធម៌យេនឌ័រ ដូចជា តាមរយៈការប្រើប្រាស់វិទ្យុដើម្បីជូនដំណឹងដល់សាធារណជន អំពីរបៀបដែលស្ត្រី និងបុរស កំពុងត្រូវបានបង្កលក្ខណៈឱ្យចូលរួម ត្រួតពិនិត្យ និង ធានាឱ្យមានគណនេយ្យភាពពីភាគីរដ្ឋាភិបាល និង អ្នកពាក់ព័ន្ធវិស័យឯកជន ព្រមទាំងអភិវឌ្ឍ និង ដឹកនាំឱ្យមានការឯកភាពពីសាធារណជនឱ្យបានទូលំទូលាយ សម្រាប់ការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងការបង្កើតគោលនយោបាយដីធ្លី។

ប្រទេសជាច្រើនខ្វះការស្រាវជ្រាវ និងចំណេះដឹងអំពីបញ្ហាដីធ្លី។ អាស្រ័យដោយពួកគេស្ថិតនៅក្បែរមូលដ្ឋាន អ្នកពាក់ព័ន្ធសង្គមស៊ីវិល អាចធ្វើការស្រាវជ្រាវក្នុងលក្ខណៈជាប្រព័ន្ធនៅថ្នាក់មូលដ្ឋាន ដើម្បីជួយធានាថាសម្លេង ចំណេះដឹង និងប្រយោជន៍របស់ស្ត្រី ត្រូវបានបញ្ចូលទៅក្នុងការបង្កើតគោលនយោបាយដីធ្លី ហើយអ្នកពាក់ព័ន្ធវិស័យឯកជន និង អង្គការអន្តរជាតិ អាចផ្តល់មូលនិធិគាំទ្រដល់ការស្រាវជ្រាវនេះ។ ឧទាហរណ៍ នៅចន្លោះឆ្នាំ២០០៨ និង ឆ្នាំ២០១០ សម្ព័ន្ធភាពដីធ្លីអន្តរជាតិ (ILC) បានសម្របសម្រួលគម្រោងស្រាវជ្រាវមួយ ស្តីពីការធានាលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានដីធ្លី នៅភាគខាងកើត និង ភាគខាងត្បូង នៃទ្វីបអាហ្វ្រិក ដោយមានគោលបំណងជាក់លាក់ ក្នុងការជះឥទ្ធិពលទៅលើការរៀបចំបង្កើត និងការអនុវត្តន៍គោលនយោបាយដីធ្លី តាមរយៈការតស៊ូមតិ ដែលមានមូលដ្ឋានផ្អែកលើលទ្ធផលស្រាវជ្រាវ។ គម្រោងនេះ មានការចូលរួមពីក្រុមស្រាវជ្រាវពហុវិស័យ និង ការជម្រុញភាពជាដៃគូក្នុងចំណោមអ្នកស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និង អង្គការមូលដ្ឋាន (សូមមើលរបាយការណ៍របស់ WOLREC, 2011 និង ILC អំពីការធានាលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានដីធ្លីសម្រាប់ឧទាហរណ៍បន្ថែម)[៣]។

កម្រិតវិសាលភាពដែលអ្នកពាក់ព័ន្ធសង្គមស៊ីវិល រាប់បញ្ចូលទាំងអង្គការស្ត្រី អាចចូលរួមនៅក្នុងដំណើរការបង្កើតគោលនយោបាយដីធ្លី អាស្រ័យទៅលើ ៖

- លំហនយោបាយដែលមានសម្រាប់សង្គមស៊ីវិលនៅក្នុងប្រទេស

- ទំនាក់ទំនងរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល និងឥរិយាបថរបស់រដ្ឋាភិបាលចំពោះការចូលរួមរបស់សង្គមស៊ីវិល នៅក្នុងការបង្កើតគោលនយោបាយដីធ្លី
- កម្រិតនៃចំណេះដឹង និងការយល់ដឹងរបស់សហគមន៍អំពីដំណើរការបង្កើតគោលនយោបាយដីធ្លី
- រយៈពេលនៃដំណើរការបង្កើតគោលនយោបាយ (រាប់បញ្ចូលការពន្យារពេលតាមលក្ខណៈបច្ចេកទេស) ដែលអាចដាក់សម្ពាធទៅលើធនធានរបស់សង្គមស៊ីវិល។

បញ្ហាប្រឈមមួយសម្រាប់ការចូលរួមរបស់សង្គមស៊ីវិល នៅក្នុងការបង្កើតគោលនយោបាយដីធ្លី គឺការធានាឱ្យមានការចូលរួម និងភាពជាតំណាងរបស់ស្ត្រី និងបុរសពីគ្រប់ក្រុមសង្គមទាំងអស់ ដូចមានពន្យល់លម្អិតនៅក្នុង *ម៉ូឌុល៣* ។ បញ្ហាប្រឈមនេះ កាន់តែមានការលំបាកនៅពេលដែលបញ្ហាដទៃទៀតក្រៅពីសមធម៌យេនឌ័រ នៅក្នុងការបង្កើតគោលនយោបាយដីធ្លី គឺជាអាទិភាព។

ប្រអប់ ១.៥ ផ្តល់នូវឧទាហរណ៍អំពីតួនាទីដ៏សំខាន់របស់សង្គមស៊ីវិល ក្នុងការរៀបចំបង្កើត និងអនុវត្តគោលនយោបាយដីធ្លីប្រកបដោយសមធម៌យេនឌ័រ។ អ្នកពាក់ព័ន្ធអង្គការសង្គមស៊ីវិល ត្រូវបានរៀបចំយ៉ាងល្អប្រសើរ ដើម្បីអនុវត្តធ្វើការតស៊ូមតិ គៀងគរសហគមន៍ និងប្រមូលកិច្ចគាំទ្រពីសាធារណជន ព្រមទាំងការចូលរួម ដើម្បីជម្រុញឱ្យមានការផ្លាស់ប្តូរ ហើយស្របពេលជាមួយគ្នានោះ ក៏ត្រូវចូលរួមដោយផ្ទាល់ជាមួយរដ្ឋាភិបាលផងដែរ ហើយពួកគេអាចផ្តល់ការបណ្តុះបណ្តាល កិច្ចគាំទ្រផ្នែកច្បាប់ និងកិច្ចគាំទ្រផ្សេងទៀត ជូនដល់អ្នកពាក់ព័ន្ធដទៃទៀត។ អង្គការស្ត្រីមួយបានធ្វើការគូសបញ្ជាក់ឱ្យដឹងថា សង្គមស៊ីវិលចាំបាច់ "ត្រូវមានការកំណត់តួនាទីឱ្យបានច្បាស់លាស់ ដើម្បីធ្វើការងារក្រោមភាពជាដៃគូជាមួយរដ្ឋាភិបាល ខណៈពេលជាមួយគ្នានោះ ក៏ត្រូវរក្សាភាពឯករាជ្យរបស់ខ្លួនផងដែរ" (WLLA, 2010b: 9)។

អាហ្វ្រិក

ប្រអប់ ១.៥ ៖
កិច្ចគាំទ្ររបស់សង្គមស៊ីវិលសម្រាប់ការបង្កើតគោលនយោបាយដីធ្លីប្រកបដោយសមធម៌យេនឌ័រ

នៅ*អាហ្វ្រិក* សង្គមស៊ីវិល បានបន្តចូលរួមប្រកបដោយភាពស្ថាបនានៅក្នុងដំណើរការបង្កើតគោលនយោបាយជាផ្លូវការ ៖

- ក្នុងអំឡុងពេលនៃការរៀបចំក្របខ័ណ្ឌ*សហជីពរបស់អាហ្វ្រិក* និង គោលការណ៍ណែនាំស្តីពីគោលនយោបាយដីធ្លីនៅអាហ្វ្រិក អ្នកពាក់ព័ន្ធសង្គមស៊ីវិលបានចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់ ផ្តល់មតិយោបល់ទៅលើសេចក្តីព្រាងឯកសារ និងអភិវឌ្ឍឯកសារមួយផ្នែក។ ក្រុមសង្គមស៊ីវិលក៏បានរៀបចំព្រឹត្តិការណ៍មួយចំនួនស្របពេលតំណាលគ្នាទៅនឹងកិច្ចប្រជុំសហជីពអាហ្វ្រិក ក្នុងអំឡុងពេលនៃដំណើរការបង្កើតគោលនយោបាយ ព្រមទាំងបានដាក់ចេញនូវឯកសារទំនាក់ទំនងគោលនយោបាយដីធ្លីផងដែរ។
- នៅក្នុង*ប្រទេសកេនយ៉ា* ក្នុងអំឡុងពេលនៃការរៀបចំបង្កើតគោលនយោបាយដីធ្លី ក្រុមសង្គមស៊ីវិល ក្រោមសម្ព័ន្ធភាពដីធ្លីរបស់ប្រទេសកេនយ៉ា បានធ្វើចលនាគៀងគរសហគមន៍ ដើម្បីទាមទារលំហនៅក្នុងសង្វៀនបង្កើតគោលនយោបាយ។ ស្ត្រី និងបុរស ជាងមួយពាន់នាក់ បានចូលរួមដោយផ្ទាល់នៅក្នុងដំណើរការបើកចំហមួយ ដែលពាក់ព័ន្ធទៅនឹងវេទិកាសាធារណៈ និងក្រុមការងារបច្ចេកទេសចំនួន៦ រួមទាំងក្រុមការងារបច្ចេកទេសមួយដែលដោះស្រាយបញ្ហាសមធម៌យេនឌ័រ។

ប្រភព ៖ Catherine Gatundu's presentation on "Africa experiences of civil society involvement in land policy process", Judy Adoko's presentation on "Constructive ways of working with customary institutions in support of women's land rights", and Seema Gaikwad's presentation on "Asian experiences of civil society engagement with land policy processes" at the May 2011 workshop; ULA, 2010; Land Watch Asia, 2010.

គោលនយោបាយដីធ្លីថ្មី ត្រូវបានអនុម័តក្នុងខែធ្នូ ឆ្នាំ២០០៩។ ក្រុមសង្គមស៊ីវិលក៏បានរួមចំណែកចំពោះកិច្ចពិភាក្សាទៅលើរដ្ឋធម្មនុញ្ញផងដែរ ក្នុងនោះរាប់បញ្ចូលការស្នើឡើងនូវគោលការណ៍រដ្ឋធម្មនុញ្ញ សម្រាប់កំណែទម្រង់ដីធ្លី ដែលជាមូលដ្ឋាននៃគោលនយោបាយដីធ្លីថ្មី។ រដ្ឋធម្មនុញ្ញថ្មីដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១០ ផ្តល់ឱ្យស្ត្រី និងបុរស នូវសិទ្ធិក្នុងការទទួលបានការប្រព្រឹត្ត និងឱកាសស្មើភាពគ្នានៅក្នុងបរិយាកាសនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គម ដោយធានាថាអង្គភាពដែលត្រូវបានបោះឆ្នោតជ្រើសរើស យ៉ាងហោចណាស់មានសមាសភាពចូលរួមពីស្ត្រីចំនួនមួយភាគបី (និង/ឬ យ៉ាងហោចណាស់មានសមាសភាពចូលរួមពីបុរសចំនួនមួយភាគបី) ព្រមទាំងលុបបំបាត់នូវការរើសអើងយេនឌ័រ ចំពោះសិទ្ធិស្នងមរតក និងសិទ្ធិទទួលបានដីធ្លី និងអចលនទ្រព្យ។

អាស៊ី

នៅ*អាស៊ី* អ្នកពាក់ព័ន្ធសង្គមស៊ីវិល បានវិនិយោគទៅលើរចនាសម្ព័ន្ធអភិបាលកិច្ចបែបផ្លូវការ និងបែបប្រពៃណី ដែលលើកកម្ពស់នូវ ការរាប់បញ្ចូល តម្លាភាព និងគណនេយ្យភាព ព្រមទាំងបានចូលរួមនៅក្នុងកំណែទម្រង់គោលនយោបាយដីធ្លី ៖

- នៅ*ប្រទេសឥណ្ឌា* ក្នុងឆ្នាំ២០០៤ អង្គការស្ត្រីបានដាក់ឱ្យដំណើរការនូវចលនាមួយ សំដៅដកចេញនូវបទប្បញ្ញត្តិរើសអើងយេនឌ័រ ពីច្បាប់សន្តតិកម្មហិនឌូឆ្នាំ១៩៥៦។ ច្បាប់ដែលត្រូវបានធ្វើវិសោធនកម្ម ក្នុងឆ្នាំ២០០៥ ផ្តល់ឱ្យកូនស្រីនូវសិទ្ធិដូចគ្នាក្នុងការជ្រើសរើសគូស្រករ ដូចគ្នាទៅនឹងកូនប្រុសផងដែរ។ ក្នុងឆ្នាំ២០០៨ គណៈកម្មាធិការទំនាក់ទំនងដីធ្លីរបស់រដ្ឋទទួលបន្ទុកការងារកំណែទម្រង់ដីធ្លីដែលនៅសេសសល់ បានផ្តល់អនុសាសន៍ឱ្យផ្តល់សិទ្ធិក្នុងការទទួលបាន និងសិទ្ធិជាម្ចាស់រួមគ្នាជាកំហិត ចំពោះដីលំនៅឋាន និងសិទ្ធិសហគមន៍សម្រាប់ស្ត្រីរាប់បញ្ចូលភាពជាម្ចាស់ទៅលើដីទ្រព្យសម្បត្តិរួមនៅក្នុងភូមិផងដែរ។
- នៅ*ប្រទេសនេប៉ាល់* ក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១១ ស្ត្រីដែលគ្មានដីបានធ្វើការអង្គុយតវ៉ា ដើរជាក្បួន និងប្រជុំជាមួយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់។ ជាការឆ្លើយតបរដ្ឋាភិបាលបានរៀបចំបង្កើតក្រុមការងារមួយដែលមានសមាជិកចំនួន៧រូប ដែលរួមមានតំណាងមួយរូបពីវេទិកាជាតិស្តីពីសិទ្ធិដីធ្លី ដើម្បីពិនិត្យមើលអនុសាសន៍ដែលធ្វើឡើងដោយគណៈកម្មការកំណែទម្រង់ដីធ្លីជាន់ខ្ពស់បែបវិទ្យាសាស្ត្រ និងដើម្បីធានាថា ស្ត្រីមានសិទ្ធិទទួលបានដីធ្លី។
- នៅក្នុង*ប្រទេសនេប៉ាល់* ផងដែរ អង្គការស្ត្រី និងក្រុមជំនួយផ្នែកច្បាប់ បានផ្តល់ឱ្យតំណាងស្ត្រីដែលត្រូវបានបោះឆ្នោតជ្រើសរើសនូវការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សមត្ថភាព ដើម្បីឱ្យពួកគេអាចចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការបង្កើតគោលនយោបាយដីធ្លី និង បញ្ចេញសម្លេងអំពីមតិយោបល់របស់ពួកគេលើបញ្ហាជុំវិញសិទ្ធិដីធ្លីរបស់ស្ត្រី។

✎បញ្ជីផ្ទៀងផ្ទាត់ ១.៥ ៖

សកម្មភាពសម្រាប់សង្គមស៊ីវិល

ប្រភព ៖ Catherine Gatundu's presentation on "Africa experiences of civil society involvement in land policy process" at the May 2011 technical workshop.

ការរៀបចំបង្កើត

- ✓ ចូលរួមដោយផ្ទាល់ជាមួយរដ្ឋាភិបាល។
- ✓ ស្នើឡើងនូវជម្រើសខ្លឹមសារអត្ថបទ និងរៀបចំឯកសារអំពីសារតា និងបញ្ហានានា។
- ✓ ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីផ្លាស់ប្តូរវិយាបថ កសាងកិច្ចគាំទ្រ និងបង្កើតឱ្យមាននូវការឯកភាពជាសាធារណៈសម្រាប់ការចូលរួមពីស្ត្រី និងបុរស នៅក្នុងដំណើរការបង្កើតគោលនយោបាយមួយ ដែលមានការពិគ្រោះយោបល់ និងមានការចូលរួមពីគ្រប់ភាគី រាប់បញ្ចូលតាមរយៈការផ្សព្វផ្សាយមាតិកាគោលនយោបាយ និង ឯកសារបច្ចេកទេសក្នុងលក្ខណៈដែលធ្វើឱ្យបុគ្គលគ្រប់រូបអាចយល់បាន (ចំណុចខ្លាំងមួយដ៏ចម្បងនៃសង្គមស៊ីវិល)។
- ✓ ផ្តល់ការទ្រទ្រង់ និងគាំទ្រផ្នែកច្បាប់។
- ✓ រៀបចំព្រឹត្តិការណ៍ ស្តីពីដំណើរការបង្កើតគោលនយោបាយ ក្នុងពេលស្របគ្នានៅឯកិច្ចប្រជុំ សន្និសីទ និងព្រឹត្តិការណ៍ដទៃទៀត។

ការអនុវត្តន៍

- ✓ រៀបចំ និងចូលរួមនៅក្នុងកិច្ចពិភាក្សាអំពីការអភិវឌ្ឍន៍ក្របខ័ណ្ឌច្បាប់។
- ✓ បណ្តុះបណ្តាលបុគ្គលិក និង សមាជិកស្ថាប័នរដ្ឋបាលដីធ្លី អំពីទិដ្ឋភាពយេនឌ័រនៃគោលនយោបាយដីធ្លីថ្មី។
- ✓ យុទ្ធនាការសម្រាប់ការអនុវត្តន៍គោលនយោបាយដីធ្លី ឧទាហរណ៍តាមរយៈការរៀបចំបង្កើតក្រុមឃ្លាំមើល និង តាមរយៈការប្រើប្រាស់ប័ណ្ណដាក់ពិន្ទុ ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តន៍របស់រដ្ឋាភិបាល និង ធ្វើការបោះពុម្ពផ្សាយអំពីគំហើញនានា។
- ✓ ត្រួតពិនិត្យផលប៉ះពាល់នៃយេនឌ័រទៅលើគោលនយោបាយ និង បទប្បញ្ញត្តិស្តីពីដីធ្លី និងអចលនទ្រព្យ។

ចូរចងចាំ!

សង្គមស៊ីវិល មានប្រសិទ្ធភាពខ្លាំងបំផុត នៅពេលដែលពួកគេធ្វើការងារសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធដទៃទៀត រាប់បញ្ចូលវិស័យឯកជន និងអង្គការអន្តរជាតិ ដែលអាចផ្តល់មូលនិធិសម្រាប់ការងារបង្កើតគោលនយោបាយរបស់សង្គមស៊ីវិល។

ប្រអប់ ១.៦ ៖

រដ្ឋាភិបាល និងសង្គមស៊ីវិលធ្វើការងារជាមួយគ្នា

ប្រភព ៖ Patricia Costas's presentation on "Genderequitable communication methods and sensitization strategies to support land governance in Bolivia" at the May 2011 technical

ច្បាប់ស្តីពីកំណែទម្រង់ដីធ្លី ឆ្នាំ១៩៥៣ របស់ប្រទេសបូលីវៀ រួមមានខចែងមិនរើសអើងមួយ ប៉ុន្តែ ច្បាប់នោះអនុញ្ញាតចំពោះតែស្ត្រីដែលពុំមានដៃគូ រាប់បញ្ចូលទាំងស្ត្រីមេម៉ាយ ក្នុងការក្លាយជាអ្នកទទួលផលនៃការបែងចែកដីធ្លី និងការទទួលបានប្លង់ដី។ ច្បាប់ដែលបង្កើតឱ្យមាននូវសេវាជាតិសម្រាប់កំណែទម្រង់ដីធ្លី ក្នុងឆ្នាំ១៩៩៦ បាននាំមកនូវសមធម៌សម្រាប់ស្ត្រី និងបុរសគ្រប់រូប ដោយមិនប្រកាន់អំពីស្ថានភាពអាពាហ៍ពិពាហ៍ និង បាននាំឱ្យមានការកើនឡើងនូវការផ្តល់ប្លង់ដីជូនដល់ស្ត្រី។ ក្នុងឆ្នាំ២០០៦ រដ្ឋធម្មនុញ្ញថ្មីបានធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌច្បាប់

workshop.

សម្រាប់សិទ្ធិស្ត្រីក្នុងការទទួលបានដីធ្លី ហើយរដ្ឋាភិបាលបានប្តេជ្ញាចិត្តធានាឱ្យស្ត្រីអាចចូលរួមបានពេញលេញនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅលើកំណែទម្រង់ដីធ្លី។ អង្គការស្ត្រី បាននិងកំពុងដើរតួនាទីគាំទ្រយ៉ាងសំខាន់នៅក្នុងដំណើរការទាំងអស់នេះ។ ក្នុងឆ្នាំ១៩៩០ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដូចជា សហព័ន្ធជាតិស្ត្រីកសិករ បានចូលរួមនៅក្នុងការធ្វើដំណើរជាក្បួន ដើម្បីទាមទារទឹកដី និងភាពថ្លៃថ្នូរសម្រាប់ស្ត្រីជនជាតិដើមភាគតិច។ ក្នុងឆ្នាំ២០០៦ ពួកគេបានចូលរួមនៅក្នុងសន្និបាតធម្មនុញ្ញជាលើកទី១ នៅក្នុងប្រវត្តិរបស់ប្រទេសបូលីវៀ។ សម្ព័ន្ធភាពអង្គការស្ត្រីមួយ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានកំណត់របៀបវារៈបទប្បញ្ញត្តិមួយសម្រាប់ស្ត្រី រាប់បញ្ចូលការបញ្ចូលសិទ្ធិរបស់ស្ត្រី ក្នុងការទទួលបានទ្រព្យសម្បត្តិទៅក្នុងរដ្ឋធម្មនុញ្ញថ្មី។ ជោគជ័យទាំងនេះ ពាក់ព័ន្ធទៅនឹងសង្គមស៊ីវិលដែលបានចូលរួមសកម្មព្រមទាំងបានផ្តល់នូវការស្រាវជ្រាវ និង ភស្តុតាងដើម្បីគាំទ្រឱ្យមានការផ្លាស់ប្តូរព្រមទាំងបានជួយបង្កើតឱ្យមានបរិយាកាសវិជ្ជមានមួយ សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ នៅក្នុងប្រទេស។

វិស័យឯកជន

ក្រុមហ៊ុន និងអ្នកអនុវត្តការងារវិស័យឯកជន ដែលអនុវត្តការងារបច្ចេកទេសប្រចាំថ្ងៃភាគច្រើននៅក្នុងវិស័យដីធ្លី រមែងតែងមានចំណេះដឹងឯកទេស និង ព័ត៌មានដែលមានតម្លៃក្នុងការអភិវឌ្ឍន៍គោលនយោបាយដីធ្លីមួយប្រកបដោយសមធម៌យេនឌ័រ។ ពួកគេក៏រមែងតែងមានលទ្ធភាពប្រាស្រ័យទាក់ទងជាមួយមន្ត្រីរដ្ឋាភិបាល ហើយព្រមទាំងជះឥទ្ធិពលរួចទៅហើយទៅលើលទ្ធផលនៃដំណើរការបង្កើតគោលនយោបាយដីធ្លី តាមរយៈបច្ចេកវិទ្យា និងប្រព័ន្ធដែលពួកគេប្រើប្រាស់ និងលើកកម្ពស់។ ការផ្តួចផ្តើមវិស័យឯកជនមានការកើនឡើងកាន់តែច្រើនជាលំដាប់នៅក្នុងកំណែទម្រង់ដីធ្លី និងកសិកម្មទូទាំងសកលលោក។ ក្នុងនោះរួមមានការផ្តួចផ្តើមឱ្យមានកំណែទម្រង់លើការបែងចែកដីឡើងវិញ ដូចជានៅក្នុងឧស្សាហកម្មផលិតស្ករ នៅអាហ្វ្រិកខាងត្បូង និងយន្តការប្រកបដោយភាពច្នៃប្រឌិតថ្មីមួយចំនួនសម្រាប់ដំណើរការចុះបញ្ជីដីធ្លី ដែលបង្កលក្ខណៈឱ្យប្រជាពលរដ្ឋអាចមានលទ្ធភាពធ្វើទៅបាន តាមរយៈភាពជាដៃគូជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ ដូចនៅក្នុងប្រទេសហ្គាណា (Bernstein, 2005; Rabley, 2010)។

បើទោះជាដូច្នេះក្តី ខណៈពេលដែលភាគីពាក់ព័ន្ធខាងរដ្ឋាភិបាលត្រូវមានគណនេយ្យភាព តាមរយៈប្រព័ន្ធនយោបាយ ហើយភាគីពាក់ព័ន្ធខាងសង្គមស៊ីវិល ត្រូវមានគណនេយ្យភាពចំពោះម្ចាស់មូលនិធិរបស់ពួកគេ តួនាទីរបស់វិស័យឯកជន នៅក្នុងដំណើរការបង្កើតគោលនយោបាយដីធ្លី ដែលមានលក្ខណៈកាន់តែទូលំទូលាយ ត្រូវតែធ្វើឱ្យកាន់តែមានតម្លាភាព។ នាពេលបច្ចុប្បន្ននេះ ការផ្តួចផ្តើមរបស់វិស័យឯកជន រមែងតែងមិនត្រូវបានយកមកធ្វើការបូកបញ្ចូល ឬ ពិនិត្យតាមដានជាផ្លូវការ។ គណនេយ្យភាពរបស់ភាគីពាក់ព័ន្ធវិស័យឯកជនមានសារៈសំខាន់ជាពិសេស ពីព្រោះពួកគេរមែងតែងជាតួអង្គដែលមានអំណាចដែលផ្តល់នូវប្រយោជន៍ក្រុមហ៊ុនខ្ពស់។ ដូច្នេះ គណនេយ្យភាព ពឹងផ្អែកទៅលើការលើកកម្ពស់ និងការត្រួតពិនិត្យលើការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន។

ភាគីពាក់ព័ន្ធវិស័យឯកជន អាចចុះហត្ថលេខាទៅលើគោលការណ៍ណែនាំអន្តរជាតិ ដែលលើកកម្ពស់ការទទួលខុសត្រូវសង្គម និងសមធម៌យេនឌ័រ ដែលការចូលរួមរបស់ពួកគេនៅក្នុងដំណើរការបង្កើតគោលនយោបាយអាចត្រូវបានវាស់ស្ទង់ និងវាយតម្លៃនៅក្នុងគ្រប់ប្រទេសទាំងអស់។ គោលការណ៍ណែនាំផ្តល់នូវកម្រងគោលការណ៍មួយដ៏សំខាន់ ដែលគ្រប់ភាគីពាក់ព័ន្ធវិស័យឯកជនទាំងអស់ដែលចូលរួមនៅក្នុងការបង្កើតគោលនយោ-បាយដីធ្លី គួរយកមកប្រើប្រាស់ និងប្តេជ្ញាសម្រេចឱ្យបាន។

អង្គការអន្តរជាតិ

អង្គការអន្តរជាតិ រមែងតែងតែជាអ្នកឧបត្ថម្ភ និង ម្ចាស់ជំនួយចម្បងៗ ដែលផ្តល់មូលនិធិដើម្បីគាំទ្រដល់កិច្ចខិតខំបង្កើតគោលនយោបាយដីធ្លីនៅក្នុងប្រទេសជាច្រើន។ ការទទួលខុសត្រូវរបស់ពួកគេ ដើម្បីគាំទ្រដល់សមធម៌យេនឌ័រ មានមូលដ្ឋានដោយផ្ទាល់ចេញពីការប្តេជ្ញាចិត្តរបស់ពួកគេ ចំពោះគោលការណ៍ណែនាំ និងកម្រងលិខិតុបករណ៍អន្តរជាតិមួយចំនួនដែលលើកកម្ពស់គោលការណ៍សមធម៌ និងសមភាពយេនឌ័រ។ ផែនការសកម្មភាពទូទាំងប្រព័ន្ធ (SWAP) ស្តីពីសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី[៩] របស់អង្គការសហប្រជាជាតិ (UN) ត្រូវបានអនុម័តក្នុងឆ្នាំ២០១២ ដើម្បីវាស់ស្ទង់ទៅលើសមភាពយេនឌ័រទូទាំងប្រព័ន្ធរបស់អង្គការសហប្រជាជាតិ និង ដើម្បីបន្តសម្រេចឱ្យបាននូវសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី នៅក្នុងគោលនយោបាយ និងកម្មវិធីរបស់អង្គការសហប្រជាជាតិ។

អង្គការអន្តរជាតិ ក៏មានតួនាទីក្នុងការសម្រុះសម្រួល រវាងភាគីពាក់ព័ន្ធខាងរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនផងដែរ ព្រមទាំងធានាឱ្យមានកិច្ចសហប្រតិបត្តិការសកម្ម រវាងភាគីពាក់ព័ន្ធទាំងនេះ នៅក្នុងដំណើរការបង្កើតគោលនយោបាយ។ តួនាទីនេះ គួរត្រូវបានយកមកប្រើប្រាស់ដើម្បីលើកកម្ពស់ និង ធ្វើការតស៊ូមតិឱ្យមានសមធម៌យេនឌ័រ។

ក្នុងករណីដែលអង្គការអន្តរជាតិ រាប់បញ្ចូលអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងម្ចាស់ជំនួយទ្វេភាគី ផ្តល់កិច្ចគាំទ្រ និងមូលនិធិដោយផ្ទាល់ជូនដល់អង្គការសង្គមស៊ីវិល ដែលចូលរួមនៅក្នុងការបង្កើតគោលនយោបាយដីធ្លីប្រកបដោយសមធម៌ ប្រព័ន្ធផ្សព្វផ្សាយ និងភាគីពាក់ព័ន្ធដទៃទៀត មានការទទួលខុសត្រូវធានាឱ្យមានគណនេយ្យភាព តាមរយៈការជូនដំណឹងដល់ប្រជាពលរដ្ឋអំពីការចូលរួមរបស់ភាគីពាក់ព័ន្ធកម្រិតអន្តរជាតិទាំងនេះ នៅក្នុងដំណើរការបង្កើតគោលនយោបាយដីធ្លីរបស់ប្រទេសពួកគេ។

ការបង្កើតគោលនយោបាយស្តីពីដីធ្លីនៅថ្នាក់មូល ដ្ឋាន

ភាគខុសប្លែកគ្នានៅក្នុងប្រទេសតាមខេត្ត ស្រុក និងសូម្បីតែសហគមន៍ អាចជះឥទ្ធិពលទៅលើប្រសិទ្ធភាពនៃការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងដំណើរការ សកម្មភាព និង ព្រឹត្តិការណ៍បង្កើតគោលនយោបាយដីធ្លី។ វិមជ្ឈការអនុញ្ញាតឱ្យភាពខុសប្លែកគ្នាក្នុងមូលដ្ឋានទាំងនេះ អាចត្រូវបានគេយកមកធ្វើការពិចារណា និងសម្របសម្រួលឱ្យមានការអភិវឌ្ឍន៍សមត្ថភាពនៅឯអភិបាលកិច្ចថ្នាក់ក្រោម សម្រាប់ការបង្កើតគោលនយោបាយប្រកបដោយសមធម៌យេនឌ័រ ទៅលើទិដ្ឋភាពជាច្រើននៃការងាររដ្ឋបាលដីធ្លី និងការគ្រប់គ្រងប្រចាំថ្ងៃ។ ក្រុមគ្រួសត្រាយផ្លូវ ដូចមានរៀបរាប់នៅក្នុងជំហានទី៣ នៃផ្នែកដែលនិយាយអំពីជំហានជាក់ស្តែង មានសារៈសំខាន់

ខ្លាំងណាស់ក្នុងការជួយបង្កើត និងអភិវឌ្ឍសមត្ថភាពនៅថ្នាក់ក្រោមជាតិ ជាពិសេសតាមរយៈការផ្តោតយកចិត្តទុកដាក់ទៅលើបញ្ហាបរិស្ថាន និងការចូលរួមរបស់ស្ត្រី។

បញ្ហាដែលត្រូវចងចាំនៅពេលរៀបចំផែនការអភិវឌ្ឍសមត្ថភាពនៅថ្នាក់ក្រោមជាតិ រួមមានការអប់រំ និងអក្ខរកម្មដែលមានកម្រិតទាប ដែលរមែងកើតមាននៅតំបន់ជនបទ ព្រមទាំងការដែលត្រូវប្រើប្រាស់ភាសាក្នុងមូលដ្ឋាន និងការពន្យល់បែបសាមញ្ញ។ ការបង្កើតគោលនយោបាយដីធ្លីប្រកបដោយសមធម៌យេនឌ័រ នៅកម្រិតមូលដ្ឋាន មានទំនាក់ទំនងជិតស្និទ្ធទៅនឹងបញ្ហាការប្រាស្រ័យទាក់ទង និងការលើកកម្ពស់ការយល់ដឹង ដូចមានលើកឡើងនៅក្នុង *ម៉ូឌុល៥*។

ការសង្ខេបអំពីសារសំខាន់ៗ

ស្តីពីការបង្កើតគោលនយោបាយ

ការចូលរួមប្រកបដោយសមធម៌ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងស្ត្រី និងបុរស មានភាពចាំបាច់ខ្លាំងណាស់។
ដំណើរការបង្កើតគោលនយោបាយដីធ្លីមានភាពខុសគ្នា ប៉ុន្តែ វាមានឥទ្ធិពលខ្លាំងក្លាទៅលើមាតិកានៃគោលនយោបាយដែលជាលទ្ធផលនៃដំណើរការនេះ។
ការយល់ដឹងអំពីបរិបទក្នុងស្រុកមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ការចូលរួមប្រកបដោយប្រសិទ្ធភាព។
គេត្រូវការឱ្យមានការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលអំពីសមធម៌យេនឌ័រ និងបញ្ហាដីធ្លីសម្រាប់ស្ត្រី និងបុរស នៅគ្រប់កម្រិតទាំងអស់។
រដ្ឋាភិបាល គឺជាម្ចាស់នៃដំណើរការបង្កើតគោលនយោបាយដីធ្លី ប៉ុន្តែ គ្រប់ភាគីពាក់ព័ន្ធទាំងអស់គួរផ្តល់កិច្ចសហប្រតិបត្តិការ និងចូលរួមពីដំបូង។ កិច្ចសន្ទនាពហុភាគីអ្នកពាក់ព័ន្ធជួយកសាងកិច្ចគាំទ្រសម្រាប់លទ្ធផលគោលនយោបាយដែលទទួលបាន។
ការបង្កើតគោលនយោបាយដីធ្លី គឺជាដំណើរការមួយដ៏វែងឆ្ងាយ និងមានការលំបាក ហើយគេអាចរៀនសូត្រអំពីមេរៀនមួយចំនួននៅក្នុងដំណើរការនេះ។
ជំហានសំខាន់ៗនៅក្នុងដំណើរការបង្កើតគោលនយោបាយដីធ្លីប្រកបដោយសមធម៌យេនឌ័រ រួមមានការកសាងអាណត្តិការងាររៀផ្ទៃក្នុងមួយ ការអភិវឌ្ឍន៍សម្ព័ន្ធភាពពហុភាគីអ្នកពាក់ព័ន្ធ ការបង្កើតក្រុមអ្នកត្រួសត្រាយផ្លូវមួយក្រុម និង ការស្វែងរកបុគ្គលផ្តើមនៅកម្រិតថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។
ការបន្តបញ្ជ្រាបអំពីបញ្ហាយេនឌ័រជូនដល់មន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធនៅក្នុងការបង្កើតគោលនយោបាយដីធ្លី មានសារៈសំខាន់ខ្លាំងណាស់។
តួនាទីរបស់សង្គមស៊ីវិលនៅក្នុងការតស៊ូមតិឱ្យមានការចូលរួម និងការត្រួតពិនិត្យទៅលើការបង្កើតគោលនយោបាយដីធ្លីប្រកបដោយសមធម៌យេនឌ័រ។
វិស័យឯកជនគួរត្រូវបានបញ្ចូលក្នុងលក្ខណៈកាន់តែមានភាពបើកចំហ និងកាន់តែមានតម្លាភាពនៅក្នុងការបង្កើតគោលនយោបាយដីធ្លី ព្រមទាំងត្រូវមានគណនេយ្យភាពចំពោះបញ្ហាសមធម៌យេនឌ័រ ដោយចាត់ទុកថាជាផ្នែកមួយនៃការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន។
អង្គការអន្តរជាតិមានការទទួលខុសត្រូវលើកកម្ពស់សមធម៌យេនឌ័រ នៅពេលគាំទ្រ និងចូលរួមនៅក្នុងកិច្ចខិតខំបង្កើតគោលនយោបាយដីធ្លី។
ការកសាងដំណើរការបង្កើតគោលនយោបាយដីធ្លីមួយប្រកបដោយសមធម៌យេនឌ័រ គួរតែជាកិច្ចខិតខំ

មួយដែលមានការចូលរួម យកចិត្តទុកដាក់ និងមានការរួមកម្លាំងគ្នា ដោយមានការចូលរួមពីភាគីពាក់ព័ន្ធគ្រប់កម្រិតទាំងអស់ ហើយត្រូវទទួលបានការគាំទ្រធនធានឱ្យបានគ្រប់គ្រាន់។

សូចនាករជាអនុសាសន៍សម្រាប់ត្រួតពិនិត្យលើការបង្កើតគោលនយោបាយ

- ចំនួនភាគរយនៃសមាជិកជាស្ត្រី និងបុរស នៃស្ថាប័ន និងរចនាសម្ព័ន្ធបង្កើតគោលនយោបាយដីធ្លីជាផ្លូវការ។
- ចំនួនភាគរយនៃកិច្ចប្រជុំ និងវេទិកាបង្កើតគោលនយោបាយដីធ្លីជាផ្លូវការ ដែលរួមមានការចូលរួមពីក្រុមសហគមន៍មូលដ្ឋានដែលតំណាងឱ្យទាំងស្ត្រី និងបុរស។
- ចំនួនភាគរយនៃមន្ត្រីរដ្ឋាភិបាលដែលចូលរួមដោយផ្ទាល់ នៅក្នុងដំណើរការបង្កើតគោលនយោបាយដីធ្លីដែលបានទទួលការបណ្តុះបណ្តាល និងបញ្ជ្រាប់អំពីបញ្ហាយេនឌ័រ។
- ចំនួនភាគរយនៃស្ត្រី និងបុរស ក្នុងចំណោមមន្ត្រីរដ្ឋាភិបាលដែលបានចូលរួមនៅក្នុងរចនាសម្ព័ន្ធ និងស្ថាប័នបង្កើតគោលនយោបាយដីធ្លី។
- ចំនួនភាគរយនៃស្ត្រី និងបុរស ក្នុងចំណោមអ្នកតំណាងសង្គមស៊ីវិលដែលបានចូលរួមនៅក្នុងរចនាសម្ព័ន្ធ និងស្ថាប័នបង្កើតគោលនយោបាយដីធ្លី។
- ចំនួនភាគរយនៃស្ត្រី និង បុរស ក្នុងចំណោមអ្នកតំណាងវិស័យឯកជនដែលបានចូលរួមនៅក្នុងរចនាសម្ព័ន្ធ និងស្ថាប័នបង្កើតគោលនយោបាយដីធ្លី។
- ចំនួនភាគរយនៃអង្គការអន្តរជាតិ ផ្តល់មូលនិធិសម្រាប់ដំណើរការបង្កើតគោលនយោបាយដីធ្លី ដែលបានវិភាជន៍ថវិកាដើម្បីលើកកម្ពស់ការចូលរួមនៅក្នុងការបង្កើតគោលនយោបាយប្រកបដោយសមធម៌យេនឌ័រ។

កំណត់សម្គាល់

1 Dalal Alnaggar, Kate Dalrymple, Patricia Costas, Catherine Gatundu, Seema Gaikwad, Paolo Groppo, Rachael Knight, Annalisa Mauro, Rebecca Sittie, Elizabeth Stair and Sabine Pallas បានផ្តល់ធាតុចូលសំខាន់ៗចំពោះម៉ូឌុលនេះ ក្នុងអំឡុងពេលសិក្ខាសាលាបច្ចេកទេស ដែលបានប្រព្រឹត្តិធ្វើឡើងក្នុងខែឧសភា ឆ្នាំ២០១១ នៅឯការិយាល័យកណ្តាលរបស់អង្គការ FAO រួមទាំងតាមរយៈការពិភាក្សារបស់ក្រុមការងារបង្កើតគោលនយោបាយ។

2 ផ្នែកនេះ ដកស្រង់ចេញពីការពិភាក្សារបស់ក្រុមការងារបង្កើតគោលនយោបាយនៅឯសិក្ខាសាលា ដែលប្រព្រឹត្តិធ្វើឡើងក្នុងខែឧសភា ឆ្នាំ២០១១។

3 www.landcoalition.org/global-initiatives/womens-land-rights/swal
4 www.unwomen.org/wp-content/uploads/2012/05/swap.pdf

ឯកសារយោង

Bernstein, A. 2005. *Land reform in South Africa – a 21st century perspective. Research Report No. 14.* Johannesburg, Centre for Development and Enterprise.

FAO. 2008b. *Good governance and natural resources tenure in South East Asia region,* O. Nabangch ang and E. Srisawalak. *Land Tenure Working Pa- per No. 4*. Rome.

FAO. 2012b. *Voluntary Guidelines on the Responsi- ble Governance of Tenure of Land, Fisheries and Forests in the Context of National Food Security*. Rome. http://www.fao.org/docrep/016/i2801e/ i2801e.pdf

Ghana Land Administration Project. no date. *An over- view of LAP's gender initiative*.www.ghanalap.gov.gh/index1.php?linkid=154&sublinkid=161

India Ministry of Rural Development. 2009. *Commit- tee on State Agrarian Relations and Unfinished Task of Land Reforms Vol. 1 – Draft Report*. New Delhi, Government of India.

IPC. 2010. *Civil Society Consultation on FAO's Vol- untary Guidelines on Responsible Land and Natural Resources Tenure, Kuala Lumpur, Malaysia, 24–26 March 2010, Final Report*. Rome, International Planning Committee for Food Sovereignty.

Land Watch Asia. 2010. *Nepal: renewed push for land reform as a new chapter in history unfolds. Cam- paign Update 2010–2011*. www.angoc.org/ portal/wp-content/uploads/2012/06/05/land- watch-asia-campaign-updates/nepal_final.pdf

McAuslan, P. 2010. Personal reflections on drafting laws to improve women's access to land: Is there a magic wand? Journal of Eastern African *Stud- ies*, 4 (1): 114–130.

Rabley, P. 2010. Alleviating poverty in the developing world – leveraging property rights with geospa- tial technology. *The American Surveyor, January 2010*. www.amerisurv.com/pdf/theamericansur-veyor_rabley-alleviatingpoverty_January2010. pdf

ULA. 2010. *The Uganda Land Alliance quarterly newslet- ter, Vol. 4*. Kampala.

WLLA. 2010a. *The impact of national land policy and land reform in Uganda*. Accra, Women's Land Link Africa.

WLLA. 2010b. *The impact of national land policy and land reform on women in Zambia*. Accra.

WOLREC. 2011. *Women's access to land and household bargaining power: a comparative action research project in patrilineal and matrilineal societies in Malawi. Research Report No. 9*. Rome, ILC, Wom- en's Legal Resource Centre. www.landcoalition.org/sites/default/files/publication/959/wlr_9_malawi.pdf

ម៉ូឌុល

២

បញ្ញាច្បាប់

បញ្ជីរាយនាមប្រអប់ និង តារាងរូបភាព

ប្រអប់

35 ប្រអប់ ២.១ ៖ បញ្ញាច្បាប់ និងគោលការណ៍ណែនាំ

38 ប្រអប់ ២.២ ៖ ការរៀបចំកាន់កាប់ដីធ្លីពហុលក្ខណៈ និងទិដ្ឋភាពផ្នែកច្បាប់ផ្សេងៗគ្នា

40 ប្រអប់ ២.៣ ៖ យេនឌ័រ និងសិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច

41 ប្រអប់ ២.៤ ៖ សន្តិសុខលើការកាន់កាប់ដីធ្លីរបស់ស្ត្រី និងមេរោគអេដស៍/ជំងឺអេដស៍

42 ប្រអប់ ២.៥ ការអនុវត្តន៍ល្អសម្រាប់ដោះស្រាយបញ្ហាស្នងមរតក

47 ប្រអប់ ២.៦ ៖ ការរៀបចំសេចក្តីព្រាងច្បាប់ ដោយមានការពិគ្រោះយោបល់ មានការចូលរួម និងប្រកបដោយសមធម៌យេនឌ័រ

51 ប្រអប់ ២.៧ ៖ មេរៀនបទពិសោធន៍ដែលទទួលបានពីការរៀបចំសេចក្តី ព្រាងច្បាប់ក្នុងមូលដ្ឋាន

57 ប្រអប់ ២.៨ ៖ ការដោះស្រាយវិវាទដីធ្លីប្រកបដោយសមធម៌យេនឌ័រ

58 ប្រអប់ ២.៩ ៖ ការធ្វើការងារជាមួយស្ថាប័នបែបប្រពៃណីក្នុងការដោះស្រាយវិវាទដីធ្លី

60 ប្រអប់ ២.១០ ៖ កិច្ចគាំទ្រផ្នែកច្បាប់សម្រាប់ម្ចាស់កម្មសិទ្ធិដីធ្លី បែបប្រពៃណី

62 ប្រអប់ ២.១១ ៖ ជំនួយផ្នែកច្បាប់សម្រាប់ប្រជាជនជនបទ

62 ប្រអប់ ២.១២ ៖ ការអនុវត្តន៍ល្អនៅក្នុងកិច្ចគាំទ្រផ្នែកច្បាប់

64 ប្រអប់ ២.១៣ ៖ ការបណ្តុះបណ្តាលជំនួយការផ្នែកច្បាប់សហគមន៍សម្រាប់ការងារលើបញ្ហាយេនឌ័រ

66 ប្រអប់ ២.១៤ ៖ មេរៀនបទពិសោធន៍អំពីកិច្ចគាំទ្រផ្នែកច្បាប់

67 ប្រអប់ ២.១៥ ៖ ក្រុមឃ្លាំមើលសហគមន៍សម្រាប់គាំទ្រដល់សិទ្ធិស្ត្រីក្នុងការទទួលបានដីធ្លី

បញ្ជីផ្ទៀងផ្ទាត់

43 បញ្ជីផ្ទៀងផ្ទាត់ ២.១ ៖ ការគាំទ្រចំពោះការស្នងមរតកប្រកបដោយសមធម៌យេនឌ័រ

45 បញ្ជីផ្ទៀងផ្ទាត់ ២.២ ៖ ការគាំទ្រចំពោះសមធម៌យេនឌ័រនៅក្នុងទិដ្ឋផ្នែកច្បាប់ផ្សេងៗគ្នា

52 បញ្ជីផ្ទៀងផ្ទាត់ ២.៣ ៖ ការគាំទ្រចំពោះការរៀបចំសេចក្តីព្រាងច្បាប់ប្រកបដោយសមធម៌យេនឌ័រ

56 បញ្ជីផ្ទៀងផ្ទាត់ ២.៤ ៖ ការបង្កើនសមធម៌យេនឌ័រក្នុងការទទួលបានយុត្តិធម៌លើបញ្ហាដីធ្លី

69 បញ្ជីផ្ទៀងផ្ទាត់ ២.៥ ៖ ការជានាឱ្យមានកិច្ចគាំទ្រផ្នែកច្បាប់ប្រកបដោយសមធម៌យេនឌ័រ

71 សូចនាករត្រួតពិនិត្យជាអនុសាសន៍សម្រាប់បញ្ហាផ្នែកច្បាប់

តារាង និង រូបភាព

46 តារាង ២.១ ៖ លិខិតុបករណ៍ច្បាប់

50 រូបភាព ២.១ ៖ ជំហាននៅក្នុងការរៀបចំសេចក្តីព្រាងច្បាប់ប្រកបដោយសមធម៌យេនឌ័រ

53 តារាង ២.២ ៖ ធាតុផ្សំក្នុងការអនុវត្តន៍សិទ្ធិដីធ្លី

ម៉ូឌុល២ ៖ បញ្ហាច្បាប់

មូលដ្ឋានក្នុងការសម្រេចឱ្យបាននូវអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ

សេចក្តីផ្តើម[៥]

ច្បាប់ផ្តល់នូវមូលដ្ឋានមួយចំនួន ដើម្បីសម្រេចឱ្យបាននូវអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ។ ច្បាប់ និងវិធានប្រកបដោយសមធម៌យេនឌ័រ ផ្តល់នូវបរិយាកាសអំណោយផលមួយ (Englert and Daley, 2008) ដែលស្ត្រី និងបុរស កាន់តែអាចមានលទ្ធភាពអនុវត្ត និងសម្រេចបាននូវសិទ្ធិរបស់ពួកគេ ក្នុងការទទួលបានដីធ្លីប្រកបដោយសមធម៌។

សារៈសំខាន់នៃបញ្ហាដីធ្លី មានទំនាក់ទំនងទៅនឹងគោលការណ៍ស្នូលចំនួនពីរ ក្នុងចំណោមគោលការណ៍ស្នូលទាំង១០ នៃការអនុវត្តន៍គោលការណ៍ណែនាំ ដែលគោលការណ៍ស្នូលទាំងពីរនោះ រួមមាន នីតិរដ្ឋ និង គណនេយ្យភាព (ប្រអប់ ២.១)។

ការបង្កើតច្បាប់

ប្រអប់ ២.១ ៖ **បញ្ហាច្បាប់ និង គោលការណ៍ណែនាំ**

៣.ខ.៧ នីតិរដ្ឋ ៖ ការអនុម័តអភិក្រមផ្អែកលើវិធាន តាមរយៈច្បាប់ដែលត្រូវបានផ្សព្វផ្សាយទូលំទូលាយ ជាភាសាសមស្រប អនុវត្តចំពោះបុគ្គលគ្រប់រូបស្មើៗគ្នា និងត្រូវបានវិនិច្ឆ័យដោយឯករាជ្យ ព្រមទាំងមានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់ពួកគេ អនុលោមតាមច្បាប់ជាតិ និង អន្តរជាតិ និង ដោយគោរពតាមការឃ្លេងដោយស្ម័គ្រចិត្ត ស្របតាមលិខិតតុបករណ៍តំបន់ និងអន្តរជាតិដែលអាចយកមកអនុវត្តបាន។

៣.ខ.៩ គណនេយ្យភាព ៖ ការធ្វើឱ្យបុគ្គល ទីភ្នាក់ងារសាធារណៈ និង តួអង្គមិនមែនរដ្ឋទទួល ខុសត្រូវលើសកម្មភាព និងសេចក្តីសម្រេចចិត្តរបស់ពួកគេ ស្របតាមគោលការណ៍នីតិរដ្ឋ។

មាតិកានៃច្បាប់ និងនីតិវិធីដែលទាក់ទ ងទៅនឹងយេនឌ័រ

៤.៤ ផ្អែកលើការពិនិត្យមើលសិទ្ធិកាន់កាប់ស្របតាមច្បាប់ជាតិ រដ្ឋគប្បីផ្តល់ការទទួលស្គាល់ស្របច្បាប់ចំពោះសិទ្ធិកាន់កាប់ស្របច្បាប់ដែលបច្ចុប្បន្នមិនត្រូវបានការពារដោយច្បាប់។ គោលនយោបាយ និងច្បាប់ទាំងឡាយដែលធានាសិទ្ធិកាន់កាប់ គប្បីមានលក្ខណៈមិនរើសអើង និង គិតគូរដល់យេនឌ័រ។ ស្របតាមគោលការណ៍នៃការពិគ្រោះយោបល់ និង ការចូលរួមនៃគោលការណ៍ណែនាំទាំងនេះ តាមរយៈវិធានដែលបានផ្សព្វផ្សាយទូលំទូលាយ រដ្ឋគប្បីកំណត់លក្ខណៈវិនិច្ឆ័យនៃសិទ្ធិទាំងឡាយដែលត្រូវបានចាត់ទុកថាស្របច្បាប់។ គ្រប់ទម្រង់ទាំងអស់នៃការកាន់កាប់ គប្បីផ្តល់ជូនមនុស្សគ្រប់រូបនូវសុវត្ថិភាពកាន់កាប់

ក្នុងកម្រិតណាមួយ ដែលជានាកិច្ចការពារតាមផ្លូវច្បាប់ប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ដែលមិនមានសង្គតភាពទៅនឹងកាតព្វកិច្ចជាធរមានរបស់រដ្ឋក្រោមច្បាប់ជាតិ និងអន្តរជាតិ និង ប្រឆាំងនឹងការបៀតបៀន និងការគម្រាមកំហែងផ្សេងទៀត។

៤.៦ រដ្ឋគប្បីលុបបំបាត់ និង ហាមឃាត់រាល់ទម្រង់នៃការរើសអើងទាក់ទងទៅនឹងសិទ្ធិកាន់កាប់ រួមទាំងការរើសអើងដែលបណ្តាលមកពីការផ្លាស់ប្តូរនៃស្ថានភាពអាពាហ៍ពិពាហ៍ កង្វះសមត្ថភាពផ្នែកច្បាប់ និង កង្វះលទ្ធភាពទទួលបានធនធានសេដ្ឋកិច្ច។ ជាពិសេស រដ្ឋគប្បីធានាសិទ្ធិកាន់កាប់ស្មើភាពគ្នាសម្រាប់ស្ត្រី និងបុរស រួមមានសិទ្ធិទទួលមរតក និង សិទ្ធិផ្ទេរសិទ្ធិកាន់កាប់ទាំងនេះ។

៥.៣ រដ្ឋគប្បី ធានាឱ្យបានថា ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និងក្របខ័ណ្ឌស្ថាប័នទាំងឡាយសម្រាប់អភិបាលកិច្ចលើការកាន់កាប់ ទទួលស្គាល់ និងគោរព ស្របតាមច្បាប់ជាតិ ចំពោះសិទ្ធិកាន់កាប់ស្របច្បាប់ រួមមានសិទ្ធិកាន់កាប់ស្របច្បាប់ជាប្រពៃណីដែលបច្ចុប្បន្នមិនត្រូវបានការពារដោយច្បាប់ និង សម្របសម្រួល លើកកម្ពស់ និង ការពារការអនុវត្តន៍សិទ្ធិកាន់កាប់។ ..... រដ្ឋគប្បីផ្តល់ក្របខ័ណ្ឌនានាដែលមានលក្ខណៈមិនរើសអើង និង លើកកម្ពស់សមធម៌សង្គម និង សមភាពយេនឌ័រ។

ប្រភព ៖ FAO, 2012b.

៩.២ ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី ដែលអនុវត្តស្វ័យអភិបាលកិច្ចលើដី ជលផល និង ព្រៃឈើ គប្បីជំរុញ និងផ្តល់សិទ្ធិប្រកបដោយសមធម៌ មានស្មេភាព និងនិរន្តរភាព ចំពោះធនធានទាំងនោះ ដោយយកចិត្តទុកដាក់ជាពិសេស លើការផ្តល់លទ្ធភាពប្រើប្រាស់ប្រកបដោយសមធម៌ជូនស្ត្រី។ ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់សមាជិកបុរស ស្ត្រី និង យុវជនទាំងអស់ ក្នុងសេចក្តីសម្រេចចិត្តអំពីប្រព័ន្ធកាន់កាប់របស់ពួកគេ គប្បីត្រូវបានជំរុញតាមរយៈស្ថាប័នមូលដ្ឋាន ឬ ស្ថាប័នប្រពៃណីរបស់ពួកគេ រួមទាំងករណីនៃប្រព័ន្ធកាន់កាប់ជាសមូហភាព។ ក្នុងករណីចាំបាច់ សហគមន៍គប្បីទទួលបានជំនួយដើម្បីបង្កើនសមត្ថភាពរបស់សមាជិកខ្លួន សំដៅចូលរួមឱ្យបានពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្ត និង អភិបាលកិច្ចលើប្រព័ន្ធកាន់កាប់របស់ពួកគេ។

១០.១ ក្នុងករណីដែលមានការកាន់កាប់ក្រៅប្រព័ន្ធលើដី ជលផល និង ព្រៃឈើ រដ្ឋគប្បីទទួលស្គាល់ការកាន់កាប់ក្រៅព័ន្ធនោះ តាមរបៀបមួយដែលគោរពសិទ្ធិក្នុងប្រព័ន្ធស្របតាមច្បាប់ជាតិ និង តាមរបៀបនានាដែលទទួលស្គាល់ការពិតនៃស្ថានភាព និង ជំរុញសុខុមាលភាពផ្នែកសង្គម សេដ្ឋកិច្ច និង បរិស្ថាន។ រដ្ឋគប្បីជំរុញគោលនយោបាយ និងច្បាប់ ដើម្បីផ្តល់ការទទួលស្គាល់ចំពោះការកាន់កាប់ក្រៅប្រព័ន្ធនេះ។ កិច្ចដំណើរការបង្កើតគោលនយោបាយ និងច្បាប់ទាំងនេះ គប្បីមានលក្ខណៈចូលរួម គិតគូរដល់យេនឌ័រ និង ខិតខំចាត់ឱ្យមានការជួយគាំទ្រផ្នែក

បច្ចេកទេស និងច្បាប់ ជូនដល់សហគមន៍ និងបុគ្គលរងផលប៉ះពាល់ទាំងឡាយ។

ការដោះស្រាយវិវាទតាមរយៈទស្សនៈវិស័យយេនឌ័រ

២១.១ សេវាដោះស្រាយវិវាទគួរផ្តល់ជូនចំពោះស្ត្រី និងបុរសគ្រប់រូប ដោយមិនប្រកាន់ទីតាំងភូមិសាស្ត្រ ភាសា និងនីតិវិធី។

២៥.៣ ក្នុងករណីសមស្រប រដ្ឋអាចពិចារណាប្រើប្រាស់យន្តការបែបប្រពៃណី និងយន្តការក្នុងមូលដ្ឋានដទៃទៀត ដែលផ្តល់វិធីដោះស្រាយវិវាទភ្លាមៗចំពោះសិទ្ធិកាន់កាប់ដី ជលផល និងព្រៃឈើ ប្រកបដោយភាពយុត្តិធម៌ គួរឱ្យជឿជាក់បាន ផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ អាចមានលទ្ធភាពប្រើប្រាស់បាន និងមិនមានការរើសអើង។

ទិដ្ឋភាពផ្នែកច្បាប់ផ្សេងៗគ្នាពីទស្សនៈវិស័យយេនឌ័រ

ទិដ្ឋផ្នែកច្បាប់ផ្សេងៗគ្នា គឺជារឿងធម្មតានៅក្នុងពិភពលោក ដែលចំណុចនេះ សំដៅចំពោះស្ថានភាពមួយដែលមានរបបច្បាប់ជាច្រើនប្រភេទផ្សេងៗគ្នា ដែលអនុវត្តចំពោះដែនសមត្ថកិច្ចតែមួយ ឧទាហរណ៍ដូចជា នៅក្នុងដែនសមត្ថកិច្ចមួយដែលមានច្បាប់លក្ខណៈប្រពៃណី ច្បាប់គតិយុត្តិ និងច្បាប់សាសនា ដែលទាក់ទងទៅនឹងបញ្ហាដីធ្លី ឬ ការរៀបចំខុសៗគ្នាចំពោះការកាន់កាប់ដីធ្លីសម្រាប់ដីសាធារណៈ និងដីឯកជន។ ចំណុចនេះធ្វើឱ្យមានក្របខ័ណ្ឌច្បាប់ស្មុគស្មាញមួយចំពោះសិទ្ធិដែលមានលក្ខណៈត្រួតស៊ីគ្នា សិទ្ធិអំណាចប្រជែងគ្នា និងជាញឹកញាប់នាំឱ្យមានវិធានដែលមានលក្ខណៈផ្ទុយគ្នា ជាមួយនឹងសញ្ញាណដែលមានលក្ខណៈអវិជ្ជមានជាសក្តានុពលសម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ នៅពេលដែលច្បាប់ និងបទដ្ឋាន ព្រមទាំងការអនុវត្តន៍ប្រពៃណីមានភាពផ្ទុយគ្នា (FAO, 2011a: 12)។

ការយល់ដឹងអំពីបរិបទ និង ភាពស្មុគស្មាញនៃក្របខ័ណ្ឌច្បាប់នៅក្នុងប្រទេសសាមី មានសារៈសំខាន់ខ្លាំងណាស់។ គេមិនត្រូវពិចារណាទៅលើច្បាប់ភូមិបាលតែម្យ៉ាងប៉ុណ្ណោះទេ ប៉ុន្តែ គេក៏ត្រូវពិចារណាផងដែរទៅលើច្បាប់ស្តីពីគ្រួសារ និងការស្នងមរតក ច្បាប់អាពាហ៍ពិពាហ៍ ក្រមរដ្ឋប្បវេណី និងក្រមជនបទ ព្រមទាំងច្បាប់ និង វិធានបែបប្រពៃណី និងសាសនា និង របៀបលក្ខណៈដែលច្បាប់ និងវិធានទាំងនោះ មានអន្តរកម្មរវាងគ្នាទៅវិញទៅមក និង/ឬ ត្រួតស៊ីគ្នា។ ឧទាហរណ៍ ច្បាប់ស្តីពីគ្រួសារ អាចមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ទៅលើសិទ្ធិបុគ្គលចំពោះបញ្ហាដីធ្លី អាស្រ័យដោយនៅក្នុងប្រទេសមួយចំនួន សិទ្ធិក្នុងការទទួលបានទ្រព្យសម្បត្តិក្រោមចំណងអាពាហ៍ពិពាហ៍អាចត្រូវបានកំណត់ ដោយយោងទៅតាមល័ក្ខខ័ណ្ឌ ថាតើពិធីអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងតាមបែបស៊ីវិល ប្រពៃណី ឬ សាសនា។

ប្រអប់ ២.២ បង្ហាញអំពីវិធីមួយចំនួនដែលទិដ្ឋភាពផ្នែកច្បាប់ផ្សេងៗគ្នាមានភាពពាក់ព័ន្ធទៅនឹងអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ នៅក្នុងប្រទេសផ្សេងៗគ្នា។

ប្រអប់ ២.២ ៖

ការរៀបចំកាន់កាប់ដីធ្លីពហុលក្ខណៈ និងទិដ្ឋភាពផ្នែកច្បាប់ផ្សេងៗគ្នា

ប្រភព ៖ Nakayi, 2010; WLLA, 2010a; Daley, 2011: 41–42; Undeland, 2012; Marianna Bicchieri, Patricia Costas, Seema Gaikwad and Rachael Knight personal communication.

នៅក្នុង*ប្រទេសឥណ្ឌា* សន្តតិកម្មតាមសាសនាហ៊ិនឌូ (ច្បាប់វិសោធនកម្ម) ឆ្នាំ ២០០៥ ចែងអំពីការស្នងមរតកស្មើភាពគ្នា ដោយមិនប្រកាន់អំពីយេនឌ័រ ប៉ុន្តែច្បាប់បុគ្គលរបស់សាសនាអ៊ីស្លាម មិនអនុញ្ញាតបែបនេះឡើយ ដូច្នេះ ប្រជាពលរដ្ឋដែលកាន់សាសនាខុសគ្នា ទទួលបានការប្រព្រឹត្តិផ្សេងៗគ្នា។

នៅក្នុង*ប្រទេសបូលីវៀ* រដ្ឋធម្មនុញ្ញឆ្នាំ២០០៦ កំណត់ឱ្យក្រសួងយុត្តិធម៌ជនបទប្រពៃណី និងជនជាតិដើមភាគតិច ធ្វើការភ្ជាប់ទំនាក់ទំនងប្រព័ន្ធយុត្តិធម៌គតិយុត្តិ និងប្រព័ន្ធយុត្តិធម៌បែបប្រពៃណី។ យ៉ាងណាមិញ បើទោះបីជាសិទ្ធិដីធ្លីរបស់ស្ត្រី និងជនជាតិដើមភាគតិចត្រូវបានការពារក៏ដោយ ប៉ុន្តែ ពុំមានកិច្ចការពារជាក់លាក់តាមផ្លូវច្បាប់ សម្រាប់សិទ្ធិដីធ្លីរបស់ស្ត្រីជនជាតិដើមភាគតិចឡើយ និង មានអន្តរទំនាក់ទំនងតិចតួច រវាងកិច្ចការពារនៃកម្រងសិទ្ធិទាំងពីរនេះ។

នៅ*ប្រទេសយូហ្គាន់ដា* ការបែងចែករវាងច្បាប់គតិយុត្តិ និងច្បាប់ប្រពៃណី ត្រូវបានដោះស្រាយនៅក្នុងរដ្ឋធម្មនុញ្ញ ដែលចែងអំពីសមភាពរវាងស្ត្រី និងបុរស នៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ប្រកាសថាសេចក្តីសម្រេចដែលបដិសេធចំពោះសិទ្ធិស្ត្រីក្នុងការទទួលបានដីធ្លីត្រូវចាត់ទុកជាមោឃៈ និង លើកកម្ពស់សមភាពរវាងសហព័ទ្ធនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃអាពាហ៍ពិពាហ៍។ យ៉ាងណាមិញ បើទោះបីជាច្បាប់ភូមិបាល តម្រូវឱ្យមានការយល់ព្រមពីសហព័ទ្ធទាំងសង្ខាងសម្រាប់ប្រតិបត្តិការទាំងឡាយណាដែលបង្កឱ្យមានផលប៉ះពាល់ទៅលើទ្រព្យសម្បត្តិរួម ក្រោយពេលរៀបអាពាហ៍ពិពាហ៍ក៏ដោយ អាពាហ៍ពិពាហ៍ត្រូវចុះបញ្ជីជាផ្លូវការ ដើម្បីឱ្យបទប្បញ្ញត្តិនេះ អាចយកមកអនុវត្តបាន ដូច្នេះ បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ក្រោមច្បាប់ប្រពៃណី ពុំបានទទួលកិច្ចការពារឡើយ។

នៅក្នុង*ប្រទេសម៉ូហ្សំប៊ិក* ច្បាប់ភូមិបាលបែបគតិយុត្តិ គឺជាច្បាប់ដែលមានសមធម៌យេនឌ័រ និងមានបទប្បញ្ញត្តិច្បាស់លាស់អំពីសិទ្ធិស្មើភាពគ្នា រវាងស្ត្រី និង បុរស។ ជាទូទៅ សេចក្តីសម្រេចចិត្តអំពីដីធ្លីមានមូលដ្ឋានផ្អែកលើច្បាប់ប្រពៃណី ដរាបណាវាមានសង្គតភាពទៅនឹងរដ្ឋធម្មនុញ្ញ និង ច្បាប់ភូមិបាល រាប់បញ្ចូលទាំងបទប្បញ្ញត្តិស្តីពីសមធម៌យេនឌ័រផងដែរ។ បើទោះជាដូច្នេះក្តី ស្ថិតក្រោមច្បាប់ប្រពៃណី ស្ត្រីទទួលបានសិទ្ធិដីធ្លី តាមរយៈស្វាមី ឬ ឪពុករបស់ពួកគេ ហើយរដ្ឋពុំបានបង្កើតយន្តការណាមួយសម្រាប់ត្រួតពិនិត្យទៅលើភាពអនុលោម ទៅនឹងរដ្ឋធម្មនុញ្ញ និង ច្បាប់ភូមិបាល ដើម្បីធានាថាសិទ្ធិស្របច្បាប់របស់ស្ត្រីត្រូវបានលើកកម្ពស់ឡើយ។ បន្ថែមពីនេះទៀត ច្បាប់ប្រពៃណីរមែងតែងត្រូវបានគេយកមកប្រើប្រាស់ខុសគោលដៅ ហើយស្ត្រីជនបទភាគច្រើន ពុំបានដឹងថាច្បាប់ភូមិបាលបែបគតិយុត្តិផ្តល់កិច្ចការពារចំពោះសិទ្ធិរបស់ពួកគេឡើយ។

នៅក្នុង*ប្រទេសគីហ្គីស្ថាន* និង *ប្រទេសតាជីគីស្ថាន* បើទោះបីជាច្បាប់ជាតិទទួលស្គាល់សិទ្ធិរបស់ស្ត្រីក្នុងការទទួលបានដីធ្លី លំនៅឋាន និងទ្រព្យសម្បត្តិក៏ដោយ ប៉ុន្តែច្បាប់ប្រពៃណី និង អភិក្រមបិតុនិយមបែបប្រពៃណី រមែងតែងមានអធិកភាពជានិច្ច។ ចាប់តាំងពីការដួលរលំនៃសហភាពសូវៀត គោលការណ៍អ៊ីស្លាម បានកើតឡើងសារជាថ្មី។ គោលការណ៍អ៊ីស្លាមកំណត់ចែងអំពីសិទ្ធិស្ត្រី ក្នុងការទទួលបានដីធ្លី និងទ្រព្យសម្បត្តិ ហើយនៅពេលដែលគោលការណ៍នេះត្រូវបានយកមកអនុវត្ត វាបានផ្តល់ឱ្យស្ត្រី នូវសន្តិសុខទៅលើសិទ្ធិកាន់កាប់ក្នុងកម្រិតមួយ។ បើទោះជាដូច្នេះក្តី គោលការណ៍ទាំងនេះ ពុំរមែងតែងអាចយកមកអនុវត្តបានទាំងស្រុងឡើយ ឧទាហរណ៍ដូចជា បុរសអាចជ្រើសរើសរៀបអាពាហ៍ពិពាហ៍តាមបែបសាសនាអ៊ីស្លាម ដោយពុំមានការចុះបញ្ជី និង មិនអនុវត្តតាមគោលការណ៍សាសនាអ៊ីស្លាមនៅក្នុងចំណងអាពាហ៍ពិពាហ៍ និងជាពិសេស នៅពេលលែងលះគ្នា។ ចំនួននៃការរៀបអាពាហ៍ពិពាហ៍នៅតំបន់ជនបទ ដោយគ្មានការចុះបញ្ជីជាផ្លូវការកាន់តែមានការកើនឡើង ដូច្នេះ អាពាហ៍ពិពាហ៍បែបនេះ ពុំស្ថិតក្រោមកិច្ចការពារនៃច្បាប់ជាផ្លូវការឡើយ ខណៈពេលដែលច្បាប់អ៊ីស្លាមពុំផ្តល់នូវកិច្ចការពារតាមផ្លូវច្បាប់ អាស្រ័យដោយពុំមានឧបករណ៍សម្រាប់អនុវត្ត។ ដូច្នេះ ស្ត្រីមិនអាចទាមទារទ្រព្យសម្បត្តិណាមួយឡើយ ក្នុងករណីលែងលះ ឬ នៅពេលដែលស្វាមីរបស់ពួកគេស្លាប់ ឬ បោះបង់ពួកគេចោល។

ទំនាក់ទំនងរវាងច្បាប់ស្តីពីដីធ្លី និងទ្រព្យសម្បត្តិ និងច្បាប់ស្តីពីគ្រួសារ ដែលមានទំនាក់ទំនងទៅនឹងអាពាហ៍-ពិពាហ៍ និងការស្នងមរតក មានភាពពាក់ព័ន្ធជាពិសេសទៅនឹងកំណែទម្រង់លើការកាន់កាប់។ នៅក្នុងប្រទេសជាច្រើន អាពាហ៍ពិពាហ៍ និងវិធាននៃការស្នងមរតកបែបប្រពៃណី នាំឱ្យបន្តមានវិសមភាពយេនឌ័រនៅក្នុងទំនាក់ទំនងដីធ្លីពីជំនាន់មួយទៅជំនាន់មួយទៀត (Guyer, 1987)។ រាល់កំណែទម្រង់លើការកាន់កាប់ទាំងឡាយណាដែលពុំបានពិចារណាទៅលើចំណុចនេះ នឹងមានផលប៉ះពាល់មានកម្រិត។

ដូច្នេះ អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ តម្រូវឱ្យច្បាប់ភូមិបាល និងច្បាប់ស្តីពីគ្រួសារ ត្រូវបានធ្វើកំណែទម្រង់រួមគ្នា (FAO, 2011a: 17; McAuslan, 2010: 125)។ ឧទាហរណ៍ ជោគជ័យនាពេលថ្មីៗមួយមកពីប្រទេសរ៉ាវ៉ាន់ដា ដែលកំណែទម្រង់លើការកាន់កាប់ដីធ្លីបានអនុវត្តតាមកំណែទម្រង់ចំពោះវិធានស្តីពីការស្នងមរតក និងទ្រព្យសម្បត្តិរួមក្រោយពេលរៀបអាពាហ៍ពិពាហ៍ ព្រមទាំងទទួលបាននូវលទ្ធផលការងារយេនឌ័រមួយចំនួនប្រកបដោយភាពជោគជ័យ ដោយមានស្ត្រីចូលរួមនៅក្នុងគណៈកម្មាធិការដីធ្លីក្នុងមូលដ្ឋាន និង ធ្វើការចុះបញ្ជីដីធ្លីរបស់ពួកគេ (Daley, Dore-Weeks and Umuhoza, 2010)។ ការអនុវត្តន៍កូតារបស់រដ្ឋាភិបាលប្រទេសរ៉ាវ៉ាន់ដា នៅក្នុងប្រព័ន្ធនយោបាយ ក៏បានជួយជានាឱ្យមានការចូលរួមពីស្ត្រីផងដែរ។

ច្បាប់ប្រពៃណី និងការអនុវត្តន៍កាន់កាប់ដីធ្លី មានការវិវឌ្ឍស្របតាមបរិយាកាសច្បាប់ដែលកំពុងមានការប្រែប្រួល ល័ក្ខខ័ណ្ឌសង្គម និងសេដ្ឋកិច្ចដែលកំពុងមានការប្រែប្រួល និងកត្តាខាងក្រោមមួយចំនួនដូចជា វិបត្តិអាកាសធាតុ វិបត្តិប្រជាសាស្ត្រ និង វិបត្តិហិរញ្ញវត្ថុ។ ប្រអប់ ២.៣ បង្ហាញអំពីការវិវឌ្ឍនេះ ដែលប្រជាពលរដ្ឋជនជាតិដើមភាគតិចនៃប្រទេសអូស្ត្រាលីភាគលិចបានជួបប្រទះ។

ប្រអប់ ២.៣ ៖

យេនឌ័រ និងសិទ្ធិកាន់កាប់ដីធ្លី របស់ជនជាតិដើមភាគតិច

ជនជាតិដើមរបស់*ប្រទេសអូស្ត្រាលី* ដែលរួមមាន៣,១% នៃចំនួនប្រជាជនអូស្ត្រាលីភាគខាងលិចដែលមានចំនួន ២,៣លាននាក់ រមែងតែងមានការផ្សារភ្ជាប់ផ្នែកផ្លូវចិត្តយ៉ាងខ្លាំងក្លាចំពោះទឹកដី និងមានចំណេះដឹងយេនឌ័ររឹងមាំអំពីដីធ្លី។ ជាលក្ខណៈប្រពៃណី ការទទួលខុសត្រូវចំពោះបញ្ហាដីធ្លី គឺជាការទទួលខុសត្រូវរបស់បុរស ហើយចំណេះដឹងដែលទាក់ទងទៅនឹងដីធ្លី ភាគច្រើនស្ថិតនៅលើបុរស ជាពិសេសគឺបុរសដែលមានភាពចាស់ទុំ។ ចំណេះដឹងរបស់ស្ត្រីស្ថិតនៅក្នុងព្រំដែននៃការងាររបស់ស្ត្រីប៉ុណ្ណោះ ដែលភាគច្រើនទាក់ទងទៅនឹងការប្រមូលស្បៀងអាហារ ការផ្តល់កំណើត។ល។

ច្បាប់ស្តីពីការផ្តល់ប្លង់ដី សម្រាប់ជនជាតិដើម ឆ្នាំ១៩៩៣ បានបង្កើតឱ្យមានដំណើរការច្បាប់មួយច្បាស់លាស់ សម្រាប់ក្រុមជនជាតិដើម ក្នុងការទាមទារ និងចុះបញ្ជីប្លង់ដីជនជាតិដើម ព្រមទាំងទទួលស្គាល់តាមផ្លូវច្បាប់ចំពោះសិទ្ធិរបស់ពួកគេក្នុងការចូលរួមនៅក្នុងការ ធ្វើសេចក្តីសម្រេចចិត្តអំពីបញ្ហាដីធ្លី។

បើទោះជាដូច្នេះក្តី ការទាមទារដីរបស់ជនជាតិដើម មានភាពប្រកួតប្រជែងខ្ពស់ ហើយការទទួលស្គាល់តាមផ្លូវច្បាប់ទៅលើប្លង់ដីរបស់ជនជាតិដើម គឺអាស្រ័យទៅលើភស្តុតាងដែលមានមូលដ្ឋានផ្អែកលើប្រពៃណី និងទំនៀមទម្លាប់បែបបិតុនិយម។ យ៉ាងណាមិញ ស្របពេលជាមួយគ្នានេះដែរ ច្បាប់ និងទំនៀមទម្លាប់របស់ជនជាតិដើម បានមានការផ្លាស់ប្តូរទៅជាប្រព័ន្ធញាតិសារលោហិត ដែលទទួលស្គាល់ការបន្តវេណពីម្តាយ និងឪពុក។ ស្ត្រីជនជាតិដើម និងបុរសវ័យក្មេង មានការទទួលខុសត្រូវកាន់តែច្រើននៅក្នុងសហគមន៍របស់ពួកគេ រាប់បញ្ចូលក្នុងនាមជាអ្នកនាំពាក្យ និងអ្នកធ្វើសេចក្តីសម្រេចចិត្តនៅក្នុងកន្លែងដីធ្លីមួយចំនួន ដែលមានមូលដ្ឋានអភិបាលកិច្ចទូលំទូលាយជាងរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេចចិត្តបែបប្រពៃណី ដែលផ្តោតចំពោះតែបុរសដែលមានភាពចាស់ទុំ។ ការផ្លាស់ប្តូរទាំងនេះទៅលើច្បាប់ និងទំនៀមទម្លាប់ បានពង្រឹងទៅលើការទាមទាររបស់ស្ត្រីចំពោះសិទ្ធិក្នុងការចូលរួមនៅក្នុងការគ្រប់គ្រងដីធ្លី។ តាមរយៈច្បាប់ដែលផ្តោតទៅលើករណីនីមួយៗ ថៅក្រមកំពុងពង្រីកការយល់ដឹងរបស់ខ្លួន ទាក់ទងទៅនឹងអ្វីដែលពួកគេ អាចទទួលយកបានជាភស្តុតាងសម្រាប់ការទាមទារដីធ្លី ដោយប្រើប្រាស់ច្បាប់ដើម្បីឆ្លុះបញ្ចាំងអំពីការប្រែប្រួលនៅក្នុងព័ត៌មានយេនឌ័រ និងចំណេះដឹងអំពីយេនឌ័រ ដូចជាតាមរយៈការទទួលស្គាល់តាមផ្លូវច្បាប់ចំពោះការស្នងពីញាតិសារលោហិត ក្នុងករណីជាក់លាក់មួយចំនួន។

បើទោះបីជាស្ត្រី និងបុរសនៅក្នុងសហគមន៍ជនជាតិដើម នៃប្រទេសអូស្ត្រាលីភាគខាងលិច នឹងបន្តរក្សាតួនាទីផ្សេងៗគ្នារបស់ពួកគេនៅក្នុងការគ្រប់គ្រងដីធ្លី សម្រាប់អនាគតដែលគេអាចមើលឃើញទុកជាមុនក៏ដោយ ពួកគេកំពុងផ្ទេរចំណេះដឹងអំពីដីធ្លី និង ការទាមទារដីធ្លីក្នុងលក្ខណៈមួយដែលមានភាពបត់បែនទន់ភ្លន់ ដើម្បីឆ្លើយតបទៅនឹងតួនាទីយេនឌ័រដែលកំពុងមានការផ្លាស់ប្តូរ។

ប្រភព ៖ Debra Fletcher's presentation on "Land administration – improving genderequity in institutions and activities: Aboriginal participation in land management in Australia with emphasis upon Western Australia" at the May 2011 technical workshop.

ប្រអប់ ២.៤ ៖ សន្តិសុខលើការកាន់កាប់ដីធ្លីរបស់ស្ត្រី និងមេរោគអេដស៍/ជំងឺអេដស៍

ប្រភព ៖ Wehrmanm, 2003.

បែបផែននៃអំណាចនៅកម្រិតសហគមន៍ គឺជាកត្តាមួយទៀតដែលត្រូវយកមកពិចារណា ក្នុងការធានាឱ្យមានអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌ យេនឌ័រ នៅក្នុងទិដ្ឋភាពផ្នែកច្បាប់ផ្សេងៗគ្នា។ បែបផែននៃអំណាចក្នុងមូលដ្ឋាន បង្កលក្ខណៈឱ្យប្រជាពលរដ្ឋមួយចំនួនអាចប្រើប្រាស់/រំលោភបំពានទៅលើការរៀបចំ និងស្ថាប័នកាន់កាប់ដីធ្លីជាច្រើន នៅក្នុងទិដ្ឋភាពផ្នែកច្បាប់ផ្សេងៗគ្នា និង ច្បាប់ប្រពៃណី ទៅលើក្រុមប្រជាជនដទៃទៀត ជាពិសេស ក្រុមងាយរងគ្រោះ ដូចជាស្ត្រីមេម៉ាយ។ ឧទាហរណ៍ ញាតិសាច់ថ្លៃ និងសាច់ញាតិខាងឪពុក អាចបោះបង់ស្ត្រីមេម៉ាយ ឬសាច់ញាតិជាស្ត្រី (ដូចជាបងប្អូនស្រី) តាមរយៈការទាមទារកម្មសិទ្ធិភាពដោយប្រើប្រាស់ប្លង់ដីផ្លូវការដែលស្ថិតក្រោមឈ្មោះរបស់បុរស ឬ តាមរយៈការប្រើប្រាស់យន្តការប្រពៃណី ឬ យន្តការច្បាប់ក្នុងមូលដ្ឋានដែលមិនរាប់បញ្ចូលស្ត្រី ឬ ដែលជាទូទៅប្រឆាំងនឹងស្ត្រី។

មេរោគអេដស៍ និង ជំងឺអេដស៍ អាចនាំឱ្យមានការកើនឡើងនូវអសន្តិសុខលើការកាន់កាប់ដីធ្លី សម្រាប់ស្ត្រីមេម៉ាយ និង កុមារកំព្រា ដែលរងគ្រោះពីឧបទ្ទវហេតុកាន់តែច្រើន ចំពោះការយកទ្រព្យសម្បត្តិរបស់ពួកគេ នៅពេលដែលស្វាមី និង ឪពុករបស់ពួកគេស្លាប់ដោយសារជំងឺអេដស៍។ ស្ត្រីមេម៉ាយវ័យក្មេងកាន់តែមានភាពងាយរងគ្រោះជាពិសេស អាស្រ័យដោយពួកគេពុំមានពេលវេលាដើម្បីអភិវឌ្ឍបណ្តាញសង្គមមួយដ៏រឹងមាំនៅក្បែរគ្រួសារដែលពួកគេរៀបអាពាហ៍-ពិពាហ៍ និងមិនសូវទំនងថា អាចទទួលបានកិច្ចគាំទ្រពីមេដឹកនាំក្នុងមូលដ្ឋាន និងពុំមានកូនដែលមានអាយុច្រើនល្មម ដើម្បីធ្វើការប្រឆាំងតវ៉ាជំនួសឱ្យម្តាយរបស់ពួកគេ (និងខ្លួនរបស់ពួកគេផ្ទាល់)។

ធាតុផ្សំនៃប្រព័ន្ធរដ្ឋបាលដីធ្លីរបស់រដ្ឋាភិបាល អាចជួយកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍/ជំងឺអេដស៍ទាំងនេះ ទៅលើការកាន់កាប់ដីធ្លី។ ឧទាហរណ៍ ក្រុមប្រឹក្សាដីធ្លីអាចដើរតួនាទីមួយដ៏មានតម្លៃក្នុងការទប់ស្កាត់ការលក់ដី ដែលអាចធ្វើឱ្យប៉ះពាល់ដល់សុខុមាលភាពរបស់ស្ត្រីមេម៉ាយ និងកុមារកំព្រា។ ដូច្នេះ វាមានសារៈសំខាន់ខ្លាំងណាស់ ដែលស្ត្រីទទួលបានភាពជាតំណាង និង សម្លេងស្មើភាពគ្នានៅក្នុងក្រុមប្រឹក្សាភិបាលទាំងនេះ ហើយសមាជិកក្រុមប្រឹក្សាគ្រប់រូបត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់ចំពោះប្រយោជន៍របស់ប្រជាពលរដ្ឋងាយរងគ្រោះនៅក្នុងសហគមន៍។ យន្តការដោះស្រាយ/សម្រុះសម្រួលវិវាទនៅថ្នាក់មូលដ្ឋាន ក៏អាចដើរតួនាទីមួយដ៏សំខាន់ផងដែរ ក្នុងកិច្ចការពារប្រជាពលរដ្ឋងាយរងគ្រោះ។

វាមានសារៈសំខាន់ខ្លាំងណាស់ ដែលស្ត្រីទទួលបានប្លង់ដីរួមគ្នា ឬ

និន្នាការនេះ មានការកើនឡើងដោយសារភាពខ្សត់ដី សមត្ថភាពរបស់រដ្ឋមានភាពទន់ខ្សោយក្នុងការអនុវត្តន៍សិទ្ធិស្នងមរតក ក្នុងស្ថានភាពដែលមានសម្ពាធពាណិជ្ជកម្មទៅលើដី កម្មវិធីរៀបចំរចនាសម្ព័ន្ធដីធ្លីឡើងវិញ នគរភាវូបនីយកម្ម និងមេរោគអេដស៍/ជំងឺអេដស៍ ដែលបានបង្កើនសិទ្ធិដីធ្លីរបស់បុគ្គលនៅក្នុងប្រទេសជាច្រើន ការកាត់បន្ថយចំពោះការអូសទាញកាតព្វកិច្ច និងការទទួលខុសត្រូវបែបប្រពៃណី ដូចមានរៀបរាប់នៅក្នុងប្រអប់ ២.៤ (Kapur, 2010; Harrington and Choprab, 2010)។ ដូច្នេះ គេអាចត្រូវការយុទ្ធសាស្ត្រ និងយន្តការជាក់លាក់ ដើម្បីគាំទ្រដល់សិទ្ធិរបស់ស្ត្រីមេម៉ាយក្នុងការស្នងមរតកដីធ្លី រាប់បញ្ចូលកិច្ចគាំទ្រជាក់ស្តែង ការត្រួតពិនិត្យឡើងវិញទៅលើបទប្បញ្ញត្តិ និង ការចុះបញ្ជីដីធ្លី ដូចដែលឧទាហរណ៍នៅក្នុងប្រអប់ ២.៥ បានលើកឡើង។

ប្លង់ដីក្រោមឈ្មោះផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីជានាថចំពោះសន្តិសុខលើការកាន់កាប់ដីធ្លីរបស់ពួកគេ។ ការចុះបញ្ជីអត្រានុកូលដ្ឋាន គួរមានទំនាក់ទំនងទៅនឹងការចុះបញ្ជីដីធ្លី និង គួរពង្រឹងទៅលើល័ក្ខខ័ណ្ឌតម្រូវឱ្យមានការយល់ព្រម ដើម្បីបង្ការការរំលោភបំពានទៅលើសិទ្ធិស្នងមរតករបស់ស្ត្រីមេម៉ាយ និងកុមារកំព្រា។ មន្ត្រីចុះបញ្ជីអត្រានុកូលដ្ឋាន និងមន្ត្រីចុះបញ្ជីដីធ្លី គួរទទួលបានការបណ្តុះបណ្តាលអំពីបញ្ហាទាំងនេះ ហើយទម្រង់ចុះបញ្ជី គួរត្រូវបានរៀបចំឱ្យបានជាក់លាក់ ដើម្បីបង្កលក្ខណៈឱ្យគេអាចធ្វើការចុះបញ្ជីរួមគ្នាទៅលើដីធ្លី និងទ្រព្យសម្បត្តិ។ សេចក្តីត្រូវការមួយដ៏ចម្បងក្នុងចំណោមសេចក្តីត្រូវការធំបំផុតនានា គឺជាការលើកកម្ពស់ការយល់ដឹង និងជំនួយផ្នែកច្បាប់សម្រាប់ក្រុម និង បុគ្គលងាយរងគ្រោះ ដែលរមែងតែងមិនដឹងអំពីសិទ្ធិរបស់ពួកគេ ឬ របៀបដំណើរការប្រព្រឹត្តិទៅនៃប្រព័ន្ធរដ្ឋបាលដីធ្លី។

ប្រអប់ ២.៥

ការអនុវត្តន៍ល្អសម្រាប់ដោះស្រាយបញ្ហាស្នងមរតក

ប្រភព ៖ YWAP, 2011; Rebecca Sittie, personal communication.

នៅក្នុង*ប្រទេសកេនយ៉ា* កម្មវិធីលើកកម្ពស់ស្ត្រីមេម៉ាយវ័យក្មេង បានអនុវត្តសកម្មភាពស្រាវជ្រាវដែលទទួលបានមូលនិធិគាំទ្រពីសម្ព័ន្ធភាពដីធ្លីអន្តរជាតិ ដើម្បីជួយដល់ស្ត្រីមេម៉ាយវ័យក្មេងដែលរស់នៅខេត្តណៃរ៉ូប៊ី និង បានរៀបអាពាហ៍ពិពាហ៍ ក្នុងខេត្តនីអានហ្សា។ គម្រោងនេះ ជួយដល់ស្ត្រីមេម៉ាយឱ្យជៀសវាងការបាត់បង់ទ្រព្យសម្បត្តិរបស់ពួកគេ និង ទាមទារៀមកវិញនូវការបាត់បង់សិទ្ធិដីធ្លីណាមួយ ដែលបណ្តាលមកពីភាពជាស្ត្រីមេម៉ាយរបស់ពួកគេ។ ច្បាប់ស្តីពីសន្តតិកម្មរបស់ប្រទេសកេនយ៉ា ឆ្នាំ១៩៨១ ចែងថា ស្ត្រីអាចស្នងទ្រព្យសម្បត្តិក្នុងនាមជាអ្នកពឹងអាស្រ័យទៅលើស្វាមីរបស់ពួកគេដែលបានស្លាប់។ បើទោះជាដូច្នេះក្តី ស្ត្រីមេម៉ាយវ័យក្មេង រមែងតែងជួបប្រទះបញ្ហារឹបអូសទ្រព្យសម្បត្តិ ដោយសារតែពួកគេពុំមានកូនប្រុសដែលជាមនុស្សពេញវ័យដើម្បីការពារពួកគេ ហើយពួកគេមិនសូវមានភាពរឹងមាំនៅក្នុងសហគមន៍ និងគ្រួសាររបស់លំនៅឋានស្វាមីរបស់ពួកគេ។ នៅក្នុងវប្បធម៌ Luo ក្នុងមូលដ្ឋាន ការសរសេរបណ្តាំមរតក ត្រូវបានគេយល់ឃើញថាជាប្រផ្នូលមិនល្អ ដែលជាសញ្ញានៃការស្លាប់។ ដូច្នេះ ប្រេវ៉ាឡង់នៃមេរោគអេដស៍/ជំងឺអេដស៍ បានបង្អាក់ទឹកចិត្តអ្នកដែលជាស្វាមីពីការសរសេរបណ្តាំមរតក ដែលការពារសិទ្ធិភរិយារបស់ពួកគេដែលនឹងក្លាយទៅជាស្ត្រីមេម៉ាយ។ ការលំបាកនានាផ្នែកវប្បធម៌ ក៏ធ្វើឱ្យមានការលំបាកសម្រាប់ស្ត្រីមេម៉ាយវ័យក្មេង ក្នុងការទាមទារសិទ្ធិស្នងកេរមរតករបស់ពួកគេផងដែរ។ ប្រធានភូមិជាបុរសមួយចំនួន មានការភ័យខ្លាចចំពោះការចោទប្រកាន់ថាមានទំនាក់ទំនងមិនសមស្របជាមួយស្ត្រីមេម៉ាយវ័យក្មេង ប្រសិនបើពួកគេជួយដល់ស្ត្រីមេម៉ាយទាំងនោះក្នុងការទាមទារសិទ្ធិស្នងមរតកដីធ្លីរបស់ពួកគេ។ បើទោះជាដូច្នេះក្តី ជាទូទៅគម្រោងនេះ បានមានភាពជោគជ័យក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រីមេម៉ាយវ័យក្មេងតាមរយៈលទ្ធភាពងាយស្រួលជាងមុន ក្នុងការទទួលបានយុត្តិធម៌ និងព័ត៌មាន ដែលពួកគេត្រូវការដើម្បីបន្តការទាមទាររបស់ពួកគេ។

នៅក្នុង*ប្រទេសហ្គាណា* ច្បាប់ក៏បានចែងផងដែរអំពីភាពជាម្ចាស់កម្មសិទ្ធិស្មើភាពគ្នាទៅលើទ្រព្យសម្បត្តិ នៅក្នុងអាពាហ៍ពិពាហ៍តាមបែបស៊ីវិល។ នៅពេលដែលដីធ្លីត្រូវបានចុះបញ្ជី

រួមគ្នា វាអាចកាន់តែមានការលំបាកចំពោះគ្រួសាររបស់ស្វាមីដែលបានទទួលមរណភាព ក្នុងការដេញភរិយាដែលជាស្ត្រីមេម៉ាយចេញពីដីរបស់គាត់ ឬ ចេញពីផ្ទះរបស់គាត់ក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ស្ត្រីមេម៉ាយមានកម្មសិទ្ធិភាពទៅលើទ្រព្យសម្បត្តិចំនួន៥០% រួចទៅហើយ និង បើយោងតាមច្បាប់ ស្ត្រីមេម៉ាយអាចស្នងមរតកមួយផ្នែកពីកម្មសិទ្ធិភាពចំនួន៥០% ទៀតពីស្វាមីរបស់ខ្លួន ដែលធ្វើឱ្យពួកគេកាន់តែមានភាពងាយស្រួលក្នុងការទិញយកនូវភាគហ៊ុនមួយផ្នែកទៀត ពីញាតិសាច់ថ្លៃរបស់ពួកគេ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បុរសបានគាំទ្រដល់ការចុះបញ្ជីរួមគ្នា ដើម្បីធានាឱ្យមាននូវសន្តិសុខលើសិទ្ធិកាន់កាប់ដីធ្លីសម្រាប់ភរិយារបស់ពួកគេ។

ភតិកៈ និងគ្រួសាររបស់ពួកគេក៏មានការព្រួយបារម្ភមួយចំនួន ទៅលើការស្នងមរតក និងសន្តតិកម្មដីធ្លីផងដែរ។ នៅក្នុងប្រទេសមួយចំនួន គ្រួសារទាំងមូលអាចត្រូវបានបណ្តេញចេញពីដីធ្លីដែលពួកគេប្រើប្រាស់ ឬ កាន់កាប់ នៅពេលដែលភតិកៈផ្លូវការបានស្លាប់បាត់បង់ជីវិត។ ជាញឹកញាប់ មានតែមេគ្រួសារជាបុរសប៉ុណ្ណោះ ដែលមានឈ្មោះនៅលើលិខិតជួលដី។ សមាជិកគ្រួសារដែលនៅរស់ ប្រឈមទៅនឹងការបណ្តេញចេញ លើកលែងតែសិទ្ធិកាន់កាប់ត្រូវបានការពារពីច្បាប់ស្តីពីការស្នងមតរក (FOA, 2001: 29-34)។

បញ្ជីផ្ទៀងផ្ទាត់២.១ ៖

ការគាំទ្រចំពោះការស្នងមរតកប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ WOLREC, 2011; YWAP, 2011; RWN, 2011; FAO, 2001: 29–34.

- ✓ ធានាថាក្របខ័ណ្ឌគោលនយោបាយ និង ក្របខ័ណ្ឌច្បាប់ ផ្តល់ការទទួលស្គាល់ច្បាស់លាស់ ចំពោះសិទ្ធិស្នងមតរករបស់ស្ត្រីមេម៉ាយ (និង បុរសពោះម៉ាយ) ព្រមទាំងធានាឱ្យមានយន្តការអនុវត្ត និង យន្តការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។
- ✓ ធានាថាអ្នកវិជ្ជាជីវៈក្នុងវិស័យដីធ្លី គ្រួសារ និងយុត្តិធម៌ ដឹងអំពីរបៀបដែលច្បាប់ភូមិបាលមានអន្តរទំនាក់ទំនងជាមួយច្បាប់ស្តីពីគ្រួសារ។
- ✓ រៀបចំវគ្គផ្សព្វផ្សាយ និង លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់ជាធរមាន ដើម្បីឱ្យប្រជាពលរដ្ឋ ជាពិសេសស្ត្រីដឹងអំពីច្បាប់ដែលការពារពួកគេ។
- ✓ បណ្តុះបណ្តាលអាជ្ញាធរលក្ខណៈប្រពៃណី អំពីច្បាប់គតិយុត្តិស្តីពីការស្នងមរតក។
- ✓ លើកកម្ពស់ការពិភាក្សានៅក្នុងសហគមន៍អំពី ៖ ការអនុវត្តន៍រៀបអាពាហ៍ពិពាហ៍ និង ការស្នងមរតក ចន្លោះប្រហោងរវាងការអនុវត្តន៍ទាំងនេះ និងច្បាប់គតិយុត្តិ និង ដំណោះស្រាយដែលអាចប្រព្រឹត្តិទៅបាន សម្រាប់ធ្វើការតម្រឹមទៅលើចំណុចទាំងពីរនេះ។
- ✓ ក្នុងករណីដែលកិច្ចការពារដោយច្បាប់គតិយុត្តិពុំមានភាពគ្រប់គ្រាន់ ឬ មិនអាចទទួលបាន ត្រូវជួយដល់ស្ត្រីក្នុងការប្រើប្រាស់ច្បាប់ប្រពៃណី ដើម្បីចរចារអំពីសិទ្ធិដីធ្លីរបស់ពួកគេ ឧទាហរណ៍ តាមរយៈការនិយាយអះអាងអំពីសិទ្ធិរបស់ស្ត្រីមេម៉ាយក្នុងការទទួលបាន ដីធ្លី ដោយសារតែជំនូនដែលគ្រួសាររបស់ស្ត្រីមេម៉ាយបានផ្តល់ជូន។
- ✓ អភិវឌ្ឍសមត្ថភាពរបស់អង្គការដែលគាំទ្រដល់សិទ្ធិរបស់ស្ត្រី និង ទទួលស្គាល់អំពីតួនាទីរបស់ពួកគេក្នុងការលើកកម្ពស់ការយល់ដឹង និង អនុវត្តអន្តរាគមន៍

	ជាយុទ្ធសាស្ត្រ ដើម្បីគាំទ្រដល់ស្ត្រីមេម៉ាយ។
✓	គាំទ្រដល់ការផ្តល់អំណាចតាមផ្លូវច្បាប់ តាមរយៈលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានភាពយុត្តិធម៌ យន្តការដោះស្រាយវិវាទ និងកិច្ចគាំទ្រផ្នែកច្បាប់ ដែលបង្ក លក្ខណៈឱ្យស្ត្រីមេម៉ាយអាចទាមទារសិទ្ធិរបស់ពួកគេ។
✓	នៅពេលដែលកិច្ចការពារផ្នែកច្បាប់ អនុវត្តបានចំពោះតែអាពាហ៍ពិពាហ៍បែបស៊ីវិល ត្រូវធ្វើការផ្សព្វផ្សាយជូនដល់យុវជន អំពីតម្លៃនៃការរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់ និងការធានាថាកុមារគ្រប់រូបគឺជាកូនដែលមានខាន់ស្លា។
✓	លើកទឹកចិត្តឱ្យមានការសរសេរបណ្តាំមរតក ក្នុងករណីដែលវប្បធម៌ក្នុងមូលដ្ឋានគាំទ្រដល់សកម្មភាពបែបនេះ។
✓	ចុះឈ្មោះសហព័ទ្ធទាំងពីរជាសហកតិកៈនៅក្នុងកិច្ចសន្យាជួលដី ដើម្បីឱ្យសិទ្ធិកាន់កាប់នៅតែបន្តមានសុពលភាពតាមផ្លូវច្បាប់ ក្នុងករណីដែលមានសហព័ទ្ធណាម្នាក់ទទួលមរណភាព។

ចូរចងចាំ!

អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ ដែលសំដៅចំពោះអភិបាលកិច្ចដីធ្លីសម្រាប់ ស្ត្រី និងបុរស ទាមទារឱ្យមានការយល់ដឹងអំពីទំនាក់ទំនងស្មុគស្មាញ រវាងច្បាប់ភូមិបាល និងច្បាប់ស្តីពីគ្រួសារ ព្រមទាំងគាំទ្រឱ្យមានការស្នងមរតកប្រកបដោយសមធម៌យេនឌ័រ។

ការយកដីធ្លីដោយបង្ខំ អាចជាបញ្ហានៅក្នុងបរិបទដែលមានទិដ្ឋភាពផ្នែកច្បាប់ជាច្រើនផ្សេងៗគ្នា។ បញ្ហា រួមមានដូចជា ការសម្រេចចិត្ត ថាតើនរណាគួរទទួលបានសំណងសម្រាប់ដីដែលស្ថិតក្រោមកម្មសិទ្ធិភាពរួមគ្នា និងការដោះស្រាយទំនាស់រវាងបងប្អូនបង្កើត ឬ ទំនាស់រវាងជំនាន់មួយទៅជំនាន់មួយទៀត ទាក់ទងទៅនឹងនរណាជាម្ចាស់កម្មសិទ្ធិទៅលើដីធ្លី។ វាគឺជាការអនុវត្តន៍ល្អ សម្រាប់ច្បាប់ដែលត្រូវទាមទារអត្តសញ្ញាណរបស់ប្រជាពលរដ្ឋ និង អង្គភាពទាំងអស់ដែលរងគ្រោះនៃការបាត់បង់ពីការយកដីដោយបង្ខំ និង ការបង្កើតឱ្យមាននូវយន្តការផ្តល់សំណងដែលធានាឱ្យមាននូវការធ្វើសេចក្តីសម្រេចចិត្តរួមគ្នានៅក្នុងគ្រួសារ អំពីការប្រើប្រាស់សំណងដែលទទួលបាន (FAO, 2008a: 33-34)។ សកម្មភាពដូចគ្នានេះ អនុវត្តបានចំពោះករណីដែលដីធ្លីជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ត្រូវបានទិញ ឬ ជួលដោយតួអង្គពាណិជ្ជកម្មឆ្លងប្រទេស។

ការរៀបចំជាច្រើនលើការកាន់កាប់ដីធ្លី និងស្ថាប័នដែលមានទិដ្ឋភាពផ្នែកច្បាប់ជាច្រើនផ្សេងៗគ្នា អាចផ្តល់ឱ្យក្រុមប្រជាពលរដ្ឋងាយរងគ្រោះនូវជម្រើសជាច្រើន ដើម្បីធានាសន្តិសុខចំពោះសិទ្ធិដីធ្លីរបស់ពួកគេ ដែលអនុញ្ញាតឱ្យពួកគេអាចវិលត្រឡប់មកប្រព័ន្ធបែបប្រពៃណីវិញ នៅពេលដែលប្រព័ន្ធផ្លូវការពុំមានប្រសិទ្ធភាព ឬមិនអាចរកបាន (Mackenzie, 1989; 1990; 1993)។ បើទោះបីជា នេះពុំមែនជាដំណោះស្រាយរយៈពេលវែងក៏ដោយ ប៉ុន្តែ វាមានសារៈសំខាន់ដែលគេត្រូវធ្វើការសម្របសម្រួលជាមួយស្ត្រី និងបុរសគ្រប់រូប និងពុំមែនតែអ្នកដែលមានអំណាចប៉ុណ្ណោះទេ ដើម្បីសម្រេចឱ្យបាន និងអនុវត្តសិទ្ធិដីធ្លីរបស់ពួកគេ ក្រោមប្រព័ន្ធបែបផ្លូវការ ឬ បែបប្រពៃណី ដែលស្របទៅនឹងប្រយោជន៍របស់ពួកគេប្រសើរបំផុត។ ចំណុចនេះ ទាមទារឱ្យមានសកម្មភាពមួយចំនួនដូចជា ការលើកកម្ពស់ការយល់ដឹងសាធារណៈ ការបញ្ជ្រាបយេនឌ័រនៅក្នុងស្ថាប័នអភិបាលកិច្ចលើ

ការកាន់កាប់ដីធ្លីតាមផ្លូវច្បាប់ និងតាមបែបប្រពៃណី ព្រមទាំងការបង្កើតយន្តការ និងដំណើរការច្បាប់ប្រកបដោយគណនេយ្យភាព តម្លាភាព និងមានការចូលរួម បន្តិចម្តងៗ។

សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ វត្តមាននៃទិដ្ឋភាពផ្នែកច្បាប់ផ្សេងៗគ្នា បញ្ជាក់ឱ្យដឹងថា គេត្រូវផ្តោតការយកចិត្តទុកដាក់លើសពីបញ្ហាគោលនយោបាយ ច្បាប់ និងការចូលរួម ដើម្បីដោះស្រាយចំពោះការយល់ឃើញអំពីទំនាក់ទំនងយេនឌ័រ និងរចនាសម្ព័ន្ធអំណាច ដែលឫសគល់នៃបញ្ហា។ សកម្មភាពនេះ ទាមទារឱ្យមានទស្សនៈវិស័យ និងភាពអត់ធ្មត់រយៈពេលវែងមួយ បន្ថែមពីលើការប្រាស្រ័យទាក់ទង និងការលើកកម្ពស់ការយល់ដឹង ដូចមានបញ្ជាក់នៅក្នុង*ម៉ូឌុល៥*។

✎បញ្ជីផ្ទៀងផ្ទាត់ ២.២ ៖

ការគាំទ្រចំពោះសមធម៌យេនឌ័រនៅក្នុងទិដ្ឋផ្នែកច្បាប់ផ្សេងៗគ្នា

ប្រភព ៖ WOLREC, 2011; Nakayi, 2010.

- ✓ ធ្វើការងារប្រកបដោយភាពស្ថាបនា ជាមួយស្ថាប័នបែបប្រពៃណី និង ស្ថាប័នសាសនា ព្រមទាំងមេដឹកនាំនៃស្ថាប័នទាំងនោះ និងជម្រុញឱ្យមានការចូលរួមពីសហគមន៍ទាំងមូលនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និង លទ្ធផលដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍ច្បាប់បែបប្រពៃណី និងការអនុវត្តន៍កាន់កាប់ដីធ្លី។
- ✓ លើកកម្ពស់ការយល់ដឹងអំពីរបៀបដែលអ្វីៗអាចមានការប្រែប្រួល តាមរយៈទស្សនៈវិស័យបែបប្រពៃណី។ គាំទ្រដល់ក្រុមជួយខ្លួនឯងរបស់ស្ត្រី អាស្រ័យដោយក្រុមទាំងនេះ អាចដើរតួនាទីមួយដ៏សំខាន់ក្នុងការគាំទ្រឱ្យមានការផ្លាស់ប្តូរផ្នែកវប្បធម៌។
- ✓ ធានាថាការទទួលស្គាល់ច្បាប់បែបប្រពៃណី ស្របតាមច្បាប់ជាផ្លូវការ មិននាំឱ្យឈានទៅដល់ការរំលោភបំពានទៅលើច្បាប់ប្រពៃណី ក្នុងលក្ខណៈមួយដែលបង្កឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋងាយរងគ្រោះឡើយ។
- ✓ បង្កើតកម្មវិធីបណ្តុះបណ្តាល ដែលផ្តោតទៅលើទិសដៅចំនួន២ ដោយមានមេដឹកនាំបែបប្រពៃណី/សាសនា ផ្តល់ការបណ្តុះបណ្តាល ជូនដល់ចៅក្រមផ្លូវការអំពីច្បាប់ប្រពៃណី/សាសនា និង ចៅក្រមផ្តល់ការបណ្តុះបណ្តាលជូនដល់ពួកគេអំពីច្បាប់គតិយុត្តិ។ សកម្មភាពបែបនេះ ជួយកសាងឱ្យមានការភ្ជាប់ទំនាក់ទំនងរវាងប្រព័ន្ធច្បាប់ផ្សេងៗគ្នា និង អាចធ្វើឱ្យប្រសើរឡើងនូវការប្រាស្រ័យទាក់ទង សំដៅជានាឱ្យមាននូវលទ្ធផលការងារជារួមដែលកាន់តែមានភាពយុត្តិធម៌។
- ✓ ពិនិត្យស្វែងរកអំពីទីកន្លែងដែលស្ត្រី និងបុរសអាចទទួលបានជំនួយ និងកិច្ចការពារតាមផ្លូវច្បាប់។ គាំទ្រដល់យន្តការ និងដំណើរការទាំងនេះ ព្រមទាំងសម្របសម្រួលឱ្យប្រជាពលរដ្ឋអាចមានលទ្ធភាពទទួលបានប្រយោជន៍ពីទិដ្ឋភាពផ្សេងៗគ្នានៃច្បាប់។

ចូរចងចាំ!

ច្បាប់ដែលត្រូវបានតាក់តែងឡើងជាលាយលក្ខណ៍អក្សរ គឺជាកិច្ចការពារប្រសើរបំផុតសម្រាប់ប្រឆាំងទៅនឹងការអនុវត្តន៍បែបប្រពៃណី ឬ សាសនាដែលពុំមានសមធម៌យេនឌ័រ។ បើទោះជាដូច្នេះក្តី មានចន្លោះប្រហោងយ៉ាងទូលំទូលាយ រវាងច្បាប់ និង ការអនុវត្តន៍ ហើយការអនុវត្តន៍មិនល្អ នៅតែបន្តមិនត្រូវបានគេត្រួតពិនិត្យ។

ការរៀបចំសេចក្តីព្រាងច្បាប់ និយ័តកម្ម និងនីតិវិធី

ច្បាប់ភូមិបាលមួយដ៏ល្អ រមែងតែងមិនអាចយកមកអនុវត្តបាន ដោយសារតែខ្វះលិខិតបទដ្ឋានក្រោមច្បាប់ និងនីតិវិធីសម្រាប់ការអនុវត្តន៍។ ដូច្នេះ វាមានសារៈសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តន៍ច្បាប់ភូមិបាល និងអភិវឌ្ឍនិយ័តកម្ម នីតិវិធី និងយុទ្ធសាស្ត្រប្រកបដោយសមធម៌យេនឌ័រសម្រាប់ការអនុវត្តន៍ (FAO, 2008a: 12)។ តារាង ២.១ រៀបរាប់អំពីលិខិតុបករណ៍ច្បាប់មួយចំនួនដែលត្រូវរៀបចំជាសេចក្តីព្រាង និងអនុវត្តក្នុងលក្ខណៈជាផ្នែកមួយនៃយុទ្ធសាស្ត្រអនុវត្ត សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។

តារាង ២.១ ៖ **លិខិតុបករណ៍ច្បាប់**

លិខិតុបករណ៍ច្បាប់	និយមន័យ
អនុសញ្ញាអន្តរជាតិ	សន្ធិសញ្ញា អនុសញ្ញា ឬ ទម្រង់ដទៃទៀតនៃលិខិតុបករណ៍អន្តរជាតិ ដែលត្រូវបានចងកាតព្វកិច្ចតាមផ្លូវច្បាប់ ដែលកំណត់កាតព្វកិច្ចតាមផ្លូវច្បាប់ទៅលើបណ្តាប្រទេសនានា ដែលបានផ្តល់សច្ចាប័នទៅលើអនុសញ្ញាអន្តរជាតិទាំងនោះ។
រដ្ឋធម្មនុញ្ញ	ឯកសារដែលបង្កើតគោលការណ៍មូលដ្ឋានស្របច្បាប់ ដែលគ្របដណ្តប់ទៅលើប្រទេសមួយ។ រដ្ឋធម្មនុញ្ញជាច្រើនមានទម្រង់ជាឯកសារលាយលក្ខណ៍អក្សរ ហើយរដ្ឋធម្មនុញ្ញមួយចំនួនទៀតពុំមានទម្រង់លាយលក្ខណ៍អក្សរ ដែលត្រូវបានបង្កើតតាមរយៈច្បាប់ដែលមានតាមទម្លាប់កន្លងមក និងច្បាប់យុត្តិសាស្ត្រ។
ច្បាប់ចម្បង	ច្បាប់ដែលត្រូវបានធ្វើឡើងដោយអង្គនីតិប្បញ្ញត្តិ។ លើកលែងតែច្បាប់ទាំងនេះមានលក្ខណៈលម្អិតខ្លាំង បើពុំនោះសោតទេ ច្បាប់ចម្បង អាចត្រូវការលិខិតបទដ្ឋានក្រោមច្បាប់សម្រាប់គាំទ្រ។
លិខិតបទដ្ឋានក្រោមច្បាប់	និយ័តកម្ម វិធាន ដីកា និង អនុក្រឹត្យបន្ថែមដែលចាំបាច់ ដើម្បីកំណត់អំពីខ្លឹមសារលម្អិតនៃច្បាប់បឋម ដើម្បីធានាថា ច្បាប់ទាំងនោះត្រូវបានអនុវត្តដោយឥតលម្អៀង និង ប្រកបដោយភាពយុត្តិធម៌។
វិធាន និងនីតិវិធី	ឯកសារដែលណែនាំដល់មន្ត្រី និងរដ្ឋបាលអំពីរបៀបដែលច្បាប់គួរត្រូវបានយកមកអនុវត្ត។

ច្បាប់ចម្បង ត្រូវមានភាពអនុលោមស្របទៅតាមរដ្ឋធម្មនុញ្ញ ហើយលិខិតបទដ្ឋានក្រោមច្បាប់ វិធាន និងនីតិវិធីនានាត្រូវមានភាពអនុលោមស្របតាមច្បាប់បឋម និងរដ្ឋធម្មនុញ្ញ។ ប្រសិនបើរដ្ឋធម្មនុញ្ញ រាប់បញ្ចូលកិច្ចការពារទៅលើសិទ្ធិជាមូលដ្ឋាន តាមរយៈការលើកកម្ពស់គោលការណ៍មួយចំនួន ឧទាហរណ៍ដូចជា សមធម៌យេនឌ័រ អង្គនីតិប្បញ្ញត្តិដែលបង្កើតច្បាប់ចម្បង និង អង្គភាពដែលទទួលខុសត្រូវអនុម័តលិខិតបទដ្ឋានក្រោមច្បាប់ ត្រូវពិនិត្យទៅលើគោលការណ៍ទាំងនោះ។

ដំណើរការបង្កើតគោលនយោបាយដីធ្លីមានភាពខុសគ្នាពីមាតិកានៃគោលនយោបាយដីធ្លី ដែលទទួលបាន

តាមរយៈលទ្ធផលនៃដំណើរការនេះ ដូច្នេះ ដំណើរការរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិ ក៏ខុសគ្នាពីមាតិកានៃ ច្បាប់ និយ័តកម្ម និងនីតិវិធី ដែលជាលទ្ធផលនៃដំណើរការនោះផងដែរ។ ដំណើរការរៀបចំសេចក្តីព្រាងមួយ ដែលមានសមធម៌យេនឌ័រ មិនចាំបាច់ត្រូវនាំឱ្យឈានទៅទទួលបានបទប្បញ្ញត្តិមួយ ដែលមានសមធម៌យេនឌ័រឡើយ។ បើទោះជាដូច្នេះក្តី ការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងដំណើការរៀបចំសេចក្តីព្រាង ទំនងនឹងនាំឱ្យមានច្បាប់ភូមិបាល និងលិខិតបទដ្ឋានក្រោមច្បាប់ ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការខុសៗគ្នារបស់ស្ត្រី និងបុរស ដែលមកពីក្រុមសង្គមផ្សេងៗគ្នា ដោយបង្កលក្ខណៈឱ្យមានការអនុវត្តន៍គោលនយោបាយ និងច្បាប់ភូមិបាលជារួម ប្រកបដោយសមធម៌យេនឌ័រ។

ប្រអប់ ២.៦ រៀបរាប់អំពីវិធានការដើម្បីធានាថា ដំណើរការរៀបចំសេចក្តីព្រាងច្បាប់មានលក្ខណៈបែបចូលរួមមានការពិគ្រោះយោបល់ និងរាប់បញ្ចូលទាំងស្ត្រី និងបុរស។

ប្រអប់ ២.៦ ៖

ការរៀបចំសេចក្តីព្រាងច្បាប់ដោយមានការពិគ្រោះយោបល់ មានការចូលរួម និងប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ FAO 2002c: 31–32; Government of Samoa 2008.

នៅក្នុង*ប្រទេសម៉ូហ្សំប៊ិក* ការរៀបចំសេចក្តីព្រាងច្បាប់ភូមិបាល ឆ្នាំ១៩៩៧ និងលិខិតបទដ្ឋានក្រោមច្បាប់ បានបង្កើតឱ្យមាននូវទម្លាប់ពីមុនមួយដ៏សំខាន់ សម្រាប់ជម្រុញឱ្យមានការចូលរួមពីសង្គមស៊ីវិល រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការអភិវឌ្ឍន៍គោលនយោបាយ និង ការផ្លាស់ប្តូរបទប្បញ្ញត្តិជាតិស្តីពីដីធ្លី ហើយវាត្រូវបានដកស្រង់យ៉ាងទូលំទូលាយថាជាការអនុវត្តន៍ល្អ នៅក្នុងកំណែទម្រង់ច្បាប់ភូមិបាលមួយប្រកបដោយភាពច្នៃប្រឌិត។ សន្និសីទថ្នាក់ជាតិស្តីពីដីធ្លី ឆ្នាំ១៩៩៦ ដែលបានធ្វើឡើងមុនពេលការធ្វើបទបង្ហាញអំពីច្បាប់ភូមិបាល ជូនដល់រដ្ឋសភា មានការចូលរួមពីអ្នកចូលរួមជាង ២០០នាក់ ដែលអញ្ជើញមកពីធម្មនុញ្ញភាពជាច្រើនយ៉ាងទូលំទូលាយ រាប់បញ្ចូលអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងអង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន អង្គការកសិករ និងអង្គការស្ត្រីតូចៗមកពីតំបន់ផ្សេងៗគ្នា វិស័យឯកជន និង អ្នកវិជ្ជាជីវៈ ព្រមទាំងអ្នកឯកទេសឯករាជ្យផ្នែកវិស័យដីធ្លី។ សេចក្តីព្រាងច្បាប់ត្រូវបានលើកយកមកធ្វើការពិភាក្សាវែកញែកមួយចំណុចម្តងៗ នៅក្នុងសន្និសីទរយៈពេល៣ថ្ងៃ និងទទួលបានកិច្ចគាំទ្រយ៉ាងទូលំទូលាយ។

នៅក្នុង*ប្រទេសសាម៉ៅ* កូនសៀវភៅសេចក្តីព្រាងច្បាប់ ឆ្នាំ២០០៨ បានកំណត់រកឃើញជំហានមួយចំនួនដែលក្រសួង និងទីភ្នាក់ងាររដ្ឋាភិបាល ត្រូវអនុវត្តមុនពេលចាប់ផ្តើមធ្វើកំណែទម្រង់ច្បាប់ និងរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិ រាប់បញ្ចូល និយ័តកម្ម និងនីតិវិធីសម្រាប់អនុវត្តច្បាប់ដែលមានស្រាប់។ ឧទាហរណ៍ ក្រសួងដែលផ្តល់សេចក្តីណែនាំ ត្រូវពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធឱ្យបានឆាប់បំផុតដូចដែលអាចធ្វើទៅបាន នៅពេលដែលច្បាប់/និយ័តកម្មត្រូវបានរៀបចំជាសេចក្តីព្រាង ព្រមទាំងត្រូវដាក់បញ្ចូលមតិយោបល់របស់អ្នកពាក់ព័ន្ធ ទៅក្នុងសេចក្តីព្រាងក្រោយៗទៀត។ ក្រុមប្រជាពលរដ្ឋផ្សេងៗគ្នាត្រូវបានពិគ្រោះយោបល់ ដើម្បីទទួលបានទស្សនៈពីតំណាងផ្នែកផ្សេងៗគ្នានៃសហគមន៍ទាំងមូលដែលរួមមាន ស្ត្រី បុរស យុវជន និងមនុស្សចាស់ ហើយត្រូវកត់ត្រាទុកនូវរាល់លទ្ធផលទាំងអស់នៃការពិគ្រោះយោបល់។ កូនសៀវភៅនេះ ក៏ចែងផងដែរថា រាល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិទាំងអស់ ត្រូវប្រើប្រាស់វាក្យស័ព្ទបច្ចេកទេសដែលមានលក្ខណៈអព្យាក្រឹត្យចំពោះបញ្ហាយេនឌ័រ។ ក្នុងឆ្នាំ២០០៧ នៅពេលដែលច្បាប់ទាំងអស់របស់ប្រទេសសាម៉ៅត្រូវបានច្របាច់បញ្ចូលគ្នា ពាក្យពេចន៍ដែលលម្អៀងទៅខាងបុរសត្រូវបានជំនួស ជាមួយនឹងពាក្យពេចន៍ដែលមានភាពអព្យាក្រឹត្យចំពោះបញ្ហាយេនឌ័រ។

គ្រប់កម្មវិធីទាំងអស់សម្រាប់កំណែទម្រង់ដីធ្លី រាប់បញ្ចូលកម្មវិធីដែលផ្ដល់មូលនិធិគាំទ្រដោយម្ចាស់ជំនួយ គួរគាំទ្រដល់ការរៀបចំសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត និយ័តកម្ម និងនីតិវិធី ដូចជា សៀវភៅប្រតិបត្តិ និងសៀវភៅនីតិវិធីសម្រាប់ការចុះបញ្ជីដីធ្លី។ លិខិតុបករណ៍គាំទ្រទាំងនេះ អាចគាំទ្រដល់ការអនុវត្តន៍ច្បាប់ ឬ រំលោភបំពាន ច្បាប់ ដូច្នេះ ការរៀបចំ និងការផ្សព្វផ្សាយនិយ័តកម្ម នីតិវិធី និងសៀវភៅដែលលើកកម្ពស់អភិក្រមរួមមួយ ប្រកបដោយសមធម៌យេនឌ័រ សម្រាប់ការរៀបចំ និងការអនុវត្តន៍ច្បាប់ គឺជាគន្លឹះក្នុងការធានាឱ្យមាននូវអភិបាលកិច្ចលើការកាន់កាប់ប្រកបដោយសមធម៌យេនឌ័រ (FAO, 2001a: 13)។

បន្ថែមពីនេះទៀត ស្ថាប័នដែលពាក់ព័ន្ធនៅក្នុងការងារអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ត្រូវមានការប្ដេជ្ញាចិត្តធានាថា និយ័តកម្មត្រូវបានរៀបចំជាសេចក្ដីព្រាង និងអនុវត្តបានត្រឹមត្រូវ។ ឧទាហរណ៍ ការចងក្រងឯកសារ និង នីតិវិធីដែលចាំបាច់សម្រាប់គាំទ្រដល់ការទាមទារចុះបញ្ជីដីធ្លី ត្រូវតែមាន និង បង្កលក្ខណៈឱ្យស្ត្រីព្រមទាំងបុរសអាចទទួលបាន។ ចំណុចនេះ អាចទាមទារឱ្យធ្វើការពិនិត្យកែសម្រួលឡើងវិញទៅលើនិយ័តកម្មពាក់ព័ន្ធ ដើម្បីផ្ដល់ឱ្យស្ត្រី និងបុរសនូវឱកាសស្មើភាពគ្នា ក្នុងការចុះបញ្ជីដីធ្លី (World Bank/FAO/IFAD, 2009a:145)។ និយ័តកម្មនានា ក៏គួរពង្រឹងការអនុវត្តន៍អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ ឱ្យបានកាន់តែទូលំទូលាយផងដែរ ដូចជា តាមរយៈការទាមទារឱ្យមានការផ្ដល់ប្លង់រួមគ្នាសម្រាប់ដីរបស់គូស្វាមីភរិយាដែលទទួលបានរួមគ្នា និងភស្តុតាងបញ្ជាក់អំពីការយល់ព្រមពីសហព័ទ្ធទាំងសង្ខាង សម្រាប់ការចុះបញ្ជីជាផ្លូវការអំពី ប្រតិបត្តិការនៃទ្រព្យសម្បត្តិក្រោយពេលរៀបអាពាហ៍ពិពាហ៍ (World Bank/FAO/IFAD, 2009a:145-146)។

និយ័តកម្មអំពីការរៀបចំជួលដីកសិកម្ម ក៏គួរពិចារណាផងដែរទៅលើបញ្ហាសមធម៌យេនឌ័រ។ ការរៀបចំជួលដីគឺជាប្រភពតែម៉្យាង ឬ ជាប្រភពចម្បងនៃការទទួលបានដីសម្រាប់គ្រួសារកសិករជាច្រើនទូទាំងពិភពលោក ដូច្នេះ វាគឺជាផ្នែកមួយដ៏សំខាន់នៃការកាន់កាប់ដីធ្លី។ ការអនុវត្តន៍ល្អ ដើម្បីគាំទ្រដល់ការរៀបចំជួលដីប្រកបដោយសមធម៌យេនឌ័រ (FAO, 2001; 2004) រួមមាន ៖

- ការអនុញ្ញាតឱ្យទាំងស្ត្រី និងបុរស ចុះឈ្មោះជាអ្នកជួលដែលអនុញ្ញាតឱ្យសមាជិកគ្រួសារ អាចជួលដីដោយឯករាជ្យពីមេគ្រួសារ និងបញ្ចូលឈ្មោះរបស់សមាជិកគ្រួសារគ្រប់រូបដែលប្រើប្រាស់ ឬ កាន់កាប់ដីនៅក្នុងការជួលដីជាផ្លូវការ ព្រមជាមួយនឹងឈ្មោះអ្នកជួល ហើយការប្រើប្រាស់គំរូកិច្ចសន្យាជួលអាចមានសារៈសំខាន់ជាពិសេស នៅត្រង់ចំណុចនេះ។

- ការធានាថា ម្ចាស់ដីដែលមានឈ្មោះនៅក្នុងកិច្ចសន្យាជួល មានសមាសភាពស្របច្បាប់ក្នុងការជួលដី ឧទាហរណ៍ដូចជា ម្ចាស់ដីអាចមានកាតព្វកិច្ចតាមច្បាប់ប្រពៃណីក្នុងការសុំការយល់ព្រមពីសមាជិកគ្រួសារដទៃទៀត។

- ក្នុងករណីដែលភតិកៈណាម្នាក់បានស្លាប់បាត់បង់ជីវិត ត្រូវបង្កលក្ខណៈឱ្យសហព័ទ្ធដែលនៅរស់ និងគ្រួសារបន្តរស់នៅធ្វើការងារលើដីនោះ រហូតដល់ចប់សិទ្ធិកាន់កាប់ ឬ រហូតដល់ការរៀបចំដែលមានលក្ខណៈអចិន្ត្រៃយ៍ជាងនេះ អាចត្រូវបានធ្វើឡើង ដោយរក្សានូវរាល់សិទ្ធិគ្រប់យ៉ាងដែលមានចំពោះភតិកៈដែលមានឈ្មោះនៅក្នុងកិច្ចសន្យាជួល។

រាល់ច្បាប់ភូមិបាលទាំងអស់ ត្រូវការឱ្យមានយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសម្រាប់អនុវត្តបទប្បញ្ញត្តិនៃច្បាប់ទាំងនោះ ដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ និងមានសមធម៌យេនឌ័រ ព្រមទាំងសម្រាប់ធានាឱ្យមានការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ (FAO, 2011a: 13)។ គោលការណ៍ណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ ដូចជា គោលការណ៍ណែនាំនៅក្នុងប្រទេសសាម៉ៅ (ប្រអប់ ២.៦) មានសារៈសំខាន់ជាពិសេសនៅក្នុងវិស័យការងារនេះ។ ការបង្កើតឱ្យមាននូវនីតិវិធីរៀបចំសេចក្តីព្រាងច្បាប់ប្រកបដោយបទដ្ឋាន ជួយធានាថាព័ត៌មានលម្អិតមួយចំនួនដូចជា ការរៀបចំទម្រង់ និងយន្តការប្តឹងឧទ្ធរណ៍ ការពារចំពោះសិទ្ធិស្ត្រី និង បុរស។

ការអនុវត្តន៍សាកល្បងចំពោះនិយ័តកម្ម ឬ ច្បាប់ ជួយធ្វើតេស្តដើម្បីឱ្យដឹងថា តើនីតិវិធីដែលគេបានផ្តល់ជូនមានដំណើរការប្រព្រឹត្តទៅបានល្អដល់កម្រិតណានៅមូលដ្ឋាន (Rachael Knight, personal communication) និងអាចមានសារៈប្រយោជន៍ជាពិសេស ក្នុងករណីដែលបទប្បញ្ញត្តិត្រូវបានរៀបចំសេចក្តីព្រាង ដោយមានការយកចិត្តទុកដាក់តិចតួច ចំពោះស្ថាប័ន និងដំណើរការដែលចាំបាច់សម្រាប់អនុវត្តច្បាប់ និងនិយ័តកម្មទាំងនោះ។ ក្រោយពេលអនុវត្តសាកល្បង មតិយោបល់ត្រឡប់អំពីប្រសិទ្ធភាពនៃច្បាប់ ឬ បទប្បញ្ញត្តិថ្មី អាចផ្តល់ការណែនាំសម្រាប់ការធ្វើវិសោធនកម្ម និងការកែលម្អបន្ថែម។ ការអនុវត្តន៍សាកល្បង អាចមានសារៈប្រយោជន៍បំផុតសម្រាប់ការធ្វើតេស្តទៅលើបញ្ហាសមធម៌យេនឌ័រនៃសៀវភៅប្រតិបត្តិការ និងសៀវភៅនីតិវិធី ព្រមទាំងធ្វើការកែសម្រួលទៅលើខ្លឹមសារលម្អិតនៃច្បាប់ជាធរមាន។

វាក៏មានសារៈសំខាន់ផងដែរ ក្នុងការបង្កើតអង្គភាពជាន់ខ្ពស់មួយ ដែលមានការទទួលខុសត្រូវត្រួតពិនិត្យទៅលើបញ្ហាសមធម៌យេនឌ័រ ក្នុងការអនុវត្តន៍ច្បាប់ភូមិបាល និងលិខិតបទដ្ឋានក្រោមច្បាប់។ ឧទាហរណ៍នៅក្នុងប្រទេសវ៉ាន់វ៉ាន់ជា ការិយាល័យត្រួតពិនិត្យយេនឌ័រ ធ្វើការត្រួតពិនិត្យទៅលើភាពអនុលោម ទៅនឹងសូចនាករនៃកម្មវិធីសមធម៌យេនឌ័ររបស់ខ្លួន។ ការិយាល័យបែបនេះ ទំនងនឹងមានប្រសិទ្ធភាពជាង ក្នុងការគាំទ្រចំពោះភាពអនុលោម ជាពិសេស ភាពអនុលោមស្របតាមវិធានមួយចំនួន ដូចជា កូតាសម្រាប់ការចូលរួមរបស់ស្ត្រីនៅក្នុងស្ថាប័នអភិបាលកិច្ច កិច្ចប្រជុំគណៈកម្មាធិការ។ល។ ជាជាងយន្តការឧទ្ធរណ៍ដែលមានការពាក់ព័ន្ធទៅនឹងតុលាការ តុលាការ ឬអង្គជំនុំជម្រះពិសេសលើផ្នែកដីធ្លី ដែលហាក់មានលក្ខណៈបែបប្រតិកម្មមានភាពយឺតយ៉ាវ និងត្រូវចំណាយថវិកាច្រើនសម្រាប់ដើមបណ្តឹងឧទ្ធរណ៍ និង ពុំមានភាពច្បាស់លាស់ចំពោះជោគជ័យ (McAuslan, 2010: 126)។

ការរៀបចំសេចក្ដីព្រាងច្បាប់



ការរៀបចំសេចក្ដីព្រាងបទប្បញ្ញត្តិ និងការបោះជំហានឆ្ពោះទៅរកការអនុវត្តន៍



រូបភាព ២.១ ៖ ជំហាននៅក្នុងការរៀបចំសេចក្ដីព្រាងច្បាប់ប្រកបដោយសមធម៌យេនឌ័រ

ប្រអប់ ២.៧ ៖

មេរៀនបទពិសោធន៍ ដែលទទួលបានពីការរៀបចំ សេចក្តីព្រាងច្បាប់ក្នុងមូលដ្ឋាន

ប្រភព ៖ Knight, 2011

អង្គការច្បាប់អភិវឌ្ឍអន្តរជាតិ បានអនុវត្តគម្រោងសាកល្បងមួយស្តីពីការផ្តល់ប្លង់ដីសហគមន៍ នៅក្នុង*ប្រទេសលីបេរីយ៉ា ម៉ូហ្សំប៊ិក* និង *យូហ្គាន់ដា* នៅចន្លោះឆ្នាំ២០០៩ និងឆ្នាំ២០១១។ តាមរយៈការធ្វើការងារជាមួយដៃគូសង្គមស៊ីវិលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន នៅក្នុងប្រទេសនីមួយៗ គម្រោងមានគោលបំណងស្វែងយល់អំពីរបៀបគាំទ្រដល់កិច្ចខិតខំរបស់សហគមន៍ ក្នុងការចងក្រងឯកសារអំពីការទាមទារដីធ្លី ព្រមទាំងរៀបចំ និង អនុវត្តសាកល្បងនូវយុទ្ធសាស្ត្រសម្របសម្រួលសមធម៌យេនឌ័រ ព្រមទាំងទប់ស្កាត់ភាពអយុត្តិធម៌ និង ការរើសអើង នៅក្នុងសហគមន៍។

ធាតុផ្សំមួយដ៏សំខាន់របស់គម្រោង គឺជាដំណើរការបែបចូលរួមមួយសម្រាប់បង្កើតវិធានមួយចំនួន សម្រាប់រដ្ឋបាលដីធ្លីសហគមន៍ (លក្ខន្តិកៈ/ធម្មនុញ្ញរបស់សហគមន៍)។ កិច្ចប្រជុំមួយចំនួនត្រូវបានធ្វើឡើងនៅក្នុងជំហាននីមួយៗ ក្នុងចំណោមជំហានចម្បងៗនានា ក្នុងការរៀបចំសេចក្តីព្រាងលក្ខន្តិកៈ ដូចជា ការប្រមូលផ្តុំគំនិត និងការកត់ត្រាអំពីវិធានដែលមានស្រាប់ ការលុបបំបាត់ ឬ ការកែសម្រួលទៅលើវិធាន ដែលលែងមានភាពសមស្របទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ និងការបន្ថែមវិធានថ្មីៗដែលសមស្របការត្រួតពិនិត្យសង្គតភាព និង ភាពអនុលោម ទៅនឹងរដ្ឋធម្មនុញ្ញជាតិ និងច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិ ព្រមទាំងក្រោយពេលពិនិត្យកែសម្រួលលើកចុងក្រោយ ត្រូវរៀបចំសេចក្តីព្រាងចុងក្រោយមួយសម្រាប់ការអនុម័តជាផ្លូវការ សម្រាប់ប្រើប្រាស់ជាលក្ខន្តិកៈ ឬ ធម្មនុញ្ញរបស់សហគមន៍។

ចាប់តាំងពីដំបូង ក្រុមការងារគម្រោងបានសង្កត់ធ្ងន់ថា សហគមន៍ទាំងមូលត្រូវចូលរួមនៅក្នុងដំណើរការទាំងស្រុង ហើយតំណាងបុរសព្រមទាំងស្ត្រីរបស់គ្រួសារនីមួយៗត្រូវចូលរួមនៅក្នុងកិច្ចប្រជុំលើកចុងក្រោយ ដើម្បីអនុម័តទៅលើលក្ខន្តិកៈ។

ដំណើរការរៀបចំសេចក្តីព្រាងច្បាប់ថ្នាក់មូលដ្ឋាននេះ បានបង្កលក្ខណៈឱ្យសហគមន៍អាចធ្វើការឆ្លុះបញ្ចាំង និងពិភាក្សាអំពីវិធានអភិបាលកិច្ចលើការកាន់កាប់ដីធ្លីដែលមានស្រាប់របស់ពួកគេ និង មូលហេតុដែលស្ថិតនៅពីក្រោយ ចំពោះការដែលបន្តមានវិធានអភិបាលកិច្ចបែបនេះ រាប់បញ្ចូល វិធានប្រពៃណីបែបរើសអើង ដែលស្ត្រីបានធ្វើការសាកសួរ និងដេញដោលនៅក្នុងកិច្ចប្រជុំ។ ស្ត្រីបានចាប់ផ្តើមមើលឃើញថាពួកគេអាចទាមទារសិទ្ធិដីធ្លីបានកាន់តែច្រើនជាងនេះ នៅក្នុងសហគមន៍របស់ពួកគេ ហើយសហគមន៍ត្រូវបានលើកទឹកចិត្តឱ្យពង្រឹងសិទ្ធិដីធ្លី

ធម្មនុញ្ញ និង លក្ខន្តិកៈរបស់សហគម៍ គួរតាក់តែងឡើង ឬ រៀបចំជាសេចក្តីព្រាងនៅថ្នាក់មូលដ្ឋាន ក្នុងលក្ខណៈមួយដែលអនុញ្ញាតឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រពីគ្រប់ស្ត្រី និង បុរសទាំងអស់នៅក្នុងសហគមន៍ ព្រមទាំងអាចជួយបង្កើនអក្ខរភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានអំពីច្បាប់ និងការយល់ដឹងអំពីច្បាប់គតិយុត្តិផងដែរ។ ដំណើរការរៀបចំសេចក្តីព្រាងច្បាប់ក្នុងមូលដ្ឋាន អាចបើកចំហឱកាសមួយចំនួនសម្រាប់ស្ត្រី ដើម្បីសួរសំនួរអំពីវិធាននានា ដែលធ្វើឱ្យបាត់បង់ប្រយោជន៍ ឬ រើសអើងទៅលើពួកគេ ព្រមទាំងធ្វើការតស៊ូមតិ ដើម្បីឱ្យមានវិធានមួយចំនួនដែលពង្រឹងសន្តិសុខលើការកាន់កាប់ដីធ្លី និងតួនាទីរបស់ពួកគេ នៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លីក្នុងមូលដ្ឋាន (Knight, 2001)។ ប្រអប់ ២.៧ រៀបរាប់អំពីរបៀបដែលគេសម្រេចបានសមធម៌យេនឌ័រ ប្រកបដោយជោគជ័យ នៅក្នុងដំណើរការផ្តល់ប្លង់ដីតាមសហគមន៍ ក្នុងប្រទេស លីបេរីយ៉ា ម៉ូហ្សំប៊ិក និងយូហ្គាន់ដា។

របស់ក្រុមជនងាយរងគ្រោះ ព្រមទាំងយន្តការក្នុងសហគមន៍សម្រាប់ការពារសុវត្ថិភាពចំពោះសិទ្ធិដែលមានស្រាប់។ គម្រោងនេះ ក៏បានបង្កលក្ខណៈឱ្យធ្វើការបន្សុីវិធានក្នុងមូលដ្ឋាន ទៅនឹងច្បាប់គតិយុត្តិ ដោយបង្កើនការយល់ដឹងរបស់សហគមន៍ និងស្ត្រី អំពីបញ្ហាច្បាប់ជាតិ និង សិទ្ធិមនុស្ស។ តាមរយៈការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចប្រជុំ និងការពិភាក្សា ការយល់ឃើញរបស់សហគមន៍អំពីឋានៈរបស់ស្ត្រីនៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី បានចាប់ផ្តើមមានការផ្លាស់ប្តូរ ហើយការចូលរួមប្រកបដោយសមធម៌របស់ស្ត្រី នៅក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ក្នុងមូលដ្ឋាន បានជះឥទ្ធិពលទៅលើមាតិកានៃវិធានរបស់សហគមន៍ ដែលជាលទ្ធផលទទួលបានពីដំណើរការរៀបចំសេចក្តីព្រាងច្បាប់។

✎បញ្ជីផ្ទៀងផ្ទាត់ ២.៣ ៖

ការគាំទ្រចំពោះការរៀបចំសេចក្តីព្រាងច្បាប់ប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ McAuslan, 2010.

✓	ធានាថា គ្រប់បទប្បញ្ញត្តិ និងនិយ័តកម្មស្តីពីដីធ្លីទាំងអស់ មានសង្គតភាពទៅនឹង ក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ ដែលគ្របដណ្តប់ជារួម និង ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងធានាថា ក្របខ័ណ្ឌនេះគាំទ្រដល់សមធម៌យេនឌ័រ។
✓	កំណត់អំពីដំណើរការសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ ដែលរាប់បញ្ចូលការពិគ្រោះយោបល់ និងការចូលរួមប្រកបដោយសមធម៌យេនឌ័រ ដោយធានាថា ក្រុមស្ត្រីមានការចូលរួម ហើយការរួមចំណែករបស់ពួកគេ ត្រូវបានយកមកពិចារណាឱ្យបានហ្មត់ចត់។
✓	រៀបចំកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់តែស្ត្រី សម្រាប់តែបុរស និង កិច្ចប្រជុំពិគ្រោះយោបល់រួមគ្នា ទាំងស្ត្រី និង បុរស ដែលអនុញ្ញាតឱ្យមានការផ្តល់នូវទស្សនៈ និងសេចក្តីត្រូវការផ្សេងៗគ្នា។ ស្ត្រី និងបុរស មកពីគ្រប់ក្រុមសង្គមទាំងអស់ គួរមានតំណាងចូលរួមនៅក្នុងការពិគ្រោះយោបល់ ហើយគេត្រូវពិចារណាចំពោះឧបសគ្គនានាដែលរាំងស្ទះដល់ការចូលរួម។
✓	កំណត់កូតាយេនឌ័រសម្រាប់គណៈកម្មាធិការរៀបចំសេចក្តីព្រាងច្បាប់ ដើម្បីគាំទ្រ ឱ្យមានកំណើននៃការចូលរួមពីស្ត្រី។
✓	អនុម័តទៅលើវិធានការ ដើម្បីធានាថាច្បាប់ និងនិយ័តកម្មនានា មិនអាចអនុម័ត ទៅបានឡើយ ប្រសិនបើពុំមានការពិគ្រោះយោបល់ជាមួយស្ត្រី។
✓	រៀបចំសៀវភៅប្រតិបត្តិការ និងសៀវភៅនីតិវិធីសម្រាប់រដ្ឋបាលដីធ្លី និងការគ្រប់គ្រងដីធ្លី ដែលរៀបរាប់អំពីរបៀបអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។ អនុវត្តសាកល្បងទៅលើនិយ័តកម្មនានា និងកែសម្រួលនិយ័តកម្មទាំងនោះ ដោយផ្អែកលើលទ្ធផលនៃការអនុវត្តន៍សាកល្បង។
✓	នៅពេលកំណត់កូតាសម្រាប់សមាជិកជាស្ត្រី នៅក្នុងគណៈកម្មាធិការ និង

គណៈកម្មការដីធ្លីក្នុងមូលដ្ឋាន មិនត្រូវសន្មតថា ស្ត្រីមែងតែងតែមានឆន្ទៈ និងមានពេលវេលាដើម្បីចូលរួមជាសមាជិកនៅក្នុងយន្តការបែបនេះឡើយ ជាពិសេសគឺនៅតំបន់ជនបទ ដូច្នេះ គេត្រូវគាំទ្រដល់ការចូលរួមរបស់ស្ត្រី តាមរយៈការធានាថាកិច្ចប្រជុំត្រូវបានធ្វើឡើងនៅពេលដែលមានភាពសមស្របសម្រាប់ស្ត្រី។

ចូរចងចាំ!

យុទ្ធសាស្ត្រ និងដំណើរការប្រកបដោយសមធម៌យេនឌ័រ និងមានប្រសិទ្ធភាព សម្រាប់អនុវត្តច្បាប់ភូមិបាល មានសារៈសំខាន់ខ្លាំងណាស់សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ។ ការរៀបចំសេចក្តីព្រាងច្បាប់ និងនិយ័តកម្ម ដែលមានសមធម៌យេនឌ័រ ទាំងនៅក្នុងវិធីសាស្ត្រ និង ជាតុផ្សំរបស់វា នឹងជួយគាំទ្រដល់សកម្មភាពនេះ តាំងពីដំបូង។

អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ និងការអនុវត្តន៍សិទ្ធិចំពោះដីធ្លី

ការបង្កើតឱ្យមាននូវមូលដ្ឋានច្បាប់រឹងមាំមួយ សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ តម្រូវឱ្យមានការយកចិត្តទុកដាក់ចំពោះជាតុផ្សំផ្សេងៗគ្នាដែលពាក់ព័ន្ធក្នុងការបង្កលក្ខណៈឱ្យស្ត្រី និងបុរស អាចសម្រេចបាន និងអនុវត្តសិទ្ធិដីធ្លីរបស់ពួកគេ។ ជាតុផ្សំទាំងនេះ រួមមានការទទួលបានយុត្តិធម៌ យន្តការដោះស្រាយវិវាទ និងកិច្ចគាំទ្រផ្នែកច្បាប់ ព្រមទាំងអក្ខរកម្មផ្នែកច្បាប់ ដូចមានបញ្ជាក់នៅក្នុង តារាង ២.២។ ចំណុចចំនួន៣ដំបូងគេ ត្រូវបានយកមកពិភាក្សានៅក្នុងផ្នែកដទៃទៀតនៃម៉ូឌុលនេះ ខណៈពេលដែលបញ្ហាអក្ខរកម្មផ្នែកច្បាប់ ត្រូវបានយកមកពិភាក្សាស្របគ្នាជាមួយបញ្ហាដែលមានទំនាក់ទំនងគ្នាជិតស្និទ្ធ ដូចជា ការប្រាស្រ័យទាក់ទង និងការលើកកម្ពស់ការយល់ដឹងនៅក្នុង *ម៉ូឌុល៥*។

តារាង ២.២ ៖ ជាតុផ្សំក្នុងការអនុវត្តន៍សិទ្ធិដីធ្លី

ជាតុផ្សំ	និយមន័យ
ការទទួលបានយុត្តិធម៌	លទ្ធភាពក្នុងការបន្តធ្វើការទាមទារដី ជាមួយនឹងឧបាស្រ័យទៅកាន់ប្រព័ន្ធច្បាប់ និង ប្រព័ន្ធយុត្តិធម៌ពាក់ព័ន្ធ ព្រមទាំងយន្តការដោះស្រាយវិវាទតាមបែបប្រពៃណី ឬ តាមផ្លូវច្បាប់។ ស្ថិតក្រោមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ការទទួលបានយុត្តិធម៌ ក៏រាប់បញ្ចូលផងដែរ នូវសិទ្ធិក្នុងការទទួលបានឧបាស្រ័យមួយប្រកបដោយប្រសិទ្ធភាព សម្រាប់បុគ្គលទាំងឡាយណាដែលសិទ្ធិរបស់ពួកគេត្រូវបានបញ្ជាក់ថាទទួលរងការរំលោភបំពាន។
យន្តការដោះស្រាយវិវាទ	ដំណើរការ និងស្ថាប័នផ្លូវច្បាប់ ឬតាមបែបប្រពៃណី ដែលត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយវិវាទដីធ្លី នៅក្នុងប្រព័ន្ធយុត្តិធម៌ជារួម។
កិច្ចគាំទ្រផ្នែកច្បាប់	កិច្ចគាំទ្រជាក់ស្តែងដែលគេត្រូវការ ដើម្បីបន្តធ្វើការទាមទារដីធ្លីសម្រាប់បុគ្គល រួមមានជាអាទិ៍ ព័ត៌មានអំពីនីតិវិធី ជំនួយហិរញ្ញវត្ថុ ឬ ថ្លៃចំណាយពាក់ព័ន្ធ (ជំនួយផ្នែកច្បាប់) និង កិច្ចគាំទ្រប្រកបដោយភាពវិជ្ជាជីវៈពីជំនួយការផ្នែកច្បាប់ ឬ មេធាវី (ជំនួយផ្នែកច្បាប់)។

អន្តរកម្មផ្នែកច្បាប់	ចំណេះដឹងអំពីច្បាប់ និង របៀបអនុវត្តច្បាប់ និងការយល់ដឹងអំពីទំនាក់ទំនងរវាងច្បាប់ និងការអនុវត្តន៍។

ការទទួលបានយុត្តិធម៌

ការទទួលបានយុត្តិធម៌ មានភាពខុសប្លែកពីគ្នានៅក្នុងចំណោមក្រុមប្រជាពលរដ្ឋផ្សេងៗគ្នា នៅក្នុងគ្រប់បរិបទទាំងអស់របស់ប្រទេស។ ឧទាហរណ៍ សេចក្តីត្រូវការឱ្យមានកិច្ចគាំទ្រផ្នែកច្បាប់របស់ស្ត្រីនៅតំបន់ជនបទ នឹងមានភាពខុសប្លែកគ្នាពីសេចក្តីត្រូវការរបស់ស្ត្រីនៅតំបន់ទីក្រុង ហើយសេចក្តីត្រូវការរបស់ស្ត្រី និងបុរសដែលចេះអក្សរមានភាពខុសគ្នា ពីសេចក្តីត្រូវការរបស់ស្ត្រី និងបុរសដែលមិនចេះអក្សរ ហើយសេចក្តីត្រូវការរបស់ស្ត្រីដែលពឹងផ្អែកទៅលើច្បាប់ប្រពៃណី ដើម្បីទទួលបានសិទ្ធិដីធ្លីរបស់ពួកគេ មានភាពខុសគ្នាពីសេចក្តីត្រូវការរបស់ស្ត្រីដែលបានទទួល និង/ឬ បានចុះបញ្ជីដីធ្លីរបស់ពួកគេជាផ្លូវការ ក្រោមឈ្មោះផ្ទាល់ខ្លួនរបស់ពួកគេ (Nakayi, 2010)។ ដូច្នេះ អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ គួរមានការចូលរួមពីអភិក្រមដែលធ្វើការកំណត់គោលដៅដោយប្រុងប្រយ័ត្ន ដើម្បីធ្វើឱ្យលទ្ធភាពទទួលបានយុត្តិធម៌លើបញ្ហាដីធ្លី មានសមធម៌យេនឌ័រ សម្រាប់គ្រប់ក្រុមស្ត្រី និង បុរសទាំងអស់។

បើទោះជាដូច្នេះក្តី នៅក្នុងប្រទេសជាច្រើន ការទទួលបានយុត្តិធម៌ដីធ្លីសម្រាប់ស្ត្រីនៅមានកម្រិត ដោយសារឧបសគ្គផ្នែកវប្បធម៌ សង្គម និងស្ថាប័ន។ ឧបសគ្គទាំងនោះ អាចរួមមាន ថ្លៃសេវាតុលាការ និង ថ្លៃចំណាយពាក់ព័ន្ធមានកម្រិតខ្ពស់ កង្វះចំណេះដឹងអំពីសិទ្ធិដីធ្លី និង ប្រព័ន្ធយុត្តិធម៌ផ្លូវការ រយៈចម្ងាយ របាំងភាសា ភាពជាតំណាងមិនគ្រប់គ្រាន់នៅក្នុងប្រព័ន្ធយុត្តិធម៌ កង្វះទំនុកចិត្ត និងស្វ័យភាពក្នុងការធ្វើសកម្មភាពដោយឯករាជ្យនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ និងនិយាមបទដ្ឋានសង្គមវប្បធម៌ ដែលធ្វើឱ្យស្ត្រីមានការភ័យខ្លាចចំពោះការដាក់ទោស ឬ ការដែលត្រូវបានសហគមន៍មិនរាប់រក ប្រសិនបើពួកគេបន្តធ្វើការទាមទារដីធ្លី។ ជាលទ្ធផល ស្ត្រីជាញឹកញាប់ ហាក់ត្រូវបានបដិសេធចំពោះការទទួលបានយុត្តិធម៌ជាងបុរស ហើយក៏ទំនងនឹងត្រូវបានបដិសេធចំពោះការទទួលបានយុត្តិធម៌ទាំងអស់គ្នាផងដែរ (UN Women, 2011: 54; FAO, 2006a: 154-156; GROOTS Kenya, 2011)។

ស្ថិតក្រោមទិដ្ឋភាពផ្នែកច្បាប់ផ្សេងៗគ្នា ជាពិសេស នៅតំបន់ជនបទនៃប្រទេសកំពុងអភិវឌ្ឍ ដែលអាចពុំមាន ឬគ្មានលទ្ធភាពទទួលបានសេវារបស់ស្ថាប័នរដ្ឋទទួលបន្ទុកការងារយុត្តិធម៌ដីធ្លី ជាញឹកញាប់ ច្បាប់ប្រពៃណី រមែងតែងតែជាមធ្យោបាយបឋមសម្រាប់ដោះស្រាយវិវាទដីធ្លី និង ការពង្រឹងវិជាននៅក្នុងសហគមន៍ (Knight, 2011: 148)។ ស្ត្រីអាចមានភាពងាយស្រួលជាងក្នុងការស្វែងរកអាជ្ញាធរបែបប្រពៃណី បើធៀបទៅនឹងស្ថាប័នយុត្តិធម៌ដែលមានលក្ខណៈផ្លូវការ ប្រសិនបើអាជ្ញាធរបែបប្រពៃណីស្ថិតនៅក្នុងមូលដ្ឋាន និងស្ថិតនៅជិតផ្ទះរបស់ពួកគេជាង។ បើទោះជាដូច្នេះក្តី ច្បាប់ និងអាជ្ញាធរបែបប្រពៃណី និងប្រព័ន្ធយុត្តិធម៌ផ្លូវការ ទំនងនឹងមិនអាចការពារសិទ្ធិស្ត្រីបានឡើយ អាស្រ័យដោយមានភាពលម្អៀងផ្នែកយេនឌ័រ និងមានការគ្រប់ដណ្តប់ពីបុរស។

អង្គការ UN-Women កំណត់និយមន័យទៅលើខ្សែសង្វាក់យុត្តិធម៌ ថាជា "កម្រងនៃជំហាននានាដែលត្រូវអនុវត្តដើម្បីទទួលបានយុត្តិធម៌" (UN-Women, 2011: 48)។ ខ្សែសង្វាក់យុត្តិធម៌មួយដែលមានការទទួល

ខុសត្រូវចំពោះយេនឌ័រ (UN-Women, 2011: 56-57 and 63) ត្រូវការឱ្យមាននូវ ៖

- អាណត្តិការងារ និងនីតិវិធីច្បាស់លាស់ រាប់បញ្ចូលពិធីសារដែលមានបទដ្ឋានត្រឹមត្រូវ និយ័តកម្ម សម្រាប់អនុវត្តច្បាប់ និងការសម្របសម្រួល ក្នុងចំណោមផ្នែកផ្សេងៗគ្នានៃប្រព័ន្ធយុត្តិធម៌ ដើម្បីធានាថា សេវាសាធារណៈផ្តល់ការឆ្លើយតបចំពោះស្ត្រី - ត្រូវមានមូលនិធិគាំទ្រគ្រប់គ្រាន់ ប្រកបដោយនិរន្តរភាព និងមានវិធានការសម្រាប់ត្រួតពិនិត្យការអនុវត្តន៍។

- កញ្ចប់សេវាឯកទេស ដើម្បីជួយដល់ស្ត្រីក្នុងការជំនះទៅលើឧបសគ្គផ្នែកស្ថាប័ន និង សង្គម ចំពោះបញ្ហាយុត្តិធម៌ដីធ្លីដែលពួកគេជួបប្រទះ។ អភិក្រមមួយដែលទំនងនឹងទទួលបានជោគជ័យ គឺជាការធ្វើសមាហរណកម្មសេវាកម្ម ដូចជា នៅឯការិយាល័យច្រកចេញចូលតែមួយសម្រាប់ បញ្ហាដីធ្លី ដែលគ្រប់សេវាកម្មដីធ្លីទាំងអស់ ស្ថិតនៅក្រោមដំបូលការិយាល័យតែមួយ ដែលអភិក្រមបែបនេះ ជួយកាត់បន្ថយចំនួននៃជំហានដែលគេត្រូវការ ដើម្បីទទួលបានយុត្តិធម៌។ វាអាចមានសារៈប្រយោជន៍ផងដែរ ក្នុងការដែលមានស្ត្រីធ្វើការងារនៅផ្នែកជួរមុខនៃការិយាល័យដីធ្លីនេះ អាស្រ័យដោយពួកគេ ប្រហែល ជាមានភាពងាយស្រួលទំនាក់ទំនងជាង សម្រាប់អតិថិជនជាស្ត្រី ដែលចំណុចនេះ មានពិភាក្សាផងដែរ នៅក្នុង *ម៉ូឌុល៤*។

- គាំទ្រឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យយុត្តិធម៌ ដើម្បីបង្កើនភាពជាតំណាងដែលមានតុល្យភាព យេនឌ័រនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃអភិបាលកិច្ច និង ដើម្បីលើកកម្ពស់ទំនុកចិត្ត សាធារណៈ នៅក្នុងប្រព័ន្ធយុត្តិធម៌ជារួម។

- ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាល ដើម្បីធ្វើឱ្យចៅក្រមដឹងអំពីឧបសគ្គដែលស្ត្រីជួបប្រទះ ក្នុងការ ទទួលបានយុត្តិធម៌ដីធ្លី ដែលនាំឱ្យមានការផ្លាស់ប្តូរឥរិយាបថ។ គេអាចអនុវត្តដំណោះស្រាយបែប សាមញ្ញ ប៉ុន្តែមានប្រសិទ្ធភាព ដូចជា ការឈប់យកថ្លៃសេវាតុលាការ ការផ្តល់ទម្រង់ដោយឥតគិតថ្លៃ ឬ ការផ្តោតអាទិភាពទៅលើករណីដែលមានភាពរសើប។

✎បញ្ជីផ្ទៀងផ្ទាត់ ២.៤ ៖ **ការបង្កើនសមធម៌យេនឌ័រក្នុងការទទួលបានយុត្តិធម៌លើបញ្ហាដីធ្លី** *ប្រភព ៖* Nakayi, 2010; UN Women, 2011.	✓ ផ្តល់ព័ត៌មាន និងការបណ្តុះបណ្តាលឱ្យចំគោលដៅសម្រាប់ស្ត្រី និងបុរសអំពីការ ទទួលបានយុត្តិធម៌ដីធ្លី។
	✓ ដោះស្រាយបុព្វហេតុឫសគល់ផ្នែកសង្គម និងស្ថាប័ន ដែលបណ្តាលឱ្យបាត់បង់លទ្ធភាពក្នុងការទទួលបានយុត្តិធម៌ដីធ្លី ដូចជា កត្តាវប្បធម៌ ភាពក្រីក្រ អនក្ខរភាព និងរយៈចម្ងាយ។
	✓ គាំទ្រចំពោះការកើនឡើងនៃភាពជាតំណាង និងការចូលរួមរបស់ស្ត្រី នៅក្នុងរដ្ឋបាល ដីធ្លី និងស្ថាប័នគ្រប់គ្រង ជាពិសេស នៅក្នុងយន្តការដោះស្រាយវិវាទដីធ្លី។
	✓ ទទួលស្គាល់អំពីតួនាទីរបស់ច្បាប់ និងអាជ្ញាធរបែបប្រពៃណី នៅក្នុងដំណើរការដោះស្រាយវិវាទដីធ្លី និងការបំពេញមុខងាររបស់ពួកគេ។ គាំទ្រដល់អាជ្ញាធរបែបប្រពៃណី ក្នុងការប្រែក្លាយទៅជាកាន់តែមានសមធម៌យេនឌ័រ និង កំណត់រកមូលហេតុ ថាហេតុអ្វីបានជាមានវត្តមាននៃការអនុវត្តន៍បែបប្រពៃណី និង របៀបដែលការអនុវត្តន៍បែបនេះ អាចជួយគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។
	✓ លើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរច្បាប់ប្រពៃណី ក្នុងលក្ខណៈមួយដែលស្របទៅនឹង ប្រយោជន៍របស់អ្នកមានអំណាច ដើម្បីកាត់បន្ថយការប៉ុនប៉ងណាមួយរបស់ពួកគេ ក្នុងការរំលោភអំណាច និងបង្កើតឱ្យមាននូវឧបសគ្គថ្មីៗដែលរាំងស្ទះចំពោះលទ្ធភាព ក្នុងការទទួលបានយុត្តិធម៌ដីធ្លី។ ជាពិសេស នៅពេលធ្វើការងារ ឬ ធ្វើការតស៊ូមតិជាមួយបុរស ដែលធ្វើការងារនៅក្នុងវិស័យយុត្តិធម៌ គេត្រូវជ្រើសរើសប្រើប្រាស់យុទ្ធសាស្ត្រសន្ទនា ជាជាងការប្រឈមមុខដាក់គ្នា។
	ចូរចងចាំ! ឧបសគ្គដែលរាំងស្ទះចំពោះលទ្ធភាពក្នុងការទទួលបានយុត្តិធម៌ដីធ្លី នាំឱ្យប៉ះពាល់ដល់គ្រប់ក្រុមប្រជាពលរដ្ឋងាយរងគ្រោះទាំងអស់ បើទោះបីជាស្ត្រីទំនងនឹងទទួលរងផលប៉ះពាល់អវិជ្ជមានជាពិសេសក៏ដោយ។ អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ ទាមទារឱ្យមានការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី និងបុរសគ្រប់រូប គ្រប់ស្រទាប់វណ្ណៈ សាសនា ជាតិពន្ធុ និងអាយុ ដើម្បីបង្កលក្ខណៈឱ្យពួកគេអាចសម្រេចបាន និង អនុវត្តសិទ្ធិដីធ្លីរបស់ពួកគេ។

ការដោះស្រាយវិវាទដីធ្លី

ការគាំទ្រឱ្យមានការកើនឡើងនូវភាពជាតំណាង និងការចូលរួមរបស់ស្ត្រី នៅក្នុងយន្តការដោះស្រាយវិវាទដីធ្លីបែបផ្លូវការ និង តាមផ្លូវច្បាប់ គឺជាមធ្យោបាយមួយដែលគេបានទទួលស្គាល់ ថាអាចធ្វើឱ្យប្រសើរឡើងនូវឧបាស្រ័យរបស់ស្ត្រីចំពោះដំណោះស្រាយ និងយុត្តិធម៌លើវិវាទដីធ្លី (World Bank/FAO/IFAD, 2009a: 24)។ ប្រអប់ ២.៨ បង្ហាញអំពីចំណុចនេះ ដោយសំដៅយោងចំពោះករណីប្រទេសរ៉ាវ៉ាន់ដា ដែលការកើនឡើងនូវការ

ចូលរួមរបស់ស្ត្រី នៅក្នុងគណៈកម្មាធិការដោះស្រាយវិវាទក្នុងមូលដ្ឋាន បានធ្វើឱ្យលទ្ធផលការងារដែលមានសមធម៌យេនឌ័រ កាន់តែទំនងនឹងអាចសម្រេចបាន។

ប្រអប់ ២.៨ ៖
ការដោះស្រាយវិវាទដីធ្លីប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ RWN, 2011; Daley, Dore-Weeks and Umuhoza, 2010; International Justice Mission, no date.

បណ្ដាញស្ត្រីរ៉ាវ៉ាន់ដា (RWN) បានអនុវត្តធ្វើការសិក្សាមួយនៅក្នុងស្រុកប៊ូហ្គេសេរ៉ា ដែលទទួលបានមូលនិធិគាំទ្រពីសម្ព័ន្ធភាពដីធ្លីអន្តរជាតិ ដើម្បីធ្វើការប៉ាន់ប្រមាណទៅលើបទពិសោធន៍របស់ស្ត្រី ក្នុងការអនុវត្តន៍ច្បាប់នានា ដែលការពារសិទ្ធិដីធ្លីរបស់ពួកគេ។ ការសិក្សានេះ បានរៀបរាប់អំពីសារៈសំខាន់របស់អាប៊ុនហ្ស៊ី (អ្នកសម្រុះសម្រួលក្នុងមូលដ្ឋាន) ក្នុងការការពារសិទ្ធិដីធ្លីរបស់ស្ត្រី ជាពិសេស នៅក្នុងវិវាទដែលទាក់ទងទៅនឹងការស្នងមរតក និងវិវាទដទៃទៀតនៅក្នុងគ្រួសារ ដែលជាទម្រង់នៃវិវាទទូទៅបំផុតដែលមានការពាក់ព័ន្ធជាមួយស្ត្រី។ ការសិក្សានេះ បានរកឃើញថា ស្ត្រីភាគច្រើនបានជ្រើសរើសធ្វើសេចក្ដីរាយការណ៍អំពីវិវាទរបស់ពួកគេ ទៅកាន់អាជ្ញាធរមូលដ្ឋានដោយឡែក ស្ត្រីមួយចំនួនបានទៅជួបអ្នកសម្រុះសម្រួលក្នុងមូលដ្ឋានដោយផ្ទាល់តែម្ដង។ មានតែស្ត្រីមួយចំនួនតូចប៉ុណ្ណោះ ដែលបានរាយការណ៍អំពីវិវាទរបស់ពួកគេជូនដល់ក្រុមប្រឹក្សាគ្រួសារ ដែលត្រូវបានចាត់ទុកថាមិនសូវមានភាពគួរឱ្យជឿជាក់បានដូចអាជ្ញាធរមូលដ្ឋាន ឬ អ្នកសម្រុះសម្រួល។ យ៉ាងហោចណាស់ ត្រូវមានសមាជិកអាជ្ញាធរមូលដ្ឋាន និងអ្នកសម្រុះសម្រួលក្នុងមូលដ្ឋាន ចំនួន ៣០% ជាស្ត្រីដូច្នេះហើយ ទើបស្ត្រីដែលមានករណីដីធ្លីត្រូវរាយការណ៍ ទំនងនឹងមានការទុកចិត្តទៅលើពួកគេ។

ការសិក្សានេះ បានគូសបញ្ជាក់អំពីសារៈសំខាន់នៃដំណើរការ និងស្ថាប័នដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការថ្នាក់មូលដ្ឋាន ជាពិសេស នៅតាមបណ្ដាប្រទេសមួយចំនួនដូចជា ប្រទេសរ៉ាវ៉ាន់ដា ដែលបានទទួលរងគ្រោះពីជម្លោះដ៏ធ្ងន់ធ្ងរ ដែលស្ថាប័នបែបប្រពៃណីដែលមានស្រាប់ អាចមិនត្រូវបានគេទុកចិត្តថាមានភាពអព្យាក្រឹត្យ។ អ្នកសម្រុះសម្រួលក្នុងមូលដ្ឋានខ្លួនឯងផ្ទាល់ បានអំពាវនាវស្វែងរក ៖

- ការលើកទឹកចិត្ត ឱ្យមាននីតិរដ្ឋ និងការបណ្ដុះបណ្ដាលទៀងទាត់អំពីច្បាប់ភូមិបាល សម្រាប់គណៈកម្មាធិការដោះស្រាយវិវាទក្នុងមូលដ្ឋាន
- ការផ្សព្វផ្សាយអំពីយេនឌ័រ និង ការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ភូមិបាល សម្រាប់ប្រជាពលរដ្ឋទាំងមូលឱ្យបានកាន់តែទូលំទូលាយ រាប់បញ្ចូលការបណ្ដុះបណ្ដាលពិសេស អំពីបញ្ហាយេនឌ័រសម្រាប់បុរសដែលរក្សាជំនឿ និង គុណតម្លៃបែបរើសអើង - អ្នកផ្ដល់ចម្លើយជាបុរសម្នាក់នៅក្នុងការស្រាវជ្រាវ បានគូសបញ្ជាក់ឱ្យដឹងថា "ក្នុងនាមជាបុរស យើងក៏គួរផ្ដល់តម្លៃចំពោះស្ត្រី ដូចដែលយើងផ្ដល់តម្លៃចំពោះខ្លួនឯងផងដែរ"។

កម្មវិធីបណ្ដុះបណ្ដាលអ្នកសម្រុះសម្រួលក្នុងមូលដ្ឋាន ត្រូវបានអនុវត្តដោយរដ្ឋាភិបាល និងសង្គមស៊ីវិល រាប់បញ្ចូលការអនុវត្តន៍ដោយអង្គការមិនមែនរដ្ឋាភិបាលបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងយុត្តិធម៌។ មេធាវី

ដែលធ្វើការងារជាមួយ IJM ផ្តល់នូវកិច្ចគាំទ្រជាក់ស្តែងផ្នែកច្បាប់ ជូនដល់ជនរងគ្រោះពីការដកហូតយកទ្រព្យសម្បត្តិដោយខុសច្បាប់ ជាពិសេសស្ត្រីមេម៉ាយ និងកុមារកំព្រា ដើម្បីជួយឱ្យពួកគេទទួលបានដំណោះស្រាយតាមផ្លូវច្បាប់ នៅក្នុងប្រទេសហ្សំបៀ យូហ្គាន់ដា កេនយ៉ា និង រ៉ាវ៉ាន់ដា ព្រមទាំងធ្វើការងារនៅក្នុងប្រទេសទាំងបួន ដើម្បីផ្សព្វផ្សាយជូនដល់មេដឹកនាំ និងសមាជិកគណៈកម្មាធិការដោះស្រាយវិវាទក្នុងមូលដ្ឋាន ទាំងស្ត្រី និងបុរស អំពីបញ្ហាពាក់ព័ន្ធ។

នៅក្នុងប្រទេសគីហ្គីស្ថាន ចាប់ពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០១០ កម្មវិធីដីធ្លីក្នុងដៃរបស់បុគ្គលដែលត្រឹមត្រូវរបស់ UN Women បានជួយអភិវឌ្ឍចំណេះដឹង និងសមត្ថភាពរបស់តួអង្គសំខាន់ៗនៅក្នុងវិស័យយុត្តិធម៌ ក្នុងការអនុវត្តអភិក្រមមួយដែលមានមូលដ្ឋានផ្អែកលើសិទ្ធិ ចំពោះបញ្ហាសមធម៌យេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។ គេបានផ្តោតការយកចិត្តទុកដាក់ជាក់លាក់ ទៅលើការពង្រឹងភាពជាដៃគូរវាងការិយាល័យ និងជំនាញការផ្នែកច្បាប់ ដែលមកពីនាយកដ្ឋានសុរិយោដី និង ការចុះបញ្ជីអចលនទ្រព្យដែលនាំឱ្យមានការដោះស្រាយវិវាទភ្លាមៗនៅក្នុងតុលាការ និងការទាមទារមកវិញនូវសិទ្ធិស្របច្បាប់របស់ស្ត្រីក្នុងការទទួលបានចំណែកដីធ្លី និង ការកាន់កាប់ឯកសារប្លង់ដី (Djusaeva, 2012)។

មូលហេតុមួយដែលស្ត្រីមានការលំបាកជាពិសេស ក្នុងការធានាឱ្យមានការទទួលស្គាល់ចំពោះការទាមទារដីធ្លីរបស់ពួកគេ គឺត្រង់ថាពួកគេរមែងតែងមានអំណាច និង សិទ្ធិតិចតួចក្នុងការចាត់វិធានការជាសាធារណៈ។ វិវាទដីធ្លីដែលពាក់ព័ន្ធទៅនឹងការទាមទារពីស្ត្រី រមែងតែងត្រូវបានចាត់ទុកថាជាបញ្ហាឯកជននៅក្នុងគ្រួសារ ដែលតម្រូវឱ្យមានការដំណោះស្រាយនៅត្រឹមកម្រិតនោះ។ ស្ត្រី ជាពិសេស ស្ត្រីនៅតំបន់ជនបទ រមែងតែងមើលឃើញថាពុំមានប្រព័ន្ធកាន់កាប់បែបផ្លូវការ ឬ បែបប្រពៃណីណាមួយទទួលស្គាល់សិទ្ធិដីធ្លីរបស់ពួកគេឡើយ (FAO, 2006b: 48)។

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាដំណោះស្រាយមួយដែលកាន់តែមានប្រជាប្រិយភាពឡើងជាលំដាប់។ ជម្រើសដោយឡែកក្រៅពីនេះ រួមមានជាអាទិ៍ ការពិចារណាទៅលើអ្នកសម្រុះសម្រួលនៅក្នុងតុលាការ ដើម្បីជួយដល់អ្នកដែលបានដាក់ពាក្យបណ្តឹងទៅតុលាការ ក្នុងការដោះស្រាយវិវាទរបស់ពួកគេ ដោយមិនចាំបាច់ត្រូវរង់ចាំដំណើរការតុលាការ (Magezi, 2010)។

ប្រអប់ ២.៩ ៖
ការធ្វើការងារជាមួយស្ថាប័នបែបប្រពៃណីក្នុងការដោះស្រាយវិវាទដីធ្លី

ប្រភព ៖
Harrington and Choprab, 2010: 20; Carfield, 2011; ULA, 2010;

នៅក្នុងប្រទេសជាច្រើន អាជ្ញាធរ និងស្ថាប័នបែបប្រពៃណី នៅតែមានការទទួលខុសត្រូវភាគច្រើនទៅលើដំណោះស្រាយវិវាទដីធ្លីក្នុងមូលដ្ឋាន។ យន្តការដោះស្រាយវិវាទបែបប្រពៃណី អាចមានភាពឆាប់រហ័សជាង និងងាយទទួលបានជាង ព្រមទាំងមានធម្មានុរូបផ្អែកសង្គមជាងយន្តការដោះស្រាយវិវាទតាមផ្លូវច្បាប់ ប៉ុន្តែ យន្តការបែបនេះ រមែងតែងមានការគ្របដណ្តប់ពីបុរស និងមានភាពលម្អៀងផ្នែកយេនឌ័រ។ ការកែទម្រង់ទៅលើយន្តការបែបនេះ ដើម្បីធានាឱ្យមានសមធម៌យេនឌ័រ អាចបង្កលក្ខណៈឱ្យយន្តការមានដំណើរការប្រព្រឹត្តទៅកាន់តែមានប្រសិទ្ធភាព ហើយស្របពេលជាមួយគ្នានោះ ក៏អាចរក្សាបានផងដែរនូវគុណប្រយោជន៍ប្រៀបធៀបរបស់វា (FAO, 2006a: 158 and 166)។

បញ្ហាប្រឈម គឺជាការដែលត្រូវធ្វើការងារជាមួយស្ថាប័នបែបប្រពៃណី ដើម្បីគាំទ្រ

Ahikire, 2010.

ដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ ហើយស្របពេលជាមួយគ្នានោះ ត្រូវក្តាប់យកឱកាសពីដំណើរការវិមជ្ឈការ នៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ដើម្បីធ្វើឱ្យស្ត្រី និងបុរសនៅជនបទ អាចមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានយន្តការដោះស្រាយវិវាទតាមផ្លូវច្បាប់ជាផ្លូវការ។ ប្រអប់ ២.៩ ផ្តល់នូវឧទាហរណ៍នៃការអនុវត្តន៍ល្អមួយចំនួន អំពីការធ្វើការងារជាមួយស្ថាប័នបែបប្រពៃណីនៅក្នុងការដោះស្រាយវិវាទដីធ្លី។ *ម៉ូឌុល៣* បង្ហាញអំពីបញ្ហានៃការធ្វើការងារជាមួយស្ថាប័នបែបប្រពៃណីដែលមានលក្ខណៈកាន់តែទូលំទូលាយ។

នៅក្នុង*ប្រទេសកេនយ៉ា* ក្នុងចំណោមសហគមន៍នានា នៅក្នុងខេត្តនីអានហ្សា ញាតិសាច់ថ្លៃ រមែងតែងរឹបអូសដីធ្លីពីស្ត្រីមេម៉ាយ និងធ្វើឱ្យពួកគេធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ ខណៈពេលដែលព្រឹទ្ធាចារ្យនៅក្នុងសហគមន៍ បានពោលអះអាងប្រកបដោយមោទនភាពថា វប្បធម៌របស់ពួកគេការពារស្ត្រី។ កម្មវិធីគណៈកម្មការជាតិសិទ្ធិមនុស្សមួយរបស់ប្រទេសកេនយ៉ា បានផ្តល់ឱកាសសម្រាប់ស្ត្រីមេម៉ាយក្នុងការប្រាប់ទៅកាន់ព្រឹទ្ធាចារ្យទាំងនោះ អំពីរឿងរ៉ាវនៃការដែលពួកគេត្រូវបានបណ្តេញចេញពីដីរបស់ពួកគេ។ ព្រឹទ្ធាចារ្យដែលស្ថិតនៅចន្លោះស្ថានភាពដែលពួកគេត្រូវធានាសន្តិសុខសិទ្ធិដីធ្លីរបស់ខ្សែស្រឡាយបុរស ព្រមទាំងកិច្ចការពារស្ត្រី ត្រូវអភិវឌ្ឍមធ្យោបាយប្រកបដោយភាពច្នៃប្រឌិត ដើម្បីដោះស្រាយស្ថានភាពបែបនេះ។ នៅក្នុងករណីជាច្រើន ពួកគេបានចាប់ផ្តើមការពារស្ត្រីមេម៉ាយ និងធានាថាស្ត្រីមេម៉ាយទទួលបានប្រយោជន៍មួយនៅក្នុងជីវិតរស់នៅរបស់ពួកគេ នៅលើដីរបស់ស្វាមីពួកគេដែលបានស្លាប់ទៅ។ ចំណុចនេះ គឺសម្រាប់កិច្ចការពារផ្ទាល់ខ្លួនរបស់ស្ត្រីមេម៉ាយ ប៉ុន្តែ ក៏ដើម្បីធានាផងដែរ កូនប្រុសរបស់ពួកគេនឹងទទួលបានចំណែកណាមួយនៅពេលក្រោយ ដូចមានគូសបញ្ជាក់នៅក្នុងការអនុវត្តន៍ស្នងមរតករបស់ខ្សែស្រឡាយបុរស។

នៅក្នុងភាគខាងជើង និង ភាគខាងកើតនៃប្រទេសយូហ្គាន់ដា ដែលទទួលរងគ្រោះធ្ងន់ធ្ងរពីសង្គ្រាម ប្រជាពលរដ្ឋដែលត្រូវបានជម្លៀសនៅក្នុងប្រទេស បានចាប់ផ្តើមវិលត្រឡប់មកផ្ទះ និងទាមទារដីបុព្វបុរសរបស់ពួកគេមកវិញ។ សកម្មភាពនេះ បានបង្កឱ្យមានជម្លោះជាច្រើនទៅលើការប្រជែងទាមទារ និងការទន្ទ្រានរបស់អ្នកជិតខាង និងគ្រួសារដែលទង្វើបែបនេះ មានការរុញច្រានពីការកើនឡើងនៃភាពខ្សត់ដី។ ក្នុងឆ្នាំ២០០៩ សម្ព័ន្ធភាពដីធ្លីនៃប្រទេសយូហ្គាន់ដា បានដាក់ឱ្យដំណើរការនូវគម្រោងសាកល្បងមួយ ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌ដីធ្លី តាមរយៈការផ្តល់អំណាចដល់អាជ្ញាធរបែបប្រពៃណី និង ការធ្វើសមាហរណកម្មវិស័យយុត្តិធម៌បែបប្រពៃណី និងវិស័យយុត្តិធម៌ផ្លូវការ។ ការប៉ាន់ប្រមាណគម្រោងមួយក្នុងឆ្នាំ២០១០ បានរកឃើញថា នៅពេលដែលពួកគេមានវិវាទដីធ្លី ស្ត្រី និងប្រជាពលរដ្ឋក្រីក្រ ជាទូទៅ តែងទៅជួបមេដឹកនាំ

វិវាទដីធ្លីក៏អាចដោះស្រាយបានផងដែរ នៅក្នុងដំណើរការនីតិវិធីនៃស្ថាប័នយុត្តិធម៌របស់រដ្ឋាភិបាល ដូចជាអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនៃប្រទេសយូហ្គាន់ដា ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងបែងចែកទ្រព្យសម្បត្តិរបស់បុគ្គលដែលបានទទួលមរណភាពក្នុងស្ថានភាពមួយចំនួនផ្សេងៗគ្នា រាប់បញ្ចូល ទាំងករណីដែលការដែលពួកគេបានស្លាប់ដោយពុំមានធ្វើបណ្តាំមរតក (Namutebi, 2010)។ ស្ថាប័នបែបនេះ អាចមានសារៈសំខាន់នៅពេលដែលច្បាប់ស្តីពីការស្នងមរតកជាធរមាន មានភាពរើសអើង និងមិនទាន់មានច្បាប់ថ្មីនៅឡើយ។ កិច្ចខិតខំរបស់អគ្គនាយកដ្ឋានរដ្ឋបាលនៃប្រទេសយូហ្គាន់ដា ក្នុងការធានាឱ្យមានការចូលរួមរបស់ស្ត្រី ជាពិសេសស្ត្រីមេម៉ាយ បានជួយធានាឱ្យមានលទ្ធផលការងារកាន់តែប្រកបដោយសមធម៌យេនឌ័រ ក្នុងការលើកកម្ពស់ការបែងចែកទ្រព្យសម្បត្តិ ជូនដល់ស្ត្រី ដោយជៀសវាងចំណាត់ការរបស់តុលាការ (Namutebi, 2010; Ssonko, 2010)។

បែបប្រពៃណីមុនគេ។ ដូច្នេះ គម្រោងបានធ្វើការងារដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌បែបប្រពៃណីដែលមានស្រាប់ តាមរយៈការអភិវឌ្ឍន៍សមត្ថភាពបច្ចេកទេស របស់អាជ្ញាធរបែបប្រពៃណី ដើម្បីដោះស្រាយបញ្ហារំលោភបំពានសិទ្ធិដីធ្លី។ សកម្មភាពនេះ ពាក់ព័ន្ធទៅនឹងការបណ្តុះបណ្តាលសម្រាប់អាជ្ញាធរបែបប្រពៃណី និង ការផ្សព្វផ្សាយជូនដល់សហគមន៍។ មជ្ឈមណ្ឌលសិទ្ធិដីធ្លី ត្រូវបានបង្កើតឡើងដើម្បីបណ្តុះបណ្តាលជំនួយការផ្នែកច្បាប់ និង បង្កើតឱ្យមានប្រព័ន្ធថ្មីមួយសម្រាប់សម្រុះសម្រួលវិវាទដីធ្លី ដែលជំនួយការផ្នែកច្បាប់ធ្វើការងារជាមួយមេដឹកនាំនយោបាយក្នុងមូលដ្ឋាន និងអាជ្ញាធរប្រពៃណី ដើម្បីអនុវត្តអភិក្រមយុត្តិធម៌បែបប្រពៃណី ដែលស្វែងរកឱ្យមានការយល់គ្នាទៅវិញទៅមក ជាជាងអភិក្រម "ល្បែងកំសាន្តលេខសូន្យ" របស់តុលាការ។
នៅក្នុង*ប្រទេសយូហ្គាន់ដា* មានភស្តុតាងដែលបង្ហាញអំពីស្ត្រីប្រើប្រាស់តុលាការបែបប្រពៃណី និងតុលាការរបស់គណៈកម្មាធិការក្នុងមូលដ្ឋាន (LC) បើទោះបីជាស្ត្រីភាគច្រើន បញ្ចប់ត្រឹមតុលាការកម្រិតទាប (បក្សសម្ព័ន្ធ , តុលាការ LC1, និងតុលាការ LC2) ហើយមានតែអ្នកដែលមានលទ្ធភាពប៉ុណ្ណោះ ទើបបន្តទៅតុលាការ LC3 និងតុលាការអង្គចៅក្រម ឬ ក្រុមប្រឹក្សាភិបាលដីធ្លីថ្នាក់ស្រុក។ តុលាការ LC បង្ហាញលក្ខណៈងាយស្រួលសម្រាប់ប្រជាពលរដ្ឋក្នុងការទទួលបានសេវា មិនទាមទារឱ្យមានតំណាងពីមេធាវី ប្រើប្រាស់ភាសាដែលប្រជាពលរដ្ឋងាយយល់ និងទទួលយកទម្រង់ភស្តុតាងជាច្រើនផ្សេងៗគ្នា។ បើទោះជាដូច្នេះក្តី លើកលែងតែតុលាការ LC3 តុលាការដទៃទៀត ពុំមែងតែងត្រូវបានគេមើលឃើញថាមានភាពអព្យាក្រឹត្យឡើយ ហើយពួកគេអាចមាន "ទំនាក់ទំនងជិតស្និទ្ធពេក" ទៅនឹងអ្នកប្រើប្រាស់សេវារបស់ពួកគេ។ យ៉ាងណាមិញ សាលក្រមដែលចេញពីតុលាការ LC ដែលមានមូលដ្ឋានរួមបញ្ចូលគ្នានូវចំណេះដឹង ច្បាប់គតិយុត្តិផ្លូវការ ទំនៀមទម្លាប់ និងនិយាមបទដ្ឋាន មានសក្តានុពលក្នុងការបង្កើតឡើងវិញ និងចងក្រងឯកសារអំពីនិយាមបទដ្ឋាន និង ការអនុវត្តន៍បែបប្រពៃណី ប្រកបដោយភាពវិជ្ជមាន ដើម្បីគាំទ្រដល់សមធម៌យេនឌ័រ។

កិច្ចគាំទ្រផ្នែកច្បាប់

កិច្ចខិតខំដើម្បីបង្កើនសមធម៌យេនឌ័រ ក្នុងការទទួលបានយុត្តិធម៌ដីធ្លី គួរពិចារណាទៅលើគ្រប់យន្តការដោះស្រាយវិវាទ និង ប្រព័ន្ធយុត្តិធម៌ទាំងអស់ដែលមាន និង គួរសម្របសម្រួលលទ្ធភាពរបស់ស្ត្រី និង បុរស ក្នុងការទទួលបានយុត្តិធម៌ និងប្រព័ន្ធដែលមានភាពសមស្របបំផុត ចំពោះសេចក្តីត្រូវការរបស់ពួកគេ។ កិច្ចគាំទ្រគួរ

ប្រអប់ ២.១០ ៖
កិច្ចគាំទ្រផ្នែកច្បាប់សម្រាប់ម្ចាស់កម្មសិទ្ធិដីធ្លីបែបប្រពៃណី

ចាប់ផ្តើមតាមរយៈអន្តរាគមន៍នៅកម្រិតកំពូល ដើម្បីជានាថារដ្ឋាភិបាលបង្កើតឱ្យមាននូវវិធានការពាក់ព័ន្ធ រាប់បញ្ចូលជំនួយផ្នែកច្បាប់ និង ការផ្តល់ជំនួយតាមផ្លូវច្បាប់ជាក់ស្តែងដទៃទៀត។ នៅក្នុងប្រទេស តាជីគីស្ថាន លទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាច្បាប់ដោយឥតគិតថ្លៃ បានមានភាពប្រសើរឡើង តាមរយៈការបង្កើតឱ្យមាននូវក្រុមការងារថ្នាក់ស្រុក ដែលមានបុគ្គលិកពីគណៈកម្មាធិការស្ត្រី និង មេធាវីដែលគេបានជួល (Undeland, 2012)។ ប្រអប់ ២.១០ រៀបរាប់អំពីការអនុវត្តន៍ល្អប្រកបដោយសក្តានុពលដទៃទៀត ពីប្រទេសសាម៉ោ។

ប្រភព ៖ Josephine Stowers-Fiu's presentation on "Capacity building and gender equity in land administration institutions in Samoa" at the May 2011 technical workshop.

នៅក្នុងប្រទេសមួយចំនួន ជំនួយផ្នែកច្បាប់ មិនគ្របដណ្តប់ទៅលើករណីដែលទាក់ទងទៅនឹងដីធ្លី ការស្នងមរតក និងច្បាប់ស្តីពីគ្រួសារឡើយ។ បន្ថែមពីនេះទៀត ពុំមែនគ្រប់គម្រោងជំនួយផ្នែកច្បាប់ទាំងអស់ សុទ្ធសឹងតែពិចារណាទៅលើបញ្ហាយេនឌ័រឡើយ។ ករណីលើកលែង រួមមានប្រទេសឥណ្ឌា ដែលស្ត្រីត្រូវបានកំណត់ជាក់លាក់ថា ជាអ្នកទទួលផលនៅក្នុងច្បាប់ ស្តីពីអាជ្ញាធរសេវាផ្នែកច្បាប់ ឆ្នាំ១៩៩២ និងប្រទេសហ្គាណា ដែលច្បាប់ស្តីពីគម្រោងជំនួយផ្នែកច្បាប់ មិនត្រឹមតែគ្របដណ្តប់ទៅលើបញ្ហាព្រហ្មទណ្ឌប៉ុណ្ណោះទេ ប៉ុន្តែក៏គ្របដណ្តប់ផងដែរ ទៅលើបញ្ហារដ្ឋប្បវេណី ដែលពាក់ព័ន្ធទៅនឹងសិទ្ធិស្នងមរតក (FAO, 2006a: 160)។

វាគឺជាការអនុវត្តន៍ល្អ សម្រាប់គម្រោងរដ្ឋបាលដីធ្លី ក្នុងការត្រួតពិនិត្យឡើងវិញ ទៅលើនីតិវិធីរបស់គម្រោងទាំងនោះ សម្រាប់ការដោះស្រាយវិវាទដីធ្លី និងកិច្ចគាំទ្រផ្នែកច្បាប់ ដើម្បីជានាថា ទាំងបុរស និងស្ត្រីមានលទ្ធភាពទទួលបានសេវាពាក់ព័ន្ធ និង ទទួលបាននូវការប្រព្រឹត្តប្រកបដោយសមធម៌។ សកម្មភាពនេះ អាចទាមទារឱ្យមានវិធានការពិសេស ដើម្បីសម្របសម្រួលលទ្ធភាពរបស់ស្ត្រីក្នុង ការជួបជាមួយមន្ត្រីគម្រោង និង ការិយាល័យរដ្ឋាភិបាល ដូចជាតាមរយៈការនាំយកយន្តការដោះស្រាយវិវាទដីធ្លីទៅថ្នាក់មូលដ្ឋាន ឬ ការផ្តល់កិច្ចគាំទ្រផ្នែកច្បាប់ តាមរយៈគម្រោងនេះ ដូចដែលករណីនៅប្រទេសគីហ្គីស្ថាន ដូចមានរៀបរាប់នៅក្នុងប្រអប់ ២.១១ បានអនុវត្ត។

នៅក្នុង*ប្រទេសសាម៉ោ* ដីជាង ៨០% ស្ថិតក្រោមការរៀបចំកាន់កាប់បែបប្រពៃណី ដែលផ្តល់សិទ្ធិស្មើភាពគ្នាចំពោះការត្រួតត្រា និងគ្រប់គ្រងទៅលើដីប្រពៃណីសម្រាប់ស្ត្រី និងបុរស ក្រោមសន្តតិកម្មសម្រាប់ស្ត្រី និងបុរស និង ការជួលបែបមិនផ្លូវការ។ បើទោះជាដូច្នេះក្តី ភាពជាម្ចាស់ និងសិទ្ធិអំណាចលើដីធ្លី ទំបំផុតស្ថិតនៅលើសាខាញាតិ ដែលតំណាងដោយអ្នកថែទាំ/អ្នកតំណាង ហៅថា Matai ដែលត្រូវបានជ្រើសរើសក្រោមការឯកភាពពីគ្រួសារ ដើម្បីឱ្យត្រួតត្រា និង ដឹកនាំការប្រើប្រាស់ដីធ្លី និងទ្រព្យសម្បត្តិរបស់គ្រួសារ រាប់បញ្ចូល ការជួលដីប្រពៃណីទៅឱ្យអ្នកដទៃ។ ជួនកាលសេចក្តីសម្រេចចិត្តដែល Matai បានធ្វើឡើង ត្រូវបានសួរដេញដោលនៅក្នុងតុលាការទទួលបន្ទុកបណ្តឹង ទាក់ទងនឹងដីធ្លី និងប្លង់ដី។ បើទោះបីជា Matai ភាគច្រើនគឺជាបុរសក៏ដោយ ប៉ុន្តែក៏មាន Matai មួយចំនួនតូចជាស្ត្រីផងដែរ។

ច្បាប់ភូមិបាលបែបប្រពៃណី ឆ្នាំ១៩៦៥ ចែងអំពីការជួលជាផ្លូវការនូវដីប្រពៃណី រវាងរដ្ឋមន្ត្រីធនធានធម្មជាតិ និង បរិស្ថាន (ជំនួសមុខឱ្យម្ចាស់ដីបែបប្រពៃណី) និង អ្នកប្រើប្រាស់ដី (អ្នកជួល)។ ក្រសួងបានផ្តល់ដំណើរការដាក់ពាក្យជួលដី ជំនួសឱ្យម្ចាស់ដីបែបប្រពៃណីដើម្បីជៀសវាងទំនាស់ផលប្រយោជន៍ដែលបានកើតឡើង ពីអតីតកាល នៅពេលដែលម្ចាស់ដីបែបប្រពៃណីពឹងផ្អែកទៅលើមេធាវីរបស់អ្នកជួល ដើម្បីរៀបចំឯកសារ។ ក្រសួងក៏បានជូនដំណឹងដល់ម្ចាស់ដីអំពីដំណើរការជួលដីផងដែរ ក្នុងនោះរាប់បញ្ចូលការពន្យល់អំពីល័ក្ខខ័ណ្ឌទាំងអស់នៃការជួល ដើម្បីជានាថាល័ក្ខខ័ណ្ឌទាំងនោះ ឆ្លុះបញ្ចាំងអំពីអ្វីដែលម្ចាស់ដីបែបប្រពៃណីទាំងអស់ (សាខាញាតិ) ចង់បាន។

បើទោះជាបីជាបុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការទទួលបានដីធ្លីក៏ដោយ ប៉ុន្តែ ស្ត្រីជាច្រើនខ្វះការយល់ដឹងអំពីសិទ្ធិរបស់ពួកគេ។ លើកលែងតែ Matai ជាស្ត្រី បើពុំនោះសោតទេ ស្ត្រីរមែងតែង

ពុំមានការចូលរួមនៅក្នុងការចរចារ និងការពិភាក្សាអំពីការរៀបចំផ្ទួលដីឡើយ។ ការដែលមានបុគ្គលិកជាស្ត្រីកាន់តែច្រើន ផ្តល់ដំបូន្មានដល់ម្ចាស់ដីបែបប្រពៃណីអំពីការរៀបចំផ្ទួលដី អាចជួយពង្រឹងប្រយោជន៍នៃជំនួយផ្នែកច្បាប់ ដែលផ្តល់ជូនដោយរដ្ឋាភិបាល តាមរយៈការធ្វើឱ្យដំណើរការផ្ទួលដី កាន់តែមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ កាន់តែមានលទ្ធភាពងាយទទួលបាន និងកាន់តែមានសមធម៌យេនឌ័រ។

ប្រអប់ ២.១១ ៖

ជំនួយផ្នែកច្បាប់សម្រាប់ប្រជាជនជនបទ

ប្រភព ៖ World Bank/FAO/IFAD, 2009a: 150–151.

គម្រោងផ្តល់ជំនួយផ្នែកច្បាប់ជូនដល់ប្រជាពលរដ្ឋជនបទ (LARC) នៅប្រទេស *គីហ្គីស្តាន* ដែលត្រូវបានអនុវត្តចន្លោះពីឆ្នាំ២០០៣ និងឆ្នាំ២០០៦ ដោយមានការគាំទ្រពីធនាគារពិភពលោក កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ប្រទេសស្វីស និង សហរដ្ឋអាមេរិក បានផ្តល់សេវាផ្នែកច្បាប់ និង មានគោលបំណងបង្រៀនដល់ប្រជាពលរដ្ឋជនបទ អំពីរបៀបអនុវត្តច្បាប់ ដើម្បីដោះស្រាយវិវាទដីធ្លីរបស់ពួកគេ។ ស្ត្រី និងបុរសបានដាក់ពាក្យសុំជំនួយពីគម្រោង និង ស្វែងរកជំនួយចំពោះបញ្ហាវិវាទដែលមានលក្ខណៈស្រដៀងគ្នា ដែលពាក់ព័ន្ធទៅនឹងអាជ្ញាធរភូមិ ឬ អាជ្ញាធរមូលដ្ឋានដែលមានបំណងយកដីដែលអ្នកទាមទារទទួលបាន ក្នុងអំឡុងពេលនៃកំណែទម្រង់ដីធ្លីថ្នាក់ជាតិ និងប្រគល់ទៅឱ្យបុរសដទៃទៀតនៅក្នុងភូមិ។ គម្រោងបានកត់ត្រាថាពុំមានវិវាទដីធ្លីដែលបានកើតឡើងពីការលែងលះ ឬ ការស្នងមរតកឡើយ ដែលបានឱ្យដឹងថា វិវាទប្រភេទនេះ គឺជាវិវាទដែលមិនប្រក្រតី ឬ ស្ត្រីមានភាពស្ទាក់ស្ទើរក្នុងការប្តឹងសាច់ញាតិរបស់ខ្លួនទៅតុលាការ។

នៅក្នុងករណីក្នុងគ្រួសារមួយ ស្ត្រីពិការម្នាក់ត្រូវបានឪពុករបស់គាត់ប្រគល់ផ្ទះរបស់គ្រួសារជូនគាត់ ជាមួយនឹងឯកសារផ្លូវការសមស្រប។ បើទោះជាដូច្នេះក្តី ឪពុកមា និងបងប្អូនជីដូនមួយរបស់ស្ត្រីម្នាក់នេះ បានបដិសេធចាកចេញពីផ្ទះ និងរៀបចំឯកសារដោយឡែកមួយ ដើម្បីបញ្ជាក់អំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានផ្ទះនោះ។ ក្រោយពេលដែលអាជ្ញាធរមូលដ្ឋានបានបង្អាក់ទឹកចិត្តស្ត្រីពិការម្នាក់នេះ ពីការនាំយកករណីនេះ ទៅតុលាការ និងដោយសារតែមិនបានបញ្ជូនករណីរបស់គាត់ទៅកាន់តុលាការមូលដ្ឋាន ស្ត្រីពិការម្នាក់នេះ បានទៅសុំជំនួយពីគម្រោងផ្តល់ជំនួយផ្នែកច្បាប់ជូនដល់ប្រជាពលរដ្ឋជនបទ ហើយទីបំផុត បានឈានទៅដល់ការឯកភាពព្រមព្រៀងមួយជាមួយសាខាញាតិរបស់គាត់។ ដូច្នេះ គម្រោងផ្តល់ជំនួយផ្នែកច្បាប់ជូនដល់ប្រជាពលរដ្ឋជនបទ បានជួយដល់ស្ត្រីដែលមានវិវាទដីធ្លី ប៉ុន្តែ បទពិសោធន៍របស់គម្រោងនេះ បានឱ្យដឹងថា គេត្រូវការឱ្យមាននូវកិច្ចគាំទ្រ និងជំនួយផ្នែកច្បាប់មួយដ៏រឹងមាំ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រក្នុងការដោះស្រាយវិវាទដីធ្លី ដែលនិយាមបទដ្ឋានវប្បធម៌មិនលើកទឹកចិត្តស្ត្រី ចំពោះការប្តឹងសាច់ញាតិ។

អង្គការសង្គមស៊ីវិល មានតួនាទីជាក់លាក់មួយដ៏សំខាន់ក្នុងការផ្តល់កិច្ចគាំទ្រផ្នែកច្បាប់ សម្រាប់អភិបាលកិច្ចលើ

ការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ។ អង្គការច្បាប់ អាចផ្តល់ជំនួយផ្នែកច្បាប់ជាក់ស្តែង នៅក្នុងករណីរបស់បុគ្គល ហើយស្របពេលជាមួយគ្នានោះដែរ អង្គការទាំងនោះ ក៏រមែងតែងមានសមត្ថភាព និងអាណត្តិការងារក្នុងការបន្តបណ្តឹងវិវាទជាយុទ្ធសាស្ត្រ និង ទទួលយកករណីសាកល្បងសំខាន់ៗនៅក្នុងតុលាការផងដែរ (UN-Women, 2011: 118; World Bank/FAO/IFAD, 2009a: 151; FAO, 2006a: 160; Kapur, 2011)។

ករណីសាកល្បងអាចជួយពង្រឹងការអនុវត្តន៍បទប្បញ្ញត្តិដែលមានសមធម៌យេនឌ័រ នៅក្នុងច្បាប់ភូមិបាល និងនិយ័តកម្មដែលទាក់ទងទៅនឹងបញ្ហាដីធ្លី ព្រមទាំងជានាឱ្យមាននូវអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។ ឧទាហរណ៍ ក្នុងករណីដែលច្បាប់ប្រពៃណីត្រូវបានអនុវត្តទូលំទូលាយ ករណីសាកល្បងអាចពាក់ព័ន្ធទៅនឹងកំណែទម្រង់ទៅលើទិដ្ឋភាពមួយចំនួននៃច្បាប់ប្រពៃណី ដែលមានភាពរើសអើង ជាជាងការជំនួសទាំងស្រុង (FAO, 2006a: 166)។ ដូច្នេះ កិច្ចគាំទ្រផ្នែកច្បាប់ពីសង្គមស៊ីវិល អាចធ្វើឱ្យតុលាការក្លាយជាយាន្តមួយដ៏មានសារៈប្រយោជន៍សម្រាប់អនុវត្តសមធម៌យេនឌ័រ។

ជាញឹកញាប់ អង្គការសង្គមស៊ីវិលរមែងតែងមានប្រសិទ្ធភាពបំផុត នៅពេលដែលពួកគេធ្វើការងារសហប្រតិបត្តិការជាមួយរដ្ឋាភិបាល ដូចមានរៀបរាប់នៅក្នុង ប្រអប់ ៨.១២ ទាក់ទងទៅនឹងប្រទេសប៉ាគីស្ថាន ដែលកិច្ចគាំទ្រពីសង្គមស៊ីវិលមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រនៅក្នុងអភិបាលកិច្ចលើការកាន់កាប់ក្រោមកម្មវិធីបែងចែកដីធ្លី។

ប្រអប់ ២.១២ ៖

ការអនុវត្តន៍ល្អនៅក្នុងកិច្ចគាំទ្រផ្នែកច្បាប់

ប្រភព ៖ ILC, 2010c.

គម្រោងមួយនៅក្នុង *ប្រទេសប៉ាគីស្ថាន* ដែលទទួលបានមូលនិធិគាំទ្រពីសហព័ន្ធភាពដីធ្លីអន្តរជាតិ ក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ បានបង្កើតឱ្យមាននូវគណៈកម្មាធិការជំនួយផ្នែក ច្បាប់ (LACs) ដែលមានអនុគណៈកម្មាធិការមេធាវី នៅក្នុងស្រុកចំនួន៥ នៃខេត្ត Sindh ។ គណៈកម្មាធិការជំនួយផ្នែកច្បាប់ បានលើកឡើងនូវករណីស្ត្រីដែលកំពុងប្រឈមទៅនឹងការប្តឹងជំទាស់ប្រឆាំងទៅនឹងការបែងចែកដីធ្លីរបស់ពួកគេ ក្រោមកម្មវិធីបែងចែកដី (LDP) របស់រដ្ឋាភិបាលនៅក្នុងខេត្ត Sindh និងបានរារាំងអតីតម្ចាស់ដីពីការប្តឹងជំទាស់ចំពោះការផ្តល់ដីរបស់ពួកគេ ទៅឱ្យអ្នកទទួលផលជាស្ត្រី។

អង្គការស្ត្រី ត្រូវបានបង្កើតឡើងនៅក្នុងស្រុកចំនួន៥ ហើយគម្រោងបានបណ្តុះបណ្តាលសមាជិករបស់អង្គការស្ត្រី អំពីការគ្រប់គ្រងអង្គការ និងការផ្តល់ជំនួយដល់ស្ត្រីដែលមានបញ្ហាទាក់ទងទៅនឹងសិទ្ធិទទួលបានដីធ្លីស្របច្បាប់ ក្រោមកម្មវិធីបែងចែកដីធ្លីនោះ។ គណៈកម្មាធិការជំនួយផ្នែកច្បាប់ និងអង្គការស្ត្រី បានសហការផ្តល់សេវាផ្នែកច្បាប់ជូនដល់ស្ត្រីចំនួន៥០នាក់ ដែលដីដែលពួកគេទើបត្រូវបានផ្តល់ជូន កំពុងស្ថិតក្រោមបណ្តឹងទាមទារ ហើយជាលទ្ធផល ករណីចំនួនពាក់កណ្តាលត្រូវបានដោះស្រាយដោយជោគជ័យ។ ករណីចំនួន៣៦ទៀត ត្រូវបានអតីតម្ចាស់ដីដកបណ្តឹងវិញ ក្រោយពេលមានការតស៊ូមតិពីគណៈកម្មាធិការជំនួយផ្នែកច្បាប់ និង អង្គការស្ត្រី។

គម្រោងនេះ បានរៀនសូត្រថា ការផ្តល់ជំនួយផ្នែកច្បាប់ ទាមទារឱ្យមានការប្តេជ្ញាចិត្តរយៈពេលវែងពីម្ចាស់ជំនួយ និង ម្ចាស់មូលនិធិ អាស្រ័យដោយករណីមួយចំនួន ដែល

គណៈកម្មាធិការជំនួយផ្នែកច្បាប់បានគាំទ្រ ត្រូវបានបញ្ជូនទៅកាន់ប្រព័ន្ធយុត្តិធម៌ផ្លូវការកម្រិតខ្ពស់ ស្ត្រីដែលពាក់ព័ន្ធនៅក្នុងករណីបណ្តឹង ត្រូវការឱ្យមានការបន្តផ្តល់ជំនួយផ្នែកច្បាប់ ហើយគណៈកម្មាធិការជំនួយផ្នែកច្បាប់ និងអង្គការស្ត្រី ត្រូវការអភិវឌ្ឍន៍សមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីផ្តល់កិច្ចគាំទ្រនេះនៅឯប្រព័ន្ធយុត្តិធម៌ផ្លូវការកម្រិតខ្ពស់។ គម្រោងក៏បានរៀនសូត្រផងដែរថា បន្ថែមពីលើការធ្វើឱ្យរដ្ឋាភិបាលមានគណនេយ្យភាពចំពោះបញ្ហាសមធម៌យេនឌ័រ នៅក្នុងកម្មវិធីរបស់ពួកគេ ដែលទាក់ទងទៅនឹងដីធ្លី វាក៏មានសារៈសំខាន់ផងដែរ ដែលត្រូវមានយុទ្ធសាស្ត្រសម្រាប់ការចូលរួមដោយផ្ទាល់ជាមួយមន្ត្រីដែលធ្វើការងារនៅក្នុងកម្មវិធីទាំងនេះ។

សង្គមស៊ីវិល និងអង្គការអន្តរជាតិនានា ក៏អាចផ្តល់ការបណ្តុះបណ្តាលជូនដល់ជំនួយការច្បាប់សហគមន៍ ដើម្បីធ្វើការងារលើបញ្ហាយេនឌ័រ នៅកម្រិតសហគមន៍បានផងដែរ ដូចមានបញ្ជាក់ជូនពីឧទាហរណ៍ នៅប្រទេសឥណ្ឌា ម៉ូហ្សំប៊ិក និង Commonweath Secretariat ក្នុងប្រអប់ ២.១៣។ ជំនួយការច្បាប់សហគម៍ អាចផ្តល់កិច្ចគាំទ្រផ្នែកច្បាប់ ដោយចំណាយថវិកាក្នុងកម្រិតទាបគួរឱ្យកត់សម្គាល់ អាស្រ័យដោយពួកគេត្រូវការការបណ្តុះបណ្តាលតិចជាងមេធាវីដែលមានលក្ខណៈសម្បត្តិពេញលេញ។ ពួកគេក៏មានសារៈសំខាន់ផងដែរនៅក្នុងកិច្ចខិតខំដើម្បីបង្កើនអក្ខរភាពផ្នែកច្បាប់ ដូចមានពិភាក្សាបន្ថែមទៀតនៅក្នុង *ម៉ូឌុល៥*។

ប្រអប់ ២.១៣ ៖

ការបណ្តុះបណ្តាលជំនួយការផ្នែកច្បាប់សហគមន៍សម្រាប់ការងារលើបញ្ហាយេនឌ័រ

ប្រភព ៖ Catherine Gatundu's presentation on "Africa experiences of civil society involvement in land policy process" at the May 2011 technical workshop; Marianna Bicchieri's presentation on "Gender and Land Project – Mozambique" at FAO, Rome, 13 May 2010; ILC, 2010d; Catherine Gatundu, personal communication.

នៅក្នុង*ប្រទេសឥណ្ឌា* សមាគមស្ថាបនាតំបន់ជនបទឡើងវិញ នៅអាស៊ីភាគខាងត្បូង (SARRA) បានផ្តល់ការបណ្តុះបណ្តាលជូនដល់ជំនួយការច្បាប់សហគមន៍ អំពីប្រជាជនកុលសម្ព័ន្ធដែលរស់នៅក្នុងព្រៃ ក្នុងរដ្ឋអាន់ដ្រា ប្រាដេស ក្នុងឆ្នាំ២០១០ ដោយសហការជាមួយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ដែលទទួលខុសត្រូវលើបញ្ហាព្រៃឈើ បរិស្ថាន និងកុលសម្ព័ន្ធ។ សិក្ខាសាលាបណ្តុះបណ្តាលជំនួយការផ្នែកច្បាប់រយៈពេល ៤ថ្ងៃ សម្រាប់ប្រជាជនកុលសម្ព័ន្ធ ចំនួន ៦៣នាក់ (ភាគច្រើនជាស្ត្រី និង យុវជន) រួមមានការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយរដ្ឋមន្ត្រីមួយរូប និង មន្ត្រីជាន់ខ្ពស់ដទៃទៀត។ នេះគឺជាលើកទី១ ដែលមានការប្រាស្រ័យទាក់ទងដោយផ្ទាល់បែបនេះ ហើយវាបានជម្រុញឱ្យមានទំនុកចិត្តពីប្រជាជនកុលសម្ព័ន្ធ ព្រមទាំងលើកកម្ពស់ឱ្យមានកិច្ចសន្ទនា និង ការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងរបស់ប្រជាជនកុលសម្ព័ន្ធអំពីនីតិវិធីច្បាប់ និង នីតិវិធីរដ្ឋបាល ដើម្បីទទួលបានប្លង់ដី។ សមាគមស្ថាបនាតំបន់ជនបទឡើងវិញ នៅអាស៊ីភាគខាងត្បូង បានបកប្រែច្បាប់ស្តីពីសិទ្ធិដីធ្លី ឆ្នាំ២០០៦ ជាភាសា ក្នុងស្រុក (ភាសាតេលូហ្គូ) និងបានបោះពុម្ពចំនួន ១.០០០ ច្បាប់ ព្រមជាមួយនឹងព័ត៌មានជាក់ស្តែងសម្រាប់ប្រជាជនកុលសម្ព័ន្ធ អំពីរបៀបដាក់ពាក្យសុំការប្រគល់ដីធ្លី។ ជំនួយការផ្នែកច្បាប់ដែលទើបទទួលបានការបណ្តុះបណ្តាលថ្មីៗ ស្ទើរតែពាក់កណ្តាល បានបំពេញពាក្យសុំការប្រគល់ដីធ្លីរបស់ពួកគេដោយខ្លួនឯង និងបានជួយដល់គ្រួសារកុលសម្ព័ន្ធចំនួន ៤៥ គ្រួសារដទៃទៀត ក្នុងការបំពេញទម្រង់ទាំងនោះ។

ស្ថិតក្រោមគម្រោងយេនឌ័រ និងសិទ្ធិដីធ្លីរបស់ខ្លួន ដែលមានរយៈពេល៣ឆ្នាំ នៅក្នុង

ប្រទេសម៉ូហ្សំប៊ិក និង ដោយមានកិច្ចគាំទ្រពីប្រទេសន័រវេ អង្គការ FAO និងមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្នែកគតិយុត្តិ និងយុត្តិធម៌ (CFJJ) ដែលជាស្ថាប័នរដ្ឋាភិបាល បានចាប់ផ្តើមវគ្គបណ្តុះបណ្តាលជំនួយការច្បាប់ និងកិច្ចគាំទ្រនៅមូលដ្ឋាន អំពីយេនឌ័រសម្រាប់សង្គមស៊ីវិល វិស័យសាធារណៈ និង មេដឹកនាំសហគមន៍។ កម្មវិធីបណ្តុះបណ្តាលមួយដែលទូលំទូលាយជាងនេះ អំពីបញ្ហាដីធ្លីសម្រាប់ចៅក្រម មេធាវី និងមន្ត្រីនគរបាល ដែលមានប្រតិបត្តិការចាប់តាំងពីឆ្នាំ២០០០ បានបង្ហាញឱ្យឃើញអំពីសេចក្តីត្រូវការក្នុងការផ្សព្វផ្សាយព័ត៌មានអំពីច្បាប់ភូមិបាលថ្មី ជូនដល់តួអង្គរដ្ឋាភិបាលមូលដ្ឋាន និង សង្គមស៊ីវិល ដែលធ្វើការងារដោយផ្ទាល់ជាមួយប្រជាពលរដ្ឋជនបទ។ វគ្គបណ្តុះបណ្តាលជំនួយការច្បាប់ បានចាប់ផ្តើមក្នុងឆ្នាំ២០០៥ ហើយគម្រោងបានអភិវឌ្ឍម៉ូឌុលអំពីយេនឌ័រមួយក្នុងឆ្នាំ២០១០ ដែលស្វែងរកធ្វើការងារលើបញ្ហាយេនឌ័រជាមួយបុរស ព្រមទាំងស្ត្រីតាមរយៈវគ្គបណ្តុះបណ្តាលជំនួយការផ្នែកច្បាប់ សិក្ខាសាលាថ្នាក់ស្រុកសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និង នាយនគរបាល កម្មវិធីគាំទ្របច្ចេកទេសនៅមូលដ្ឋាន និងវគ្គនានានៅតាមសហគមន៍។ គម្រោងក៏លើកកម្ពស់ការយល់ដឹងផងដែរ អំពីសិទ្ធិដីធ្លីរបស់ស្ត្រី និងសមភាពយេនឌ័រ តាមរយៈយុទ្ធនាការតស៊ូមតិថ្នាក់ជាតិមួយ។ សារត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ជាភាសាជាតិសំខាន់ៗទាំង៤ រាប់បញ្ចូលការផ្សព្វផ្សាយសារនៅលើអាវយឺត ផ្ទាំងបដា និងប្រតិទិន សៀវភៅគំនូជីវចល និងខ្សែអាត់វីដេអូ ព្រមទាំងតាមរយៈការសម្តែងល្ខោនតាមសហគមន៍ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត។ គម្រោងកំពុងផលិតសៀវភៅមួយសម្រាប់បញ្ចូលទៅក្នុងសម្ភារៈសិក្សានៃកម្មវិធីបណ្តុះបណ្តាលជំនួយការច្បាប់ និង វិស័យយុត្តិធម៌ ដែលមានលក្ខណៈទូលំទូលាយជាងនេះ។

កូនសៀវភៅ *Commonweath Secretariat* ដែលត្រូវបានផ្សព្វផ្សាយនៅឯកិច្ចប្រជុំរដ្ឋមន្ត្រីយុត្តិធម៌នៅប្រទេសអូស្ត្រាលី ក្នុងខែកក្កដា ឆ្នាំ២០១១ និងផ្សព្វផ្សាយក្រោមភាពជាដៃគូជាមួយអង្គការ ActionAid មានគោលបំណង "ផ្តល់ព័ត៌មានជាក់ស្តែងសំខាន់ៗជូនដល់តួអង្គពាក់ព័ន្ធទាំងអស់ ដែលធ្វើការងារសំដៅធ្វើឱ្យមានប្រសិទ្ធភាពចំពោះការទាមទារធនធាន និង សិទ្ធិរបស់ស្ត្រីក្រោមច្បាប់ និងទំនៀមទម្លាប់"។ កូនសៀវភៅនេះ គឺជាឧបករណ៍មួយសមស្របសម្រាប់ចៅក្រម មន្ត្រីរដ្ឋបាលក្នុងមូលដ្ឋាន មេដឹកនាំបែបប្រពៃណី មេដឹកនាំសហគមន៍ និងស្ត្រីជនបទនៅថ្នាក់មូលដ្ឋាន ហើយសៀវភៅនេះ នឹងមានសារៈប្រយោជន៍ជាពិសេស សម្រាប់ប្រើប្រាស់ជាសេចក្តីណែនាំបណ្តុះបណ្តាល និង ឯកសារយោងសម្រាប់ជំនួយការច្បាប់សហគមន៍។ សៀវភៅនេះត្រូវបានបោះពុម្ពជាភាសាជាច្រើនផ្សេងៗគ្នា និងផ្តល់នូវសេចក្តីណែនាំជាជំហានៗ សម្រាប់អភិវឌ្ឍឱ្យមានការយល់ដឹងគ្រប់ជ្រុងជ្រោយមួយអំពីច្បាប់ និង លើកទឹកចិត្តឱ្យមានការអនុវត្តន៍ច្បាប់ពេញលេញ ដើម្បីការពារលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសិទ្ធិដីធ្លី។

គម្រោងដែលត្រូវបានពិភាក្សានៅក្នុងប្រអប់ ២.៧ ក៏បានប្រើប្រាស់កិច្ចគាំទ្រពីជំនួយការផ្នែកច្បាប់ ជាវិធីមួយសម្រាប់គាំទ្រដល់ដំណើរការផ្តល់ប្លង់ដីសហគមន៍។ គម្រោងនេះ មានភាពច្នៃប្រឌិតជាពិសេស ក្នុងការស្វែងរក

បង្កើតឱ្យមាននូវកម្រិត និងប្រភេទនៃកិច្ចគាំទ្រផ្នែកច្បាប់ដែលមានប្រសិទ្ធភាពបំផុត ដើម្បីជានាឱ្យមាននូវអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ នៅក្នុងសហគមន៍មូលដ្ឋាន ដូចមានរៀបរាប់បន្ថែមទៀត នៅក្នុងប្រអប់ ២.១៤។

ប្រអប់ ២.១៤ ៖
មេរៀនបទពិសោធន៍អំពីកិច្ចគាំទ្រផ្នែកច្បាប់

ប្រភព ៖ Rachael Knight's presentation on "Gender-equitable participation in land governance: community land titling in Liberia, Mozambique and Uganda" at the May 2011 technical workshop; Knight 2011; Catherine Gatundu, personal communication.

នៅក្នុងគម្រោងផ្តល់ប្លង់ដីសហគមន៍ នៅ*ប្រទេសលីបេរីយ៉ា ម៉ូហ្សំប៊ិក និងយូហ្គាន់ដា* ដូចមានរៀបរាប់នៅក្នុងប្រអប់ ២.៧ ក្រុមសហគមន៍ ត្រូវបានផ្តល់ជូននូវជំនួយផ្នែកច្បាប់ក្នុងកម្រិតផ្សេងៗគ្នា ខណៈពេលដែលពួកគេអនុវត្តតាមដំណើរការផ្តល់ប្លង់ដីសហគមន៍ ដែលត្រូវបានផ្តល់អាណត្តិការងារស្របច្បាប់ដោយប្រទេសរបស់ពួកគេ។ វឌ្ឍនភាពរបស់ក្រុមទាំងនេះ ត្រូវបានត្រួតពិនិត្យ ហើយលទ្ធផលត្រូវបានយកមកប្រៀបធៀប និងវិភាគ ដើម្បីកំណត់ថាតើអង្គការអន្តរជាតិ រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អាចគាំទ្រដល់ការអនុវត្តន៍បទប្បញ្ញត្តិស្តីពីការផ្តល់ប្លង់ដីសហគមន៍ដោយរបៀបណា។

នៅក្នុងប្រទេសនីមួយៗ សហគមន៍ចំនួន២០ ត្រូវបានស្នើសុំឱ្យចូលរួមនៅក្នុងគម្រោងនេះ ដែលសហគមន៍នីមួយៗត្រូវបានចាត់តាំងឱ្យស្ថិតនៅក្នុងក្រុមមួយក្នុងចំណោមក្រុមទាំង៤ ដែលទទួលបានកិច្ចគាំទ្រផ្នែកច្បាប់ក្នុងកម្រិតខុសៗគ្នា ៖

- ការអប់រំ និង ការបណ្តុះបណ្តាលអំពីច្បាប់ប្រចាំខែ ត្រូវបានផ្តល់ជូនដោយក្រុមការងារមេធាវីតាមមូលដ្ឋានមួយ និងអ្នកចងក្រងសហគមន៍/អ្នកបច្ចេកទេសក្នុងនោះ សមាជិកសហគមន៍ទាំងអស់ ត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលទាំងនេះ ហើយវិធានការជាក់លាក់ ត្រូវបានអនុម័តដើម្បីធានាឱ្យមានការចូលរួមពីស្ត្រី។
- កិច្ចគាំទ្រពីជំនួយការផ្នែកច្បាប់ពី "ជំនួយការផ្នែកច្បាប់លើបញ្ហាដីធ្លី" ដែលត្រូវ បានបោះឆ្នោតជ្រើសរើស និងបម្រើការងារនៅតាមសហគមន៍ចំនួន២រូប (ស្ត្រី ១រូប និង បុរស ១រូប នៅក្នុងប្រទេសម៉ូហ្សំប៊ិក និង យូហ្គាន់ដា និងទៅតាមជម្រើសរបស់សហគមន៍នៅក្នុងប្រទេសលីបេរីយ៉ា) បូករួមនឹងការអប់រំ និង ការបណ្តុះបណ្តាលអំពីច្បាប់ប្រចាំខែ - ជំនួយការផ្នែកច្បាប់បានទទួលការបណ្តុះបណ្តាលស៊ីជម្រៅ រាប់បញ្ចូលទាំងការបញ្ចូលក្រុមងាយរងគ្រោះ និងយុទ្ធសាស្ត្រសម្រាប់បន្សីុសិទ្ធិបែបប្រពៃណី ទៅនឹងច្បាប់ជាតិ និង គោលការណ៍សិទ្ធិមនុស្ស។
- ការអប់រំអំពីច្បាប់ប្រចាំខែ និងកិច្ចគាំទ្របច្ចេកទេសពេញលេញពីមេធាវីនៅក្នុង គម្រោង និងក្រុមការងារតាមមូលដ្ឋាន នៅក្នុងដំណើរការផ្តល់ប្លង់ដីសហគមន៍ រាប់បញ្ចូលជំនួយលើការដោះស្រាយទំនាស់។
- ក្រុមត្រួតពិនិត្យ - សហគមន៍បានចូលរួមនៅក្នុងកិច្ចប្រជុំមួយដែលពួកគេត្រូវបាន ផ្តល់ជូននូវឯកសារច្បាប់ និងនិយ័តកម្មជាតិស្តីពីដីធ្លី សេចក្តីណែនាំ និងសម្ភារៈបណ្តុះបណ្តាលដទៃទៀត អំពីការអនុវត្តន៍តាមដំណើរការផ្តល់ប្លង់ដីសហគមន៍។

នៅក្នុងប្រទេសទាំង៣ សហគមន៍ដែលបានទទួលកិច្ចគាំទ្រពីជំនួយការផ្នែកច្បាប់

និងការអប់រំ ព្រមទាំងការបណ្តុះបណ្តាលអំពីច្បាប់ប្រចាំខែ (ចំណុចទី២ នៅក្នុងបញ្ជីរាយនាមខាងលើ) បានទទួលជោគជ័យខ្លាំងបំផុត ក្នុងការបញ្ចប់ដំណើរការចុះបញ្ជីដោយធ្វើបានប្រសើរជាងអ្នកដែលបានទទួលកិច្ចគាំទ្រផ្នែកច្បាប់ពេញលេញ។ ជំនួយការផ្នែកច្បាប់ដើរតួនាទីមួយគួរឱ្យកត់សម្គាល់ ក្នុងការគាំទ្រឱ្យមានការចូលរួមរបស់សហគមន៍នៅក្នុងគម្រោង។ គំហើញទាំងនេះ បានឱ្យដឹងថាការបណ្តុះបណ្តាល និងការត្រួតពិនិត្យទៅលើជំនួយការផ្នែកច្បាប់សហគមន៍ ដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមូលដ្ឋាន អាចជាវិធីមួយដែលចំណាយតិច មានភាពសក្តិសិទ្ធិ និងមានប្រសិទ្ធភាពក្នុងការគាំទ្រដល់សហគមន៍ជាច្រើន តាមរយៈដំណើរការចងក្រងឯកសារអំពីដីធ្លី។ បទពិសោធន៍របស់គម្រោងក៏បានឱ្យដឹងផងដែរថា ការផ្តល់ប្លង់ដីសហគមន៍អាចទទួលបានការគាំទ្រប្រសើរបំផុត ពីជំនួយការច្បាប់សហគមន៍ ក្រោមការត្រួតពិនិត្យពីក្រុមគាំទ្រផ្នែកច្បាប់ និងបច្ចេកទេសមួយក្រុម។

បញ្ហាមួយដ៏សំខាន់ចុងក្រោយ គឺជាសេចក្តីត្រូវការក្នុងការពិចារណាស្វែងរកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត ជាពិសេស នៅកម្រិតមូលដ្ឋាន។ ប្រអប់ ២.១៥ រៀបរាប់អំពីក្រុមឃ្លាំមើល ដែលជាយន្តការមួយសម្រាប់កិច្ចគាំទ្រផ្នែកច្បាប់ នៅក្នុងប្រទេសកេនយ៉ា។ ក្រុមឃ្លាំមើល អាចសម្រាលសម្ពាធទៅលើប្រព័ន្ធយុត្តិធម៌ផ្លូវការ និងដើរតួនាទីជាយាន្តមួយសម្រាប់ផ្តល់ជំនួយផ្នែកច្បាប់ ជូនដល់ប្រជាពលរដ្ឋមូលដ្ឋាន នៅក្នុងដំណើរការនីតិវិធីតុលាការក្នុងមូលដ្ឋាន និង យន្តការដោះស្រាយវិវាទ។ ក្រុមទាំងនេះ ក៏អាចដើរតួនាទីមួយទៀតជាយន្តការមួយដែលមានលក្ខណៈកាន់តែទូលំទូលាយ សម្រាប់អភិបាលកិច្ចដោយមានការចូលរួមនៅថ្នាក់មូលដ្ឋាន។

ប្រអប់ ២.១៥ ៖

ក្រុមឃ្លាំមើលសហគមន៍សម្រាប់គាំទ្រដល់សិទ្ធិស្ត្រី ក្នុងការទទួលបានដីធ្លី

ប្រភព ៖ GROOTS Kenya, 2011.

អង្គការសង្គមស៊ីវិល ដែលមានឈ្មោះថា GROOTS Kenya បានជួយដល់សហគមន៍មូលដ្ឋាននៅក្នុងស្រុកហ្គាទុនឌូ ក្នុងការរៀបចំបង្កើតក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍ (WDGs) ដើម្បីការពារស្ត្រីមេម៉ាយ និងកុមារកំព្រា ពីការបាត់បង់ដីធ្លី និងទ្រព្យសម្បត្តិរបស់ពួកគេ។

ក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍ មានមូលដ្ឋានផ្អែកលើគំនិតថាសមាជិកសហគមន៍ទាំងស្ត្រី និងបុរស គួរធ្វើការរួមគ្នាដើម្បីទប់ស្កាត់ការរំលោភបំពានទៅលើសិទ្ធិទទួលបានទ្រព្យសម្បត្តិ នៅក្នុងសហគមន៍របស់ពួកគេ។ ក្រុមឃ្លាំមើលបញ្ហាដីធ្លីនិងទ្រព្យសម្បត្តិនៅក្នុងសហគមន៍នីមួយៗ មានសមាជិកជាបុរស និងស្ត្រី ចន្លោះពី ១៥នាក់ទៅ ២៥នាក់ ដែលបានស្ម័គ្រចិត្តក្រោយពេលមានដំណើរការសហគមន៍បែបចូលរួមមួយ។ ដំណើរការនេះ រួមមាន ការប៉ាន់ប្រមាណទៅលើសេចក្តីត្រូវការសហគមន៍ ការគៀងគរអ្នកពាក់ព័ន្ធសំខាន់ៗ ដូចជា ចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិ អង្គការសិទ្ធិមនុស្ស និងអាជ្ញាធរថ្នាក់ខេត្ត តាមរយៈការចែករំលែកលទ្ធផលនៃការប៉ាន់ប្រមាណ និងការពន្យល់អំពីផលប៉ះពាល់នៃការរំលោភបំពានសិទ្ធិដីធ្លី ព្រមទាំងកិច្ចសន្ទនានៅក្នុងសហគមន៍។ អ្នកចូលរួមជាស្ត្រីទទួលបានការលើកទឹកចិត្តជាពិសេស។ នៅពេលដែលការរំលោភបំពានសិទ្ធិដីធ្លីមួយ មានការពាក់ព័ន្ធជាមួយសមាជិកសហគមន៍ងាយរងគ្រោះ ក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិ

នៅក្នុងសហគមន៍ធ្វើការកំណត់ទៅលើអង្គហេតុនៃករណី ជូនដំណឹងទៅកាន់សមាជិកសហគមន៍ដទៃទៀត និងធ្វើការសម្រុះសម្រួលដើម្បីធានាថា ជនដែលបានប្រព្រឹត្តអំពើរំលោភបំពានប្រគល់ទ្រព្យសម្បត្តិទៅឱ្យម្ចាស់កម្មសិទ្ធិស្របច្បាប់វិញ។ វិធីសាស្ត្រសម្រុះសម្រួលផ្សេងៗគ្នាជាច្រើន ត្រូវបានយកមកប្រើប្រាស់ ដែលមានការចូលរួមពីមេដឹកនាំសហគមន៍ មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន មេដឹកនាំដទៃទៀត និងចាស់ព្រឹទ្ធាចារ្យ។ ក្នុងករណីចាំបាច់ ក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍ រៀបចំឱ្យមានការដាក់ពាក្យបណ្តឹងនៅឯតុលាការ និង ធានាថាវិធានរបស់តុលាការត្រូវបានអនុវត្ត។ ក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍ ក៏ទទួលបានផងដែរនូវការបញ្ជូនពីប្រជាពលរដ្ឋ ឬ ស្ថាប័នមួយចំនួន ដូចជា នគរបាល ប្រព័ន្ធយុត្តិធម៌ អាជ្ញាធរថ្នាក់ខេត្ត អ្នកចុះបញ្ជីដីធ្លីថ្នាក់ស្រុក អង្គជំនុំជម្រះវិវាទដីធ្លី និងក្រុមប្រឹក្សាភិបាលទទួលបន្ទុកការងារត្រួតពិនិត្យដីធ្លី។ សហគមន៍ផ្តល់មតិយោបល់ត្រឡប់ តាមរយៈការវាយតម្លៃ និងការត្រួតពិនិត្យឡើងវិញ ដែលដឹកនាំធ្វើដោយក្រុមឃ្លាំមើលបញ្ហាដីធ្លី និង ទ្រព្យសម្បត្តិនៅក្នុងសហគមន៍ ហើយក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍ ដែលទទួលបានជោគជ័យ ត្រូវបានលើកទឹកចិត្តឱ្យចែករំលែកអំពីវឌ្ឍនភាព និងការអនុវត្តន៍របស់ពួកគេ តាមរយៈការផ្លាស់ប្តូរបទពេសិធាន៍ ឬ ទស្សនៈកិច្ចទៅកាន់សហគមន៍ដទៃដែលជួបប្រទះបញ្ហាស្រដៀងគ្នា។

តាមរយៈដៃគូ ដូចជា GROOTS Kenya និងទីភ្នាក់ងារដទៃទៀត សមាជិករបស់ក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍ នៅក្នុងស្រុកហ្គាទុនឌូ បានទទួលការបណ្តុះបណ្តាលមូលដ្ឋាន ក្នុងនាមជាជំនួយការផ្នែកច្បាប់ ដែលបង្កលក្ខណៈឱ្យពួកគេអាចផ្តល់ការសម្រុះសម្រួល រវាងភាគីវិវាទ និងជំបូន្មានផ្នែកច្បាប់ជាមូលដ្ឋាន។ ក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍ ក៏កសាងឱ្យមានការយល់ដឹង និងផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋអំពីបណ្តាញសមស្របសម្រាប់រក្សាសន្តិសុខសុវត្ថិភាពឯកសារ ដែលការពារ សិទ្ធិរបស់ពួកគេផងដែរ។

ក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍នៅក្នុងស្រុកហ្គាទុនឌូ បានគាំទ្រដល់រដ្ឋបាលខេត្ត តាមរយៈការដោះស្រាយករណីនៅថ្នាក់មូលដ្ឋាន និងការកាត់បន្ថយសម្ពាធទៅលើប្រព័ន្ធយុត្តិធម៌ផ្លូវការ។ ការច្នៃប្រឌិតថ្មីដទៃទៀត រួមមាន លទ្ធភាពរបស់ក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍ ក្នុងការធ្វើសេចក្តីថ្លែង ក្នុងអំឡុងពេលដែលមានករណីដីធ្លីនៅក្នុងប្រព័ន្ធយុត្តិធម៌ផ្លូវការ។ តាមរយៈការផ្តល់របាយការណ៍ប្រចាំខែ ជូនដល់រដ្ឋបាលខេត្ត អំពីការបំពេញការងាររបស់អាជ្ញាធរបែបប្រពៃណី ក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍ បានបង្ហាញខ្លួនឯងថាជាមធ្យោបាយមួយដ៏ល្អប្រសើរនៃអភិបាលកិច្ចដោយមានការចូលរួម ដែលផ្តល់កិច្ចគាំទ្រដ៏មានតម្លៃ សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ។ យ៉ាងណាមិញ ក្រុមឃ្លាំមើលបញ្ហាដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងសហគមន៍ ជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះការទទួលស្គាល់ ឧបសគ្គរាំងស្ទះផ្នែកហិរញ្ញវត្ថុ និងវប្បធម៌ កង្វះមូលដ្ឋានរូបវន្ត (ការិយាល័យ) និងអំពើពុករលួយ។

✓	ប៉ាន់ប្រមាណទៅលើប្រភេទ និង កម្រិតនៃកិច្ចគាំទ្រផ្នែកច្បាប់ដែលសហគមន៍ត្រូវការ រាប់បញ្ចូលវិធីប្រសើរបំផុតក្នុងការសម្របសម្រួលឱ្យមានកិច្ចការពារសិទ្ធិដីធ្លីរបស់ស្ត្រី និងក្រុមងាយរងគ្រោះ ក្នុងអំឡុងពេលដែលមានកិច្ចខិតខំផ្តល់ប្លង់ដីសហគមន៍។
✓	បណ្តុះបណ្តាលជំនួយការច្បាប់សហគមន៍ឱ្យចេះធ្វើការងារជាមួយស្ត្រី និង បុរស អាស្រ័យដោយបុរសក៏ត្រូវការគាំទ្រឱ្យមានការផ្លាស់ប្តូរផងដែរ។ ផ្តល់ឱ្យជំនួយការច្បាប់សហគមន៍នូវកិច្ចគាំទ្រហិរញ្ញវត្ថុ កិច្ចគាំទ្រផ្នែកភស្តុភារ និងកិច្ចគាំទ្រដទៃទៀត ជាពិសេសក្នុងការគាំទ្រដល់ក្រុមងាយរងគ្រោះ ដូចជាស្ត្រីមេម៉ាយ កុមារកំព្រា និង ជនជាតិដើមភាគតិច។
✓	រៀបចំបង្កើតក្រុមឃ្លាំមើលសហគមន៍ និងភ្ជាប់ទំនាក់ទំនងពួកគេទៅនឹងមជ្ឈមណ្ឌល ជំនួយផ្នែកច្បាប់ ដើម្បីទទួលបានកិច្ចគាំទ្រ។
✓	រៀបចំបង្កើតតុលាការក្នុងមូលដ្ឋានចល័ត និង ការិយាល័យចល័តសម្រាប់ចុះបញ្ជីអាពាហ៍ពិពាហ៍ បញ្ជីកំណើត និងបញ្ជីមរណភាព ដើម្បីធ្វើឱ្យកាន់តែមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋ ក្នុងការទទួលបានឯកសារច្បាប់មូលដ្ឋាន និង ដាក់ពាក្យបណ្តឹងនៅក្នុងប្រព័ន្ធតុលាការផ្លូវការ នៅពេលដែលស្ថាប័នដោះស្រាយវិវាទបែបប្រពៃណី ឬ ស្ថាប័នដោះស្រាយវិវាទក្នុងមូលដ្ឋាន មិនអាចដោះស្រាយករណីទាំងនោះបាន។
✓	អភិវឌ្ឍន៍មូលដ្ឋានទិន្នន័យមួយអំពីករណីនៅឯតុលាការ និង ករណីយុត្តិសាស្ត្រតាមផ្លូវច្បាប់ ដែលលើកកម្ពស់ និងគាំទ្រអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ នៅកម្រិតថ្នាក់ជាតិ និងបង្កើតយុទ្ធនាការណ៍លើកកម្ពស់ការយល់ដឹង ដើម្បីជូនដំណឹងដល់អ្នកឃ្លាំមើលសហគមន៍ និង ជំនួយការផ្នែកច្បាប់ អំពីឧទាហរណ៍ទាំងនេះ។
✓	លើកទឹកចិត្តឱ្យមានការចងក្រងឯកសារអំពីការអនុវត្តន៍ល្អ និង ការរៀនសូត្រពីគ្នាទៅវិញទៅមក។

ចូរចងចាំ!

អភិក្រមផ្សេងៗគ្នាប្រកបដោយភាពច្នៃប្រឌិត ចំពោះកិច្ចគាំទ្រផ្នែកច្បាប់ គឺជាអភិក្រមដែលមានប្រសិទ្ធភាពបំផុត។ រដ្ឋាភិបាលគួរកំណត់ឱ្យមាននូវឧទាហរណ៍មួយពីកម្រិតកំពូល ប៉ុន្តែអង្គការសង្គមស៊ីវិល ក៏មានសារៈសំខាន់ខ្លាំងផងដែរ ក្នុងការឈោងចាប់ និង គាំទ្រដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

បញ្ជីផ្ទៀងផ្ទាត់២.៥ ៖ ការជានាឱ្យមានកិច្ចគាំទ្រផ្នែកច្បាប់ប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ WOLREC, 2011; YWAP, 2011; RWN, 2011; FAO, 2001: 29–34.

កំណត់សម្គាល់

[៥] Marianna Bicchieri, Patricia Costas, Nigel Edmead, Debbie Fletcher, Renée Giovarelli, Rachael Knight, Martha Osorio, Rebecca Sittie, Josephine Stowers-Fiu and Margret Vidar បានផ្តល់ធាតុចូលសំខាន់ៗនៅក្នុងម៉ូឌុលនេះ ក្នុងអំឡុងពេលនៃសិក្ខាសាលា បច្ចេកទេសដែលប្រព្រឹត្តធ្វើឡើងក្នុងខែឧសភា ឆ្នាំ២០១១ នៅឯការិយាល័យកណ្តាលរបស់អង្គការ FAO រាប់បញ្ចូលតាមរយៈការពិភាក្សា របស់ក្រុមការងារបច្ចេកទេសច្បាប់ចំនួនពីរក្រុមផងដែរ។

ការសង្ខេបអំពីសារសំខាន់ៗ

ស្តីពីបញ្ហាច្បាប់

វាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការដែលមានមូលដ្ឋានច្បាប់ត្រឹមត្រូវ សម្រាប់ក្របខ័ណ្ឌបទប្បញ្ញត្តិ និងក្របខ័ណ្ឌគោលនយោបាយ ដើម្បីគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ និងដើម្បីឱ្យយន្តការអនុវត្ត និងត្រួតពិនិត្យមានប្រសិទ្ធភាព។

ការមានប្រព័ន្ធច្បាប់ច្រើន និងច្បាប់ប្រពៃណី ផ្តល់នូវឱកាសសម្រាប់ស្ត្រី និងបុរស ដើម្បីសម្រេចឱ្យបាននូវសិទ្ធិដីធ្លីរបស់ពួកគេ។ បើទោះបីជាទាំងនេះ មិនមែនជាដំណោះស្រាយរយៈពេលវែងក៏ដោយ គួរមានកិច្ចខិតខំដើម្បីស្វែងរកឱកាសទាំងនេះ និងធ្វើឱ្យបុគ្គលគ្រប់រូបមានលទ្ធភាពទទួលបានឱកាស។

ការរៀបចំសេចក្តីព្រាងច្បាប់ និយ័តកម្ម និងនីតិវិធីដែលមានការចូលរួម និងមានការពិគ្រោះយោបល់ជាមួយស្ត្រី និងបុរស មកពីក្រុមសង្គមផ្សេងៗគ្នា ផ្តល់នូវកិច្ចគាំទ្រសំខាន់ៗចំពោះអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។

ការទទួលបានយុត្តិធម៌ ពុំមែងតែងមានសមធម៌យេនឌ័រឡើយ។ វាមានភាពចាំបាច់ដែលត្រូវធ្វើការងារជាមួយប្រព័ន្ធយុត្តិធម៌បែបផ្លូវការ និងបែបប្រពៃណី និង យន្តការដោះស្រាយវិវាទក្នុងមូលដ្ឋាន និងយន្តការដោះស្រាយវិវាទបែបប្រពៃណី ដើម្បីសម្រេចឱ្យបាននូវសមធម៌យេនឌ័រ។

គេគួរប្រើប្រាស់អភិក្រមប្រកបដោយភាពច្នៃប្រឌិត ចំពោះកិច្ចគាំទ្រផ្នែកច្បាប់ ដូចជា ក្រុមឃ្លាំមើលសហគមន៍ និងជំនួយការច្បាប់សហគមន៍។ កម្រិត និងប្រភេទនៃកិច្ចគាំទ្រដែលគេត្រូវការនៅក្នុងបរិបទនីមួយៗ គួរត្រូវបានប៉ាន់ប្រមាណដោយប្រុងប្រយ័ត្ន។

សូចនាករត្រួតពិនិត្យជាអនុសាសន៍ សម្រាប់បញ្ហាផ្នែកច្បាប់

- វត្តមាននៃច្បាប់ និង គោលនយោបាយដែលគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។
- ចំនួនភាគរយនៃស្ត្រី និងបុរសដែលជាសមាជិកនៃគណៈកម្មការកែទម្រង់ច្បាប់ភូមិបាល។
- ចំនួនភាគរយនៃស្ត្រី និងបុរស ដែលជាសមាជិកនៃក្រុមរៀបចំសេចក្តីព្រាងច្បាប់ ដែលធ្វើការងារលើច្បាប់ និយ័តកម្ម និងនីតិវិធីបុគ្រសម្ព័ន្ធ ដែលទាក់ទងទៅនឹងដីធ្លី។
- វត្តមាននៃដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ដោយមានការចូលរួម និងមានការពិគ្រោះយោបល់ជាមួយស្ត្រី និងបុរសពីថ្នាក់មូលដ្ឋាន។
- ចំនួនភាគរយនៃសំណើរបស់ក្រុមស្ត្រីដែលត្រូវបានយកមកពិចារណា និង ធ្វើសមាហរណកម្មទៅក្នុងលិខិតុបករណ៍ច្បាប់ដែលត្រូវបានអនុម័ត។
- វត្តមាននៃច្បាប់ស្តីពីការស្នងមរតក ដែលមានសង្គតភាព និងគាំទ្រដល់កំណែទម្រង់លើការកាន់កាប់ និងអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។
- ចំនួននៃយន្តការអនុវត្ត និងត្រួតពិនិត្យសម្រាប់ច្បាប់ភូមិបាល។
- ចំនួនភាគរយនៃស្ត្រី និងបុរស ដែលទទួលបានការបណ្តុះបណ្តាលអំពីការទទួលបានយុត្តិធម៌ដីធ្លី។
- ចំនួនភាគរយនៃស្ត្រី និងបុរស ដែលជាសមាជិកនៃស្ថាប័ន និងយន្តការដោះស្រាយវិវាទដីធ្លី រាប់បញ្ចូលក្រុមឃ្លាំមើលក្នុងមូលដ្ឋាន។
- ចំនួនភាគរយនៃស្ត្រី និងបុរសដែលជាសមាជិកអាជ្ញាធរបែបប្រពៃណីដោះស្រាយបញ្ហាដីធ្លី។
- ចំនួនការផ្តួចផ្តើមដើម្បីលុបបំបាត់ឧបសគ្គក្នុងការទទួលបានយុត្តិធម៌ដីធ្លីសម្រាប់ស្ត្រី។
- ចំនួនភាគរយនៃស្ត្រី និងបុរសដែលទទួលបានកិច្ចគាំទ្រផ្នែកច្បាប់ក្នុងករណីដីធ្លី នៅក្នុងប្រព័ន្ធយុត្តិធម៌ផ្លូវការ។
- ចំនួនភាគរយនៃវិវាទ ទាក់ទងនឹងសិទ្ធិទទួលបានដីធ្លី និងទ្រព្យសម្បត្តិរបស់ស្ត្រីនៅចំពោះមុខតុលាការ និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

ឯកសារយោង

Ahikire, J. 2010. Half full or half empty glass. Decentralisation and women's land rights in Uganda. Paper presented at the Women's Land Rights Conference, Speke Resort Munyonyo, Uganda, 4–6 October 2010.

Carfield, M. 2011. Land justice in Uganda: Preserving peace, promoting integration. In E. Harper, ed. Working with customary justice systems: postconflict and fragile states, pp. 127-–143. Rome, International Development Law Organization.

Daley, E. 2011. Gendered impacts of commercial pressures on land. Rome, ILC. www.landcoalition.org/sites/default/files/publication/902/mokoro_gender_web_11.03.11. pdf

Daley, E. Dore-Weeks, R. & Umuhoza, C. 2010. Ahead of the game: Land tenure reform in Rwanda and the process of securing women's land rights. Journal of Eastern African Studies, 4(1): 131–152.

Djusaeva, S. 2012. Promoting rural women's rights to land: UN Women programme experience in Kyrgyzstan and Tajikistan. Paper prepared for the Expert Group Meeting on Good Practices in Realizing Women's Rights to Productive Resources, with a Focus on Land, organized by UNWomen in collaboration with the United Nations Office of the High Commissioner for Human Rights, Geneva, 25–27 June 2012.

Englert, B. & Daley, E. 2008. Introduction. In E. Daley and B. Englert. Women's land rights and privatization in Eastern Africa. Woodbridge, UK, Boydell and Brewer.

FAO. 2001. Good practice guidelines for agricultural leasing arrangements. Land Tenure Studies No. 2. Rome.

FAO. 2002c. Law-making in an African context: The 1997 Mozambican Land Law, C. Tanner. FAO Legal Papers Online No. 26, Rome.www.fao.org/fileadmin/user_upload/legal/docs/lpo26.pdf

FAO. 2004. Leasing agricultural land. Land Tenure Notes No. 1. Rome. ftp://ftp.fao.org/docrep/fao/007/y5513e/y5513e00.pdf

FAO. 2006a. Gender and law: Women's rights in agriculture, L. Cotula. FAO Legislative Study No. 76, Rev.1.Rome. ftp://ftp.fao.org/docrep/fao/005/y4311e/y4311e00.pdf

FAO. 2006b. Land tenure alternative conflict management. Land Tenure Manuals No. 2. Rome. ftp://ftp.fao.org/docrep/fao/009/a0557e/a0557e00.pdf

FAO. 2008a. Compulsory acquisition of land and compensation. Land Tenure Studies No. 10. Rome. ftp://ftp.fao.org/docrep/fao/011/i0506e/i0506e00.pdf

FAO. 2009c. "We all inherited this earth", inheritance rights of widows and children in the context of AIDS: legal overview. Rome. (unpublished report)

FAO. 2011a. Governing land for women and men – gender and voluntary guidelines on responsible governance of tenure of land and other natural resources, E. Daley and C.M. Park. Land Tenure Working Paper No. 19. Rome. http://www.fao.org/docrep/014/ma811e/ma811e00.pdf

FAO. 2012b. Voluntary Guidelines on the Responsible Governance of Tenure of Land, Fisheries and Forests in the Context of National Food Security. Rome. http://www.fao.org/docrep/016/i2801e/i2801e.pdf

Government of Samoa. 2008. Legislative drafting handbook. Legislative drafting requirements approved by the Attorney General for use in Samoa from July 2008. Apia, Legislative Division of the Office of the Attorney General.

GROOTS Kenya. 2011. Complementing the state: the contribution of the "watchdog groups" in protecting women's land rights in Gatundu District, Kenya. Rome, ILC.

Guyer, J. 1987. Women and the state in Africa: Marriage law, inheritance and resettlement. Working Papers in African Studies No. 129. Boston, Massachusetts, USA, African Studies Centre, Boston University.

Harrington, A. & Choprah, T. 2010. Arguing traditions. Denying Kenya's women access to land rights. Justice for the Poor Research Report No. 2/2010. Washington, DC, World Bank. ILC. 2010c. Women's Access to Land – Project Brief 3: Promoting women's property rights and ownership in Pakistan. Rome. (unpublished)

ILC. 2010d. Women's Access to Land – Project Brief 4: Sustainable empowerment of tribal communities through land rights movement with women partnership for securing dignity and equity. Rome. (unpublished) International Justice Mission. Our Work: What We Do.http://www.ijm.org/ourwork/whatwedo

Kapur, A. 2011. Two faces of change: The need for a bi-directional approach to improve women's land rights in plural legal systems. In E. Harper, ed. Working with customary justice systems: Post-conflict and fragile states, pp. 73–92. Rome, International Development Law Organization.

Knight, R. 2011. The community land titling initiative: An investigation into the protection of customary land claims. In E. Harper, ed. Working with customary justice systems: post-conflict and fragile states, pp. 145–170. Rome, International Development Law Organization.

Mackenzie, F. 1989. Land and territory: the interface between two systems of land tenure, Murang'a District, Kenya. Africa, 59(1): 91–109.

Mackenzie, F. 1990. Gender and land rights in Murang'a District, Kenya. Journal of Peasant Studies, 17(4): 609–643.

Mackenzie, F. 1993. A piece of land never shrinks: Reconceptualizing land tenure in a smallholding 48 REFERENCES district, Kenya. In T. Bassett and D. Crummey, eds. Land in African agrarian systems. Madison, Wisconsin, USA, University of Wisconsin Press.

Magezi, J. 2010. The role of case law in upholding women's land Rights. Paper presented at the Women's Land Rights Conference, Speke Resort Munyonyo, Uganda, 4–6 October 2010.

McAuslan, P. 2010. Personal reflections on drafting laws to improve women's access to land: Is there a magic wand? Journal of Eastern African Studies, 4(1): 114–

130.

Nakayi, R. 2010. Is more less? Enhancing women's access to justice in Uganda. Paper presented at the Women's Land Rights Conference, Speke Resort Munyonyo, Uganda, 4–6 October 2010.

Namutebi, M. 2010. The Office of the Administrator General and women's land rights. Paper presented at the Women's Land Rights Conference, Speke Resort Munyonyo, Uganda, 4–6 October 2010.

RWN. 2011. Experiences of women in asserting their land rights: the case of Bugesera District, Rwanda. Rome, Rwanda Women's Network, ILC.www.landcoalition.org/sites/default/files/publication/956/wlr_5_rwn.pdf

Ssonko, M. N. 2010. The application of succession law in the realization of women's land rights in Uganda. Paper presented at the Women's Land Rights Conference, Speke Resort Munyonyo, Uganda, 4–6 October 2010.

ULA. 2010. The Uganda Land Alliance quarterly newsletter, Vol. 4. Kampala.

Undeland, A. 2012. Lessons learned and good practices in realizing women's rights to productive resources with a focus on land: Kyrgyzstan and Tajikistan. Paper prepared for the Expert Group Meeting on Good Practices in Realizing Women's Rights to Productive Resources, with a Focus on Land, organized by UN Women in collaboration with the United Nations Office of the High Commissioner for Human Rights, Geneva, 25–27 June 2012.

UN Women. 2011. Progress of the world's women 2011–2012: In pursuit of justice. New York. http://progress.unwomen.org/pdfs/en-report-progress.pdf WLLA. 2010a. The impact of national land policy and land reform in Uganda. Accra, Women's Land Link Africa.

WOLREC. 2011. Women's access to land and household bargaining power: a comparative action research project in patrilineal and matrilineal societies in Malawi. Research Report No. 9. Rome, ILC, Women's Legal Resource Centre. www.landcoalition.org/sites/default/files/publication/959/wlr_9_malawi.pdf

World Bank/FAO/IFAD. 2009a. Module 4: Gender issues in land policy and administration. In Gender in agriculture sourcebook. Washington, DC and Rome.

YWAP. 2011. Assisting Kayole widows in gaining control to family land, Kenya. Research Report No. 10. Rome, ILC, Young Widows Advancement Program. www.landcoalition.org/sites/default/files/publication/951/wlr_10_ywap.pdf

ម៉ូឌុល

៣

ស្ថាប័ន

បញ្ជីរាយនាមប្រអប់ និង តារាងរូបភាព

ប្រអប់

75
ប្រអប់ ៣.១ ៖
ស្ថាប័ន និងគោលការណ៍ណែនាំ
78
ប្រអប់ ៣.២ ៖
សមធម៌យេនឌ័រនៅក្នុងស្ថាប័ន
រដ្ឋបាលដីធ្លីថ្នាក់ជាតិ
79
ប្រអប់ ៣.៣ ៖
ការចូលរួមរបស់ស្ត្រីនៅក្នុង
អភិបាលកិច្ចដីធ្លីក្នុងមូលដ្ឋាន
82
ប្រអប់ ៣.៤ ៖
ការចូលរួមប្រកបដោយ
សមធម៌យេនឌ័រនៅក្នុងស្ថាប័ន
ដែលទាក់ទងទៅនឹងដីធ្លី
85
ប្រអប់ ៣.៥ ៖
ការធ្វើការងារជាមួយស្ថាប័ន
បែបប្រពៃណី
87
ប្រអប់ ៣.៦ ៖
ការកសាងសមត្ថភាពសម្រាប់
អភិបាលកិច្ចលើការកាន់កាប់ដីធ្លី
ប្រកបដោយសមធម៌យេនឌ័រ
90
ប្រអប់ ៣.៧ ៖ ការគាំទ្រឱ្យមាន
ការអប់រំវិទ្យាសាស្ត្រ និង
បច្ចេកទេសសម្រាប់កុមារី
91
ប្រអប់ ៣.៨ ៖
បញ្ហាប្រឈមចំពោះសមធម៌
យេនឌ័រនៅក្នុងសកម្មភាព និង
បច្ចេកវិទ្យារដ្ឋបាលដីធ្លី

បញ្ជីផ្ទៀងផ្ទាត់

81
បញ្ជីផ្ទៀងផ្ទាត់ ៣.១ ៖
ការធានាឱ្យមានស្ថាប័នដីធ្លី
ដែលមានសមធម៌យេនឌ័រ
86
បញ្ជីផ្ទៀងផ្ទាត់ ៣.២ ៖
ការធ្វើការងារជាមួយស្ថាប័ន
បែបប្រពៃណី និងស្ថាប័នមូលដ្ឋាន
88
បញ្ជីផ្ទៀងផ្ទាត់ ៣.៣ ៖
ការកសាងសមត្ថភាពស្ត្រី
89
បញ្ជីផ្ទៀងផ្ទាត់ ៣.៤ ៖
ការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន
សម្រាប់សមធម៌យេនឌ័រ
92
បញ្ជីផ្ទៀងផ្ទាត់ ៣.៥ ៖
សកម្មភាពសម្រាប់ប្រទេសនានា
ដែលមានគម្លាតយេនឌ័រធ្ងន់ធ្ងរ
93
បញ្ជីផ្ទៀងផ្ទាត់ ៣.៦ ៖
ការធ្វើឱ្យប្រសើរឡើងនូវសមធម៌
យេនឌ័រនៅក្នុងរដ្ឋបាលដីធ្លី
95
សូចនាករត្រួតពិនិត្យ
ជាអនុសាសន៍សម្រាប់ស្ថាប័ន

តារាង និង រូបភាព

77
រូបភាព ៣.១ ៖
ការប្រាស្រ័យទាក់ទងក្នុង
ចំណោមស្ថាប័នដែលពាក់ព័ន្ធ
នៅក្នុងអភិបាលកិច្ចលើការ
កាន់កាប់ដីធ្លី

ម៉ូឌុល៣ ៖ ស្ថាប័ន

ការកសាងស្ថាប័នដីធ្លីដែលមានសមធម៌យេនឌ័រ និងការអភិវឌ្ឍន៍សមត្ថភាពសម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ

សេចក្តីផ្តើម[៦]

អភិបាលកិច្ចដីធ្លីសម្រាប់ស្ត្រី និងបុរស ប្រកបដោយភាពយុត្តិធម៌ និងមានការទទួលខុសត្រូវ ព្រមទាំងក្នុងលក្ខណៈមួយដែលផ្តល់ប្រយោជន៍ជាវិជ្ជមានសម្រាប់សង្គមទាំងមូល ទាមទារឱ្យមានការបញ្ចូលយេនឌ័រទាំងពីរប្រកបដោយសមធម៌ ទៅក្នុងរាល់គ្រប់ស្ថាប័នដីធ្លី និងដំណើរការអភិបាលកិច្ចទាំងអស់។ ដូច្នេះ គេត្រូវការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រី និងបុរស ដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាព នៅក្នុងស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី និងសមត្ថភាពរបស់ស្ថាប័នដីធ្លី ដើម្បីដោះស្រាយបញ្ហាយេនឌ័រនៅក្នុងដំណើរការអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។

ស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ បានទទួលការគាំទ្រពីគោលការណ៍អនុវត្តស្នូលនៃគោលការណ៍ណែនាំ ស្តីពីការពិគ្រោះយោបល់ និងការចូលរួម ព្រមទាំងកឋាខ័ណ្ឌជាច្រើនដទៃទៀតនៅក្នុងអត្ថបទ (ប្រអប់ ៣.១)។

ប្រអប់ ៣.១ ៖ ស្ថាប័ន និង គោលការណ៍ណែនាំ

៣.ខ.៦ ការពិគ្រោះយោបល់ និងការចូលរួម ៖ ការចូលរួម និងការស្វែងរកកិច្ចគាំទ្រពីអ្នកដែលមានសិទ្ធិកាន់កាប់ស្របច្បាប់ ដែលអាចទទួលរងផលប៉ះពាល់ពីសេចក្តីសម្រេចចិត្ត មុនពេលដែលសេចក្តីសម្រេចចិត្តត្រូវបានធ្វើឡើង និងឆ្លើយតបទៅនឹងវិភាគទានរបស់ពួកគេ ដោយពិចារណាទៅលើអតុល្យភាពអំណាចដែលមានស្រាប់រវាងភាគី ផ្សេងៗគ្នា ព្រមទាំងធានាឱ្យមានការចូលរួមសកម្ម ដោយសេរី ប្រកបដោយប្រសិទ្ធភាព ប្រកបដោយអត្ថន័យ និងផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយ អំពីបុគ្គល និងក្រុមនានា នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលពាក់ព័ន្ធ។

៥.៣ រដ្ឋគួរធានាថា ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌរចនាសម្ព័ន្ធ សម្រាប់អភិបាលកិច្ចលើការកាន់កាប់ ទទួលស្គាល់ និងគោរពចំពោះសិទ្ធិកាន់កាប់ស្របច្បាប់ ដោយយោងតាមច្បាប់ជាតិ រាប់បញ្ចូលសិទ្ធិកាន់កាប់បែបប្រពៃណី ដែលបច្ចុប្បន្ន ពុំទទួលបានកិច្ចការពារពីច្បាប់... រដ្ឋគួរផ្តល់ក្របខ័ណ្ឌដែលពុំមានការរើសអើង និងលើកកម្ពស់សមធម៌សង្គម ព្រមទាំងសមភាពយេនឌ័រ។

៥.៦ រដ្ឋគួររៀបចំឱ្យមានការទទួលខុសត្រូវនៅគ្រប់កម្រិតនៃរដ្ឋាភិបាល ដែលអាចផ្តល់សេវាជូនដល់ប្រជាជនប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត... រដ្ឋគួរធានាឱ្យមានការសម្របសម្រួល រវាងទីភ្នាក់ងារអនុវត្ត ព្រមទាំងរដ្ឋាភិបាលមូលដ្ឋាន និងជនជាតិដើមភាគតិច និង សហគមន៍ដទៃទៀត ដែលមានប្រព័ន្ធកាន់កាប់បែបប្រពៃណី។

ប្រភព ៖ FAO, 2012b.

៦.១ ក្នុងកម្រិតដែលធនធានអនុញ្ញាត រដ្ឋគួរធានាថាទីភ្នាក់ងារអនុវត្ត និងអាជ្ញាធរយុត្តិធម៌មានសមត្ថភាពផ្នែកធនធានមនុស្ស សមត្ថភាពរូបវន្ត សមត្ថភាពហិរញ្ញវត្ថុ និងសមត្ថភាពក្នុងទម្រង់ដទៃទៀត ដើម្បីអនុវត្តគោលនយោបាយ និងច្បាប់ ឱ្យបានទាន់ពេលវេលា មានប្រសិទ្ធភាព និង ផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ។ បុគ្គលិកនៅគ្រប់កម្រិតរចនាសម្ព័ន្ធទាំងអស់ គួរបន្តទទួលបានការបណ្តុះបណ្តាល និង គួរត្រូវបានជ្រើសរើសក្រោមមូលដ្ឋាននៃការធានាឱ្យមានសមភាពយេនឌ័រ និងសមភាពសង្គម។

ស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី

ស្ថាប័នដីធ្លីរបស់រដ្ឋដែលមានការទទួលខុសត្រូវចំពោះអភិបាលកិច្ចលើការកាន់កាប់ដីធ្លី រួមមាន ទីភ្នាក់ងារដីធ្លីជាតិ និងស្ថាប័នរដ្ឋបាល និងគ្រប់គ្រងដីធ្លីថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន។ ស្ថាប័ននៅកម្រិតថ្នាក់ជាតិ ថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន មានតួនាទីផ្សេងៗគ្នានៅក្នុងដំណើរការអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។ ជាធម្មតា ទីភ្នាក់ងារ និងក្រសួងដែលទទួលបន្ទុកការងារដីធ្លីនៅកម្រិតថ្នាក់ជាតិ គឺជាអ្នកឃ្លាំមើលទៅលើការអភិវឌ្ឍន៍ និង ការអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្ត្រ ព្រមទាំងផ្តល់កិច្ចគាំទ្របច្ចេកទេសកម្រិតខ្ពស់។ ស្ថាប័ននៅកម្រិតថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន ផ្តោតយកចិត្តទុកដាក់សំខាន់ទៅលើការផ្តល់សេវាដែលពាក់ព័ន្ធនឹងដីធ្លីជូនដល់សាធារណជន ដូច្នេះ ជាញឹកញាប់ ស្ថាប័នទាំងនោះមានការពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លីប្រចាំថ្ងៃ។

ស្ថាប័នទាំងនេះ ប្រាស្រ័យទាក់ទងជាមួយស្ថាប័នដទៃទៀត ដែលមានទំនាក់ទំនងទៅនឹងបញ្ហាដីធ្លី ដូចជា ស្ថាប័នគ្រប់គ្រងតំបន់វាលស្មៅ គណៈកម្មាធិការគ្រប់គ្រងផ្ទៃរងទឹកភ្លៀង និងធារាសាស្ត្រ ស្ថាប័នរដ្ឋបាលដីធ្លីបែបប្រពៃណី និង ស្ថាប័នដែលទទួលខុសត្រូវចំពោះការធ្វើនិយ័តកម្មទៅលើសកម្មភាពសេដ្ឋកិច្ចមួយចំនួន ដូចជា ការទាញប្រយោជន៍ពីធនធានបែបពាណិជ្ជកម្ម (ឧ. កសិឧស្សាហកម្ម ជលផល រ៉ែ ទេសចរណ៍។ល។)។ រូបភាព ៣.១ បង្ហាញអំពីទំនាក់ទំនងមួយចំនួន។

ភាពជាតំណាង និង ការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី រួមមាន ការរៀបចំឱ្យស្ត្រីធ្វើជាមេដឹកនាំនៅក្នុងអង្គភាពធ្វើសេចក្តីសម្រេចចិត្ត និងជាអ្នកចូលរួមសកម្មនៅក្នុងដំណើរការរៀបចំផែនការ ព្រមទាំងអាចបង្កើនលទ្ធភាពនៃការសម្រេចបានលទ្ធផលការងារប្រកបដោយសមធម៌យេនឌ័រ ពីដំណើរការអភិបាលកិច្ចលើការកាន់កាប់ដីធ្លី (World Bank/FAO/IFAD, 2009a: 131)។

រូបភាព ៣.១ ៖ ការប្រាស្រ័យទាក់ទងក្នុងចំណោមស្ថាប័នដែលពាក់ព័ន្ធនៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី



រចនាសម្ព័ន្ធ ការភ្ជាប់ទំនាក់ទំនង និងនីតិវិធីប្រតិបត្តិការរបស់ស្ថាប័ន មានភាពខុសគ្នាក្នុងចំណោមបណ្តាប្រទេស និងបរិបទផ្សេងៗគ្នា។ ដូច្នេះ វិធានការដែលគេត្រូវការដើម្បីគាំទ្រចំពោះភាពជាតំណាង និងការចូលរួមរបស់ស្ត្រី នៅក្នុងស្ថាប័នដែលពាក់ព័ន្ធនៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ក៏នឹងមានភាពខុសគ្នាផងដែរ។

ឧទាហរណ៍ នៅក្នុងរដ្ឋពហុជាតិសាសន៍នៃប្រទេសបូលីវៀ មជ្ឈមណ្ឌលអានឡៀនសម្រាប់ទំនាក់ទំនង និងការអភិវឌ្ឍន៍ ដែលជាក្រុមសង្គមស៊ីវិលមួយ លើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងស្ថាប័នគ្រប់គ្រងដីធ្លីជនជាតិដើមភាគតិច តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំ (បទបង្ហាញរបស់ Patricia Costas នៅឯសិក្ខាសាលាបច្ចេកទេស ក្នុងខែឧសភា ឆ្នាំ២០១១)។ នៅក្នុងប្រទេសវ៉ាន់វ៉ាទូ ក្នុងឆ្នាំ២០០៨/ ២០០៩ មជ្ឈមណ្ឌលដីធ្លីជាតិរបស់រដ្ឋាភិបាល បានផ្តល់ការបណ្តុះបណ្តាលជូនដល់មន្ត្រីដីធ្លីថ្នាក់ស្រុក ស្តីពីភារកិច្ច និងមុខងាររបស់គណៈកម្មាធិការដីធ្លីថ្នាក់ស្រុក និងថ្នាក់មូលដ្ឋានថ្មី រាប់បញ្ចូលតាមរយៈការផ្តល់ព័ត៌មានដល់ពួកគេអំពីល័ក្ខខ័ណ្ឌតម្រូវផ្នែកច្បាប់ សម្រាប់ភាពជាតំណាង និងការចូលរួមរបស់ស្ត្រី (Elizabeth Daley, personal communication)។

បញ្ហាដទៃទៀតដែលត្រូវពិចារណា ទាក់ទងទៅនឹងគ្រឿងលើកទឹកចិត្តសម្រាប់បុគ្គលិក និងសមាជិកស្ថាប័នដីធ្លីដើម្បីលើកកម្ពស់សមធម៌យេនឌ័រនៅក្នុងស្ថាប័នរបស់ពួកគេ និង វិធីបង្កើតឱ្យមានឆន្ទៈ និងការប្តេជ្ញាចិត្ត ដើម្បីគាំទ្រជាទូទៅដល់ស្ថាប័នដីធ្លីប្រកបដោយសមធម៌យេនឌ័រ។

ស្ថាប័នរដ្ឋបាល និងគ្រប់គ្រងដីធ្លីថ្នាក់ជាតិ

ភាពជាតំណាង និងការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងស្ថាប័នរដ្ឋបាល និងគ្រប់គ្រងដីធ្លីថ្នាក់ជាតិ នៅតែបន្តជាបញ្ហាប្រឈមមួយ នៅក្នុងប្រទេសជាច្រើន អាស្រ័យដោយខ្វះឱកាស លក្ខណៈសម្បត្តិ និងការអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិក ដើម្បីធ្វើឱ្យប្រសើរឡើងនូវតុល្យភាពយេនឌ័រ។

កិច្ចខិតខំដើម្បីលើកទឹកចិត្តស្ត្រី ឱ្យធ្វើការងារនៅក្នុងស្ថាប័នដីធ្លី បានជម្រុញឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងទីភ្នាក់ងារដីធ្លីថ្នាក់ជាតិ ក្នុងប្រទេសចាម៉ៃកា ដូចមានរៀបរាប់នៅក្នុងប្រអប់ ៣.២។ ស្ថានភាពនៅក្នុងប្រទេសចាម៉ៃកា ទទួលបានជំនួយពីអត្រាអប់រំ និង អក្ខរកម្មស្ត្រីដែលមានកម្រិតខ្ពស់ជាទូទៅ នៅក្នុងតំបន់ការីបៀនទាំងមូល។ នៅក្នុងតំបន់ដែលអត្រាការអប់រំ និងអក្ខរកម្មរបស់ស្ត្រីមានកម្រិតទាបជាងបុរស គួរឱ្យកត់សម្គាល់ យុទ្ធសាស្ត្ររបស់ប្រទេសចាម៉ៃកា នឹងពុំមានភាពគ្រប់គ្រាន់ឡើយ។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រ នៅក្នុងស្ថាប័នរដ្ឋបាល និងគ្រប់គ្រងដីធ្លីថ្នាក់ជាតិ ជាធម្មតា គេតែងត្រូវការឱ្យមានសកម្មភាពវិជ្ជមាននៅក្នុងគោលនយោបាយការងារ និងការកំណត់រកឧបសគ្គនានាដែលស្ត្រីជួបប្រទះ ជាពិសេស នៅកម្រិតជាន់ខ្ពស់។ គេក៏ត្រូវការឱ្យមានយន្តការគ្រប់គ្រាន់ផងដែរ ដើម្បីធានាឱ្យមានភាពជាតំណាងរបស់ស្ត្រី នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដំណើរការរៀបចំផែនការ និងដំណើរការអនុវត្តន៍ ដែលប៉ះពាល់ដល់សិទ្ធិដីធ្លីរបស់ពួកគេ។

ប្រអប់ ៣.២ ៖

សមធម៌យេនឌ័រ នៅក្នុងស្ថាប័ន រដ្ឋបាលដីធ្លីថ្នាក់ជាតិ

ប្រភព ៖ Elizabeth Stair's presentation on "Land and gender: the Jamaican context" at the May 2011 technical workshop.

ទីភ្នាក់ងារដីធ្លីថ្នាក់ជាតិ (NLA) របស់*ប្រទេសចាម៉ៃកា* មានអាណត្តិការងារក្នុងការធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលដីធ្លី និង លើកកម្ពស់ការធ្វើឱ្យមានភាពប្រក្រតី ចំពោះការកាន់កាប់ដីធ្លីសម្រាប់ស្ត្រី និងបុរស បើទោះបីជាទីភ្នាក់ងារនេះ ពុំមានអាណត្តិការងារជាក់លាក់ ដើម្បីលើកកម្ពស់សមធម៌យេនឌ័រ នៅក្នុងការកាន់កាប់ដីធ្លី ឬអភិបាលកិច្ចលើការកាន់កាប់ដីធ្លីក៏ដោយ។ បើទោះជាដូច្នេះក្តី កម្មវិធីរដ្ឋបាល និងគ្រប់គ្រងដីធ្លីរបស់រដ្ឋាភិបាល (LAMP) សម្របសម្រួលទៅលើការចុះបញ្ជីដីធ្លី សម្រាប់គ្រួសារក្រីក្រក្នុងតម្លៃទាប អាស្រ័យដោយប្រមាណពីរភាគបីនៃគ្រួសារចាម៉ៃកា ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ មានស្ត្រីជាមេគ្រួសារ។ បន្ថែមពីនេះទៀត នៅក្នុងខែមេសា ឆ្នាំ២០១១ ទីភ្នាក់ងារដីធ្លីថ្នាក់ជាតិ បានបង្កើតជនបង្គោលយេនឌ័រ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការបំបែកទៅតាមភេទ ចំពោះទិន្នន័យដីធ្លី ដែលទីភ្នាក់ងារនេះប្រមូលបាន។

បុគ្គលិករបស់ទីភ្នាក់ងារដីធ្លីថ្នាក់ជាតិ មានតុល្យភាពយេនឌ័រ ដោយ ៥១% (២៩៧នាក់) ជាបុរស និង ៤៩% (២៩០នាក់) ជាស្ត្រី។ ក្រុមការងារគ្រប់គ្រង មាន ៥៧% (១៦នាក់) ជាបុរស និង ៤៣% (១២នាក់) ជាស្ត្រី។ បើទោះជាដូច្នេះក្តី នៅក្នុងមុខងារបច្ចេកទេសមួយចំនួន មានភាពខុសគ្នាយ៉ាងច្បាស់លាស់ចំពោះបញ្ហាយេនឌ័រ ដូចជា មានតែ ៦% ប៉ុណ្ណោះនៃមេធាវីរបស់ទីភ្នាក់ងារដីធ្លីថ្នាក់ជាតិជាបុរស និងមានតែ ២០% ប៉ុណ្ណោះនៃបុគ្គលិកអង្កេតរបស់ទីភ្នាក់ងារនេះជាស្ត្រី។ ក្នុងចំណោមបុគ្គលិកវាយតម្លៃដីធ្លី ដែលជាញឹកញាប់បុរសតែងមានចំនួនច្រើនជាង មានស្ត្រីចំនួន ៥២% ដែលត្រូវបានលើកទឹកចិត្តឱ្យចូលរួមនៅក្នុងវិជ្ជាជីវៈនេះ ពីអ្នកវាយតម្លៃដីធ្លីជាស្ត្រីដទៃទៀត។ ចំណុចនេះ បង្ហាញឱ្យឃើញអំពីតម្លៃរបស់មេដឹកនាំជាស្ត្រី ក្នុងការធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រ នៅក្នុងស្ថាប័ន

រដ្ឋបាល និងគ្រប់គ្រងដីធ្លីថ្នាក់ជាតិ។

ស្ថាប័នរដ្ឋបាល និងគ្រប់គ្រងដីធ្លីថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន

នៅក្នុងប្រទេសជាច្រើន រដ្ឋបាលដីធ្លីដែលធ្វើឡើងដោយរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងថ្នាក់ស្រុក គឺជាចំណុចស្នូលនៃការអនុវត្តន៍គោលនយោបាយ និង កម្មវិធីដីធ្លី ដោយមានបុគ្គលិកវិជ្ជាជីវៈនៅក្នុងស្ថាប័នថ្នាក់ស្រុក ដើរតួនាទីជាអន្តរការី រវាងទីភ្នាក់ងារដីធ្លី ឬ ក្រសួងថ្នាក់ជាតិ និងគណៈកម្មាធិការដីធ្លីមូលដ្ឋាននៅកម្រិតសហគមន៍។

វិមជ្ឈការបង្កើតឱ្យមានឱកាស និងបញ្ហាប្រឈម សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ ជាពិសេស ទាក់ទងទៅនឹងសិទ្ធិដីធ្លីរបស់ស្ត្រី។ បើពិនិត្យមើលលើទិដ្ឋភាពមួយផ្នែក វាជួយបង្កើនលទ្ធភាពឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រនៅក្នុងស្ថាប័នដីធ្លី អាស្រ័យដោយវិមជ្ឈការទាមទារឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន និង ក្រុមពាក់ព័ន្ធជាច្រើនយ៉ាងទូលំទូលាយ នៅក្នុងដំណើរការអភិបាលកិច្ចលើការកាន់កាប់ដីធ្លីដែលមានការពិគ្រោះយោបល់ (ILC, 2009: 3)។

បើពិនិត្យមើលទៅលើទិដ្ឋភាពមួយផ្នែកទៀត ស្ថាប័នដីធ្លីដែលត្រូវបានធ្វើវិមជ្ឈការ អាចមិនសូវទទួលយកការចូលរួម និងភាពជាតំណាងប្រកបដោយសមធម៌យេនឌ័រ។ ប្រសិនបើវិមជ្ឈការត្រូវបានអនុម័តយកមកអនុវត្ត គេត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេស ថាតើភារកិច្ចណាខ្លះដែលត្រូវធ្វើវិមជ្ឈការ និង កំណត់ឱ្យបានច្បាស់លាស់ទៅលើអាណត្តិការងារ តួនាទី និងការទទួលខុសត្រូវ។ បន្ថែមពីនេះទៀត ស្ថាប័នដីធ្លីដែលត្រូវបានធ្វើ-វិមជ្ឈការ អាចខកខានក្នុងការអនុវត្តន៍កូតាជាកំហិត ដែលត្រូវបានរៀបចំឡើងដើម្បីធានាឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រ ឬ សម្របសម្រួលការចូលរួមរបស់ស្ត្រី ត្រឹមកម្រិតអប្បបរមាដែលអាចទទួលយកបាន។ និយាមបទដ្ឋានវប្បធម៌ និង ឥរិយាបថចំពោះយេនឌ័រ និងដីធ្លី អាចមានភាពខ្លាំងក្លាជាងនៅកម្រិតអភិបាលកិច្ចដែលក្បែរសហគមន៍មូលដ្ឋានជាតិ (Whitechead and Tsikata, 2003)។ វិធានការដើម្បីលើកកម្ពស់ និង គាំទ្រឱ្យមានការចូលរួមរបស់ស្ត្រីប្រកបដោយប្រសិទ្ធភាព រាប់បញ្ចូលការបង្កើតឱ្យមានសមាជិក និងមេដឹកនាំជាស្ត្រី ក្នុងកម្រិតអប្បបរមាជាកំហិត ដែលធានាឱ្យមានភាពជាតំណាងពិតប្រាកដរបស់ស្ត្រីនៅក្នុងស្ថាប័នដីធ្លីថ្នាក់ស្រុក និង ថ្នាក់មូលដ្ឋាន។

ប្រអប់ ៣.៤ ផ្តល់ឧទាហរណ៍អំពីវិធានការលើកកម្ពស់ការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងស្ថាប័នដីធ្លីថ្នាក់មូលដ្ឋាន ខណៈពេលដែល *ម៉ូឌុល ៥* ពិភាក្សាអំពីសកម្មភាពផ្សព្វផ្សាយ និង លើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ ដែលគាំទ្រឱ្យមាន

ប្រអប់ ៣.៣ ៖

ការចូលរួមរបស់ស្ត្រីនៅក្នុងអភិបាលកិច្ចដីធ្លីក្នុងមូលដ្ឋាន

នៅក្នុងរដ្ឋអាំហារ៉ា នៃ*ប្រទេសអេត្យូពី* ការស្រាវជ្រាវតាមមូលដ្ឋានដែលធ្វើឡើងដោយវិទ្យាស្ថានអន្តរជាតិ សម្រាប់ការងារបរិស្ថាន និងអភិវឌ្ឍ បានរកឃើញថា បើទោះបីជាសមភាពយេនឌ័រ ត្រូវបានកំណត់នៅក្នុងគោលនយោបាយស្តីពីដីធ្លី ក្នុងតំបន់ក៏ដោយ ក៏នៅមានចន្លោះប្រហោងក្នុងការអនុវត្តន៍គោលនយោបាយនេះផងដែរ។ ការស្រាវជ្រាវរួមមាន ក្រុមពិភាក្សាជាមួយក្រុមស្ត្រី និងគណៈកម្មាធិការរដ្ឋបាលប្រើប្រាស់ដីធ្លី (LUACs) នៅកម្រិត Goat ដែលជាកម្រិតរដ្ឋបាលមូលដ្ឋានតូចជាងគេបំផុត ដើម្បីប្រមូលទស្សនៈ និងបទពិសោធន៍អំពីដំណើរការចុះបញ្ជីដីធ្លីក្នុងមូលដ្ឋាន។ ក្រុមពិភាក្សា និងកិច្ចសម្ភាសន៍ដោយឡែក ត្រូវបានធ្វើឡើងជាមួយគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងមន្ត្រីការិយាល័យនៃការិយាល័យរដ្ឋបាលធនធានធម្មជាតិ និងការប្រើប្រាស់ដីធ្លី នៅឯកម្រិត វ៉ូរេដា (ថ្នាក់ស្រុក)។

ប្រភព ៖ Hilhorst, 2010; Teklu, 2005

ការស្រាវជ្រាវបានរកឃើញថាមានស្ត្រីតិចតួចណាស់ ដែលស្ថិតនៅក្នុងគណៈកម្មាធិការរដ្ឋបាលប្រើប្រាស់ដីធ្លី ថ្នាក់ភូមិ និងថ្នាក់ Goat បើទោះបីជាមានសេចក្តីណែនាំពីថ្នាក់ស្រុកថា គណៈកម្មាធិការរដ្ឋបាលប្រើប្រាស់ដីធ្លីថ្នាក់ភូមិ ត្រូវមានសមាជិកជាស្ត្រី យ៉ាងហោចណាស់មានសមាជិកជាស្ត្រីចំនួន២រូប ក៏ដោយ។ ក្រុមពិភាក្សាបានបង្ហាញឱ្យដឹងថាស្ត្រីមិនបានចូលរួមនៅក្នុងកិច្ចប្រជុំ ដើម្បីជ្រើសរើសគណៈកម្មាធិការរដ្ឋបាលប្រើប្រាស់ដីធ្លីឡើយ ដោយសារតែពួកគេមិនបានចូលរួមកិច្ចប្រជុំខ្វះព័ត៌មានអំពីពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំ ឬ មើលឃើញថាការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការរដ្ឋបាលប្រើប្រាស់ដីធ្លីគឺជាការងារបុរស។ នៅឯការិយាល័យរដ្ឋបាលប្រើប្រាស់ដីធ្លីថ្នាក់ស្រុក (LUADs) ក៏ពុំមានបុគ្គលិកគ្រប់គ្រាន់ផងដែរ និង ពុំមានជនបង្គោលយេនឌ័រសម្រាប់ឃ្លាំមើលទៅលើដំណើរការចុះបញ្ជីដីធ្លី។ សមាជិកគណៈកម្មាធិការរដ្ឋបាលប្រើប្រាស់ដីធ្លី មានការយល់ឃើញ និង បកស្រាយខុសៗគ្នាទៅលើច្បាប់ ដែលបញ្ហានេះមួយផ្នែក គឺបណ្តាលមកពីការអប់រំរបស់ពួកគេមានកម្រិត ប៉ុន្តែ ក៏ដោយសារតែមន្ត្រីការិយាល័យស្រុកខ្វះការបណ្តុះបណ្តាល និង សមត្ថភាពក្នុងការតាមដានផងដែរ។

ស្ត្រីភាគច្រើន ដែលត្រូវបានពិគ្រោះយោបល់នៅក្នុងការស្រាវជ្រាវបានជឿយ៉ាងមុតមាំថា ការចូលរួមនៅក្នុងការចុះបញ្ជីដីធ្លី គឺជាភារកិច្ចរបស់បុរស ហើយការចូលរួមរបស់ស្ត្រីនៅក្នុងគណៈកម្មាធិការមូលដ្ឋានសម្រាប់ដំណើរការចុះបញ្ជី ក៏មិនធ្វើឱ្យមានភាពខុសប្លែកគ្នាអ្វីដែរ។ យ៉ាងណាមិញ ដំណើររឿងអំពីស្ត្រីម្នាក់ដែលស្ថិតនៅក្នុងគណៈកម្មាធិការរដ្ឋបាលប្រើប្រាស់ដីធ្លីថ្នាក់ Goat បានឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃសមាជិកគណៈកម្មាធិការជាស្ត្រី ៖

នាងមានអាយុ ៣៤ឆ្នាំ រៀបអាពាហ៍ពិពាហ៍រួច និងបានទទួលការអប់រំត្រឹមថ្នាក់ទី៧។ ការងារនេះ មានការលំបាកសម្រាប់នាងនៅពេលដំបូង អាស្រ័យដោយការយល់ឃើញជាទូទៅថា ស្ត្រីមិនអាចរ៉ាប់រងភារកិច្ចបែបនេះបាន។ យ៉ាងណាមិញ នាងបានបញ្ជាក់ថាខ្លួននាងមានសមត្ថភាព និងធ្វើការងារបានល្អជាងបុរសមួយចំនួន នៅក្នុងគណៈកម្មាធិការ ដែលចំណុចនេះ ត្រូវបានបញ្ជាក់យ៉ាងដូច្នេះ ពីសមាជិកគណៈកម្មាធិការដទៃទៀតជាបុរស និង មន្ត្រីការិយាល័យរដ្ឋបាលប្រើប្រាស់ដីធ្លីថ្នាក់ស្រុក។ តាមបទពិសោធន៍របស់នាង ស្ត្រីហាក់មានទំនោរការថា មានអារម្មណ៍ងាយស្រួលជាង ក្នុងការប្រាប់អំពីបញ្ហារបស់ពួកគេ ទៅកាន់ស្ត្រីដទៃទៀត ជាជាងការប្រាប់បញ្ហារបស់ពួកគេទៅកាន់បុរស។ នាងក៏បានធ្វើការកត់សម្គាល់ផងដែរថា ស្ត្រីហាក់មានភាពអព្យាក្រឹត្យជាង និងប្រតិបត្តិតាមច្បាប់នៅក្នុងការអនុវត្តន៍គោលនយោបាយដែលមានភាពរសើបបែបនេះ។ នាងបន្តបញ្ជាក់ឱ្យដឹងទៀតថា បុរសជាច្រើនបានព្យាយាមដកឈ្មោះរបស់ភរិយាពួកគេចេញពីការចុះបញ្ជី។ នៅក្នុងករណីជាច្រើន សមាជិកមួយចំនួនរបស់ គណៈកម្មាធិការរដ្ឋបាលប្រើប្រាស់ដីធ្លី បានឃុបឃិតជាមួយបុរសដែលជាស្វាមីទាំងនោះ

ការផ្លាស់ប្តូររយៈពេលវែងទៅលើគុណតម្លៃ និងឥរិយាបថ ដែលបានចាក់ឫសយ៉ាងជ្រៅ នៅក្នុងស្ថាប័ន និងក្រៅស្ថាប័ន។ នៅថ្នាក់មូលដ្ឋាន ស្ត្រីក៏អាចត្រូវបានគេរើសអើង និងដកចេញពីដំណើរការចុះបញ្ជីអំពីសិទ្ធិដីធ្លីបែបប្រពៃណីផងដែរ។ ការធានាឱ្យមានការចូលរួមរបស់ស្ត្រីកាន់តែច្រើនឡើង នៅក្នុងគណៈកម្មាធិការថ្នាក់មូលដ្ឋាន ដែលផ្តល់ និងគ្រប់គ្រងដីធ្លី អាចធ្វើឱ្យប្រសើរឡើងនូវឱកាសរបស់ស្ត្រី ក្នុងការទទួលបានប្រយោជន៍ពីការចុះបញ្ជី អំពីសិទ្ធិដីធ្លីបែបប្រពៃណី ដូចដែលប្រអប់ ៣.៣ បង្ហាញអំពីករណីពីរដ្ឋអាំហារ៉ា ក្នុងប្រទេសអេត្យូពី។

ជាធម្មតា សមាជិករបស់គណៈកម្មាធិការដីធ្លីមូលដ្ឋាន គឺជាអ្នកស្ម័គ្រចិត្តដែលត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត ឬ តាមរយៈការតែងតាំង ហើយឋានៈរបស់ពួកគេ ទាក់ទងទៅនឹងស្ថាប័នដីធ្លីស្របច្បាប់ មានភាពខុសប្លែកពីគ្នា (Hilhorst, 2010)។ សកម្មភាពសម្រាប់លើកទឹកចិត្តស្ត្រី និងក្រុមដែលត្រូវបានគេមើលរំលង ដើម្បីឱ្យចូលរួមនៅក្នុងស្ថាប័នមូលដ្ឋាន ដែលទទួលខុសត្រូវចំពោះអភិបាលកិច្ចលើការកាន់កាប់ដីធ្លី រួមមាន ការរៀបចំកិច្ចប្រជុំក្រុមស្ត្រីដោយឡែក ដើម្បីជួយដល់ពួកគេ ក្នុងការអភិវឌ្ឍន៍ទំនុកចិត្តលើបញ្ហា ដើម្បីត្រៀមលក្ខណៈសម្រាប់ចូលរួមនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការពេញអង្គ និងកិច្ចពិភាក្សាដែលមានលក្ខណៈកាន់តែទូលំទូលាយ (បទបង្ហាញរបស់ Rachael Knight នៅឯសិក្ខាសាលាបច្ចេកទេស ក្នុងខែឧសភា ឆ្នាំ២០១១)។

ដោយឡែក នាងជឿថាស្ត្រីគ្រប់រូប ដែលស្ថិតនៅក្នុងគណៈកម្មាធិការនេះ នឹងងើបឈរឡើង ដើម្បីសិទ្ធិស្ត្រី។

បើទោះជាដូច្នេះក្តី គេត្រូវការឱ្យមានការយកចិត្តទុកដាក់នៅពេលកំណត់អាណត្តិការងារអំពីការចូលរួមរបស់ស្ត្រីនៅក្នុងស្ថាប័នថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន។ វាពុំរមែងតែងតែមានប្រសិទ្ធភាពឡើយ ក្នុងការបង្កើតរចនាសម្ព័ន្ធដឹកនាំថ្មី ឬ កំណត់កម្រិតអប្បបរមានៃភាពជាតំណាង និងការចូលរួមរបស់ស្ត្រីនៅក្នុងស្ថាប័នដីធ្លី។ ការយល់ដឹងអំពីបញ្ហាសមធម៌យេនឌ័រ មានសារៈសំខាន់ដូចគ្នា ដូចដែលគម្រោងនៅក្នុងប្រទេសលីបេរីយ៉ា រៀបរាប់បង្ហាញនៅក្នុងប្រអប់ ២.៧ និង ២.១៤។ បើទោះបីជាការចូលរួមរបស់ស្ត្រី មិនត្រូវបានកំណត់នៅក្នុងប្រទេសលីបេរីយ៉ាក៏ដោយ ប៉ុន្តែលទ្ធផលរបស់គម្រោង រួមមានការបោះឆ្នោតជ្រើសរើសស្ត្រីជាអភិបាលក្រុង តាមរយៈភាពប្រសើរឡើងនៃការយល់ដឹងផ្ទាល់ខ្លួនរបស់ពួកគេ អំពីបញ្ហាសមធម៌យេនឌ័រ។ នៅពេលដែលភាពជាតំណាងរបស់ស្ត្រីអំពីស្ថាប័នដីធ្លីមូលដ្ឋាន ត្រូវបានកំណត់ថាជាកាតព្វកិច្ច វាអាចមានភាពប្រសើរបំផុត ក្នុងការទុកឱ្យស្ត្រី និងបុរស នៅក្នុងសហគមន៍ធ្វើការសម្រេចចិត្តដោយខ្លួនឯង អំពីរបៀបដែលពួកគេនឹងប្រតិបត្តិតាម (Knight, 2011)។

បញ្ជីផ្ទៀងផ្ទាត់ ៣.១ ៖
ការធានាឱ្យមានស្ថាប័នដីធ្លីដែលមានសមធម៌យេនឌ័រ

✓	បង្កើតយន្តការស្ថាប័ន រាប់បញ្ចូលទាំងយន្តការដែលមានមូលដ្ឋានផ្អែកលើសមាជិកភាព ដែលបង្កលក្ខណៈឱ្យស្ត្រីគាំទ្រ និង មានសម្លេងនៅក្នុងអង្គភាពរដ្ឋាភិបាលមូលដ្ឋាន។
✓	លើកទឹកចិត្តឱ្យមានការប្រើប្រាស់កូតាសមាជិកជាស្ត្រី និងបុរស នៅក្នុងទីភ្នាក់ងារដីធ្លីថ្នាក់ជាតិ និងគណៈកម្មាធិការដីធ្លីថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន។
✓	បង្កើតឱ្យមានកូតាស្ត្រី និងបុរស សម្រាប់កូរ៉ុម នៅឯកិច្ចប្រជុំរបស់ស្ថាប័នដីធ្លី។
✓	ផ្សព្វផ្សាយជូនដល់សមាជិកគ្រប់រូបនៃស្ថាប័នដីធ្លី អំពីសារៈសំខាន់នៃសមធម៌យេនឌ័រ នៅក្នុងដំណើរការ និងសមាសភាពរបស់ស្ថាប័នទាំងនោះ។
✓	លើកទឹកចិត្តឱ្យមានការចូលរួមរបស់ស្ត្រី នៅក្នុងកិច្ចប្រជុំអំពីបញ្ហាដីធ្លី និងស្ថាប័នដីធ្លី ដែលតំណាងឱ្យពួកគេ ឧទាហរណ៍តាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំដើម្បីបង្កើនសមត្ថភាពរបស់ពួកគេ។

ចូរចងចាំ!

ភាពជាតំណាងរបស់ស្ត្រីជាកំហិត នៅក្នុងស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី គឺជាចំណុចចាប់ផ្តើមមួយដ៏សំខាន់ ប៉ុន្តែ វាមិនទាន់គ្រប់គ្រាន់ឡើយ ដើម្បីធានាឱ្យមានការចូលរួមសកម្ម និងប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រី ជាមួយនឹងសហការីរបស់ពួកគេជាបុរស។ គេចាំបាច់ត្រូវផ្សព្វផ្សាយ និងកសាងសមត្ថភាពសម្រាប់សមាជិកគ្រប់រូបនៃស្ថាប័នដីធ្លី ដើម្បីគាំទ្រឱ្យមានអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។

ស្ថាប័នដែលទាក់ទងទៅនឹងដីធ្លី

ស្ថាប័នមួយចំនួនដូចជា គណៈកម្មាធិការគ្រប់គ្រងផ្ទៃរងទឹកភ្លៀង និងធារាស្ត្រក្នុងមូលដ្ឋាន ស្ថាប័នគ្រប់គ្រងតំបន់វាលស្មៅ និងស្ថាប័នរដ្ឋបាលដីធ្លីបែបប្រពៃណី រមែងតែងដោះស្រាយបញ្ហា ដែលពាក់ព័ន្ធទៅនឹងដីធ្លី និងធនធានធម្មជាតិដទៃទៀត ដូចជា ការទទួលបានទឹកសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋាន សិទ្ធិទទួលបានទឹកនៅតំបន់វាលស្មៅ សិទ្ធិតាមបែបប្រពៃណីក្នុងការទទួលបានទឹកសម្រាប់ធារាសាស្ត្រ និងការទទួលបានដីវាលស្មៅសម្រាប់ចិញ្ចឹមសត្វ (FAO, 2011a: 25)។ ដោយសារតែទំនាក់ទំនងជិតស្និទ្ធទាំងនេះ កំណែទម្រង់គោលនយោបាយដែលបានប៉ុនប៉ងធ្វើនិយ័តកម្មទៅលើធនធានធម្មជាតិដោយឡែកពីគ្នា រមែងតែងមានផលវិបាកដែលគេមិនបានដឹងមុន ទៅលើទម្រង់នៃការកាន់កាប់ និងប្រើប្រាស់ដីធ្លីក្នុងមូលដ្ឋាន រាប់បញ្ចូលផលប៉ះពាល់អវិជ្ជមានទៅលើស្ត្រីផងដែរ (Adams, Berkoff and Daley, 2006)។ ការធានាថា ស្ថាប័នក្នុងមូលដ្ឋានដែលដោះស្រាយបញ្ហាគ្រប់គ្រងផ្ទៃរងទឹកភ្លៀង ធារាសាស្ត្រ និងតំបន់វាលស្មៅ មានសមធម៌យេនឌ័រ អាចជួយឱ្យជៀសវាងបាននូវផលវិបាកមួយចំនួនដែលគេមិនបានមើលឃើញជាមុន។ ប្រអប់ ៣.៤ ផ្តល់នូវឧទាហរណ៍មួយចំនួនអំពីមេរៀនដែលបានរៀនសូត្រពីកិច្ចខិតខំលើកទឹកចិត្តឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រនៅក្នុងស្ថាប័នដែលទាក់ទងទៅនឹងដីធ្លី។

ប្រអប់ ៣.៤ ៖

ការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងស្ថាប័នដែលទាក់ទងទៅនឹងដីធ្លី

ប្រភព ៖ Seeley, Batra and Sarin, 2000; FAO, 2006a: 45–46; World Bank/FAO/IFAD, 2009c: 451–452 and 456–457; Flintan and Cullis, 2010; Agarwal, 2009.

នៅក្នុង*ប្រទេសឥណ្ឌា* គោលការណ៍ណែនាំស្តីពីផ្ទៃរងទឹកភ្លៀង ឆ្នាំ១៩៩៤ លើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើនពីស្ត្រី និង ក្រុមដែលត្រូវបានគេមើលរំលងនៅក្នុងការអភិវឌ្ឍន៍ផ្ទៃរងទឹកភ្លៀង។ គោលការណ៍ណែនាំនេះ អំពាវនាវឱ្យគម្រោងផ្ទៃរងទឹកភ្លៀងនានា បង្កើតក្រុមអ្នកប្រើប្រាស់ និងក្រុមជួយខ្លួនឯង ដែលរួមមាន ស្ត្រី ឬ សម្រាប់តែស្ត្រីប៉ុណ្ណោះ។ យ៉ាងណាមិញ ការចូលរួមប្រកបដោយសមធម៌យេនឌ័រ មានការលំបាកក្នុងការសម្រេចឱ្យបាន ហើយជំនួសឱ្យការដែលត្រូវបានគេទទួលស្គាល់ថាជាសមាជិកពេញសិទ្ធិនៃក្រុមគ្រប់គ្រងផ្ទៃរងទឹកភ្លៀង ជាទូទៅ ស្ត្រីត្រូវបានគេយល់ឃើញថាចូលរួមដើម្បីបំពេញកូតាប៉ុណ្ណោះ។ មួយផ្នែកនៃបញ្ហានេះ គឺដោយសារតែការគ្រប់គ្រងផ្ទៃរងទឹកភ្លៀងនៅក្នុងប្រទេសឥណ្ឌា ផ្តោតយកចិត្តទុកដាក់ទៅលើដីកសិកម្មនៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀងដែលគ្រប់គ្រងដោយបុរស។ ក្នុងឆ្នាំ១៩៩៩ ដើម្បីឆ្លើយតបទៅនឹងការរិះគន់ថា កម្មវិធីអភិវឌ្ឍន៍ផ្ទៃរងទឹកភ្លៀង គឺសម្រាប់តែបុរស រដ្ឋាភិបាលខេត្តអាន់ដ្រា ប្រាដេស បានធ្វើការភ្ជាប់ទំនាក់ទំនងជាផ្លូវការនូវក្រុមជួយខ្លួនឯងរបស់ស្ត្រី ចំនួន ១.២០០ក្រុម នៅក្នុងតំបន់ម៉ាហាប៊ូណាហ្គា ទៅនឹងកម្មវិធី ហើយអ្នកតំណាងមកពីក្រុមទាំងនេះ ដែលមានសមាសភាពមកពីក្រុមសង្គម និង ក្រុមបង្កើតប្រាក់ចំណូលផ្សេងៗគ្នា បានក្លាយជាអ្នកតំណាងស្ត្រី នៅក្នុងគណៈកម្មាធិការគ្រប់គ្រងផ្ទៃរងទឹកភ្លៀង។

នៅក្នុង*ប្រទេសអេត្យូពី* អភិក្រមបែបចូលរួមចំពោះការគ្រប់គ្រងដីស្ងួត នៅតំបន់វាលស្មៅ បានបើកចំហឱកាសថ្មីៗ សម្រាប់ការចូលរួមដែលមានសមធម៌យេនឌ័រប្រសើរជាងមុន។ ជោគជ័យជាច្រើន គឺបណ្តាលមកពីការកំណត់ផែនទីធនធាន តាមរយៈដំណើរការសហគមន៍មួយដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ ដែលលំហាត់កំណត់ផែនទី និងលំហាត់ប្រមូលព័ត៌មាន ត្រូវបានអនុវត្តជាមួយស្ត្រី និងបុរសដោយឡែកពីគ្នា។

សកម្មភាពបែបនេះ ជានាថាទស្សនៈ និង ការយល់ឃើញរបស់អ្នកប្រើប្រាស់ធនធានគ្រប់រូបត្រូវបានដាក់បញ្ចូល។
នៅក្នុង*ប្រទេសឥណ្ឌា* និង *ប្រទេសនេប៉ាល់* ភស្តុតាងបានឱ្យដឹងថា ការជំនះទៅលើឧបសគ្គនៃការចូលរួមរបស់ស្ត្រីនៅក្នុងអភិបាលកិច្ចព្រៃឈើ ទំនងនឹងមានផលប៉ះពាល់មួយដែលផ្តល់នូវសារៈប្រយោជន៍ទៅលើលទ្ធផលអភិរក្ស។ ឧទាហរណ៍ ការសិក្សាមួយបានរកឃើញថា ក្រុមគ្រប់គ្រងព្រៃឈើសហគមន៍ ដែលមានសមាមាត្រស្ត្រីច្រើននៅក្នុងគណៈកម្មាធិការប្រតិបត្តិរបស់ពួកគេ បាននាំឱ្យមានភាពរីកចម្រើនយ៉ាងខ្លាំងគួរឱ្យកត់សម្គាល់ចំពោះល័ក្ខខ័ណ្ឌព្រៃឈើ។ ក្រុមដែលមានគណៈកម្មាធិការប្រតិបត្តិគ្រប់រូបជាស្ត្រី នៅក្នុងប្រទេសនេប៉ាល់ ក៏ទទួលបានលទ្ធផលការងារដាំព្រៃឈើឡើងវិញ ប្រសើរជាងក្រុមដទៃទៀតផងដែរ បើទោះបីជាពួកគេគ្រប់គ្រងទៅលើព្រៃដែលមានទំហំតូចជាង និងមានភាពវិចវិលខ្លាំងជាងក៏ដោយ។
នៅក្នុង*ប្រទេសអេហ្ស៊ីប* គម្រោងគ្រប់គ្រងធនធានម៉ាទ្រូ របស់ធនាគារពិភពលោក មានបំណងទម្លាយវដ្តនៃការវិចវិលធនធានធម្មជាតិ និង ភាពក្រីក្រនៅក្នុងសហគមន៍បេដូអ៊ីន។ គម្រោងនេះ ធ្វើការងារជាមួយក្រុមសហគមន៍ដើម្បីកំណត់អំពីសេចក្តីត្រូវការរបស់ស្ត្រី និងបុរស និង ធានាថា ពួកគេចូលរួមនៅក្នុងការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងធនធានក្នុងមូលដ្ឋាន។ ដើម្បីបង្កលក្ខណៈឱ្យក្រុមសហគមន៍នេះ អាចដោះស្រាយបញ្ហាយេនឌ័រប្រកបដោយប្រសិទ្ធភាព បុគ្គលិកគម្រោងបានទទួលការបណ្តុះបណ្តាលអំពីយេនឌ័រ ហើយភ្នាក់ងារផ្សព្វផ្សាយជាស្ត្រី នៅក្នុងតំបន់អនុគម្រោងនីមួយៗ ធ្វើការងារដោយផ្ទាល់ជាមួយស្ត្រី។
កម្មវិធីគ្រប់គ្រងធនធានកសិកម្ម ដែលផ្តោតយកចិត្តទុកដាក់លើកសិករ (FARM) ដែលអនុវត្តដោយអង្គការ FAO និងគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) នៅក្នុង*ប្រទេសចិន ឥណ្ឌា ឥណ្ឌូនេស៊ី នេប៉ាល់ ហ្វីលីពីន ស្រីលង្កា ថៃ និងវៀតណាម* ចន្លោះពីឆ្នាំ១៩៩៣ និង ឆ្នាំ១៩៩៨ បានលើកកម្ពស់សន្តិសុខស្បៀងគ្រួសារ និងការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព នៅក្នុងវិស័យកសិកម្មក្នុងតំបន់រងទឹកភ្លៀង ដែលគ្មានលក្ខណៈអំណោយផលផ្នែកអេកូឡូស៊ី។ កម្មវិធីនេះបានលើកទឹកចិត្តឱ្យមានការចូលរួមពីស្ត្រី នៅគ្រប់កម្រិតទាំងអស់នៃដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងសកម្មភាពដទៃទៀត។ កម្មវិធីគ្រប់គ្រងធនធានកសិកម្ម ដែលផ្តោតយកចិត្តទុកដាក់លើកសិករ បានប្រើប្រាស់អភិក្រមរៀបចំផែនការប៉ាន់ប្រមាណបែបចូលរួម ដែលបញ្ចូលឧបករណ៍វិភាគយេនឌ័រទៅតាមភាពជាក់ស្តែងមួយ ដើម្បីត្រួតពិនិត្យទៅលើសកម្មភាព បញ្ហា ចំណេះដឹង និងការទទួលបានធនធានធម្មជាតិសម្រាប់ស្ត្រី និង បុរស ព្រមទាំងអនុវត្តធ្វើការបណ្តុះបណ្តាលគ្រូបង្គោល ក្រោមកម្មវិធីវិភាគសង្គមសេដ្ឋកិច្ច និងយេនឌ័រ (SEAGA) របស់អង្គការ FAO។ លទ្ធផលដែលទទួលបាន គឺការយល់ដឹងប្រសើរជាងមុនអំពីបញ្ហាសមធម៌សង្គម នៅក្នុងចំណោមសមាជិកសហគមន៍ ដោយស្ត្រីចាប់ផ្តើមដើរតួនាទីសំខាន់នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការដឹកនាំ។
នៅក្នុង*ប្រទេសប៉ាគីស្ថាន* អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមានឈ្មោះថា ប៉ាតាន់ គាំទ្រដល់អង្គការសហគមន៍ ដែលពុំមានភាពជាតំណាងគ្រប់គ្រាន់ និង អភិវឌ្ឍស្ថាប័នក្នុងមូលដ្ឋានឱ្យមានសមធម៌យេនឌ័រ ដើម្បីបង្កើនសមត្ថភាពរបស់សហគមន៍ ក្នុងការ

ដោះស្រាយទៅនឹងគ្រោះមហន្តរាយធម្មជាតិ ដូចជា ទឹកជំនន់។ អង្គការប៉ាតាន់ បានធ្វើការងារជាមួយសហគមន៍ ដើម្បីរៀបចំឱ្យមានអ្នកតំណាង និងវេទិកាប្រជាធិបតេយ្យ ដែលមានឈ្មោះថា ប៉ាតាន់ ដេហ៊ី តាន់ហ៊្វីមស៍ (PDTs) សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តជាសមូហភាព។ ដោយមានការហាមឃាត់ពីប្រពៃណីក្នុងមូលដ្ឋានមិនឱ្យចូលរួមនៅក្នុងវេទិកា PDTs ស្ត្រីបានបង្កើតវេទិកាផ្ទាល់ខ្លួនរបស់ពួកគេ។ នៅពេលដែលទឹកជំនន់ឆ្នាំ១៩៩២ បានបំផ្លិចបំផ្លាញភូមិជាច្រើន អង្គការប៉ាតាន់ បានផ្តួចផ្តើមគម្រោងមួយ ដើម្បីស្តារលំនៅដ្ឋានឡើងវិញ ដោយមានស្ត្រីចូលរួមនៅក្នុងគម្រោង PDTs។ នៅក្នុងប្រទេសប៉ាគីស្ថាន ស្ត្រីរក្សារចនាបទលំនៅដ្ឋានបែបប្រពៃណី (កាថា) ប៉ុន្តែគម្រោងបានឱ្យពួកគេចូលរួមនៅក្នុងការរចនា និង សាងសង់លំនៅដ្ឋានដែលមានរចនាបទប្រសើរជាងមុន (ប៉ាកា)។ អង្គការប៉ាតាន់ បានណែនាំអំពីគោលគំនិតសហកម្មសិទ្ធិភាពទៅលើលំនៅដ្ឋានថ្មីនេះ និង បានផ្តល់កម្ចីដល់គ្រួសារដែលស្ត្រីជាអ្នកទទួលខុសត្រូវក្នុងការសង។ នៅពេលដំបូង បុរសជំទាស់ទៅនឹងការដែលស្ត្រីទទួលយកការទទួលខុសត្រូវនេះ ប៉ុន្តែនៅទីបំផុត ពួកគេបានមើលឃើញអំពីតម្លៃនៃ សហកម្មសិទ្ធិភាព។ បទពិសោធន៍ដែលទទួលបានពីគម្រោងស្តារលំនៅដ្ឋាននេះ បានផ្តល់ទំនុកចិត្តដល់ស្ត្រីក្នុងការធ្វើសកម្មភាពសមូហភាពនៅក្នុងគម្រោងដទៃទៀត។

ការធ្វើការងារជាមួយស្ថាប័នដីធ្លីបែបប្រពៃណី

នៅក្នុងប្រទេសជាច្រើន ស្ថាប័នបែបប្រពៃណីគ្របដណ្តប់ទៅលើរាល់ទិដ្ឋភាពផ្នែកសង្គម វប្បធម៌ សេដ្ឋកិច្ច និង នយោបាយរបស់ប្រជាជន និង ដើរតួនាទីមួយដ៏សំខាន់ក្នុងការគ្រប់គ្រងទៅលើសិទ្ធិទទួលបានដីធ្លី ទឹក និង វាលស្មៅសម្រាប់ចិញ្ចឹមសត្វ។ ដូច្នេះ ស្ថាប័នរដ្ឋបាលដីធ្លីបែបប្រពៃណី គួរទទួលបានការគាំទ្រក្នុងលក្ខណៈជាផ្នែកមួយនៃអភិក្រមទូលំទូលាយ និង ជាក់ស្តែង ដើម្បីឱ្យមានការផ្លាស់ប្តូរ (Daley and Englert, 2010)។

ស្ថាប័នបែបប្រពៃណីដែលគ្របដណ្តប់ដោយបុរស រើសអើង និងមិនរាប់បញ្ចូលស្ត្រី គួរទទួលបានជំនួយក្នុងការជំនះទៅលើឧបសគ្គទាំងនេះ និងទទួលយកគោលការណ៍សមធម៌យេនឌ័រ។ ឧទាហរណ៍ មេដឹកនាំបែបប្រពៃណី និងស្ត្រីនៅថ្នាក់មូលដ្ឋាន អាចចូលរួមក្នុងការបែងចែករវាងការអនុវត្តន៍វប្បធម៌ ដែលគាំទ្រដល់សិទ្ធិដីធ្លីរបស់ស្ត្រី និង ការអនុវត្តន៍វប្បធម៌ដែលមិនគាំទ្រសិទ្ធិដីធ្លីរបស់ស្ត្រី។ ជម្រើសដទៃទៀត រួមមានការផ្តល់ការបណ្តុះបណ្តាលសហគមន៍សម្រាប់មេដឹកនាំជាបុរស និងស្ត្រី ការបង្ហាញអំពីករណីអនុវត្តល្អ និងការលើកកម្ពស់ឱ្យមានការផ្លាស់ប្តូរ បទពិសោធន៍គ្នាទៅវិញទៅមក (WLLA, 2010a)។

ដូចមានគូសបញ្ជាក់នៅក្នុង *ម៉ូឌុល២* ជួនកាល ស្ត្រីមានភាពងាយស្រួលជាងក្នុងការទៅរកមេដឹកនាំបែបប្រពៃណីក្នុងមូលដ្ឋាន បើធៀបទៅនឹងការប្រាស្រ័យទាក់ទងជាមួយស្ថាប័នផ្លូវការ ជាពិសេស នៅពេលដែលស្ថាប័នផ្លូវការ គឺជាស្ថាប័នដែលថ្មី (FAO, 2011a: 17)។ ស្ត្រីអាចមានស្ថាប័នបែបប្រពៃណីផ្ទាល់ខ្លួនដោយឡែកពីគ្នា ដែលអាចដាក់បញ្ចូលទៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ ដោយពុំចាំបាច់ត្រូវបង្កើតស្ថាប័នថ្មី (Flintan, 2010b)។

ស្ថាប័នរដ្ឋបាលដីធ្លីបែបប្រពៃណី អាចដើរតួនាទីមួយដ៏សំខាន់ក្នុងការជះឥទ្ធិពលឱ្យមានការផ្លាស់ប្តូរងាកទៅរក

ការអនុវត្តន៍កាន់កាប់ដែលមានសមធម៌យេនឌ័រប្រសើរជាងមុន ដូចមានរៀបរាប់នៅក្នុងប្រអប់ ៣.៥ អំពីករណី ពីប្រទេសយូហ្គាន់ដា និង ម៉ាឡាវី។

ប្រអប់ ៣.៥ ៖

ការធ្វើការងារជាមួយស្ថាប័នបែបប្រពៃណី

ប្រភព ៖ WOLREC, 2011; ULA, 2010; Adoko, 2011; Akin, no date.

ចលនាសមធម៌ដីធ្លីនៅក្នុង*ប្រទេសយូហ្គាន់ដា* (LEMU) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ ដើម្បីលើកកម្ពស់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីបែបប្រពៃណីប្រកបដោយសមធម៌យេនឌ័រ នៅក្នុងប្រទេសយូហ្គាន់ដា ភាគខាងជើង និងភាគខាងកើត។ ចលនានេះ មានការចូលរួមពីអាជ្ញាធរប្រពៃណីក្នុងមូលដ្ឋាន ក្នុងការបង្កើតឱ្យមានការឯកភាពជារួម និងការលើកទឹកចិត្តឱ្យមានសុខដុមនីយកម្មទៅលើប្រព័ន្ធបែបប្រពៃណី និងប្រព័ន្ធតាមផ្លូវច្បាប់ ដើម្បីលើកកម្ពស់ការជានាឱ្យបាននូវសិទ្ធិដីធ្លី។ សកម្មភាពលើកកម្ពស់ការយល់ដឹងរបស់ចលនាសមធម៌ដីធ្លី នៅក្នុងប្រទេសយូហ្គាន់ដា រួមមាន ៖

- ការចងក្រងឯកសារអំពីច្បាប់ប្រពៃណីនៅក្នុងក្រមអនុវត្ត សម្រាប់ចែកចាយជូន ដល់តុលាការផ្លូវការ។
- ការគាំទ្រដល់សហគមន៍ក្នុងការកំណត់ព្រំប្រទល់កម្មសិទ្ធិភាពដីធ្លីរបស់ពួកគេ និង ប្រើប្រាស់សិទ្ធិតាមរយៈវិធីសាស្ត្រក្នុងមូលដ្ឋានមួយចំនួន ដូចជា ការដាំដើមឈើ និងការគូសផែនទី។
- ការបណ្តុះបណ្តាលនគរបាលអំពីសិទ្ធិដីធ្លីបែបប្រពៃណី និង ការគាំទ្រចំពោះការ អនុវត្តន៍ដីកា។
- ការបណ្តុះបណ្តាលនិស្សិតសកលវិទ្យាល័យអំពីការកាន់កាប់ដីធ្លីតាមបែបប្រពៃណី និងការបង្កើតឱកាសសម្រាប់ពួកគេធ្វើការសម្រុះសម្រួលនៅក្នុងបញ្ហាវិវាទដីធ្លីជាក់ស្តែង។

យោងតាមសំណើរបស់រដ្ឋាភិបាលថ្នាក់ស្រុក និងក្រសួងដែនដី ចលនាសមធម៌ដីធ្លី នៅក្នុងប្រទេសយូហ្គាន់ដា បានផ្តល់ការបណ្តុះបណ្តាលជូនដល់មេដឹកនាំបែបប្រពៃណី និង សមាជិកគណៈកម្មាធិការដីធ្លីក្នុងមូលដ្ឋាន អំពីច្បាប់ភូមិបាលបែបគតិយុត្តិ និងបែបប្រពៃណី និងការកាត់បន្ថយជម្លោះ ព្រមទាំងបណ្តុះបណ្តាលអំពីការរៀបចំបង្កើតតំបន់គណៈកម្មាធិការដីធ្លី សម្រាប់រដ្ឋបាលដីធ្លីក្នុងមូលដ្ឋាន។

នៅក្នុង*ប្រទេសម៉ាឡាវី* ការសិក្សាស្រាវជ្រាវមួយ ដែលធ្វើឡើងដោយមជ្ឈមណ្ឌលធនធានច្បាប់ស្ត្រី (WOLREC) ដែលទទួលបានមូលនិធិគាំទ្រពី សម្ព័ន្ធភាពដីធ្លីអន្តរជាតិ (ILC) បានធ្វើការងារជាមួយប្រធានសហគមន៍ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរសង្គម សំដៅអនុញ្ញាតឱ្យស្ត្រីមេម៉ាយ អាចមានលទ្ធភាពទទួលបានដីធ្លី។ ប្រធានសហគមន៍បានទទួលស្គាល់ថា ការផ្តល់ជំនូនអាពាហ៍ពិពាហ៍ជូនដល់ភាគីខាងបុរស ផ្តល់ឱកាសសម្រាប់ស្ត្រីមេម៉ាយក្នុងការចរចារអំពីការទទួលបានដីធ្លី។ ជាធម្មតា ស្ត្រីមេម៉ាយត្រូវបានដកហូតទ្រព្យសម្បត្តិ ដែលភាគច្រើន គឺដោយសារតែការខ្សត់ដី នាំឱ្យគ្រួសាររបស់ស្វាមីដែលបានស្លាប់បាត់បង់ជីវិត ធ្វើការប្រឆាំងទៅនឹងគំនិតបែបប្រពៃណី ដែលស្ត្រីទទួលបានកម្មសិទ្ធិភាពរួមគ្នា ចំពោះដីធ្លីរបស់ស្វាមីពួកគេ ក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ក្រោយពេលដែលមានកិច្ចខិតខំពីការសិក្សានេះ មេដឹកនាំសហគមន៍មួយចំនួន បានចាប់ផ្តើមធ្វើការប្រានចោលនូវការដកហូតកម្មសិទ្ធិភាពដីធ្លីរបស់ស្ត្រីមេម៉ាយ នៅតាមកិច្ចប្រជុំសាធារណៈ ពិធីបុណ្យសព និងការជួបជុំគ្នាដទៃទៀត នៅ

ក្នុងភូមិ។ យ៉ាងណាមិញ ជាដំបូង ការសិក្សាត្រូវជំនះទៅលើភាពមានកម្រិតមួយចំនួន ដែលរាប់បញ្ចូលទាំងភាពស្ទាក់ស្ទើរនៅពេលដំបូង របស់មេដឹកនាំសហគមន៍ ការភ័យខ្លាចចំពោះអាជ្ញាធរកម្រិតខ្ពស់ជាង និង កង្វះចំណេះដឹងអំពីច្បាប់ភូមិបាលដែលមានលក្ខណៈបែបគតិយុត្តិ។

✎បញ្ជីផ្ទៀងផ្ទាត់ ៣.២ ៖

ការធ្វើការងារជាមួយស្ថាប័នបែបប្រពៃណី និងស្ថាប័នមូលដ្ឋាន

ប្រភព ៖ Judy Adoko's paper on "Constructive ways of working with customary institutions in support of women's land rights" at the May 2011 technical workshop; Flintan, 2010a; 2010b.

✓	ស្រាវជ្រាវអំពីការអនុវត្តន៍ និងស្ថាប័នកាន់កាប់បែបប្រពៃណី និងលើកកម្ពស់ការយល់ដឹងអំពីការអនុវត្តន៍ និងស្ថាប័នកាន់កាប់បែបប្រពៃណី នៅក្នុងចំណោមអ្នកបង្កើតគោលនយោបាយ និងអ្នកបង្កើតច្បាប់នៅកម្រិតថ្នាក់ជាតិ។ ស្វែងយល់អំពីរបៀបធ្វើសេចក្តីសម្រេចចិត្តទៅលើអភិបាលកិច្ចលើការកាន់កាប់ដីធ្លី និង ប្រែក្លាយឱ្យទៅជាសកម្មភាព និងលទ្ធផលការងារ។
✓	កំណត់រកការអនុវត្តន៍ ដំណើរការ និងស្ថាប័នបែបប្រពៃណី ដែលគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ និង ស្វែងរកធ្វើការលុបបំបាត់ការអនុវត្តន៍ ដំណើរការ និងស្ថាប័នទាំងឡាយណាដែលរើសអើង ឬ មិនរាប់បញ្ចូលស្ត្រី។
✓	ផ្សព្វផ្សាយដល់មេដឹកនាំបែបប្រពៃណី និងសមាជិកស្ថាប័នដែលទាក់ទងទៅនឹងដីធ្លីក្នុងមូលដ្ឋាន អំពីសារៈសំខាន់នៃអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ និងគាំទ្រដល់ពួកគេក្នុងការសម្របខ្លួនទៅនឹងដំណើរការអភិបាលកិច្ចថ្មី។ មិនត្រូវសន្មតថា មេដឹកនាំបែបប្រពៃណីទាំងអស់ សុទ្ធសឹងតែប្រឆាំងទៅនឹងការផ្លាស់ប្តូរឡើយ។
✓	គាំទ្រដល់រដ្ឋបាលដីធ្លី តាមរយៈស្ថាប័នបែបប្រពៃណី និងស្នើសុំឱ្យរដ្ឋាភិបាលធ្វើឱ្យស្ថាប័នបែបប្រពៃណីទាំងនោះមានគណនេយ្យភាព ចំពោះសមធម៌យេនឌ័រ។
✓	បញ្ចូលស្ថាប័ន និងវេទិកាបែបប្រពៃណីដែលមានស្រាប់របស់ស្ត្រី ទៅក្នុងការរៀបចំអភិបាលកិច្ចលើការកាន់កាប់ដីធ្លីក្នុងមូលដ្ឋាន។

ចូរចងចាំ!

ជាញឹកញាប់ ស្ថាប័នបែបប្រពៃណីដែលមានស្រាប់ គឺជាទីកន្លែងដែលប្រសើរបំផុតសម្រាប់ ចាប់ផ្តើមបន្តអនុវត្តអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយការទទួលខុសត្រូវ និង មានសមធម៌យេនឌ័រនៅថ្នាក់មូលដ្ឋាន។

ស្ថាប័នដទៃទៀត

ប្រព័ន្ធយុត្តិធម៌ដែលមានតុលាការ និងការិយាល័យរបស់ខ្លួន នៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានទូទាំងប្រទេស ក៏មានតួនាទីគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រផងដែរ។ ចៅក្រម ព្រះរាជអាជ្ញា នាយនគរបាល និងមន្ត្រីដទៃទៀត ត្រូវដឹងអំពីច្បាប់ដែលបានចែងអំពីសមភាពយេនឌ័រចំពោះសិទ្ធិទទួលបានដីធ្លី និង ទ្រព្យសម្បត្តិ និង ឧបសគ្គដែលក្រុមប្រជាជនផ្សេងៗគ្នាជួបប្រទះ ក្នុងការព្យាយាមការពារសិទ្ធិរបស់ពួកគេ។ ដូចមានគូសបញ្ជាក់នៅក្នុង *ម៉ូឌុល២* ការគាំទ្រឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌

ជួយធ្វើឱ្យលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ កាន់តែមានភាពប្រសើរឡើង។

ផលិតករ និងអង្គការកសិករ អាចគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រនៅថ្នាក់មូលដ្ឋាន។ ស្ថាប័នទាំងនេះ រមែងតែងដើរតួនាទីជាអន្តរការី រវាងសហគមន៍មូលដ្ឋាន និងអង្គភាពបង្កើតគោលនយោបាយនៅកម្រិតថ្នាក់ជាតិ និងសកល និង ក្រសួងរដ្ឋាភិបាល ព្រមទាំងចូលរួមនៅក្នុងការតស៊ូមតិដែលមានសារៈប្រយោជន៍ទាក់ទងទៅនឹងបញ្ហាដីធ្លី និង សកម្មភាពផ្សព្វផ្សាយព័ត៌មាននៅកម្រិតផ្សេងៗគ្នា។ ការគាំទ្រចំពោះភាពជាតំណាងរបស់ស្ត្រីនៅក្នុងអង្គការជនបទ ជួយសម្របសម្រួលឱ្យមានសមធម៌យេនឌ័រនៅក្នុងដំណើរការគ្រប់គ្រង និង ដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ថាប័នទាំងនេះ ក៏ដូចជានៅក្នុងដំណើរការអភិបាលកិច្ចលើការកាន់កាប់ដីធ្លីដែលកាន់តែទូលំទូលាយ (FAO, 2011a: 11)។

សមភាពយេនឌ័រ និងការចូលរួមរបស់បុគ្គលគ្រប់រូប ទាំងស្ត្រី និងបុរស នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងស្ថាប័ននានា គឺជាសិទ្ធិមនុស្សមួយ ហើយភស្តុតាងបានឱ្យដឹងថា ការបង្កលក្ខណៈឱ្យមានការចូលរួមពីស្ត្រីនៅក្នុងមូលដ្ឋាន ព្រមជាមួយនឹងបុរស នៅក្នុងគ្រប់ស្ថាប័នទាំងអស់ដែលទាក់ទងទៅនឹងដីធ្លី ក៏អាចធ្វើឱ្យប្រសើរឡើងផងដែរ នូវលទ្ធផលសមធម៌យេនឌ័រជារួមសម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លី។ ប្រអប់ ៣.៤ ផ្តល់នូវឧទាហរណ៍ អំពីការអនុវត្តន៍ល្អនៅក្នុងចំណុចនេះ។

ការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ

គេត្រូវការឱ្យមានវិធានការអភិវឌ្ឍសមត្ថភាពជាក់លាក់ ដើម្បីដោះស្រាយបញ្ហារបស់ស្ត្រី ដែលទាក់ទងទៅនឹងកង្វះលទ្ធភាពទទួលបានការអប់រំឧត្តមសិក្សា និង កង្វះការលើកទឹកចិត្តឱ្យសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកទេស ដែលរារាំងស្ត្រីមិនឱ្យចូលទៅក្នុងវិជ្ជាជីវៈបច្ចេកទេសមួយចំនួនក្នុងវិស័យដីធ្លី។ គេក៏ត្រូវការឱ្យមានការអភិវឌ្ឍន៍សមត្ថភាពទូទៅផងដែរ នៅក្នុងស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ដើម្បីបង្កើនចំណេះដឹងនិងការយល់ដឹងអំពីបញ្ហាយេនឌ័រ។ ប្រអប់ ៣.៦ ផ្តល់ឧទាហរណ៍អំពីការអនុវត្តន៍ល្អ នៅក្នុងការអភិវឌ្ឍន៍សមត្ថភាពស្ថាប័នប្រកបដោយសមធម៌យេនឌ័រ។

ប្រអប់ ៣.៦ ៖

ការកសាងសមត្ថភាពសម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ

នៅក្នុង*ប្រទេសឥណ្ឌា* ចន្លោះពីឆ្នាំ២០០១ និងឆ្នាំ២០០៩ គម្រោងអភិវឌ្ឍផ្ទៃរងទឹកភ្លៀងកាណាតាកា ដែលទទួលបានមូលនិធិគាំទ្រពីធនាគារពិភពលោក មានបំណងធ្វើឱ្យប្រសើរឡើងនូវសក្តានុពលដែលប្រកបដោយផលិតភាពនៃផ្ទៃរងទឹកភ្លៀង នៅក្នុងស្រុកចំនួន៧ នៃរដ្ឋកាណាតាកា តាមរយៈការចូលរួមពីពលរដ្ឋក្នុងមូលដ្ឋាន នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិសហគមន៍ រាប់បញ្ចូលតាមរយៈការបង្កើនឱកាសសម្រាប់ស្ត្រីដើម្បីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ គម្រោងបានអភិវឌ្ឍឱ្យមានភាពជាដៃគូជាមួយជំនាញការបច្ចេកទេសរបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ អាជ្ញាធរមូលដ្ឋាន និងអង្គការស្រាវជ្រាវ ព្រមទាំងបានរៀបចំបង្កើតអង្គការសហគមន៍ ដូចជាក្រុមស្ត្រី និងក្រុមប្រជាពលរដ្ឋគ្មានដី ដែលត្រូវបានភ្ជាប់ទំនាក់

ប្រភព ៖ World Bank/FAO/IFAD, 2009b: 457 and 463–465; ADB, 2006;

ទំនងជាផ្លូវការជាមួយកម្មវិធីផ្ទេរវង់ទឹកភ្លៀង។ ការបង្កើតឱ្យមាននូវវេទិកាសម្រាប់តែស្ត្រីដែលគាំទ្រដោយបុរស បានលើកទឹកចិត្តឱ្យមានការធ្វើសេចក្តីសម្រេចចិត្តរួមគ្នា និងកម្មសិទ្ធិភាពទៅលើទ្រព្យសម្បត្តិរួមគ្នាផងដែរ។ ប្រយោជន៍ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការទទួលបានសុខភាព ការអប់រំ និង បទដ្ឋាននៃជីវភាពរស់នៅជារួមប្រសើរជាងមុន សម្រាប់គ្រួសារដែលបានចូលរួម។

Khudayberdiyeva, 2009; Djusaeva, 2012.

នៅក្នុង*ប្រទេសតាជីគីស្ថាន* កម្មវិធីដែលគាំទ្រដោយអង្គការ UN Women បានគាំទ្រដល់ការអនុម័តប្រើប្រាស់យន្តការមួយ សម្រាប់ផ្តល់ឱ្យទីភ្នាក់ងារដីធ្លីនូវមតិយោបល់ត្រឡប់របស់ប្រជាពលរដ្ឋអំពីកំណែទម្រង់ដីធ្លីដែលកំពុងតែបន្តអនុវត្ត។ យន្តការនេះបានប្រើប្រាស់ទំនាក់ទំនងទ្វេទិស រវាងទីភ្នាក់ងារដីធ្លីថ្នាក់ស្រុក និងប្រជាពលរដ្ឋជនបទដោយសង្កត់ធ្ងន់លើកិច្ចខិតខំសំដៅលុបបំបាត់នូវទម្លាប់វប្បធម៌ និងសង្គមដែលនៅតែមានភាពរឹងមាំនៅឡើយ ក្នុងតំបន់ជនបទ។ ការអនុវត្តន៍សាកល្បងនូវយន្តការផ្តល់មតិយោបល់ត្រឡប់ ដែលត្រូវបានត្រួតពិនិត្យ តាមរយៈប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ បានបង្ហាញឱ្យឃើញអំពីសេចក្តីត្រូវការយ៉ាងខ្លាំងក្លាឱ្យមានការបន្តពង្រឹងបន្ថែមទៅលើសមត្ថភាពរដ្ឋាភិបាលមូលដ្ឋាន សម្រាប់ការផ្តល់សេវាដែលមានមូលដ្ឋានផ្អែកលើសិទ្ធិ និងផ្តោតយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ។ ជាលទ្ធផល មន្ត្រី និងបុគ្គលិករដ្ឋាភិបាលមូលដ្ឋានជាង ៦៥០នាក់ មកពីទីភ្នាក់ងារដីធ្លី គណៈកម្មាធិការស្ត្រី អង្គការមិនមែនរដ្ឋាភិបាល និង ក្រុមសហគមន៍ជនបទមិនផ្លូវការ បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលអំពីទិដ្ឋភាពយេនឌ័រ នៃដំណើរការកំណែទម្រង់ដីធ្លី។ សកម្មភាពនេះ បានធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់សិក្ខាកាមនៅក្នុងដំណើរការរៀបចំរចនាសម្ព័ន្ធដីធ្លីឡើងវិញ រាប់ចាប់ពីការទទួលបានជំនាញកាន់តែប្រសើរក្នុងការដោះស្រាយបញ្ហាព្រួយបារម្ភរបស់កសិករ រហូតដល់ការចូលរួមកាន់តែច្រើននៅក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹង។

បញ្ជីផ្ទៀងផ្ទាត់ ៣.៣ ៖

ការកសាងសមត្ថភាពស្ត្រី

ប្រភព ៖ Discussions of the working group on institutions at the May 2011 technical workshop; World Bank/FAO/IFAD, 2009b:458.

- ✓ បណ្តុះបណ្តាលស្ត្រីអំពីបច្ចេកទេសក្នុងការនិយាយជាសាធារណៈ និងបច្ចេកទេសពិភាក្សាវែកញែក ដើម្បីបង្កើនទំនុកចិត្តរបស់ពួកគេ។
- ✓ បណ្តុះបណ្តាលស្ត្រីអំពីគោលនយោបាយ និងច្បាប់ពាក់ព័ន្ធ ដើម្បីឱ្យពួកគេអាចរួមចំណែកប្រកបដោយប្រសិទ្ធភាពនៅក្នុងកិច្ចប្រជុំរបស់ស្ថាប័នពួកគេ។
- ✓ បណ្តុះបណ្តាលស្ត្រី និងបុរស អំពីនីតិវិធី និងដំណើរការរបស់ស្ថាប័ន ជាពិសេស អំពីបទប្បញ្ញត្តិសម្រាប់គាំទ្រ និង ធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រ នៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។
- ✓ ធានាថានីតិវិធីប្រតិបត្តិការរបស់ស្ថាប័ន ពិចារណាទៅលើសេចក្តីត្រូវការការប្តេជ្ញាចិត្តចំពោះពេលវេលា ភាពមានកម្រិតនៃការធ្វើចលនា និងនិយាមបទដ្ឋានវប្បធម៌របស់សមាជិកជាស្ត្រី ដើម្បីបង្កើនផលប៉ះពាល់នៃការចូលរួមរបស់ស្ត្រីជាអតិបរមា។ ចំណុចនេះ អាចរាប់បញ្ចូលការបង្កើតបទប្បញ្ញត្តិអំពីការថែទាំកុមារ ក្នុងអំឡុងពេលកិច្ចប្រជុំ និងសកម្មភាពរបស់ស្ថាប័ន។

ចូរចងចាំ!

សមាជិកជាស្ត្រីរបស់ស្ថាប័នដីធ្លី អាចត្រូវការការបណ្តុះបណ្តាល និងកិច្ចគាំទ្រពិសេស ដើម្បីអនុវត្តតួនាទីរបស់ពួកគេឱ្យមានប្រសិទ្ធភាព ជាពិសេស ក្នុងករណីដែលពួកគេមានបទពិសោធន៍តិចតួចនៃការចូលរួមក្នុងស្ថាប័នបែបនេះ។

✎បញ្ជីផ្ទៀងផ្ទាត់ ៣.៤ ៖ **ការអភិវឌ្ឍន៍សមត្ថភាពស្ថាប័នសម្រាប់សមធម៌យេនឌ័រ**

ប្រភព ៖ Seeley, Batra and Sarin, 2000.

- ✓ ជ្រើសរើសស្ត្រីឱ្យបម្រើការងារនៅក្នុងមុខតំណែងថ្នាក់កំពូល នៅក្នុងស្ថាប័នដីធ្លី ដើម្បីផ្តល់ឧទាហរណ៍អំពីការដឹកនាំស្ថាប័នដែលមានសមធម៌យេនឌ័រ និង ផ្តល់កិច្ចគាំទ្រសមស្របជូនដល់ពួកគេ។
- ✓ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបុគ្គលិក និង សមាជិករបស់គ្រប់ស្ថាប័នទាំងអស់ ដែលពាក់ព័ន្ធនៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ដែលរួមមានជាអាទិ៍ មន្ត្រីនគរបាល ចៅក្រម និងអាជ្ញាធរបែបប្រពៃណី អំពីបញ្ហាយេនឌ័រ។
- ✓ លើកទឹកចិត្តអង្គការវិស័យឯកជននៅក្នុងវិស័យដីធ្លី ឱ្យដោះស្រាយបញ្ហាសមធម៌យេនឌ័រនៅក្នុងការងាររបស់ពួកគេ ជាមួយស្ថាប័នដីធ្លីនៅគ្រប់កម្រិត។ មិនត្រូវពឹងផ្អែកទៅលើរដ្ឋាភិបាល និង ក្រុមហ៊ុនធំៗដែលមានប្រតិបត្តិការនៅក្នុងប្រទេសផ្សេងៗគ្នា ឱ្យធ្វើការដឹកនាំក្នុងការផ្លាស់ប្តូរការអនុវត្តន៍ប្រចាំថ្ងៃ តាមស្ថាប័ននៅថ្នាក់មូលដ្ឋានឡើយ។
- ✓ បណ្តុះបណ្តាលបុគ្គលិកតាមមូលដ្ឋានជាស្ត្រីរបស់គម្រោងដែលទាក់ទងទៅនឹងដីធ្លី និងមន្ត្រីដីធ្លីជាស្ត្រី ក្នុងការសម្របសម្រួលឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លីក្នុងមូលដ្ឋាន។
- ✓ បន្តអនុវត្តដំណើរការបែបចូលរួម និង ការច្នៃប្រឌិតថ្មីនៃការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្តថ្នាក់មូលដ្ឋាន ដើម្បីកសាងសមត្ថភាពពីកម្រិតសហគមន៍មូលដ្ឋានឡើងទៅ។
- ✓ ធានាថាសមាជិកជាស្ត្រី និងបុរស នៃស្ថាប័នដីធ្លី ត្រូវបានផ្តល់តួនាទី និងការទទួលខុសត្រូវដែលមានសារៈសំខាន់ស្មើគ្នា។
- ✓ ទទួលស្គាល់ថា ស្ត្រីដែលមានសាវតាផ្នែកសង្គមសេដ្ឋកិច្ច សាសនា វណ្ណៈផ្សេងៗគ្នា ។ល។ អាចមានចំណាប់អារម្មណ៍ខុសៗគ្នាក្នុងការចូលរួម និងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងស្ថាប័នដីធ្លី។ រចនាសម្ព័ន្ធ និងដំណើរការរបស់ស្ថាប័ន ត្រូវពិចារណាទៅលើចំណុចនេះ ដើម្បីធានាឱ្យមានអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌ សម្រាប់ស្ត្រី និងបុរសគ្រប់រូប។

ចូរចងចាំ!

ស្ថាប័នរមែងតែងមានការវិវឌ្ឍន៍ជានិច្ច ដូច្នេះ ការកសាងសមត្ថភាពស្ថាប័ន ដើម្បីដោះស្រាយបញ្ហាសមធម៌យេនឌ័រ នៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ត្រូវតែជាដំណើរការមួយដែលបន្តមានការវិវឌ្ឍន៍ផងដែរ។

ភាពជាតំណាងប្រកបដោយសមធម៌យេនឌ័រ នៅក្នុងវិជ្ជាជីវៈបច្ចេកទេស

កន្លងមក រដ្ឋបាលដីធ្លីគឺជាវិស័យមួយដែលមានការគ្របដណ្តប់ពីបុរស ជាពិសេស នៅក្នុងវិជ្ជាជីវៈដែលកាន់តែមានលក្ខណៈបច្ចេកទេស ដូចជា ការធ្វើអង្កេត។ ចំណុចនេះ បាននាំឱ្យមានការយល់ឃើញអំពីសមធម៌យេនឌ័រថា ទាមទារត្រឹមតែផ្តល់ការងារជូនស្ត្រីនៅក្នុងផ្នែកណាមួយ នៅក្នុងស្ថាប័ន និង គម្រោងរដ្ឋបាលដីធ្លីប៉ុណ្ណោះ មិនចំពោះថាពួកគេត្រូវបានប្រគល់តួនាទីអ្វីឡើយ (World Bank, 2005: 18)។

ស្ត្រីវ័យក្មេងដែលមានបំណងចង់ចូលទៅក្នុងវិស័យដីធ្លី ជាអ្នកវិជ្ជាជីវៈបច្ចេកទេស រមែងតែងត្រូវជំនះទៅលើ ៖

- ឧបសគ្គផ្នែករូបវន្ត និងឧបសគ្គផ្ទាល់ខ្លួន ចំពោះការចំណាយពេលវេលាយូរអង្វែងនៅតាមមូលដ្ឋាន ដែលជាញឹកញាប់ មានត្រឹមតែល័ក្ខខ័ណ្ឌជីវភាពរស់នៅកម្រិតមូលដ្ឋាន ដែលនេះ ជាការតម្រូវនៅក្នុងវិជ្ជាជីវៈ ដូចជា ការងារអង្កេតបែបនេះ។
- ការអប់រំបច្ចេកទេសមានកម្រិតទាបជាងបុរសវ័យក្មេង អាស្រ័យដោយគ្រួសាររមែងតែងផ្តល់ឱកាសជូនដល់បុរសច្រើនជាង ក្នុងការបន្តការអប់រំឧត្តមសិក្សា ជាពិសេស នៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ។
- ការរើសអើងការងារដោយប្រយោល អាស្រ័យដោយបែបផែនជាតួយ៉ាងរបស់កុមារី និងស្ត្រីវ័យក្មេង នៅក្នុងតួនាទីការងារផ្ទះ ការងារបន្តពូជ និងតួនាទីទាបជាបុរស ព្រមទាំងដោយសារតែការអនុវត្តន៍បែបរើសអើងយេនឌ័រនៅក្នុងដំណើរការជ្រើសរើសបុគ្គលិក។
- ការដែលមិនសូវមានលទ្ធភាពដូចបុរសវ័យក្មេង ក្នុងការទទួលបានបណ្តាញព័ត៌មាន និងយន្តការស្វែងរកការងារ រាប់បញ្ចូលតាមរយៈបណ្តាញ និងសមាគមវិជ្ជាជីវៈ។

ជាទូទៅ ស្ត្រីរមែងតែងមានវត្តមានការងារច្រើនជាង នៅក្នុងការងារការិយាល័យរដ្ឋបាលដីធ្លី។ ឧទាហរណ៍ ស្ត្រីត្រូវបានគេទទួលស្គាល់ថា ដើរតួនាទីសំខាន់ជាភ្នាក់ងារសេវាអតិថិជន នៅក្នុងការិយាល័យចុះបញ្ជីដីធ្លី។ ជាញឹកញាប់ អតិថិជនជាស្ត្រីតែងមានភាពងាយស្រួលជាងក្នុងការប្រាស្រ័យទាក់ទងជាមួយស្ត្រីដទៃទៀត ដែលធ្វើការងារនៅការិយាល័យជួរមុខ ដូច្នេះ វាមានសារៈសំខាន់ដែលត្រូវធានាឱ្យមានតុល្យភាពយេនឌ័រ ចំពោះបុគ្គលិកការិយាល័យ។

នៅក្នុងប្រទេសជាច្រើន ស្ត្រីក៏ចូលរួមផងដែរ នៅក្នុងការផ្សព្វផ្សាយអំពីរបៀបដំណើរការនៃប្រព័ន្ធព័ត៌មានដីធ្លី រាប់បញ្ចូលតាមរយៈការអភិវឌ្ឍន៍ និងការដាក់ពង្រាយឧបករណ៍នៅក្នុងវិស័យឯកជន។ ជាញឹកញាប់ ពួកគេក៏ជាអ្នកប្រើប្រាស់ប្រព័ន្ធ និងមូលដ្ឋានទិន្នន័យព័ត៌មានដីធ្លីផងដែរ ឧទាហរណ៍ នៅក្នុងតួនាទី ដូចជាស្មៀន និង អ្នកបញ្ចូលទិន្នន័យ។

បើទោះជាដូច្នេះក្តី គេត្រូវការឱ្យមានសកម្មភាពផ្តោតយកចិត្តទុកដាក់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងទិដ្ឋភាពផ្នែកបច្ចេកទេសនៃរដ្ឋបាលដីធ្លី ជាពិសេសក្នុងការធានាឱ្យមានតុល្យភាពយេនឌ័រកាន់តែ

ប្រអប់ ៣.៧ ៖

ការគាំទ្រឱ្យមានការអប់រំវិទ្យាសាស្ត្រ និងបច្ចេកទេសសម្រាប់កុមារី

ប្រភព ៖ Rebecca Sittie's presentation on "Gender issues in managing and implementing land registration in Ghana" at the May 2011 technical workshop; Rebecca Sittie, personal communication.

ប្រសើរ រវាងការងារនៅក្នុងការិយាល័យ និង ការងារតាមមូលដ្ឋាន។ ឧទាហរណ៍ គេត្រូវការឱ្យមានវិធានការមួយចំនួន ដើម្បីលើកកម្ពស់ការយល់ដឹង និង ផ្តល់ព័ត៌មានអំពីការងារ ដោយបញ្ជាក់ឱ្យបានច្បាស់ថា ពួកគេមានភាពបើកចំហ ចំពោះយេនឌ័រទាំងពីរ ហើយកិច្ចខិតខំក្នុងការទាក់ទាញស្ត្រីវ័យក្មេងឱ្យបានកាន់តែច្រើន ទៅក្នុងវិជ្ជាជីវៈ បច្ចេក-ទេស និង ការងារតាមមូលដ្ឋាន គួរពន្យល់អំពីគុណសម្បត្តិ និង គុណវិបត្តិ ព្រមទាំងសម្របសម្រួលបទពិសោធន៍ជាក់ ស្តែងតាមមូលដ្ឋាន។ ករណីសិក្សាពីប្រទេស ហ្គាណា ដែលមានរៀបរាប់នៅក្នុងប្រអប់ ៣.៧ ផ្តល់នូវឧទាហរណ៍អំពីការអនុវត្តន៍ល្អមួយ អំពីការគាំទ្រដល់ការអប់រំវិទ្យាសាស្ត្រ និង បច្ចេកទេសសម្រាប់ស្ត្រី និង កុមារី។ ប្រអប់ ៣.៨ ពន្យល់អំពីស្ថានភាពមួយជ្រុងទៀតនៅតំបន់អារ៉ាប់។

ដោយមានការគាំទ្រពីក្រសួងកិច្ចការនារី និងកុមារ ក្រសួងអប់រំរបស់ប្រទេសហ្គាណា បានដាក់ឱ្យដំណើរការនូវ "គ្លីនិក" មួយចំនួនក្នុងអំឡុងពេលនៃវិស្សមកាលរយៈពេលវែងរបស់សាលារៀន នៅក្នុងតំបន់ទាំង១០។ ស្ត្រីដែលបានសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ និង គណិតវិទ្យា បានចូលរួមគ្លីនិកទាំងនេះ ដើម្បីនិយាយជាមួយកុមារីដែលមានអាយុ ១៣ឆ្នាំ ទៅ១៦ឆ្នាំ ដោយលើកទឹកចិត្តពួកគេឱ្យបន្តសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ និង បច្ចេកទេសនៅឯសាលារៀន និងក្រោយពេលបញ្ចប់ការសិក្សានៅឯសាលារៀន។ ស្ត្រីគំរូក៏ថ្លែងចំណាប់អារម្មណ៍លើកទឹកចិត្តនៅឯសាលាបឋមសិក្សាផងដែរ ដើម្បីជម្រុញឱ្យកុមារី ផ្តោតគោលដៅឱ្យបានខ្ពស់។ ស្របពេលជាមួយគ្នានេះដែរ ការិយាល័យស្ត្រី នៃស្ថាប័នអ្នកអង្កេតរបស់ហ្គាណា បានរៀបចំធ្វើទស្សនៈកិច្ចកុមារីនៅឯវិទ្យាល័យ ដើម្បីណែនាំអំពីវគ្គសិក្សាអំពីការធ្វើអង្កេតដែលមាននៅកម្រិតសាកលវិទ្យាល័យ។

ជាលទ្ធផលនៃកិច្ចខិតខំទាំងនេះ និង គោលនយោបាយទូទៅរបស់រដ្ឋាភិបាល ស្តីពីការលើកកម្ពស់ការអប់រំកុមារី ក្នុងឆ្នាំ២០០៥ និស្សិតបញ្ចប់ការសិក្សាថ្មីចំនួន៤០នាក់ ក្នុងចំណោម១១០នាក់ ពីផ្នែកសេដ្ឋកិច្ចដីធ្លី នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា Kwame Nkrumah គឺជាស្ត្រី។ រយៈពេលប៉ុន្មានឆ្នាំបន្តបន្ទាប់មក គេបានកត់ត្រាឃើញសមាមាត្រ នៃការចុះឈ្មោះចូលរៀនរបស់ស្ត្រីនៅក្នុងវគ្គសេដ្ឋកិច្ចដីធ្លី ក្នុងកម្រិតប្រហាក់ប្រហែលគ្នា។

ប្រអប់ ៣.៨ ៖

បញ្ហាប្រឈមចំពោះសមធម៌យេនឌ័រនៅក្នុងសកម្មភាពនិងបច្ចេកវិទ្យារដ្ឋបាលដីធ្លី

នៅក្នុងប្រទេសទាំង២២ នៃពិភពអារ៉ាប់ ការរើសអើងយេនឌ័រ មានទិដ្ឋភាពស្មុគស្មាញមួយចំនួនដែលទាក់ទងទៅនឹងបញ្ហាសាសនា វប្បធម៌ សង្គម នយោបាយ និងសេដ្ឋកិច្ច។ បុរស ដែលចូលរួមនៅក្នុងទិដ្ឋភាពបច្ចេកទេសនៃវិស័យដីធ្លីក្នុងប្រទេសទាំងនេះ រមែងតែងមានអារម្មណ៍ថា ការរើសអើងយេនឌ័រ ការពារស្ត្រី ដោយសារតែការងារតាមមូលដ្ឋានត្រូវបានគេចាត់ទុកថា ពុំមានភាពសមស្របសម្រាប់ស្ត្រី ហើយឧបករណ៍សម្ភារៈមានទម្ងន់ធ្ងន់ខ្លាំងពេក។ ស្របពេលជាមួយគ្នានេះដែរ ស្ត្រីមួយចំនួន ជាពិសេសស្ត្រីនៅតំបន់ជនបទ មានការភ័យខ្លាចចំពោះការធ្វើដំណើរហួសពីតួនាទីយេនឌ័របែបប្រពៃណីរបស់ពួកគេ ដែលជាញឹកញាប់រមែងតែងមិនត្រូវបានរាប់បញ្ចូល អាស្រ័យដោយផលប៉ះពាល់ជាសក្តានុពលទៅលើកេរ្តិ៍ឈ្មោះរបស់ពួកគេ។ ស្ត្រីមិនសូវមានពេលវេលា ដោយសារតែបន្ទុកការងារធ្ងន់ធ្ងរនៅក្នុងផ្ទះ ហើយជារឿយៗ ភាពចល័តរបស់ពួកគេ រមែងតែងមានកម្រិត ដូចជា ពួកគេអាចមិនត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរ ឬ ចេញទៅក្រៅតែម្នាក់ឯង។ ការអប់រំមានការបែងចែកយេនឌ័រយ៉ាងធ្ងន់ធ្ងរ ហើយស្ត្រីដែលធ្វើការងារ រមែងតែងជ្រើសរើសការងារក្នុងមូលដ្ឋានដែលមិនប៉ះពាល់ដល់បន្ទុកការងារក្នុងផ្ទះ និង កេរ្តិ៍ឈ្មោះក្នុងសង្គមរបស់ពួកគេ។ នៅក្នុង

ប្រភព៖ Dalal Alnaggar's presentation on "Developing enderequitable land survey and technologies in the Arab region" at

ពិភពអារ៉ាប់ទាំងមូល មានតែស្ត្រីរៀបការរួចចំនួន ១៨% ប៉ុណ្ណោះ គឺជាចំណែកមួយនៃកម្លាំងពលកម្មដែលទទួលបានប្រាក់កម្រៃ ហើយស្ត្រីដែលស្ថិតនៅក្នុងមុខតំណែងកម្រិតខ្ពស់នៅក្នុងវិស័យវិទ្យាសាស្ត្រ មានចំនួនត្រឹមតែ ២% ប៉ុណ្ណោះ។

នៅក្នុង*ប្រទេសអេហ្ស៊ីប ហ្សកដង់ លីបាណង់ ម៉ូរ៉ុកកូ* និង *ទុយនីស៊ី* ស្ត្រីអាចធ្វើការងារនៅក្នុងសហគមន៍បច្ចេកទេសនៃវិស័យជីផ្លីបាន ប៉ុន្តែ ពុំមែនការងារទាំងអស់ សុទ្ធសឹងតែបើកចំហចំពោះស្ត្រី និងបុរសឡើយ អាស្រ័យដោយការងារមួយចំនួន ដែលទាមទារឱ្យមានលក្ខណៈសម្បត្តិខ្ពស់ ត្រូវបានរក្សាទុកសម្រាប់តែបុរសប៉ុណ្ណោះ។ នៅក្នុងពិភពអារ៉ាប់ទាំងមូល មានគម្លាតយេនឌ័រមួយដ៏ធំ នៅកម្រិតធ្វើសេចក្តីសម្រេចចិត្ត ក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកទេសរបស់រដ្ឋាភិបាល និងវិស័យឯកជន។ ឧទាហរណ៍ នៅក្នុងប្រទេសអេហ្ស៊ីប ក្នុងទសវត្សរ៍ឆ្នាំ២០០០-២០១០ ស្ត្រីរួមមានប្រមាណមួយភាគបី នៃនិស្សិតសាកលវិទ្យាល័យក្នុងវគ្គសិក្សាផ្នែកវិទ្យាសាស្ត្រ ប៉ុន្តែ ក្នុងឆ្នាំ២០១១ មានតែស្ត្រី ៥០នាក់ប៉ុណ្ណោះ ដែលមានសញ្ញាបត្រថ្នាក់អនុបណ្ឌិតលើផ្នែកអង្កេត និងមានស្ត្រី ១៥នាក់ប៉ុណ្ណោះ ដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត។ ពុំមានអ្នកអង្កេតជាស្ត្រី ដែលមានសញ្ញាបត្រថ្នាក់ក្រោយឧត្តមសិក្សា នៅក្នុងប្រទេសអារ៉ាប់ដទៃទៀតឡើយ។

the May 2011 technical workshop; Dalal Alnaggar personal communication.

✎បញ្ជីផ្ទៀងផ្ទាត់ ៣.៥ ៖

សកម្មភាពសម្រាប់ប្រទេសនានា ដែលមានគម្លាតយេនឌ័រធ្ងន់ធ្ងរ

- ✓ នៅក្នុងបរិបទដែលមានគម្លាតយេនឌ័រធ្ងន់ធ្ងរ ត្រូវកំណត់រកបញ្ហាប្រឈមចម្បងៗចំពោះសមធម៌យេនឌ័រ នៅក្នុងទិដ្ឋភាពបច្ចេកទេសនៃរដ្ឋបាលដីធ្លី។
- ✓ បង្កើតឱ្យមាននូវធនាគារទិន្នន័យមួយ អំពីការងារវិទ្យាសាស្ត្រ និង ការងារបច្ចេកទេស ព្រមទាំងលើកទឹកចិត្តស្ត្រីឱ្យដាក់ពាក្យ។
- ✓ គាំទ្រស្ត្រីដែលមានឯកទេសផ្នែកព័ត៌មានវិទ្យា ការវាយតម្លៃ និង ការរៀបចំកំណត់បទដ្ឋាន។
- ✓ គាំទ្រចំពោះការអប់រំវិទ្យាសាស្ត្រ និងបច្ចេកទេស ព្រមទាំងវិធានការកសាងសមត្ថភាពសម្រាប់កុមារី និងស្ត្រីវ័យក្មេង។
- ✓ បង្កើតកូតាអប្បបរមា សម្រាប់ការចូលរួមរបស់ស្ត្រី នៅក្នុងតួនាទីបច្ចេកទេសក្នុងទីភ្នាក់ងារ និងផ្នែករដ្ឋបាលដីធ្លី។
- ✓ គាំទ្រដល់អ្នកអង្កេតជាស្ត្រី និងអ្នកវិជ្ជាជីវៈបច្ចេកទេសដទៃទៀត ក្នុងការធ្វើការងារជាមួយទីភ្នាក់ងារអន្តរជាតិ រដ្ឋាភិបាល និងវិស័យឯកជន តាមរយៈការ

	ប្រើប្រាស់បច្ចេកវិទ្យា និងព័ត៌មានសមស្រប រាប់បញ្ចូលបច្ចេកវិទ្យាថ្មីៗ ដែលកាន់តែមានភាពអព្យាក្រឹត្យចំពោះយេនឌ័រ។
✓	បង្កើនបទដ្ឋាន និងការគ្របដណ្តប់នៃការអប់រំវិទ្យាសាស្ត្រ និងបច្ចេកទេស នៅតំបន់ជនបទ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះការអប់រំកុមារី។
✓	លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់របស់ស្ត្រី ដោយកំណត់អំពីសិទ្ធិ និងការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ពួកគេ។ ផ្តោតយកចិត្តទុកដាក់ទៅលើការលុបបំបាត់ជំនឿថា ការងារធ្វើឱ្យធ្លាក់តម្លៃស្ត្រី និងប៉ះពាល់ដល់បន្ទុកការងារក្នុងផ្ទះ ព្រមទាំងកេរ្តិ៍ឈ្មោះក្នុងសង្គមរបស់ពួកគេ។

ចូរចងចាំ!

គេត្រូវការឱ្យមានវិធានការកំណត់គោលដៅ ដើម្បីគាំទ្រដល់ការចូលរួមរបស់ស្ត្រី នៅក្នុងរដ្ឋបាលដីធ្លី ក្នុងបណ្តាប្រទេសដែលគម្លាតយេនឌ័រធ្ងន់ធ្ងរ បានចាក់ឫសយ៉ាងជ្រៅនៅក្នុងជំនឿវប្បធម៌ និងសាសនា។

បញ្ជីផ្ទៀងផ្ទាត់ ៣.៦ ៖ **ការធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រនៅក្នុងរដ្ឋបាលដីធ្លី**

ដើម្បីធ្វើឱ្យប្រសើរឡើងនូវតុល្យភាពយេនឌ័រ នៅក្នុងចំណោមអ្នកវិជ្ជាជីវៈវិស័យដីធ្លី និងគាំទ្រឱ្យមានការចូលរួមប្រកបដោយសមធម៌ រវាងស្ត្រី និងបុរស នៅក្នុងរដ្ឋបាលដីធ្លី គេត្រូវការអភិវឌ្ឍបច្ចេកវិទ្យា និងប្រព័ន្ធទូទាំងពិភពលោក ដែលក្រុមប្រជាពលរដ្ឋកាន់តែទូលំទូលាយ អាចយកមកប្រើប្រាស់ និងដើម្បីកែសម្រួលឡើងវិញទៅលើលក្ខណៈសម្បត្តិដែលគេត្រូវការ សម្រាប់ការងារបច្ចេកទេសជាក់លាក់មួយចំនួន សំដៅកាត់បន្ថយឧបសគ្គចំពោះការទទួលបាន ជាពិសេសសម្រាប់ស្ត្រី។ បច្ចេកទេសអង្កេត និងវាស់វែង ក៏គួរធ្វើឱ្យមានភាពសាមញ្ញផងដែរ ក្នុងករណីដែលអាចធ្វើទៅបាន ដើម្បីឱ្យជំនួយការអ្នកអង្កេត ដែលមានលក្ខណៈសម្បត្តិទាបជាង អាចគ្រប់គ្រងទៅលើបច្ចេកទេសទាំងនោះបានផងដែរ (FAO, 2011a: 10)។ កំណើននៃការប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួម និងមានថ្លៃចំណាយទាបនៃការអង្កេត និងការចុះបញ្ជីដីធ្លី កំពុងមានផលប៉ះពាល់វិជ្ជមានមួយគួរឱ្យកត់សម្គាល់ទៅលើសមធម៌យេនឌ័ររួចទៅហើយ នៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។

✓	គាំទ្រចំពោះលទ្ធភាពរបស់ស្ត្រី និង បុរស ក្នុងការចូលទៅក្នុងផ្នែកបច្ចេកទេសនៃវិស័យដីធ្លី ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព រាប់បញ្ចូលតាមរយៈសកម្មភាពវិជ្ជមាន នៅក្នុងចន្លោះរយៈពេលខ្លី និងរយៈពេលមធ្យម។
✓	ប្រមូល និងផ្សព្វផ្សាយទិន្នន័យដែលមានការបំបែកព័ត៌មានទៅតាមយេនឌ័រ នៅក្នុងគ្រប់ស្ថាប័ន និងគម្រោងរដ្ឋបាលដីធ្លីទាំងអស់ រាប់បញ្ចូលទិន្នន័យអំពីបុគ្គលិកផងដែរ។

✓	រៀបចំ និងអភិវឌ្ឍសមត្ថភាពបច្ចេកទេសរបស់ស្ត្រីនៅក្នុងវិស័យដីធ្លី តាមរយៈការអប់រំវិជ្ជាជីវៈ ការបណ្តុះបណ្តាល និងបណ្តាញវិជ្ជាជីវៈ រាប់បញ្ចូលសមាគមអ្នកអង្កេតជាស្ត្រីផងដែរ។
✓	កំណត់រកបុគ្គលឆ្នើម និងលើកកម្ពស់គ្រូបណ្តុះបណ្តាល និងជនគំរូជាស្ត្រី។
✓	អភិវឌ្ឍការបណ្តុះបណ្តាលបណ្តើរធ្វើការងារបណ្តើរ ដើម្បីកសាងសមត្ថភាពស្ថាប័នវិទ្យាសាស្ត្រ និងបច្ចេកទេស សំដៅគាំទ្រដល់ការអភិវឌ្ឍន៍អាជីពរបស់ស្ត្រី ឧទាហរណ៍តាមរយៈបទពិសោធន៍វិជ្ជាជីវៈជាក់ស្តែងនៅក្នុងវិស័យ ក្រោយបញ្ចប់ការសិក្សាសាកលវិទ្យាល័យ។
✓	សម្របសម្រួលដល់ភាពចល័តរបស់ស្ត្រីនៅក្នុងតួនាទីបច្ចេកទេសផ្សេងៗគ្នាក្នុងរដ្ឋបាលដីធ្លី ដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងរបស់ពួកគេ អំពីទិដ្ឋភាពទាំងស្រុងនៃការងារបច្ចេកទេសរបស់រដ្ឋបាលដីធ្លី ខណៈពេលដែលពួកគេបោះជំហានឈានឡើង នៅក្នុងវិជ្ជាជីវៈនេះ។
✓	រៀបចំការបណ្តុះបណ្តាលអំពីយេនឌ័រ ការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹង សម្រាប់អ្នកវិជ្ជាជីវៈ ជាស្ត្រី និង បុរស ក្នុងវិស័យដីធ្លី។
✓	អភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់បញ្ចូលបញ្ហាកង្វល់ និងបទពិសោធន៍របស់ស្ត្រី និងបុរស ទៅក្នុងការរៀបចំការអនុវត្តន៍ ការត្រួតពិនិត្យ និងវាយតម្លៃទៅលើគម្រោងនានា នៅក្នុងគ្រប់ទិដ្ឋភាពបច្ចេកទេសទាំងអស់នៃរដ្ឋបាលដីធ្លី។
✓	ផ្តល់កិច្ចគាំទ្រ និងសម្ភារៈឱ្យបានគ្រប់គ្រាន់សម្រាប់ស្ត្រី ដើម្បីធ្វើការងារនៅមូលដ្ឋាន។

ចូរចងចាំ!

សមភាពយេនឌ័រនៅក្នុងរដ្ឋបាលដីធ្លីមិនអាចសម្រេចទៅបានឡើយ លុះត្រាណាតែស្ត្រីអាចចូលរួមនៅក្នុងសកម្មភាពបច្ចេកទេស និងប្រព័ន្ធ ក្នុងលក្ខណៈស្មើភាពគ្នាទៅនឹងបុរស។

ការសង្ខេបអំពីសារសំខាន់ៗ

ស្តីពីស្ថាប័ន

ស្ថាប័នដីធ្លីដែលមានភាពជាតំណាង និងមានការចូលរួមប្រកបដោយសមធម៌យេនឌ័រ មានភាពប្រសើរជាងនៅក្នុងការងារអភិបាលកិច្ចដីធ្លីសម្រាប់ស្ត្រី និងបុរស។
គេត្រូវការលើកកម្ពស់ការយល់ដឹងសាធារណៈអំពីសារៈសំខាន់នៃការចូលរួមប្រកបដោយប្រសិទ្ធភាពពីស្ត្រី និងបុរស នៅក្នុងស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លីគ្រប់កម្រិត ពីថ្នាក់ជាតិរហូតដល់ថ្នាក់ស្រុក។
ដំណើរការវិមជ្ឈការបង្កើតឱ្យមាននូវឱកាស និង បញ្ហាប្រឈមសម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។
ស្ថាប័នមួយចំនួន ដូចជា ស្ថាប័នមូលដ្ឋានទទួលបន្ទុកការងារគ្រប់គ្រងផ្ទៃរងទឹកភ្លៀង ធារាសាស្ត្រ និងតំបន់វាលស្មៅ ក៏មានតួនាទីនៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រផងដែរ។
ស្ថាប័នរដ្ឋបាលដីធ្លីបែបប្រពៃណី អាចដើរតួនាទីមួយដ៏សំខាន់ក្នុងការជះឥទ្ធិពលឱ្យមានការផ្លាស់ប្តូរឆ្ពោះទៅរកការអនុវត្តន៍បែបប្រពៃណី ដែលមានសមធម៌យេនឌ័រកាន់តែប្រសើរ។
គេអាចត្រូវការវិធានការកសាងសមត្ថភាពជាក់លាក់ ដើម្បីគាំទ្រដល់សមាជិកស្ថាប័នដីធ្លីជាស្ត្រីនៅគ្រប់កម្រិត។ សមត្ថភាពស្ថាប័នដើម្បីដោះស្រាយបញ្ហាសមធម៌យេនឌ័រ នៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី គួរតែបន្តធ្វើការត្រួតពិនិត្យឡើងវិញ និងអភិវឌ្ឍ។
គេត្រូវការឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងទិដ្ឋភាពផ្នែកបច្ចេកទេសនៃអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ដូចជា សកម្មភាព បច្ចេកវិទ្យា និងប្រព័ន្ធរដ្ឋបាលដីធ្លី ដើម្បីសម្របទៅតាមប្រយោជន៍របស់ប្រជាពលរដ្ឋគ្រប់រូប ទាំងស្ត្រី និងបុរស។

សូចនាករត្រួតពិនិត្យជាអនុសាសន៍សម្រាប់ស្ថាប័ន

- ចំនួនភាគរយនៃស្ត្រី និងបុរស នៅក្នុងស្ថាប័នរដ្ឋបាល និងគ្រប់គ្រងដីធ្លីថ្នាក់កណ្តាល។
- ចំនួនភាគរយនៃស្ត្រី និងបុរស នៅក្នុងស្ថាប័នរដ្ឋបាល និងគ្រប់គ្រងដីធ្លីថ្នាក់ស្រុក។
- ចំនួនភាគរយនៃស្ត្រី និងបុរស នៅក្នុងស្ថាប័នរដ្ឋបាល និងគ្រប់គ្រងដីធ្លីថ្នាក់មូលដ្ឋាន។
- ចំនួនភាគរយនៃស្ត្រី និងបុរស នៅក្នុងស្ថាប័នដីធ្លីបែបប្រពៃណី និងស្ថាប័នក្នុងមូលដ្ឋានដទៃទៀត ដែលទាក់ទងទៅនឹងដីធ្លី។
- ចំនួនមន្ត្រីដីធ្លីដែលទទួលបានការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលអំពីយេនឌ័រ។
- ចំនួនស្ថាប័នដីធ្លីបែបប្រពៃណី និងស្ថាប័នក្នុងមូលដ្ឋានដទៃទៀតទាក់ទងនឹងដីធ្លី ដែលបានទទួលការបណ្តុះបណ្តាល និងការផ្សព្វផ្សាយអំពីបញ្ហាយេនឌ័រ និងដីធ្លី។
- ចំនួនការផ្តួចផ្តើមសម្រាប់លុបបំបាត់ឧបសគ្គចំពោះការទទួលបានយុត្តិធម៌ដីធ្លីសម្រាប់ស្ត្រី។
- ចំនួនភាគរយនៃស្ត្រី និងបុរស ដែលបានទទួលកិច្ចគាំទ្រផ្នែកច្បាប់នៅក្នុងករណីដីធ្លីក្នុងប្រព័ន្ធយុត្តិធម៌ផ្លូវការ។
- ចំនួនភាគរយនៃវិវាទ ទាក់ទងនឹងសិទ្ធិទទួលបានដីធ្លី និងទ្រព្យសម្បត្តិរបស់ស្ត្រីនៅចំពោះមុខតុលាការ និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

កំណត់សម្គាល់

[៦] Debra Fletcher, Rachael Knight, Martha Osorio, Elizabeth Stair, Josephine Stowers-Fiu, Mika Törhönen and Margret Vidar បានផ្តល់ជាតុចូលសំខាន់ៗនៅក្នុងម៉ូឌុលនេះ ក្នុងអំឡុងពេលនៃសិក្ខាសាលាបច្ចេកទេស ដែលប្រព្រឹត្តធ្វើឡើង ក្នុងខែឧសភា ឆ្នាំ២០១១ នៅឯការិយាល័យកណ្តាលរបស់អង្គការ FAO រាប់បញ្ចូលតាមរយៈការពិភាក្សារបស់ក្រុមការងារផ្នែកស្ថាប័ន។

ឯកសារយោង

Adams, M., Berkoff, J. & Daley, E. 2006. Land-water interactions: opportunities and threats to water entitlements of the poor in Africa for productive use. Human Development Report Occasional Paper No. 2006/20. Washington, DC, UNDP. http://hdr.undp.org/en/reports/global/hdr2006/papers/adams%20martin%20et%20al.pdf

ADB. 2006. Republic of Uzbekistan: land improvement project. Report and Recommendation of the President to the Board of Directors, Proposed Loans and Technical Assistance Grant. Manila, Asian Development Bank. www2.adb.org/documents/rrps/uzb/37536-01-uzb-rrp.pdf

Agarwal, B. 2009. Gender and forest conservation: The impact of women's participation in community forest governance. Ecological Economics, 68(11): 2785–2799.

Alden Wily, E. 2003. Governance and land relations: A review of decentralisation of land administration and management in Africa. London, IIED. http://pubs.iied.org/pdfs/9304IIED.pdf

Basangwa, S.K. 2010. Women in land administration. Paper presented at the Women's Land Rights Conference, Speke Resort Muynonyo, Uganda, 4–6 October 2010.

Daley, E., Dore-Weeks, R. & Umuhoza, C. 2010. Ahead of the game: Land tenure reform in Rwanda and the process of securing women's land rights. Journal of Eastern African Studies, 4(1): 131–152.

Daley, E. & Englert, B. 2010. Securing land rights for women. Journal of Eastern African Studies, 4(1): 91–113.

Djusaeva, S. 2012. Promoting rural women's rights to land: UN Women programme experience in Kyrgyzstan and Tajikistan. Paper prepared for the Expert Group Meeting on Good Practices in Realizing Women's Rights to Productive Resources, with a Focus on Land, organized by UNWomen in collaboration with the United Nations Office of the High Commissioner for Human Rights, Geneva, 25–27 June 2012.

FAO. 2006a. Gender and law: Women's rights in agriculture, L. Cotula. FAO Legislative Study No. 76, Rev.1.Rome. f tp://ftp.fao.org/docrep/fao/005/y4311e/y4311e00.pdf

FAO. 2011a. Governing land for women and men – gender and voluntary guidelines on responsible governance of tenure of land and other natural resources, E. Daley and C.M. Park. Land Tenure Working Paper No. 19. Rome. http://www.fao.org/docrep/014/ma811e/ma811e00.pdf

FAO. 2012b. Voluntary Guidelines on the Responsible Governance of Tenure of Land, Fisheries and Forests in the Context of National Food Security.Rome. http://www.fao.org/docrep/016/i2801e/i2801e.pdf

Flintan, F. 2010b. Sitting at the table: Securing benefits for pastoral women from land tenure reforms in Ethiopia. Journal of Eastern African Studies, 4 (1): 153–178.

Flintan, F. 2010a. Learning by doing: Working towards participatory rangeland management (PRM) in pastoral areas through ELMT/ELSE. Washington, DC, USAID.

Flintan, F. & Cullis, A., compilers. 2010. Introductory guidelines to participatory rangeland management in pastoral areas. Ethiopia, Save the Children USA, FAO and ECHO. www.cop-ppld.net/fileadmin/user_upload/cop-ppld/items/introductory%20guidelines%20prm.pdf

Hilhorst, T. 2010. Decentralization, land tenure reforms and local institutional actors: building partnerships for equitable and sustainable land governance in Africa. Land Tenure Journal, 1(10): 35–59.
ILC. 2009. Advancing the monitoring of land governance
for ensuring impact on poverty reduction. Paper presented atLand Governance in Support of the MDGs: Responding to New Challenges, World Bank, Washington, DC, 9–10 March 2009.

Khudayberdiyeva, M. 2009. Uzbekistan Land Improvement Project.Tashkent, ADB Uzbekistan.

Knight, R. 2011. The community land titling initiative: An investigation into the protection of customary land claims. In E. Harper, ed. Working with customary justice systems: Post-conflict and fragile states, pp. 145–170. Rome, International Development Law Organization.

Seeley, J., Batra, M. & Sarin, M. 2000. Women's participation in watershed development in India. Gatekeeper Series No. 92. London, IIED. http://pubs.iied.org/pdfs/6347IIED.pdf

Teklu, A. 2005. Research report 4 – land registration and women's land rights in Amhara Region, Ethiopia. London, IIED.

ULA. 2010. The Uganda Land Alliance quarterly newsletter, Vol. 4. Kampala.

Whitehead, A. &Tsikata, D. 2003. Policy discourse on women's land rights in sub-Saharan Africa: The implications of the re-turn to the customary. Journal of Agrarian Change, 3(1–2): 67–112.

WLLA. 2010a. The impact of national land policy and land reform in Uganda. Accra, Women's Land Link Africa.

WOLREC. 2011. Women's access to land and household bargaining power: a comparative action research project in patrilineal and matrilineal societies in Malawi. Research Report No. 9. Rome, ILC, Women's Legal Resource Centre. www.landcoalition.org/sites/default/files/publication/959/wlr_9_malawi.pdf

World Bank. 2005. Gender issues and best practices in land administration projects: A synthesis report. Washington, DC. http://siteresources.worldbank.org/intard/resources/gender_land_fulltxt.pdf

World Bank/FAO/IFAD. 2009a. Module 4: Gender issues in land policy and administration. In Gender in agriculture sourcebook. Washington, DC and Rome.

World Bank/FAO/IFAD. 2009b. Module 10: Gender and natural resources management. In Gender in agriculture sourcebook. Washington, DC and Rome.

ម៉ូឌុល

៤

បញ្ញាបច្ចេកទេស

បញ្ជីរាយនាមប្រអប់ និង តារាងរូបភាព

ប្រអប់

99
ប្រអប់ ៤.១ ៖
សមធម៌យេនឌ័រ
បញ្ហាបច្ចេកទេស
និងគោលការណ៍ណែនាំ
101
ប្រអប់ ៤.២ ៖
ការអនុវត្តន៍ល្អសម្រាប់សមធម៌
យេនឌ័រក្នុងគម្រោងដីធ្លី
105
ប្រអប់ ៤.៣ ៖
ការធានាឱ្យមានសមធម៌
យេនឌ័រនៅក្នុងការរៀបចំសិទ្ធិ
តាមបែបប្រពៃណីឱ្យមាន
លក្ខណៈផ្លូវការ
106
ប្រអប់ ៤.៤ ៖
ការកំណត់ផែនទីសហគមន៍
ដោយមានការចូលរួម
តាមរយៈការប្រើប្រាស់
បច្ចេកវិទ្យាGPS
108
ប្រអប់ ៤.៥ ៖
ការធ្វើឱ្យការចុះបញ្ជីដីធ្លី
កាន់តែងាយស្រួលទទួលបាន
សម្រាប់ស្ត្រី
108
ប្រអប់ ៤.៦ ៖
ការធ្វើសកម្មភាពទៅលើកម្រៃ
សេវាចុះបញ្ជីដើម្បីគាំទ្រដល់
សមធម៌យេនឌ័រ នៅក្នុង
រដ្ឋបាលដីធ្លី
112
ប្រអប់ ៤.៧ ៖
ជម្រើសដោយឡែកក្រៅពីការ
ផ្តល់ប្លង់ដី
117
ប្រអប់ ៤.៨ ៖
ការធ្វើផែនការប្រើប្រាស់ដី
ដោយមានការចូលរួមប្រកប
ដោយសមធម៌យេនឌ័រ
121
ប្រអប់ ៤.៩ ៖
ផលប៉ះពាល់នៃការបែងចែកដីធ្លី
ឡើងវិញទៅលើស្ត្រីនៅអឺរ៉ុបភាគ
ខាងកើត

បញ្ជីផ្ទៀងផ្ទាត់

103
បញ្ជីផ្ទៀងផ្ទាត់ ៤.១ ៖
ការលើកកម្ពស់សមធម៌យេនឌ័រ
នៅក្នុងគម្រោងរដ្ឋបាលដីធ្លី
109
បញ្ជីផ្ទៀងផ្ទាត់ ៤.២ ៖
ការធ្វើឱ្យប្រសើរឡើងនូវ
សមធម៌យេនឌ័រនៅក្នុងការងារ
អង្កេត និងការចុះបញ្ជីដីធ្លី
114
បញ្ជីផ្ទៀងផ្ទាត់ ៤.៣ ៖
ការធានាឱ្យមានប្រព័ន្ធព័ត៌មាន
ដីធ្លីប្រកបដោយសមធម៌យេនឌ័រ
115
បញ្ជីផ្ទៀងផ្ទាត់ ៤.៤ ៖
ការគាំទ្រចំពោះការវាយតម្លៃ
ប្រកបដោយសមធម៌យេនឌ័រ
បញ្ជីផ្ទៀងផ្ទាត់ ៤.៥ ៖
115
ការគាំទ្រចំពោះការកំណត់
យកពន្ធដែលមានសមធម៌
យេនឌ័រ
118
បញ្ជីផ្ទៀងផ្ទាត់ ៤.៦ ៖
ការគាំទ្រចំពោះការធ្វើផែនការ
ប្រើប្រាស់ដីប្រកបដោយ
សមធម៌យេនឌ័រ
119
បញ្ជីផ្ទៀងផ្ទាត់ ៤.៧ ៖
ការគាំទ្រចំពោះការប្រចាប់ដីធ្លី
បញ្ចូលគ្នាប្រកបដោយសមធម៌
យេនឌ័រ
122
បញ្ជីផ្ទៀងផ្ទាត់ ៤.៨ ៖
ការគាំទ្រចំពោះបដិទានដីធ្លី
ប្រកបដោយសមធម៌យេនឌ័រ
124
បញ្ជីផ្ទៀងផ្ទាត់ ៤.៩ ៖
ការគាំទ្រចំពោះកំណែទម្រង់
លើការបែងចែកដីធ្លីឡើងវិញ
ប្រកបដោយសមធម៌យេនឌ័រ
126
បញ្ជីផ្ទៀងផ្ទាត់ ៤.១០ ៖
ការគាំទ្រចំបោះការផ្តល់សំណង
ប្រកបដោយសមធម៌យេនឌ័រ
128
សូចនាករត្រួតពិនិត្យ
ជាអនុសាសន៍សម្រាប់
បញ្ហាបច្ចេកទេស

តារាង និង រូបភាព

111
រូបភាព ៤.១ ៖
ការបន្តទទួលបានសិទ្ធិដីធ្លី

ម៉ូឌុល ៤ ៖ បញ្ហាបច្ចេកទេស

ការធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រ នៅក្នុងអតិក្រម វិធីសាស្ត្រ និងបច្ចេកវិទ្យារដ្ឋបាលដីធ្លី

សេចក្តីផ្តើម[៧]

រដ្ឋបាលដីធ្លីតម្រូវឱ្យពិចារណាទៅលើបញ្ហាយេនឌ័រសំខាន់ៗចំនួន២ ៖ ១) តើការរៀបចំសកម្មភាពរដ្ឋបាលដីធ្លីដោះស្រាយចំពោះសេចក្តីត្រូវការ ប្រយោជន៍ និងបញ្ហាកង្វល់របស់ស្ត្រីបានគ្រប់គ្រាន់ដល់កម្រិតណា និង ២) តើស្ត្រីអាចចូលរួមដោយស្មើភាពនៅក្នុងសកម្មភាពរដ្ឋបាលដីធ្លីបានដោយរបៀបណា។

សេចក្តីត្រូវការក្នុងការដោះស្រាយបញ្ហាសមធម៌យេនឌ័រនៅក្នុងសកម្មភាព បច្ចេកវិទ្យា និងប្រព័ន្ធរដ្ឋបាលដីធ្លីទទួលបានការគាំទ្រដោយផ្ទាល់នៅក្នុងគោលការណ៍ណែនាំទាំងមូល (សូមមើលឧទាហរណ៍នៅក្នុងប្រអប់ ៤.១)។

ការធានា និងការវិភាជន៍សិទ្ធិដីធ្លី

ប្រអប់ ៤.១ ៖
សមធម៌យេនឌ័រ បញ្ហាបច្ចេកទេស និងគោលការណ៍ណែនាំ

៧.៤ រដ្ឋគប្បីធានាថា ស្ត្រី និងបុរស ទទួលបានសិទ្ធិដូចគ្នា នៅក្នុងសិទ្ធិកាន់កាប់ដែលទើបត្រូវបានទទួលស្គាល់ និង ធានាថាសិទ្ធិទាំងនោះត្រូវបានឆ្លុះបញ្ចាំងក្នុងការចុះបញ្ជី។.... គប្បីប្រើប្រាស់អតិក្រមសមស្របក្នុងមូលដ្ឋាន ដើម្បីបង្កើនតម្លាភាពនៅពេលដែលការចុះបញ្ជីអំពីសិទ្ធិកាន់កាប់ត្រូវបានបង្កើតឡើង ដំបូង រួមទាំងការកំណត់ផែនទីសិទ្ធិកាន់កាប់ផងដែរ។
១០.៣ នៅពេលដែល រដ្ឋផ្តល់ការទទួលស្គាល់ស្របច្បាប់ចំពោះការកាន់កាប់ក្រៅប្រព័ន្ធ ការទទួលស្គាល់នេះគប្បីធ្វើតាមរយៈកិច្ចដំណើរការដោយមានការចូលរួម និងគិតគូរដល់យេនឌ័រ ដោយយកចិត្តទុកដាក់ដោយឡែកចំពោះអ្នកជួល។
១១.៦ រដ្ឋគប្បីបង្កើតវិធានការការពារដើម្បីការពារសិទ្ធិកាន់កាប់ស្របច្បាប់របស់សហព័ទ្ធ សមាជិកគ្រួសារ និងអ្នកដទៃទៀត ដែលមិនត្រូវបានបង្ហាញជាសម៉ីជនមានសិទ្ធិកាន់កាប់នៅក្នុងប្រព័ន្ធចុះបញ្ជី ដូចជា បញ្ជីដីធ្លីជាដើម។
៧.១ នៅពេលរដ្ឋទទួលស្គាល់ ឬ បែងចែកសិទ្ធិកាន់កាប់ដី ជលផល និង ព្រៃឈើ រដ្ឋគប្បីបង្កើតស្របតាមច្បាប់ជាតិ នូវវិធានការការពារដើម្បីជៀសវាងការរំលោភ ឬការរំលត់សិទ្ធិកាន់កាប់របស់អ្នកដទៃ រួមទាំងសិទ្ធិកាន់កាប់ស្របច្បាប់ ដែលបច្ចុប្បន្នមិនត្រូវបានការពារដោយច្បាប់។ ជាពិសេស វិធានការការពារ គប្បីការពារស្ត្រី និងជនងាយរងគ្រោះដែលមានសិទ្ធិកាន់កាប់បន្ទាប់បន្សំ ដូចជាសិទ្ធិយកផលជាដើម។

ប្រភព ៖ FAO, 2012b.

ការចុះបញ្ជីសិទ្ធិកាន់កាប់

១៧.៣ រដ្ឋគប្បីខិតខំធានាឱ្យបានថាប្រជាពលរដ្ឋគ្រប់រូបអាចចុះបញ្ជីសិទ្ធិកាន់កាប់របស់ខ្លួន និង ទទួលបានព័ត៌មានដោយគ្មានការរើសអើង ទោះជាផ្អែកលើមូលដ្ឋានអ្វីក៏ដោយ។

ការធ្វើនិយ័តកម្មផែនការរៀបចំដែនដី

២០.២ តាមរយៈការពិគ្រោះយោបល់ និងការចូលរួម រដ្ឋគប្បីអភិវឌ្ឍ និង ផ្សព្វផ្សាយគោលនយោបាយ និងច្បាប់ ស្តីពីការធ្វើនិយតកម្មផែនការរៀបចំដែនដី ដោយគិតគូរដល់យេនឌ័រ។
២០.៣ រដ្ឋគប្បីធានាថា ការធ្វើនិយ័តកម្មផែនការរៀបចំដែនដី ត្រូវបានធ្វើតាមវិធីមួយដែលទទួលស្គាល់ទំនាក់ទំនងប្រទាក់ក្រឡាគ្នារវាង ដី ជលផល និង ព្រៃឈើ និង ការប្រើប្រាស់ធនធានទាំងនេះ រួមទាំងទិដ្ឋភាពយេនឌ័រនៃការប្រើប្រាស់។

បដិទានដីធ្លី

១៤.៤ រដ្ឋគប្បីអភិវឌ្ឍគោលនយោបាយ និងច្បាប់គិតគូរដល់យេនឌ័រ ដែលចែងពីនីតិវិធីច្បាស់លាស់ប្រកបដោយតម្លាភាពសម្រាប់បដិទាន។ ព័ត៌មានស្តីពីនីតិវិធីបដិទាន គប្បីផ្សព្វផ្សាយឱ្យបានទូលាយ ជាភាសាសមស្រប។ អ្នកទាមទារគប្បីត្រូវបានផ្តល់ជូននូវជំនួយគ្រប់គ្រាន់ រួមមាន តាមរយៈជំនួយផ្នែកច្បាប់ និង ជំនួយការមេធាវី នៅក្នុងកិច្ចដំណើរការទាំងមូល។

កំណែទម្រង់លើការបែងចែកដីធ្លីឡើងវិញ

១៥.៥ ក្នុងករណីដែលរដ្ឋសម្រេចអនុវត្តកំណែទម្រង់លើការបែងចែកដីឡើងវិញ រដ្ឋគប្បីបញ្ជាក់ឱ្យបានច្បាស់នូវគោលដៅនៃកម្មវិធីកំណែទម្រង់ និង ចង្អុលបង្ហាញដីដែលត្រូវបានលើកលែងពីការបែងចែកឡើងវិញនេះ។ មុខសញ្ញាអ្នកទទួលផលដូចជាគ្រួសារ រួមទាំងអ្នកស្វែងរកសួនដំណាំនៅផ្ទះ ស្ត្រី អ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ អ្នកចិញ្ចឹមសត្វ ក្រុមជនជួបការលំបាកជាប្រវត្តិសាស្ត្រ ក្រុមជនត្រូវគេមើលរំលង ជនជាតិដើមភាគតិច អ្នកដើរប្រមូលផល និង អ្នកផលិតស្បៀងខ្នាតតូច គប្បីត្រូវកំណត់ឱ្យបានច្បាស់លាស់។

បញ្ហាទូទៅទាក់ទងនឹងរដ្ឋបាលដីធ្លី និងការគ្រប់គ្រងដីធ្លី[៥]

ឧបសគ្គទូទៅមួយចំនួននៃអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ មានប្រភពចេញពីតម្លៃរបស់សង្គមដែលបានចាក់ឫសយ៉ាងជ្រៅ (បទបង្ហាញរបស់ Renée Giovarelli នៅឯសិក្ខាសាលាបច្ចេកទេស ខែឧសភា ឆ្នាំ២០១១)៖

- នៅក្នុងទូទាំងពិភពលោក បុគ្គលិក និងអ្នកអនុវត្តគម្រោងរដ្ឋបាលដីធ្លីភាគច្រើនជាបុរស។ ជាលទ្ធផល ស្ត្រីរមែងតែងមិនចូលរួម ឬ មិនមានវត្តមាននៅក្នុងសកម្មភាពគម្រោងនៅមូលដ្ឋាន ដូចជាការកំណត់ព្រំប្រទល់ ឬ ការអង្កេតដីធ្លី (សូមមើល *ម៉ូឌុល៣*)។

- ជារឿយៗ ស្ត្រីរមែងតែងមិនត្រូវបានបញ្ចូលនៅក្នុងការរៀបចំគម្រោង ឬ ប្រយោជន៍ពីសកម្មភាពគម្រោងដូចជា ការទទួលបានសេវាឥណទាន ឬ សេវាសហគមន៍។

- ជារឿយៗ ស្ត្រីរមែងតែងមានចំណេះដឹងតិចជាងបុរស អំពីបញ្ហាកាន់កាប់ដីធ្លី និងបញ្ហាអភិបាលកិច្ច ដែលទទួលរងផលប៉ះពាល់ពីគម្រោងមួយ ឬ អំពីសញ្ញាណជាសក្តានុពលរបស់គម្រោង សម្រាប់ការអនុវត្តន៍គ្រប់គ្រង និងអភិបាលកិច្ចលើការកាន់កាប់ដីធ្លីដែលមានស្រាប់។

- បុគ្គលិករដ្ឋបាលដីធ្លី និងអ្នកអនុវត្តគម្រោង ក្រោមគម្រោងដែលទទួលបានមូលនិធិគាំទ្រពីម្ចាស់ជំនួយ អាចមិនដឹងទាំងស្រុងអំពីទិដ្ឋភាពផ្នែកសង្គម និងវប្បធម៌ នៃសិទ្ធិដីធ្លីនៅក្នុងតំបន់ដែលពួកគេកំពុងធ្វើការងារ។

វាមានសារៈសំខាន់ដែលត្រូវធានាថា រាល់គ្រប់សកម្មភាពរដ្ឋបាលដីធ្លីទាំងអស់ បញ្ជ្រាបបញ្ហាសមធម៌យេនឌ័រ តាមរយៈការពិចារណាទៅលើកម្រងបញ្ហាយេនឌ័រទាំងមូល ក្នុងអំឡុងពេលនៃការរៀបចំ ការអនុវត្តន៍ ការត្រួតពិនិត្យ និងវាយតម្លៃគម្រោង (World Bank/FAO/IFAD, 2009a: 130-132)។ បញ្ហាដែលត្រូវដោះស្រាយ អាស្រ័យទៅលើភារកិច្ចជាក់លាក់ និងបរិបទរបស់ប្រទេស ប៉ុន្តែ មានឧទាហរណ៍ជាច្រើននៃការអនុវត្តន៍ល្អ ដែលត្រូវដកស្រង់ ដែលឧទាហរណ៍មួយចំនួនមានរៀបរាប់នៅក្នុងប្រអប់ ៤.២។

ការទទួលបានប្លង់ដីរួមគ្នា

ប្រអប់ ៤.២ ៖ ការអនុវត្តន៍ល្អសម្រាប់សមធម៌យេនឌ័រក្នុងគម្រោងដីធ្លី

ប្រភព ៖ Elizabeth Stair's presentation on "Land and gender: the Jamaican context" at the May 2011 technical workshop; Giovarelli and Lastarria-Cornhiel, 2006; World Bank/FAO/IFAD, 2009a:139–140 and 145; Teklu, 2005; FAO, 2012a.

នៅក្នុង *ប្រទេសឥណ្ឌា* កម្មវិធីទិញដីលំនៅដ្ឋាន បានជួយដល់គ្រួសារជនបទដែលគ្មានដីឱ្យទទួលបានដីមួយប្លង់តូច សម្រាប់សាងសង់លំនៅដ្ឋាន និង ប្រកបអាជីវកម្មខ្នាតតូចនៅតាមផ្ទះ ដោយស្ត្រីជាអ្នកគ្រប់គ្រង។ ការចូលរួមពេញលេញរបស់អ្នកទទួលផលនៅគ្រប់កម្រិតទាំងអស់នៃកម្មវិធីទាំងនេះ រាប់ចាប់ពីការកំណត់រកដីសមស្របរហូតដល់ការរៀបចំផែនការអភិវឌ្ឍន៍ដីធ្លី បានរួមចំណែកធ្វើឱ្យការអនុវត្តន៍ទទួលបានជោគជ័យ។ កម្មវិធីជាច្រើនបានផ្តល់ប្លង់ដីរួមគ្នាជូនដល់ស្វាមី និងភរិយា ដោយជូនកាល គេបានចុះឈ្មោះភរិយាជាមុន ដោយឡែក កម្មវិធីដទៃទៀត ផ្តល់ប្លង់ដីជូនដល់ស្ត្រីតែប៉ុណ្ណោះ។ ជោគជ័យត្រូវបានសម្របសម្រួលតាមរយៈការយល់ដឹងអំពីបញ្ហាសមធម៌យេនឌ័រ នៅក្នុងចំណោមសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។

នៅក្នុងគម្រោងរដ្ឋបាលដីធ្លីបន្ថែមរបស់*ប្រទេសកម្ពុជា* ឆ្នាំ២០០២-២០០៧ ប្លង់ដីថ្មីចំនួន ៧៨% ត្រូវបានចេញរួមគ្នាទៅឱ្យស្វាមី និងភរិយា។ គម្រោងនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសង្គមសេដ្ឋកិច្ចទូទៅរបស់ស្ត្រី។ ដើម្បីលើកកម្ពស់និរន្តរភាពរយៈពេលវែង គម្រោងនេះ ត្រូវបានភ្ជាប់ទៅនឹងគម្រោងអភិវឌ្ឍដទៃទៀត ដូចជាគម្រោងធានាលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាឥណទាន និង សេវាផ្សព្វផ្សាយ។

ការប៉ាន់ប្រមាណសង្គមមួយ ដែលត្រូវបានធ្វើឡើងមុនពេលអនុវត្តគម្រោង បានប្រើប្រាស់ទស្សនៈវិស័យយេនឌ័រមួយចំពោះសិទ្ធិដីធ្លី ហើយការព្រួយបារម្ភចំពោះបញ្ហាយេនឌ័រត្រូវបានបញ្ចូលទៅក្នុងការរៀបចំគម្រោង។ ការចូលរួមរបស់ស្ត្រី ក៏ត្រូវបានសង្កត់ធ្ងន់ផងដែរនៅក្នុងដំណាក់កាលរៀបចំ និង អនុវត្តគម្រោង។ គម្រោងនេះ បានធ្វើយុទ្ធនាការចុះផ្ទាល់តាមមូលដ្ឋានជាសាធារណៈគ្រប់ជ្រុងជ្រោយមួយ ដែលមានវគ្គបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រញឹកញាប់ ដែលមានការចូលរួមពីស្ត្រី និងបុរសរាប់បញ្ចូលទាំងមន្ត្រីរដ្ឋបាល និងគ្រង់គ្រងដីធ្លីគ្រប់កម្រិត។ ស្ត្រីត្រូវបានកំណត់គោលដៅជាក់លាក់ ដោយសារតែពួកគេមានកម្រិតអនក្ខរភាពខ្ពស់ជាងបុរស និងជាទូទៅ ខ្វះការអប់រំអំពីសិទ្ធិដីធ្លី។ គម្រោងនេះ ក៏បានជួលទីប្រឹក្សាផ្នែកយេនឌ័រឱ្យធ្វើការងារជាមួយក្រុមអនុវត្ត។

នៅក្នុង*ប្រទេសអេដូពី* ក្រោយពេលចេញសេចក្តីប្រកាសស្តីពីការប្រើប្រាស់ និងរដ្ឋបាលដីធ្លីនៅក្នុងតំបន់អាំហារ៉ា ក្នុងឆ្នាំ២០០០ ការិយាល័យតំបន់ទទួលបន្ទុកធនធានធម្មជាតិ និងការប្រើប្រាស់ដី បានអភិវឌ្ឍយុទ្ធសាស្ត្រអនុវត្តមួយ និងគោលការណ៍ណែនាំដែលកំណត់អំពីការទទួលខុសត្រូវ និងគណនេយ្យភាពរបស់តួអង្គផ្សេងៗគ្នានៅក្នុងការចុះបញ្ជីសិទ្ធិដីធ្លី។ គោលការណ៍ណែនាំទាំងនេះ បានចែងថា ការចុះបញ្ជីប្លង់ដីរួមគ្នា ត្រូវបញ្ចូលឈ្មោះ និងរូបថតរបស់ភរិយា និងស្វាមីនៅលើលិខិតបញ្ជាក់ ហើយសហព័ទ្ធទាំងពីរត្រូវចុះហត្ថលេខាលើលិខិតបញ្ជាក់ប្លង់ដី មុនពេលលិខិតនេះ ត្រូវបានផ្តល់ជូនទៅឱ្យគ្រួសារ។ ការកំណត់ចែងទាំងនេះ ជួយធានាឱ្យមានសមធម៌យេនឌ័រនៅក្នុងការចុះបញ្ជីសិទ្ធិដីធ្លី យ៉ាងណាមិញស្រុកទាមទារឱ្យមានកិច្ចគាំទ្របន្ថែមទៀត នៅក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងប្រតិបត្តិការ និងការរៀបចំកម្មវិធីរបស់ពួកគេ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រនៅថ្នាក់មូលដ្ឋាន។

នៅក្នុង*ប្រទេសហុងឌូរ៉ាស់* គម្រោងអភិវឌ្ឍន៍កសិកម្មជ្រលងភ្នំហ្គាយអេប ដែលទទួលបានមូលនិធិគាំទ្រពីគណៈកម្មាធិការសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្មអន្តរអាមេរិក បានធ្វើការងារជាមួយទីភ្នាក់ងារផ្តល់ប្លង់ដីនៃប្រទេសហុងឌូរ៉ាស់ ដើម្បីបញ្ចូលឈ្មោះរបស់ភរិយានៅក្នុងប្លង់ដី បើទោះបីជាបទប្បញ្ញត្តិពាក់ព័ន្ធនៅមានកម្រិត ហើយការអនុវត្តន៍ស្នងមរតក និងការអនុវត្តន៍ចំពោះការទទួលបានទ្រព្យសម្បត្តិក្រោយពេលរៀបអាពាហ៍ពិពាហ៍ មិនបានរាប់បញ្ចូលស្ត្រីក៏ដោយ។ គម្រោងទទួលបានជោគជ័យ អាស្រ័យដោយគម្រោងនេះបានត្រួតពិនិត្យឡើងវិញទៅលើនីតិវិធីផ្តល់ប្លង់ដី ដើម្បីធ្វើឱ្យនីតិវិធីទាំងនោះ បង្កលក្ខណៈឱ្យស្ត្រីកាន់តែមានភាពងាយស្រួលក្នុងការទទួលបានប្លង់ដី និងរាប់បញ្ចូលស្ត្រី និងដោយសារតែគម្រោងនេះ រៀបចំការបណ្តុះបណ្តាលអំពីយេនឌ័រ សម្រាប់បុគ្គលិកគម្រោងមន្ត្រីផ្តល់ប្លង់ដីរបស់រដ្ឋាភិបាល និងមន្ត្រីសាធារណៈ ព្រមទាំងអាជ្ញាធរមូលដ្ឋាន។

ការអប់រំ និងការលើកកម្ពស់ការយល់ដឹងសាធារណៈ

នៅក្នុង*ប្រទេសចាម៉ៃកា* ការងាររបស់ទីភ្នាក់ងារដីធ្លីជាតិ (NLA) នៅក្នុងការអប់រំសាធារណៈ គាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។ ឧទាហរណ៍ ទីភ្នាក់ងារដីធ្លីជាតិ រៀបចំធ្វើការបង្ហាញតាមផ្លូវទូទាំងប្រទេស ដែលជាធម្មតាសកម្មភាពនេះ ធ្វើឡើងនៅក្នុងថ្ងៃដែលមានសកម្មភាពទីផ្សារ នៅពេលដែលស្ត្រីមកពី

តំបន់ជនបទ ទំនងនឹងមានវត្តមាននៅទីប្រជុំជន។ នៅក្នុងការបង្ហាញតាមផ្លូវទាំងនេះ ទីភ្នាក់ងារដីធ្លីជាតិ ផ្តល់ព័ត៌មាន និងធ្វើបទបង្ហាញជូនដល់ស្ត្រីក្នុងលក្ខណៈជាក្រុម និងលក្ខណៈបុគ្គល។ ប្រធានបទរួមមាន ប្រយោជន៍នៃការធ្វើបណ្តាំមរតក ការចុះឈ្មោះរបស់ពួកគេនៅក្នុងទ្រព្យសម្បត្តិរបស់ដៃគូពួកគេ ការធ្វើឱ្យមានភាពប្រក្រតីនូវការកាន់កាប់របស់ពួកគេដែលមានស្រាប់ តាមរយៈការចុះបញ្ជី និង ការធ្វើប្តូរដីទៅលើដីដែលពួកគេទិញក្រោមសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ។ បុគ្គលិកកម្មវិធីរដ្ឋបាល និងការគ្រប់គ្រងដីធ្លីរបស់ចាម៉ៃកា បានចូលរួមនៅក្នុងវគ្គទាំងនេះ។ ទីភ្នាក់ងារដីធ្លីជាតិ ផ្តល់ព័ត៌មាន តាមរយៈខិត្តប័ណ្ណ សម្ភារៈបោះពុម្ពដទៃទៀត និងអ៊ិនធឺណែត។

ការកំណត់ផែនទីដោយមានការចូលរួម

នៅក្នុង*ប្រទេសម៉ូហ្សំប៊ិក* អភិក្រមស្តីពីការអភិវឌ្ឍន៍ទឹកដី ដោយមានការចូលរួម និងមានការចរចារ (PNTD) របស់អង្គការ FAO ត្រូវបានគេយកមកប្រើប្រាស់នៅក្នុងការកំណត់ព្រំដែនដីសហគមន៍។ សមាជិកសហគមន៍ រាប់បញ្ចូលក្រុមស្ត្រី និងបុរសដោយឡែកពីគ្នា ផលិតផែនទីក្នុងអំឡុងពេលនៃដំណើរការពិគ្រោះយោបល់មួយដែលមានការចូលរួម។ ក្រោយមក ទម្រង់ផែនទីចុងក្រោយមួយត្រូវបានគេឯកភាព និងចុះបញ្ជីនៅក្នុងផ្នែកសុរិយោដីក្រោយពេលពិភាក្សាជាមួយសហគមន៍ជិតខាង។ នាពេលថ្មីៗនេះ អង្គការ FAO បានធ្វើសមាហរណកម្មអភិក្រមស្តីពីការអភិវឌ្ឍន៍ទឹកដី ដោយមានការចូលរួម និង មានការចរចារ និងអភិក្រមការវិភាគសង្គមសេដ្ឋកិច្ច និងយេនឌ័រ (SEAGA) ទៅក្នុងគោលការណ៍ណែនាំស្តីពីការធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រក្នុងបញ្ហាដែនដី ដើម្បីលើកកម្ពស់ការប្រើប្រាស់វិធីសាស្ត្រ និង ឧបករណ៍បែបចូលរួមដែលផ្តោតយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ នៅក្នុងដំណើរការចរចារ ដែលទាក់ទងទៅនឹងការទទួលបាន និងការប្រើប្រាស់ដី និងធនធានធម្មជាតិ។

បញ្ជីផ្ទៀងផ្ទាត់ ៤.១ ៖ ការលើកកម្ពស់សមធម៌យេនឌ័រនៅក្នុងគម្រោងរដ្ឋបាលដីធ្លី

- ✓ អភិវឌ្ឍឱ្យមានការយល់ដឹងអំពីប្រព័ន្ធកាន់កាប់ក្នុងមូលដ្ឋាន និងបទប្បញ្ញត្តិ ដែលប្រព័ន្ធនេះធ្វើឡើងសម្រាប់ស្ត្រី។ ត្រូវដឹងថា ព័ត៌មានទាំងនេះភាគច្រើន នឹងមិនត្រូវបានកត់ត្រាជាលាយលក្ខណ៍អក្សរឡើយ។
- ✓ ពិនិត្យទៅលើភាពមានកម្រិតនៅក្នុងច្បាប់ គោលនយោបាយ និងនិយ័តកម្ម ផ្សេងៗគ្នា ដែលទាក់ទងទៅនឹងសមភាពយេនឌ័រ។
- ✓ ធ្វើការប៉ាន់ប្រមាណសង្គម មុនពេលអនុវត្តគម្រោង រាប់បញ្ចូលរចនាសម្ព័ន្ធគ្រួសារផងដែរ។ ភាពជាតំណាងរបស់ស្ត្រីនៅក្នុងការងារក្នុងមូលដ្ឋាន អំណាចក្នុង ការធ្វើសេចក្តីសម្រេចចិត្ត និងតួនាទីនៅក្នុងគ្រួសារ និងសង្គម ព្រមទាំងគំរូនៃ ការស្នងមរតក ការរៀបអាពាហ៍ពិពាហ៍ និងការលែងលះ។
- ✓ កំណត់គោលដៅទៅលើស្ត្រីថាជាអ្នកទទួលផលពីគម្រោង និង សួរទៅកាន់ពួកគេថាតើពួកគេត្រូវការអ្វី និង តើពួកគេមើលឃើញថាមានឧបសគ្គរាំងស្ទះអ្វីខ្លះចំពោះរដ្ឋបាលដីធ្លីប្រកបដោយសមធម៌យេនឌ័រ។

ប្រភព ៖ Dalal Alnaggar's presentation on "Developing genderequitable land survey and technologies in the Arab region", and Kate Dalrymple's presentation on "Gender and technology issues in land administration projects in Southeast Asia and the Pacific" at the May 2011 technical workshop.

- ✓ អភិវឌ្ឍគោលការណ៍ណែនាំសម្រាប់ការអនុវត្តន៍ ជាភាសាក្នុងមូលដ្ឋាន ដោយ មានតំណាង និងការចូលរួមសកម្មពីស្ត្រី។
- ✓ តម្លើងប្រព័ន្ធត្រួតពិនិត្យមួយដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ តាំងពីដំបូង រាប់បញ្ចូលសូចនាករយេនឌ័រផងដែរ។
- ✓ ជួលទីប្រឹក្សា ឬ ជនបង្គោលយេនឌ័រ១រូប ដើម្បីធ្វើការងារជាមួយក្រុមអនុវត្ត។
- ✓ ភ្ជាប់ទំនាក់ទំនងសកម្មភាពរដ្ឋបាលដីធ្លី ទៅនឹងគម្រោងដទៃទៀត ដូចជាសកម្មភាពសម្រាប់ធានាលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាឥណទាន និងសេវាផ្សព្វផ្សាយ។
- ✓ លើកកម្ពស់ការប្រើប្រាស់វិធីសាស្ត្រ និងឧបករណ៍បែបចូលរួម ដែលផ្តោតការ យកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ នៅក្នុងការធ្វើនិយ័តកម្មទៅលើការ ទទួលបាន និងការប្រើប្រាស់ដី និងធនធានធម្មជាតិ។
- ✓ នៅពេលរៀបចំផែនការបណ្តុះបណ្តាល យុទ្ធនាការទំនាក់ទំនង និងការលើក កម្ពស់ការយល់ដឹង ត្រូវពិចារណាទៅលើកត្តាដែលមានភាពជាក់លាក់ទៅតាម បរិបទ ដូចជា ភាសា និង ទំនៀមទម្លាប់ក្នុងមូលដ្ឋាន ដែលអាចរាំងស្ទះចំពោះលទ្ធភាពក្នុងការធ្វើសកម្មភាពសម្រាប់ក្រុមស្ត្រី និងបុរសផ្សេងៗគ្នា។
- ✓ ផ្តល់ការបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ សម្រាប់ស្ត្រី និង បុរសបុគ្គលិកគម្រោង និងមន្ត្រីរដ្ឋបាលដីធ្លី ដោយផ្តល់វគ្គបណ្តុះបណ្តាលដោយឡែក សម្រាប់ស្ត្រីក្នុងករណីចាំបាច់។
- ✓ ធ្វើយុទ្ធនាការចុះផ្ទាល់តាមមូលដ្ឋានជាសារណៈឱ្យបានគ្រប់ជ្រុងជ្រោយ និង ការងារអប់រំដែលកំណត់គោលដៅទៅលើបុរស និងស្ត្រីដោយស្មើភាពគ្នា។
- ✓ ពិចារណាទៅលើឧបសគ្គរាំងស្ទះផ្នែកភាសា អនក្ខរភាព និង កង្វះព័ត៌មាន ព្រមទាំងមធ្យោបាយធ្វើដំណើរ ជាពិសេសសម្រាប់ស្ត្រី។
- ✓ ក្នុងករណីដែលឯកសារអត្តសញ្ញាណជាតិ ត្រូវបានប្រើប្រាស់ ត្រូវបញ្ចូលសមាសធាតុមួយ ដើម្បីជួយដល់ស្ត្រី និងបុរស ក្នុងការទទួលបានឯកសារទាំងនេះ។
- ✓ ផ្តល់សៀវភៅផ្ទត់ព័ត៌មាន ខ្សែអាត់វីដេអូ ការផ្សព្វផ្សាយតាមវិទ្យុ អត្ថបទសារព័ត៌មាន និងរ៉ូបសាយ ដែលផ្តោតទៅលើស្ថានភាពស្ត្រី និងប្រើប្រាស់បរិបទដែលពួកគេស្គាល់ និងមានភាពពាក់ព័ន្ធចំពោះពួកគេ ដូចជា តាមរយៈការប្រើប្រាស់រូបភាពស្ត្រីនៅក្នុងការពន្យល់។
- ✓ តម្លើងប្រព័ន្ធវាយតម្លៃ ដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ និង ប្រមូលទិន្នន័យអំពីការអនុវត្តន៍ល្អ ព្រមទាំងទិន្នន័យដែលមានការបំបែកព័ត៌មានទៅតាមយេនឌ័រ ដើម្បីតាមដានផលប៉ះពាល់រយៈពេលវែងលើបញ្ហា

សមភាពយេនឌ័រ។

ការចុះបញ្ជីសិទ្ធិកាន់កាប់

សន្តិសុខលើការកាន់កាប់ អាចធានាសុវត្ថិភាពបានក្រោមទម្រង់ផ្សេងៗគ្នាដែលបញ្ជាក់ច្បាស់លាស់អំពីសិទ្ធិរបស់អ្នកប្រើប្រាស់ដី និងម្ចាស់ដី ៖ ប្លង់ដីផ្លូវការ កិច្ចសន្យាជួលច្បាស់លាស់រយៈពេលវែង កិច្ចព្រមព្រៀងជួលដែលគួរឱ្យជឿជាក់បាន ឬ ការទទួលស្គាល់ជាផ្លូវការអំពីសិទ្ធិមិនផ្លូវការបែបប្រពៃណី និងសិទ្ធិស្របច្បាប់ជាមួយនឹងយន្តការដោះស្រាយវិវាទ ដែលបង្កលក្ខណៈឱ្យគេអាចទទួលបាន និង មានប្រសិទ្ធភាព។ ឧទាហរណ៍ជាច្រើនបង្ហាញថា ការលើកកម្ពស់សន្តិសុខលើការកាន់កាប់ ផ្តល់នូវប្រយោជន៍ដល់បុគ្គល គ្រួសារ និងសហគមន៍ តាមរយៈ ការលើកទឹកចិត្តឱ្យមានការវិនិយោគនៅក្នុងការកែលម្អដី គេហដ្ឋាន និងបរិស្ថានជុំវិញដែលធ្វើឱ្យប្រសើរឡើងនូវជីវភាព និង បទដ្ឋានរស់នៅ (UN-HABITAT, 2008:8)។ ប្រអប់ ៤.៣ រៀបរាប់អំពីបញ្ហាសមធម៌យេនឌ័រ ដែលបានកើតឡើងក្នុងអំឡុងពេលនៃការចុះបញ្ជីជាផ្លូវការនូវសិទ្ធិតាមបែបប្រពៃណីនៅអាហ្វ្រិកខាងត្បូង។

ប្រអប់ ៤.៣ ៖ ការធានាឱ្យមានសមធម៌យេនឌ័រនៅក្នុងការរៀបចំសិទ្ធិ តាមបែបប្រពៃណីឱ្យមានលក្ខណៈផ្លូវការ

ប្រភព ៖ South Africa Department of Land Affairs, 1997: 65 and 68; World Bank/FAO/IFAD, 2009: 456.

អត្ថបទមួយ ក្នុងឆ្នាំ១៩៩៧ ដែលនិយាយអំពីគោលនយោបាយដីធ្លីរបស់*អាហ្វ្រិកខាងត្បូង* បានសង្កត់ធ្ងន់ទៅលើគ្រោះថ្នាក់ដែលកើតឡើងពីសិទ្ធិតាមព្រឹត្តន័យ (តាមបែបប្រពៃណី) ដែលត្រូវបានរៀបចំឱ្យមានលក្ខណៈផ្លូវការ ដោយស្ថិតក្រោមសិទ្ធិនេះ ជាធម្មតា មានតែបុគ្គលម្នាក់គត់ ដែលទទួលបានប្លង់ដី បើទោះបីជាក្នុងករណីដែលមានបុគ្គលលើសពីមួយនាក់មានសិទ្ធិតាមព្រឹត្តន័យយ៉ាងដូច្នេះក៏ដោយ។ "ប្រជាពលរដ្ឋដែលធ្លាប់មានសិទ្ធិស្មើគ្នាកន្លងមក នៅក្នុងភាពអសន្តិសុខរបស់ពួកគេ ឥឡូវនេះ ត្រូវបានបែងចែកដាច់ស្រឡះ នៅពេលដែលសន្តិសុខត្រូវបានប្រគល់ទៅឱ្យបុគ្គលតែម្នាក់ ដែលជាទូទៅបុគ្គលម្នាក់នោះ គឺជាបុរសមេគ្រួសារ។ បទពិសោធន៍បានបង្ហាញឱ្យដឹងថា ជារឿយៗស្ត្រី និងមនុស្សចាស់ គឺជាអ្នកដែលបាត់បង់សិទ្ធិនៅក្នុងដំណើរការនេះ" (នាយកដ្ឋានកិច្ចការដីធ្លីអាហ្វ្រិកខាងត្បូង ១៩៩៧ ៖ ៦៥)។ "ឧទាហរណ៍ ជាទូទៅ លិខិតអនុញ្ញាតកាន់កាប់ត្រូវបានបែងចែកទៅឱ្យមេគ្រួសារជាបុរស។ ក្នុងករណីដែលលិខិតអនុញ្ញាតកាន់កាប់ទាំងនោះ ត្រូវផ្លាស់ប្តូរទៅជាកម្មសិទ្ធិភាពរបស់ម្ចាស់លិខិតអនុញ្ញាត លិខិតទាំងនោះត្រូវបានផ្លាស់ប្តូរទៅឱ្យមេគ្រួសារជាបុរសស្ទើរតែគ្រប់ករណីទាំងអស់។ ជារឿយៗបុរសជាមេគ្រួសារម្នាក់នេះ គឺជាអ្នកដែលបានចាកចេញទៅធ្វើការនៅទីក្រុង និងអាចមានគ្រួសារទីពីរនៅទីនោះ។ ប្រសិនបើគាត់ក្លាយទៅជាម្ចាស់កម្មសិទ្ធិដែលអាចលក់ ឬផ្ទេរកម្មសិទ្ធិភាពបាន វាបង្កើតឱ្យមាននូវការលើកទឹកចិត្តឱ្យគាត់លក់ដី និង អាចធ្វើឱ្យសមាជិកគ្រួសារដទៃទៀតរងគ្រោះទៅនឹងការបាត់បង់កម្មសិទ្ធិ (នាយកដ្ឋានកិច្ចការដីធ្លីអាហ្វ្រិកខាងត្បូង ១៩៩៧ ៖ ៦៨)។

តាមរយៈការកសាងបន្ថែមទៅលើបទពិសោធន៍ទាំងនេះ អត្ថបទ ឆ្នាំ១៩៩៧ នេះធានាថា ស្ត្រីទទួលបានកិច្ចការពារទូលំទូលាយ តាមរយៈការណែនាំអំពីទម្រង់ទ្រព្យសម្បត្តិ និង នីតិវិធីថ្មីសម្រាប់ "ការផ្លាស់ប្តូរ" (ការធ្វើឱ្យមានលក្ខណៈផ្លូវការ) ចំពោះសិទ្ធិតាមព្រឹត្តន័យ។ "កំណែទម្រង់លើការកាន់កាប់ផ្តល់ឱកាសសំខាន់ៗដើម្បីកសាងកិច្ចការពារ

សិទ្ធិស្ត្រី ទៅក្នុងទម្រង់កម្មសិទ្ធិភាពថ្មីដែលកំពុងត្រូវបានអភិវឌ្ឍ ជាពិសេស សិទ្ធិដែលមានមូលដ្ឋានលើគ្រួសារ និង ប្រព័ន្ធកម្មសិទ្ធិភាពជាក្រុម" (នាយកដ្ឋានកិច្ចការដីធ្លីអាហ្វ្រិកខាងត្បូង ១៩៩៧ ៖ ៦៨)។

ការអង្កេត ការផ្ទៀងផ្ទាត់ និងការចុះបញ្ជីដីធ្លី

ការអង្កេត និងការចុះបញ្ជីដីធ្លី គឺជាសកម្មភាពរដ្ឋបាលដីធ្លីសំខាន់ៗសម្រាប់ចុះបញ្ជីសិទ្ធិដីធ្លីនៅក្នុងប្រទេសជាច្រើន។ បច្ចេកវិទ្យាទំនើបដែលងាយស្រួលប្រើប្រាស់ សម្រាប់ធ្វើការអង្កេត និងចុះបញ្ជីដីធ្លី សម្របសម្រួលឱ្យមានការបណ្តុះបណ្តាលតាមមូលដ្ឋានឆាប់រហ័ស និង ប្រកបដោយភាពសក្តិសិទ្ធិ សម្រាប់ទាំងស្ត្រី និងបុរស នៅក្នុងដំនើរការបច្ចេកទេសប្រចាំថ្ងៃនៃរដ្ឋបាលដីធ្លី និងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។ ជារឿយៗ បច្ចេកវិទ្យាទំនើបតែងមានភាពងាយស្រួលក្នុងការអនុវត្តន៍ និងសន្សំសំចៃថវិកា ដែលបច្ចេកវិទ្យាបែបនេះ គាំទ្រដល់សមធម៌យេនឌ័រ តាមរយៈការធ្វើឱ្យសកម្មភាពបច្ចេកទេសកាន់តែងាយរកបាន និងមានលទ្ធភាពប្រើប្រាស់បានសម្រាប់ក្រុមប្រជាពលរដ្ឋ ដែលកាន់តែទូលំទូលាយជាងនេះ។ ដូច្នេះ ការធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រ នៅក្នុងទិដ្ឋភាពផ្នែកបច្ចេកទេសនៃរដ្ឋបាលដីធ្លី គឺជាគោលដៅមួយដែលអាចសម្រេចបាន។

ឧទាហរណ៍ បច្ចេកវិទ្យាប្រព័ន្ធកំណត់ទីតាំងសកល (GPS) ដែលមានលក្ខណៈស្មុគស្មាញ បែរជាមានភាពសាមញ្ញក្នុងការអនុវត្តន៍នៅតាមមូលដ្ឋាន តាមរយៈឧបករណ៍ GPS កាន់ដោយដៃ ដែលផ្តល់នូវសុក្រឹត្យភាពក្នុងកម្រិតមួយសមស្រប។ នៅក្នុងគម្រោងធ្វើឱ្យមានភាពប្រក្រតីលើការកាន់កាប់ដីធ្លី ក្នុងប្រទេសហ្គាណា ការងារស្រាវជ្រាវតាមមូលដ្ឋាននៅក្នុងភូមិ ភាគច្រើនត្រូវបានអនុវត្តដោយស្ត្រីដែលបានទទួលការបណ្តុះបណ្តាលក្នុងមូលដ្ឋាន ដែលបានធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយទៀតដើម្បីសម្ភាសន៍ប្រជាជន និងធ្វើការចុះបញ្ជីអំពីសិទ្ធិដីធ្លី និងព្រំប្រទល់របស់ពួកគេ ដោយប្រើប្រាស់កុំព្យូទ័រយួរដៃ និងឧបករណ៍ GPS ដែលកាន់ដោយដៃ។ សកម្មភាពនេះ បានធ្វើឱ្យដំណើរការចុះបញ្ជីកាន់តែមានភាពសក្តិសិទ្ធិ អាស្រ័យដោយទិន្នន័យត្រូវបានបញ្ចូលដោយស្វ័យប្រវត្តិពីមូលដ្ឋានដោយផ្ទាល់ទៅក្នុងប្រព័ន្ធព័ត៌មានដីធ្លី។ គម្រោងនេះបានរកឃើញថា ស្ត្រីមានភាពងាយស្រួលជាង ក្នុងការនិយាយអំពីបញ្ហាដីធ្លីរបស់ពួកគេ ទៅកាន់អ្នកអនុវត្តការងារជាស្ត្រីជាជាងអ្នកអនុវត្តការងារជាបុរស (បទបង្ហាញរបស់ Rebecca Sittie and Nigel Edmead នៅឯសិក្ខាសាលាបច្ចេកទេស ខែឧសភា ឆ្នាំ២០១១, Rebecca Sittie, personal communication)។

បច្ចេកវិទ្យា GPS ក៏ជាឧបករណ៍មួយដ៏សំខាន់ក្នុងការគាំទ្រដល់ការងារកំណត់ផែនទីដោយមានការចូលរួម សម្រាប់ការរៀបចំផែនការប្រើប្រាស់ដី ប្រកបដោយសមធម៌យេនឌ័រ ដូចដែលប្រអប់ ៤.៤ បានពន្យល់

ប្រអប់ ៤.៤ ៖
ការកំណត់ផែនទីសហគមន៍ដោយមានការចូលរួមតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា GPS

ប្រភព ៖ Seema Gaikwad, personal communication.

សហគមអភិវឌ្ឍអន្តរវប្បធម៌របស់*ប្រទេសហ្វីលីពីន* (PAFID) គាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច ក្នុងការបង្កើតផែនទី 3-D ដែលមានការចូលរួម និងការរៀបចំពាក្យបណ្តឹងទាមទារដីបុព្វបុរស និងធនធានរបស់ពួកគេវិញ។ ដំណើរការនេះ មានការចូលរួមពីសហគមន៍ទាំងមូល - ទាំងស្ត្រី និងបុរស ទទួលបានការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យា GPS និងចូលរួមនៅក្នុងការកំណត់ផែនទី

ដោយលើកឡើងអំពីករណីប្រទេសហ្វីលីពីន។

ការកំណត់ផែនទីរាងជាប្រអប់ ដោយផ្អែកលើរូបថតពីលើអាកាស ឬ រូបភាពផ្កាយរណប មានភាពងាយស្រួលជាង សម្រាប់ធ្វើឱ្យសហគមន៍ទាំងមូលយល់ អាស្រ័យដោយប្រជាពលរដ្ឋមិនចាំបាច់ត្រូវការឱ្យមានការបណ្តុះបណ្តាលពិសេស ដើម្បីឱ្យពួកគេអាចកំណត់អត្តសញ្ញាណដើមឈើ ឬ ដំណាំកសិផល ដែលកំណត់ព្រំប្រទល់ដីរបស់ពួកគេនៅលើរូបថតពីលើអាកាស ឬ រូបភាពផ្កាយរណបឡើយ។ ដូច្នេះ វិធីសាស្ត្រនៃការកំណត់ផែនទីរាងជាប្រអប់បែបនេះ អាចជាវិធីមួយដែលផ្តល់ភាពអង់អាច បង្កលក្ខណៈងាយស្រួល និង មានសមធម៌យេនឌ័រ ក្នុងការចុះបញ្ជីសិទ្ធិដីធ្លី។ ជាធម្មតា ការកំណត់ផែនទីរាងជាប្រអប់ មានមូលដ្ឋានផ្អែកលើភស្តុតាង និង ចំណេះដឹងក្នុងមូលដ្ឋានអំពីព្រំប្រទល់ដីធ្លី ជាពិសេសភស្តុតាង និងចំណេះដឹងដែលទទួលបានពីអ្នកជិតខាង និង សមាជិកសហគមន៍ដទៃទៀត ដែលគួរមានវត្តមាន នៅពេលដែលតំបន់មួយ កំពុងត្រូវបានគេធ្វើការកំណត់ព្រំប្រទល់។

ធនធាន ហើយផែនទីដែលសម្រេចបាន គឺពឹងទៅលើការរួមបញ្ចូលគ្នានូវចំណេះដឹងរបស់ពួកគេអំពីតំបន់ ដែលកំពុងត្រូវបានប៉ាន់ប្រមាណ។ ប្រជាពលរដ្ឋវ័យក្មេង គឺជាអ្នកសិក្សារៀនសូត្របានឆាប់រហ័ស អាស្រ័យដោយពួកគេមានទំនុកចិត្តខ្លាំងជាង ក្នុងការស្វែងរក និងប្រើប្រាស់ឧបករណ៍ថ្មីៗ។ សហគមអភិវឌ្ឍអន្តរវប្បធម៌របស់ប្រទេសហ្វីលីពីន បានផ្តល់ការបណ្តុះបណ្តាលជនជាតិដើមភាគតិច ជាង១៤៨នាក់ អំពីការប្រើប្រាស់បច្ចេកវិទ្យា GPS សម្រាប់ការផ្ទៀងផ្ទាត់នៅមូលដ្ឋាន និងការកំណត់អត្តសញ្ញាណទៅលើចំណុច យោងរបស់សហគមន៍។ ជាលទ្ធផល ប្រជាជនជនជាតិម៉ាងយ៉ាន នៃកោះមីនដូរ៉ូ បានអភិវឌ្ឍនិយមន័យថ្មីមួយសម្រាប់ឧបករណ៍ GPS ជាភាសាក្នុងស្រុករបស់ពួកគេ ដោយកំណត់និយមន័យឧបករណ៍នេះ ថា Gamit Pang-Sukat "ឧបករណ៍សម្រាប់វាស់វែង"។

ស្ត្រីដែលបានចូលរួមនៅក្នុងដំណើរការកំណត់ផែនទី 3-D បានកំណត់រកឃើញប្រភពទឹកទទួលទានដែលមានសុវត្ថិភាព និងទីតាំងគ្លីនិក និងសាលារៀន។ ក្នុងអំឡុងពេលនៃដំណើរការនេះ ស្ត្រីមានឋានៈស្មើគ្នាទៅនឹងបុរស ក្នុងការសម្រេចចិត្តរបស់សហគមន៍ អំពីទិន្នន័យដែលត្រូវបញ្ចូលទៅក្នុងផែនទី 3-D។ ស្ត្រី និងបុរស ក៏មានឱកាសស្មើគ្នាផងដែរក្នុងការប្រើប្រាស់ផែនទី។ ស្ត្រីចូលរួមចាប់តាំងពីការកសាងគំរូនេះដំបូង រហូតដល់ដំណាក់កាលកំណត់កូដ និងបកស្រាយទិន្នន័យ។

ក្នុងឆ្នាំ២០០៣ សហគមអភិវឌ្ឍអន្តរវប្បធម៌របស់ប្រទេសហ្វីលីពីន ត្រូវបានស្នើសុំឱ្យចែករំលែកអភិក្រមធ្វើផែនទី 3-D របស់ខ្លួនជាមួយប្រទេសដទៃទៀត និងរៀបចំផ្តល់វគ្គបណ្តុះបណ្តាលនៅក្នុង *ប្រទេសឥណ្ឌា និង ភូមា*។

ការធ្វើឱ្យការចុះបញ្ជីដីធ្លី និងការផ្តល់ប្លង់ដីកាន់តែងាយទទួលបាន និងមានសមធម៌យេនឌ័រ

ស្ថាប័នរដ្ឋបាលដីធ្លីនៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន ខ្វះការិយាល័យ និងបុគ្គលិកដែលមានសមត្ថភាព។ ស្ថាប័នទាំងនោះ អាចស្ថិតនៅឆ្ងាយដាច់ស្រយាលពីសហគមន៍ជនបទ និងមានថវិកា និងធនធានមានកម្រិតសម្រាប់ការធ្វើដំណើរទៅមូលដ្ឋាន។ ដោយឡែក លទ្ធភាពរបស់ប្រជាពលរដ្ឋជនបទ ក្នុងការទំនាក់ទំនងជាមួយការិយាល័យរដ្ឋបាលដីធ្លីមានការរាំងស្ទះ ដោយសារកង្វះមធ្យោបាយធ្វើដំណើរ ផ្លូវថ្នល់ល្អ និងថវិកា ជាពិសេសសម្រាប់ស្ត្រីដែលនៅក្នុងសង្គមជាច្រើនមានឱកាសតិចជាងបុរស ក្នុងការធ្វើដំណើរ។ វិធីម៉្យាងក្នុងការធ្វើឱ្យការចុះបញ្ជីដីធ្លីកាន់តែមានភាពងាយស្រួលក្នុងការទទួលបានសម្រាប់ស្ត្រី គឺតាមរយៈការធ្វើវិមជ្ឈការស្ថាប័នរដ្ឋបាលដីធ្លី ដូចដែលប្រអប់ ៤.៥ រៀបរាប់អំពីករណីនៅប្រទេសហ្គាណា។

ប្រអប់ ៤.៥ ៖

ការធ្វើឱ្យការចុះបញ្ជីដីធ្លីកាន់តែងាយស្រួលទទួលបាន សម្រាប់ស្ត្រី

ប្រភព ៖ Rebecca Sittie's presentation on "Gender issues in managing and implementing land registration in Ghana" at the May 2011 technical workshop.

នៅក្នុងប្រទេសហ្គាណា ចំនួនឯកសារដែលស្ត្រីបានចុះបញ្ជី ក្រោមឈ្មោះផ្ទាល់ខ្លួនរបស់ពួកគេ នៅក្នុងប្រព័ន្ធចុះបញ្ជីលិខិតកាន់កាប់ បានមានការកើនឡើងគួរឱ្យកត់សម្គាល់ នៅចន្លោះឆ្នាំ២០០៥ នៅពេលដែលមានកន្លែងចុះបញ្ជីដីធ្លីចំនួនពីរប៉ុណ្ណោះនៅក្នុងប្រទេសទាំងមូល និង ឆ្នាំ២០០៦ នៅពេលដែលរដ្ឋបាលដីធ្លីត្រូវបានធ្វើវិមជ្ឈការ និងមានកន្លែងចុះបញ្ជីជាច្រើនបន្ថែមទៀត ត្រូវបានរៀបចំឱ្យមានដំណើរការនៅក្រៅរដ្ឋរាជធានី (សូមមើលរូបភាពខាងក្រោម)។ វិមជ្ឈការមានការបំពេញបន្ថែមពីយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈមួយ ដែលផ្តល់ព័ត៌មានដល់ស្ត្រី និងបុរសអំពីការបើកឱ្យមានដំណើរការនូវការិយាល័យចុះបញ្ជីលិខិតកាន់កាប់ថ្មី ដែលពួកគេអាចចុះបញ្ជីឯកសាររបស់ពួកគេបាន។

ចំនួនឯកសារដែលចុះបញ្ជីដោយស្ត្រី ចន្លោះពីឆ្នាំ២០០៥-២០១០



ថ្លៃសេវា និង សោហ៊ុយសម្រាប់សេវាចុះបញ្ជីដីធ្លី ក៏មានផលប៉ះពាល់ទៅលើលទ្ធភាពប្រើប្រាស់សេវារបស់ស្ត្រីផងដែរ ដូចដែលមានបង្ហាញនៅក្នុងឧទាហរណ៍ក្នុងប្រអប់ ៤.៦។

ប្រអប់ ៤.៦ ៖

ការធ្វើសកម្មភាពទៅលើកម្រៃ សេវាចុះបញ្ជីដើម្បីគាំទ្រដល់សមធម៌យេនឌ័រនៅក្នុងរដ្ឋបាលដីធ្លី

ប្រភព ៖ Seema Gaikwad's presentation on "Asian experiences of civil society engagement with land policy processes", and Rebecca Sittie's presentation on "Gender issues in managing and implementing land registration in Ghana" at the May 2011 technical workshop; Undeland, 2012.

នៅក្នុងប្រទេសនេប៉ាល់ រដ្ឋាភិបាលបានអនុម័តទៅលើសារាចរណ៍ណែនាំមួយ ដែលមិនយកថ្លៃសេវាចុះបញ្ជីមួយផ្នែក នៅពេលដែលដីត្រូវបានចុះបញ្ជីក្រោមឈ្មោះរបស់ស្ត្រី។ ការលើកលែងចំពោះការយកថ្លៃសេវាចុះបញ្ជីដីធ្លីនេះ បានចាប់ផ្តើមក្នុងកម្រិត ១០% ក្នុងឆ្នាំ២០០៦ និង កើនឡើង ២០% ក្នុងឆ្នាំ២០០៧ និង ២៥% ក្នុងឆ្នាំ២០០៩ (បច្ចុប្បន្ន គេកំពុងធ្វើការទាមទារឱ្យមានការលើកលែងរហូតដល់ ៥០%)។ ជាលទ្ធផល ចំនួនដី ដែលបានចុះបញ្ជីក្រោមឈ្មោះរបស់ស្ត្រី មានការកើនឡើងជាង ៣ដង។ យ៉ាងណាមិញ វាមានការលំបាកក្នុងការដឹងថា តើការកើនឡើងនេះ បាននាំឱ្យសិទ្ធិដីធ្លីរបស់ស្ត្រីកាន់តែមានសន្តិសុខសុវត្ថិភាពប្រសើរជាងមុន នៅក្នុងការអនុវត្តន៍ជាក់ស្តែងដែរឬទេ។

នៅក្នុងគម្រោងចំនួនពីរ ក្នុង*ប្រទេសហ្គាណា* ថ្លៃចុះបញ្ជីត្រូវបានកាត់បន្ថយក្នុងកម្រិតគួរឱ្យកត់សម្គាល់ ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចុះបញ្ជីដីធ្លីរបស់ពួកគេ។ គម្រោងរដ្ឋបាលដីធ្លីរបស់រដ្ឋាភិបាល ដែលទទួលបានមូលនិធិគាំទ្រពីធនាគារពិភពលោក បានកាត់បន្ថយថ្លៃចុះបញ្ជីប្លង់ដីនៅតំបន់ទីក្រុង មកត្រឹមប្រមាណមួយភាគបួននៃតម្លៃធម្មតា។ នៅក្នុងគម្រោងផ្តល់ប្លង់ដីក្នុងលក្ខណៈជាប្រព័ន្ធនៅតំបន់ជនបទ (មានរៀបរាប់នៅក្នុងប្រអប់ ៥.២) រដ្ឋាភិបាលបានផ្តល់ការលើកលែងទៅលើពន្ធប្រថាប់ត្រា ហើយគណនី

Millennium Challenge Account បានគ្របដណ្តប់ទៅលើថ្លៃចំណាយសរុបនៃការរៀបចំឯកសារ ការអង្កេត និងការធ្វើផែនទី ថ្លៃចុះបញ្ជី និង ថ្លៃសេវាផ្នែកច្បាប់។ បើទោះបីជាមានសំនួរដែលបានលើកឡើង ទាក់ទងទៅនឹងនិរន្តរភាពនៃកិច្ចគាំទ្រប្រភេទនេះក៏ដោយ ប៉ុន្តែ វាទំនងជាឧបករណ៍មួយដ៏សំខាន់ក្នុងការជម្រុញឱ្យមានសមធម៌យេនឌ័រ នៅក្នុងការចុះបញ្ជីដីធ្លី និងរដ្ឋបាលដីធ្លី អាស្រ័យដោយការផ្តល់ប្លង់ដីក្នុងលក្ខណៈជាប្រព័ន្ធត្រូវបានពង្រីកទៅកាន់តំបន់ជនបទក្នុងប្រទេសហ្គាណា។

នៅក្នុង*ប្រទេសគីហ្គីស្ថាន* ថ្លៃចំណាយចុះបញ្ជីទ្រព្យសម្បត្តិ និងដីធ្លី ត្រូវបានកំណត់ថាជាឧបសគ្គរាំងស្ទះមួយដ៏ចម្បងចំពោះស្ត្រី បើទោះបីជាប្រព័ន្ធរបស់ប្រទេសមានលក្ខណៈជាគំរូ ក្នុងការចុះបញ្ជីសហកម្មសិទ្ធិភាពគ្រប់រូបក៏ដោយ។

បញ្ជីផ្ទៀងផ្ទាត់ ៤.២ ៖

ការធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រនៅក្នុងការងារអង្កេត និងការចុះបញ្ជីដីធ្លី

ប្រភព ៖ Dalal Alnaggar's presentation on "Developing gender-equitable land survey and technologies in the Arab region" at the May 2011 technical workshop.

- ✓ មុនពេលចុះបញ្ជីដីធ្លី ត្រូវធ្វើការប៉ាន់ប្រមាណមួយអំពីសិទ្ធិដែលមានស្រាប់ ដោយផ្តោតយកចិត្ត ទុកដាក់ទៅលើសិទ្ធិស្ត្រី (បានចុះបញ្ជី និងមិនបានចុះបញ្ជី) និងគំរូ នៃការស្នងមរតក ការរៀបអាពាហ៍ពិពាហ៍ និងការលែងលះ។
- ✓ អភិវឌ្ឍគោលការណ៍ណែនាំសម្រាប់ការអនុវត្តន៍ និង សៀវភៅសម្រាប់បុគ្គលិក តាមមូលដ្ឋាន ព្រមទាំងធានាឱ្យមានការចូលរួមរបស់ស្ត្រី។
- ✓ រៀបចំតម្លើងប្រព័ន្ធត្រួតពិនិត្យមួយ ដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហា យេនឌ័រ រាប់បញ្ចូលសូចនាករយេនឌ័រផងដែរ។
- ✓ កំណត់គោលដៅទៅលើគ្រួសារដែលមានស្ត្រីជាមេគ្រួសារ សម្រាប់ការចុះបញ្ជីដីធ្លី និងសួរពួកគេ ថាតើពួកគេត្រូវការអ្វីខ្លះ និង តើពួកគេមើលឃើញឧបសគ្គត្រង់ ចំណុចណាខ្លះនៅក្នុងការផ្តល់ប្លង់ដីប្រកបដោយសមធម៌យេនឌ័រ។
- ✓ លើកកម្ពស់ឱ្យមានការចូលរួមពីប្រតិបត្តិករជាស្ត្រីនៅក្នុងដំណើរការចុះបញ្ជី ។
- ✓ លើកកម្ពស់ឱ្យមានការផ្តល់ប្លង់ដីរួមគ្នា និង ការចុះបញ្ជីស្ត្រីជាម្ចាស់កម្មសិទ្ធិដីធ្លី របស់ពួកគេតែម្នាក់គត់។
- ✓ រៀបចំប្រព័ន្ធព័ត៌មានដីធ្លី និងមូលដ្ឋានទិន្នន័យ ដើម្បីបញ្ចូលជំហានមួយចំនួន ដែលធានាថា ច្បាប់ និងនិយ័តកម្មនានា ទាក់ទងទៅនឹងសមធម៌យេនឌ័រត្រូវបានអនុវត្ត។
- ✓ គាំទ្រដល់ការធ្វើផែនទីរាងជាប្រអប់ ដែលមានមូលដ្ឋានផ្អែកលើភស្តុតាង និង ចំណេះដឹងក្នុងមូលដ្ឋាន អំពីព្រំដែនដី ដោយធានាឱ្យមាននូវវត្តមានរបស់ស្ត្រី

(រាប់បញ្ចូលគ្រួសារដែលមានបុរសជាមេគ្រួសារ) អ្នកជិតខាង និងសមាជិកសហគមន៍ដទៃទៀត នៅក្នុងដំណើរការកំណត់ព្រំប្រទល់។

- ✓ ធ្វើវិមជ្ឈការកន្លែងចុះបញ្ជីដីធ្លី ដើម្បីធ្វើឱ្យសហគមន៍ជនបទកាន់តែមានភាពងាយស្រួលក្នុងការទទួលបានសេវា។

- ✓ ប្រាប់បញ្ចូលសកម្មភាពផ្តល់ប្លង់ដីជាមួយគម្រោងអភិវឌ្ឍសេដ្ឋកិច្ច ដូចជាគម្រោងផ្សព្វផ្សាយកសិកម្ម គម្រោងអភិវឌ្ឍអាជីវកម្មខ្នាតតូច ឬមីក្រូឥណទាន។

- ✓ រក្សាថ្លៃសេវាឱ្យមានកម្រិតទាប ដើម្បីសម្របសម្រួលឱ្យស្ត្រី និងក្រុមងាយរង គ្រោះដទៃទៀត មានលទ្ធភាពទទួលបានសេវា។

- ✓ អនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងសាធារណៈ ដែលកំណត់គោលដៅទៅ លើស្ត្រី ដោយផ្តល់ព័ត៌មានជូនដល់ពួកគេអំពីសារៈសំខាន់នៃសិទ្ធិដីធ្លី និងការចុះបញ្ជីដីធ្លី ក្នុងករណីដែលពួកគេអាចចុះបញ្ជីទៅលើសិទ្ធិរបស់ពួកគេបាន និងក្រោមល័ក្ខខ័ណ្ឌណាខ្លះ ដែលអនុញ្ញាតឱ្យពួកគេអាចធ្វើយ៉ាងដូច្នេះបាន - ថ្លៃសេវា សេចក្តីត្រូវការឱ្យមានភស្តុតាង...។ល។

- ✓ ពិចារណាទៅលើអនក្ខរភាព និង កង្វះព័ត៌មាន ព្រមទាំងមធ្យោបាយធ្វើដំណើរ។

- ✓ ផ្តល់សៀវភៅផ្នត់ព័ត៌មាន ខ្សែអាត់វីដេអូ ការផ្សព្វផ្សាយតាមវិទ្យុសារព័ត៌មាន និងវិបសាយជូនដល់ស្ត្រីដែលអាចត្រូវការឱ្យមានការរៀបចំដោយឡែកពីបុរស។

- ✓ ពិនិត្យផ្ទៀងផ្ទាត់ថា ប្លង់ដីមានលក្ខណៈត្រឹមត្រូវ ហើយម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិគ្រប់រូប ត្រូវបានផ្តល់ប្លង់ដីដោយស្របច្បាប់។

- ✓ ធានាថា ប្លង់ដីត្រូវបានផ្តល់ស្របពេលជាមួយគ្នា ចំពោះស្ត្រី និងបុរសដែលជា ម្ចាស់សិទ្ធិលើទ្រព្យសម្បត្តិ។

- ✓ សម្របសម្រួលឱ្យមានដំណើរការប្តឹងជំទាស់សម្រាប់ស្ត្រី តាមរយៈការបង្កើតឱ្យ មានទំនាក់ទំនងជាមួយមេធាវី និង ជំនួយការផ្នែកច្បាប់ដែលអាចផ្តល់ជំនួយ ជាក់លាក់។

- ✓ រៀបចំតម្លើងប្រព័ន្ធវាយតម្លៃដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ និងប្រមូលការអនុវត្តន៍ល្អ ព្រមទាំងទិន្នន័យដែលបំបែកព័ត៌មានទៅតាមយេនឌ័រ ដើម្បីពិនិត្យតាមដានទៅលើផលប៉ះពាល់រយៈពេលវែងនៃសមភាពយេនឌ័រ។

ជម្រើសដោយឡែកនៃការផ្ដល់ប្លង់ដី

ការប៉ុនប៉ងរៀបចំឱ្យមានលក្ខណៈផ្លូវការទៅលើសិទ្ធិបែបមិនផ្លូវការ និងការកាន់កាប់បែបប្រពៃណី រមែងតែងផ្ដោតទៅលើការផ្ដល់ឱ្យបុគ្គលនូវប្លង់កាន់កាប់គ្មានពេលកំណត់។ ការផ្ដល់ប្លង់ដី បាននិងកំពុងមានប្រជាប្រិយភាពនៅក្នុងទីភ្នាក់ងារអន្តរជាតិ និងអ្នកទទួលផលជាច្រើន។ បើទោះជាដូច្នេះក្ដី គេត្រូវផ្ដោតការយកចិត្តទុកដាក់ដើម្បីធានាថា ការធ្វើឱ្យមានលក្ខណៈផ្លូវការ មិនបណ្ដាលឱ្យស្ត្រីបាត់បង់សិទ្ធិបន្ទាប់បន្សំរបស់ពួកគេ ដូចជាសិទ្ធិក្នុងការទទួលបាន ប្រើប្រាស់ ប្រមូល ឬ ដាំដុះ ដែលពួកគេមានក្រោមច្បាប់ប្រពៃណីឡើយ (ប្រអប់ ៤.៣)។ តាមរយៈការធ្វើឱ្យធ្លាក់ចុះនូវសិទ្ធិដីធ្លី ដែលស្ត្រីធ្លាប់មានកន្លងមក ការផ្ដល់ប្លង់ដីអាចបង្កើនភាពអសន្តិសុខចំពោះស្ត្រី។

ពុំមានទម្រង់នៃការកាន់កាប់ណាតែមួយ ដែលអាចស្របទៅតាមសេចក្ដីត្រូវការផ្សេងៗគ្នារបស់គ្រប់ក្រុមសង្គមទាំងអស់បានឡើយ។ នៅពេលដែលកម្រងនៃជម្រើសកាន់កាប់ដីធ្លីមួយចំនួនត្រូវបានទទួលស្គាល់ ស្ត្រី និងបុរសពីគ្រប់ក្រុមសង្គមទាំងអស់ កាន់តែអាចមានលទ្ធភាពទទួលបាននូវសេចក្ដីត្រូវការរបស់ពួកគេ ដែលរមែងតែងមានការប្រែប្រួលទៅតាមសម័យកាល។ ការទទួលស្គាល់តាមផ្លូវច្បាប់ ទៅលើទម្រង់នៃការកាន់កាប់ផ្សេងៗគ្នាក៏អាចលើកកម្ពស់ឱ្យមានការអភិវឌ្ឍន៍ទីផ្សារដីធ្លីយ៉ាងសកម្មផងដែរ (UN-HABITAT, 2008a: 10)។ នៅក្នុងប្រទេសភាគច្រើន សិទ្ធិដីធ្លី និងប្រភេទនៃការកាន់កាប់ផ្សេងៗគ្នាដែលមាន បង្កើតឱ្យមាននូវដំណើរការបន្តមួយ (រូបភាព ៤.១)។ ជ្រុងមួយនៃដំណើរការបន្តនេះ គឺជាទម្រង់នៃការកាន់កាប់រួមគ្នាបែបមិនផ្លូវការ ឬខុសច្បាប់ ដូចជា ការទទួលស្គាល់តាមព្រឹត្តន័យ ទៅលើការតាំងទីលំនៅបែបមិនផ្លូវការ ឬ ខុសច្បាប់ ឬកិច្ចការពារពីផ្នែកនយោបាយ ប្រឆាំងទៅនឹងការបណ្ដេញចេញដោយបង្ខំ។ នៅជ្រុងកណ្ដាល គឺជាសិទ្ធិកាន់កាប់ សិទ្ធិប្រើប្រាស់រួម កម្មសិទ្ធិអវិជ្ជមានសមូហភាព សម្បទានពិសេស និង ការកាន់កាប់សមូហភាពតាមបែបប្រពៃណី ដែលអាចមានលក្ខណៈមិនផ្លូវការ ឬ ផ្លូវការ។ ជ្រុងមួយទៀតនៃដំណើរការបន្តនេះ គឺជាសហកម្មសិទ្ធិភាព និងការជួលដោយមានការចុះបញ្ជី ដែលជាធម្មតា គេសំដៅហៅថា ប្រភេទនៃការកាន់កាប់ "បែបផ្លូវការ" (UN-HABITAT, 2007b: 24)។

រូបភាព ៤.១ ៖ ការបន្តទទួលបានសិទ្ធិដីធ្លី



ប្រភព ៖ UN-HABITAT, 2008a: 8.

ជម្រើសដោយឡែក ក្រៅពីការផ្តល់ប្លង់ដី (ប្រអប់ ៤.៧) អាចផ្តល់សន្តិសុខលើការកាន់កាប់បាន ប៉ុន្តែ ត្រូវជ្រើសរើសទៅតាមបរិបទ ដូចជា ការតាំងទីលំនៅ នៅតំបន់ជនបទ តំបន់ប្រជុំជន តំបន់ទីក្រុង ការតាំងទីលំនៅមិនរៀបរយ។ល។ កម្រិតសមធម៌យេនឌ័រនៃទម្រង់កាន់កាប់ទាំងនេះ មានភាពខុសគ្នាយ៉ាងខ្លាំង ហើយសន្តិសុខលើការកាន់កាប់ដែលភ្ជាប់ទៅនឹងទម្រង់នៃការកាន់កាប់នីមួយៗ ក៏មានភាពខុសគ្នាផងដែរ ដែលអាស្រ័យទៅលើកត្តាជាច្រើន។ ឧទាហរណ៍ បើប្រៀបធៀបទៅនឹងការកាន់កាប់គ្មានពេលកំណត់ ការជួល ជាពិសេស កិច្ចសន្យាភតិកម្ម មានតម្លៃទាបជាង អាចផ្តល់ជូនបានឆាប់រហ័សជាង មានភាពបត់បែនជាង អាចធ្វើទៅបានបើទោះបីជាកម្មសិទ្ធិភាពដីធ្លីស្ថិតក្រោមវិវាទក៏ដោយ អាចកែលម្អទៅតាមសេចក្តីត្រូវការ និង ទាមទារឱ្យមានប្រព័ន្ធបច្ចេកវិទ្យាដែលមានតម្លៃថោក និងសាមញ្ញ។ វិធានការ ដូចជា ការចុះបញ្ជីរួមគ្នាទៅលើលិខិតជួល ឬ ការចុះបញ្ជីដោយដាក់ឈ្មោះសហព័ទ្ធទាំងពីរ អាចមានភាពចាំបាច់ ដើម្បីជៀសវាងការមិនបញ្ចូលស្ត្រី (Augustinus and Benschop, 2003: 4)។

ប្រភេទនៃការកាន់កាប់មិនផ្លូវការមួយចំនួន ដូចជា ការទទួលស្គាល់ទៅលើការកាន់កាប់តាមព្រឹត្តន័យ តាមរយៈការគាំទ្រផ្នែកនយោបាយ ភស្តុតាងដែលបញ្ជាក់អំពីការបង់វិក្កយបត្រទឹកភ្លើង ភស្តុតាងផ្ទាល់មាត់ សិទ្ធិប្រពៃណីដែលត្រូវបានទទួលស្គាល់ក្នុងលក្ខណៈមិនផ្លូវការ ការយល់ឃើញចំពោះការកាន់កាប់ដែលមានសន្តិសុខល្អ គឺជាប្រភេទនៃការកាន់កាប់បែបមិនផ្លូវការទូទៅបំផុតនៅក្នុងតំបន់អណាធិបតេយ្យ និងការតាំងទីលំនៅមិនរៀបរយ។ សន្តិសុខនៃការកាន់កាប់ដែលគេផ្តល់ជូន អាស្រ័យទៅលើស្ថានភាពក្នុងមូលដ្ឋាន និង ថាតើវាមានការបំពេញបន្ថែមពីទម្រង់ដទៃទៀតនៃកិច្ចការពារប្រឆាំងទៅនឹងការបណ្តេញចេញដោយបង្ខំ ដែរឬទេ (Augustinus and Benschop, 2003: 4)។ គេអាចផ្តល់មូលដ្ឋានសម្រាប់អភិក្រមកែលម្អការកាន់កាប់ជាបណ្តើរៗ ដែលសិទ្ធិកាន់កាប់ត្រូវបានរៀបចំឱ្យមានលក្ខណៈផ្លូវការ ឬ កែលម្អបន្តិចម្តងៗជាបន្តបន្ទាប់។ អភិក្រមកែលម្អជាបណ្តើរៗ អាចបង្កើនសន្តិសុខពីរយៈពេលខ្លីទៅរយៈពេលមធ្យម ខណៈពេលដែលអាជ្ញាធរអភិវឌ្ឍជម្រើសដោយឡែករយៈពេលវែង ដែលកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងផ្តោតការយកចិត្តទុកដាក់នៅក្នុងមូលដ្ឋាន (UN-HABITAT, 2008a: 10-11 and 20)។

សន្តិសុខ និងសេវាកម្មនៅក្នុងប្រទេសកូឡុំប៊ី

ប្រព័ន្ធកាន់កាប់បែបផ្លូវការ រមែងតែងត្រូវបានចាត់ទុកថាមានសារៈសំខាន់ក្នុងការធានាដល់លទ្ធភាពក្នុងការទទួលបានសេវាសាធារណៈ។ បើទោះជាដូច្នេះក្តី នៅក្នុងប្រទេសកូឡុំប៊ី ច្បាប់អនុញ្ញាតឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានសេវាកម្ម ដូចជា ទឹក អនាម័យ អគ្គិសនី ប្រព័ន្ធបង្ហូរទឹក ការប្រមូលសំរាម ទូរស័ព្ទ និងឧស្ម័ន ដរាបណាពួកគេអាចបញ្ជាក់ថាពួកគេរស់នៅក្នុងផ្ទះរបស់ពួកគេ និង អាចបង់ថ្លៃសេវាដែលផ្តល់ជូនបាន។ កម្រងនៃប្រព័ន្ធកាន់កាប់កម្រិតមធ្យម មួយចំនួនដូចជា ការប្រកាសអំពីកម្មសិទ្ធិភាព ការទិញ និងការលក់សិទ្ធិសម្រាប់ប្រើប្រាស់នៅពេលអនាគត និងភតិកម្មសមូហភាព ផ្តល់នូវការបោះជំហានឆ្ពោះទៅរកការពង្រឹងសិទ្ធិ និងកិច្ចការពារពីការបណ្តេញចេញ ដែលបង្កលក្ខណៈឱ្យគ្រួសារក្រីក្រទទួលបានសន្តិសុខចំពោះលំនៅដ្ឋាន ដែលពួកគេ

ប្រអប់ ៤.៧ ៖ ជម្រើសដោយឡែក ក្រៅពីការផ្តល់ប្លង់ដី

ប្រភព ៖ Aristazabal and Gomez, 2004; Yahya, 2002; Farfan, 2002.

អាចមានលទ្ធភាពរកបាន ដោយមិនប្រកាន់អំពីឋានៈនៃការកាន់កាប់របស់ពួកគេ។

លិខិតអនុញ្ញាតកាន់កាប់បណ្ដោះអាសន្នក្នុងប្រទេសកេនយ៉ា

ក្រុមប្រឹក្សាក្រុងណៃរ៉ូប៊ី បានណែនាំលិខិតអនុញ្ញាតកាន់កាប់បណ្ដោះអាសន្ន (TOLs) ដើម្បីលើកកម្ពស់ការប្រើប្រាស់ដីសាធារណៈដែលនៅទំនេរក្នុងតំបន់ទីតាំងយុទ្ធសាស្ត្រ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដូចជា កន្លែងប្រជុំផ្លូវ ដីបម្រុងថ្នល់ នៅក្នុងកន្លែងដែលមាន ដង់ស៊ីតេខ្ពស់ និងដីចំហនៅតំបន់ជាយក្រុង។ ស្ថិតក្រោមលិខិតអនុញ្ញាតកាន់កាប់បណ្ដោះអាសន្ន អាជ្ញាធរមូលដ្ឋានបែងចែកដីធ្លី សម្រាប់ការប្រើប្រាស់ក្នុងគោលបំណងផលិតកម្ម ហើយស្របពេលជាមួយគ្នានោះ ក៏រក្សាឱ្យបានផងដែរនូវការគ្រប់គ្រងរយៈពេលវែង។ លិខិតអនុញ្ញាតនេះ អាចធ្វើថ្មីឡើងវិញមួយឆ្នាំម្ដង ហើយអ្នកកាន់កាប់ ត្រូវបានអនុញ្ញាតឱ្យសាងសង់សំណង់ពាក់កណ្ដាលអចិន្ត្រៃយ៍។ អ្នកកាន់កាប់ត្រូវបង់ថ្លៃជួលដីមួយឆ្នាំម្ដង ដែលចូលទៅក្នុងចំណូលរបស់ក្រុង។ បើទោះបីជាលិខិតអនុញ្ញាត កាន់កាប់បណ្ដោះអាសន្ននេះ មានបំណងបង្កើតប្រាក់ចំណូលដីធ្លីបែបពាណិជ្ជកម្មក៏ដោយ ប៉ុន្តែជួនកាល វាត្រូវបានប្រើប្រាស់សម្រាប់គោលបំណងលំនៅដ្ឋានផងដែរ ហើយគេអាចចម្លងគំរូនេះទៅអនុវត្តនៅកន្លែងដទៃទៀត។

ការជួលដីបណ្ដោះអាសន្ននៅក្នុងប្រទេសថៃ

សហគមន៍ដែលមានប្រាក់ចំណូលទាបនៅក្នុងទីក្រុងបាងកក បានធ្វើការវិវឌ្ឍន៍ទៅលើការរៀបចំដាក់ស្ដែងមួយជាមួយម្ចាស់ដី ដែលបង្កលក្ខណៈឱ្យពួកគេរស់នៅក្នុងតំបន់ដែលបង្កលក្ខណៈឱ្យពួកគេទទួលបានឱកាសប្រកបរបរចិញ្ចឹមជីវិត។ ប្រជាជនក្រីក្រស្វែងរកម្ចាស់ដីដែលកំពុងរង់ចាំឱ្យដីរបស់ពួកគេឡើងថ្លៃ មុនពេលអភិវឌ្ឍដីនោះ និងជួលដីឱ្យពួកគេក្នុងរយៈពេលខ្លីទៅរយៈពេលមធ្យម ដោយបង់ថ្លៃជួលទៅតាមលទ្ធភាពរបស់ពួកគេ។ ម្ចាស់ដីចូលចិត្តការជួលរបៀបនេះ អាស្រ័យដោយវាគឺជាកិច្ចការពារចំពោះការទន្ទ្រានដីធ្លីរបស់ពួកគេពីភាគីទី៣។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ សហគមន៍ និងអាជ្ញាធរ បាននិងកំពុងស្វែងរកវិធីពង្រីកសេវាមូលដ្ឋានទៅកាន់កន្លែងដទៃទៀត ហើយប្រជាជនក្រីក្រ អាចចរចារឱ្យមានការរៀបចំស្រដៀងគ្នាជាមួយម្ចាស់ដីនៅក្នុងតំបន់ថ្មីៗទាំងនោះ។

បញ្ហាយេនឌ័រក្នុងការរៀបចំ និងបង្កើតប្រព័ន្ធ និងមូលដ្ឋានទិន្នន័យព័ត៌មានដីធ្លី[70]

បើទោះបីជាបញ្ហាយេនឌ័រ ជាធម្មតាមិនត្រូវបានកសាងទៅក្នុងប្រព័ន្ធ និងមូលដ្ឋានទិន្នន័យព័ត៌មានដីធ្លីក៏ដោយ ការរៀបចំប្រព័ន្ធព័ត៌មានដីធ្លី ត្រូវស្របទៅតាមក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធរាប់បញ្ចូលទាំងក្របខ័ណ្ឌសម្រាប់បញ្ហាយេនឌ័រផងដែរ។ ឧទាហរណ៍ ប្រសិនបើការផ្ដល់ប្លង់ដីរួមគ្នាត្រូវបាន

កំណត់ដោយច្បាប់ ប្រព័ន្ធគួរត្រូវបានរៀបចំឡើងក្នុងលក្ខណៈមួយដើម្បីគាំទ្រដល់ចំណុចនេះ។ ការរៀបចំប្រព័ន្ធព័ត៌មានដីធ្លីនៅលើក្រដាសឱ្យក្លាយទៅជាប្រព័ន្ធដែលគ្រប់គ្រងដោយកុំព្យូទ័រ ផ្តល់នូវឱកាសសម្រាប់បញ្ចូលបញ្ហាយេនឌ័រ ដូចជា តាមរយៈការណែនាំប្រព័ន្ធសម្រាប់ចុះបញ្ជីយេនឌ័ររបស់ម្ចាស់ដី សំដៅអនុញ្ញាតឱ្យមានការបំបែកព័ត៌មានអំពីយេនឌ័រ និង ការវិភាគទៅលើទិន្នន័យ។ ទម្រង់ប្រមូលទិន្នន័យ និងឯកសារចុះបញ្ជី គួរបញ្ចូលឱ្យមានចន្លោះ គ្រប់គ្រាន់សម្រាប់សរសេរឈ្មោះរបស់ម្ចាស់ដីគ្រប់រូប និង អ្នកដែលមានប្រយោជន៍នៅក្នុងដីនោះ។

មូលដ្ឋានទិន្នន័យ និងប្រព័ន្ធដែលគ្រប់គ្រងដោយកុំព្យូទ័រ អាចត្រូវបានរៀបចំឡើងយ៉ាងងាយស្រួល ដើម្បីចុះបញ្ជីសិទ្ធិសហព័ទ្ធ កម្មសិទ្ធិភាពដីធ្លីរួមគ្នា និងប្រយោជន៍របស់សមាជិកគ្រួសារនៅក្នុងដីនោះ ព្រមទាំងទាមទារឱ្យមានការផ្តល់លិខិតបញ្ជាក់ស្របច្បាប់ ឯកសារ ឬ ព័ត៌មានដទៃទៀត (ឧ. លិខិតអាពាហ៍ពិពាហ៍) មុនពេលបន្តទៅជំហានបន្ទាប់ នៅក្នុងដំណើរការបញ្ចូលទិន្នន័យ។ ឧទាហរណ៍ នៅក្នុងប្រទេសយូហ្គាន់ដា ការផ្ទេរដី តម្រូវឱ្យផ្តល់ទម្រង់ដីធ្លី លេខ ៤១ "ទម្រង់យល់ព្រមពីសហព័ទ្ធចំពោះប្រតិបត្តិការដីធ្លី" ដូច្នេះ ប្រព័ន្ធព័ត៌មានដីធ្លីត្រូវបានរៀបចំឡើង ដើម្បីធានាថាទម្រង់នេះ ត្រូវបានស្នើមុនពេលដែលគេអាចអនុវត្តជំហានបន្ទាប់ក្នុងការផ្ទេរប្តូរដីជាផ្លូវការ។

ដើម្បីធ្វើឱ្យរដ្ឋបាលដីធ្លីកាន់តែមានសមធម៌យេនឌ័រ អ្នកអនុវត្តការងារជាស្ត្រី គួរចូលរួមនៅក្នុងការរៀបចំ និងការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យា ហើយការបណ្តុះបណ្តាលអំពីរដ្ឋបាល និងប្រតិបត្តិការនៃប្រព័ន្ធ និងមូលដ្ឋានទិន្នន័យព័ត៌មានដីធ្លី គួរត្រូវបានរៀបចំឡើងឱ្យស្របទៅតាមសេចក្តីត្រូវការអប់រំរបស់ស្ត្រី និងបុរស។ ឧបករណ៍ទាំងនេះ គួរត្រូវបានវាយតម្លៃពីទស្សនៈវិស័យយេនឌ័រ។ លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃយេនឌ័ររបស់បណ្តាឧបករណ៍ដីធ្លីសកល (GLTN) ដែលត្រូវបានអភិវឌ្ឍឡើងតាមរយៈយន្តការអភិវឌ្ឍឧបករណ៍ដីធ្លីប្រកបដោយសមធម៌យេនឌ័រ គឺជាឧទាហរណ៍មួយដែលប្រសើរបំផុត អំពីការអនុវត្តន៍ល្អក្នុងចំណុចនេះ (UN-HABITAT, 2007a; 2009; 2011)។

✎បញ្ជីផ្ទៀងផ្ទាត់ ៤.៣ ៖ **ការធានាឱ្យមានប្រព័ន្ធព័ត៌មានដីធ្លីប្រកបដោយសមធម៌យេនឌ័រ**

ប្រភព៖ FAO, 2009c: 115.

✓	ប្រើប្រាស់បច្ចេកវិទ្យាមានតម្លៃទាប ដែលក្រុមប្រជាពលរដ្ឋទូលំទូលាយអាចមាន លទ្ធភាពប្រើប្រាស់បាន។
✓	ធានាឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងការអភិវឌ្ឍន៍កម្រងសំនួរ និងការអង្កេត។
✓	ប្រមូលទិន្នន័យដែលមានការបំបែកព័ត៌មានទៅតាមយេនឌ័រ។
✓	នៅពេលប្រមូលទិន្នន័យ ត្រូវសម្ភាសន៍ស្ត្រីដាច់ដោយឡែកពីបុរស ដើម្បីទទួលបានដំណើររឿងពិតរបស់ពួកគេ។
✓	ប្រើប្រាស់ការកំណត់ផែនទីសហគមន៍ដោយមានការចូលរួម សម្រាប់ការធ្វើផែនការ ប្រើប្រាស់ដី និងការប៉ាន់ប្រមាណធនធានដោយជម្រុញឱ្យមានការចូលរួមពីស្ត្រី និងយុវជនដោយឡែកពីគ្នាពីបុរស និងមនុស្សដែលមានវ័យចំណាស់ជាង ព្រមទាំងធានាឱ្យមានវត្តមានរបស់ស្ត្រីនៅក្នុងគ្រប់ក្រុមការងារទាំងអស់។
✓	ពន្យល់ឱ្យបានច្បាស់លាស់អំពីបច្ចេកវិទ្យា និង ផ្តល់ការងារជូនដល់អ្នកអនុវត្តការងារជាស្ត្រីឱ្យបានកាន់តែច្រើននៅក្នុងការងារតាមមូលដ្ឋាន ដើម្បីជួយបង្ហាញថា

	សកម្មភាពរដ្ឋបាលដីធ្លីមានសមធម៌យេនឌ័រ។
✓	ធានាថាទម្រង់ប្រមូលទិន្នន័យ និងឯកសារចុះបញ្ជី ផ្តល់នូវចន្លោះគ្រប់គ្រាន់សម្រាប់បំពេញឈ្មោះម្ចាស់ដីគ្រប់រូប និងអ្នកដែលមានប្រយោជន៍នៅក្នុងដីនោះ ព្រមទាំង មានចន្លោះសម្រាប់កត់ត្រាអំពីយេនឌ័រ។
✓	វាយតម្លៃទៅលើឧបករណ៍តាមរយៈទស្សនៈវិស័យយេនឌ័រ (ឧ. តាមរយៈលក្ខណៈ វិនិច្ឆ័យវាយតម្លៃយេនឌ័ររបស់បណ្តាញឧបករណ៍ដីធ្លីសកល)។

ចូរចងចាំ!
បើទោះបីជាបច្ចេកវិទ្យាមានភាពអព្យាក្រឹត្យលើបញ្ហាយេនឌ័រក៏ដោយ ប៉ុន្តែ ការប្រើប្រាស់បច្ចេកវិទ្យា អាចពុំមានភាពអព្យាក្រឹត្យលើបញ្ហាយេនឌ័រឡើយ។

ការវាយតម្លៃ[១១]

អាស្រ័យដោយស្ត្រីជាច្រើនមានធនធានហិរញ្ញវត្ថុតិចជាងបុរស ដូច្នេះ វាមានសារៈសំខាន់ជាពិសេស ដែលទ្រព្យសម្បត្តិរបស់ស្ត្រីត្រូវវាយតម្លៃប្រកបដោយភាពយុត្តិធម៌។ ការវាយតម្លៃប្រកបដោយភាពយុត្តិធម៌ ត្រូវពិចារណាទៅលើគោលបំណងនៃការវាយតម្លៃទ្រព្យសម្បត្តិចំនួន២ ដែលមានលក្ខណៈផ្ទុយគ្នា ៖ ១) សម្រាប់គណនាទៅលើពន្ធទ្រព្យសម្បត្តិ និង ២) សម្រាប់គណនាសំណងចំពោះម្ចាស់កម្មសិទ្ធិ ក្នុងករណីអស្សាមិករណ៍។

✎បញ្ជីផ្ទៀងផ្ទាត់ ៤.៤ ៖ **ការគាំទ្រចំពោះការវាយតម្លៃប្រកបដោយសមធម៌យេនឌ័រ**

ប្រភព៖ Nigel Edmead's presentation on "Gender issues in designing and setting up land information systems and databases: experiences from Ghana, Zambia and Uganda" at the May 2011 technical workshop.

✓	ធានាថាប្រព័ន្ធវាយតម្លៃពិចារណាទៅលើតម្លៃមិនមែនទីផ្សារមួយចំនួនដូចជាតម្លៃ សង្គម វប្បធម៌ សាសនា ស្មារតី និងបរិស្ថាន។
✓	ប៉ាន់ប្រមាណទៅលើឥទ្ធិពលនៃកត្តាសង្គម ដូចជាទំនាក់ទំនងសង្គម កិត្យានុភាព ភាតរភាព ទៅលើការចរចារ ដើម្បីកំណត់តម្លៃទ្រព្យសម្បត្តិជាពិសេស សម្រាប់ ក្រុមងាយរងគ្រោះ ដូចជា ស្ត្រីមេម៉ាយ និងស្ត្រីមេគ្រួសារដែលមានអំណាច ទន់ខ្សោយក្នុងការចរចារផ្នែកនយោបាយ។
✓	រក្សាតម្លៃសេវាឱ្យស្ថិតនៅកម្រិតអប្បបរមា។
✓	ពន្យល់ទៅកាន់ម្ចាស់ដីអំពីរបៀបសម្រេចទៅលើការវាយតម្លៃ ជាពិសេស ស្ត្រីដែល រមែងតែងមានកម្រិតអក្ខរភាពទាបជាងបុរស និងខ្វះព័ត៌មាន។
✓	ទប់ស្កាត់អំពើពុករលួយ តាមរយៈការបង្កលក្ខណៈឱ្យមានព័ត៌មានវាយតម្លៃ និង ការវិភាគជូនដល់សាធារណជន។

ការកំណត់ពន្ធ[១២]

គោលនយោបាយពន្ធដារ មានផលប៉ះពាល់ទៅលើភាពក្រីក្រ ការបែងចែកប្រាក់ចំណូល និងសមធម៌យេនឌរ។ គេត្រូវយកចិត្តទុកដាក់ដើម្បីធានាថា គោលនយោបាយពន្ធដារ ពុំបង្កឱ្យមានការរើសអើងទៅលើបុរស ឬ ស្ត្រី

កាន់តែមានភាពធ្ងន់ធ្ងរ ជាពិសេស ក្រុមងាយរងគ្រោះ ដូចជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។ ការកំណត់យកពន្ធធ្ងន់ធ្ងរទៅលើ (សហ) កម្មសិទ្ធិភាពទ្រព្យសម្បត្តិ អាចលើកទឹកចិត្តឱ្យប្រជាពលរដ្ឋគេចពីការចុះបញ្ជីផ្លូវការ និង បន្តស្ថិតក្រោមទម្រង់នៃការកាន់កាប់ដែលមិនសូវមានសន្តិសុខល្អប្រសើរ។ ក្នុងលក្ខណៈជាវិធានទូទៅ ពន្ធដីធ្លីប្រចាំឆ្នាំ មិនគួរមានតម្លៃលើសពី ១% នៃតម្លៃទ្រព្យសម្បត្តិឡើយ ហើយពន្ធសម្រាប់ការទទួលបានដី មិនគួរមានតម្លៃលើសពី ៣% ឡើយ។

បញ្ជីផ្ទៀងផ្ទាត់ ៤.៥ ៖

ការគាំទ្រចំពោះការកំណត់យកពន្ធដែលមានសមធម៌យេនឌ័រ

- ✓ ធានាថា ស្ត្រី និងបុរស ទទួលបានការប្រព្រឹត្តស្មើភាពគ្នានៅក្នុងក្រុម និង និយ័តកម្ម ស្តីពីពន្ធដារ។
- ✓ ដោះស្រាយផលប៉ះពាល់ខុសៗគ្នាដែលពន្ធដីធ្លី អាចមានទៅលើស្ត្រី និងបុរស ដូចជា ចំណែករបស់ពួកគេនៅក្នុងកម្មសិទ្ធិភាព ការប្រើប្រាស់ដីធ្លី និងជីវភាព រស់នៅ និងការអនុវត្តន៍ផ្ទេរដីធ្លី។
- ✓ ធានាថាការពិភាក្សាវែកញែកនយោបាយ ទាក់ទងទៅនឹងគោលនយោបាយដីធ្លី ទទួលបានព័ត៌មានពេញលេញ អំពីផលប៉ះពាល់សង្គមនៃជម្រើសគោល នយោបាយស្តីពីពន្ធដារ ជាពិសេស ទៅលើបញ្ហាសមធម៌យេនឌ័រ។
- ✓ កំណត់រកមូលដ្ឋានពន្ធដារមួយ ដែលងាយយកមកអនុវត្ត និងប៉ាន់ប្រមាណ ប៉ុន្តែក៏ត្រូវធានាឱ្យមានភាពយុត្តិធម៌ និងសមស្របផងដែរ។
- ✓ ធានាថា ពន្ធមានមូលដ្ឋានផ្អែកលើតម្លៃសមស្រប។
- ✓ ពិចារណាផ្តល់ការលើកលែងពន្ធ និងការសម្រាលពន្ធ សម្រាប់ក្រុមងាយរងគ្រោះ ដូចជាស្ត្រីក្រីក្រ។
- ✓ ប៉ាន់ប្រមាណ ថាតើអ្នកបង់ពន្ធអាចទទួលយកការបង់ពន្ធដល់កម្រិតណា និង ពន្យល់ទៅកាន់ពួកគេអំពីសេចក្តីត្រូវការ និងការប្រើប្រាស់ពន្ធដែលបានប្រមូល។ អ្នកបង់ពន្ធអាចចូលរួមនៅក្នុងការកំណត់អត្រាពន្ធ និង សម្រេចចិត្តអំពីរបៀបដែលគេគួរប្រើប្រាស់ចំណូលពីពន្ធ។
- ✓ ប៉ាន់ប្រមាណ និងប្រមូលពន្ធក្នុងលក្ខណៈដែលមិនរើសអើងទៅលើស្ត្រី និងបុរស ដោយពិចារណាទៅលើបញ្ហាមួយចំនួន ដូចជា អនក្ខរភាព និងកង្វះព័ត៌មាន ឬ មធ្យោបាយធ្វើដំណើរដែលអាចច្របាច់បញ្ចូលគ្នាជាមួយសកម្មភាពដទៃទៀត ដូចជាកិច្ចប្រជុំសហគមន៍ ទីផ្សារ ឬ វគ្គបណ្តុះបណ្តាល។
- ✓ ធានាថាចំណូលពីពន្ធត្រូវបានប្រើប្រាស់ក្នុងលក្ខណៈដែលផ្តល់ប្រយោជន៍ដល់ស្ត្រី និងបុរស តាមរយៈការជម្រុញឱ្យមានការចូលរួមពីយេនឌ័រទាំងពីរនៅក្នុង ការវិភាគសេចក្តីត្រូវការ ដូចជា តាមរយៈការធ្វើផែនការថវិកាដោយមាន ការចូលរួមនៅកម្រិតថ្នាក់ក្រុង។
- ✓ ធ្វើការបណ្តុះបណ្តាលអំពីការបំពេញទម្រង់ពន្ធដារ និងចំនួនទឹកប្រាក់ដែលត្រូវ បង់នៅក្នុងស្ថានភាពផ្សេងៗគ្នា ដូចជា

ប្រភព ៖ FAO *et al.*, 2007.

	ប្រតិបត្តិការទ្រព្យសម្បត្តិ ការទទួលបាន អចលនទ្រព្យ រាប់បញ្ចូលតាមរយៈការស្នងមរតក ឬ ការផ្តល់ជាអំណោយ។ល។
✓	ធានាឱ្យមានតម្លាភាព តាមរយៈការផ្សព្វផ្សាយអំពីការប៉ាន់ប្រមាណជាសាធារណៈ។
✓	រៀបចំនីតិវិធីដែលផ្តល់ឱកាសដល់ស្ត្រី និងបុរស ធ្វើការប្តឹងតវ៉ាឱ្យមានការពិនិត្យឡើងវិញទៅលើការប៉ាន់ប្រមាណពន្ធរបស់ពួកគេ។

ការធ្វើផែនការប្រើប្រាស់ដី[១៣]

ការធ្វើផែនការប្រើប្រាស់ដី នាំឱ្យមានផលប៉ះពាល់ទៅលើរបៀបដែលប្រជាពលរដ្ឋអាចប្រើប្រាស់ដី ដែលស្ថិតក្រោមសិទ្ធិរបស់ពួកគេ។ នៅក្នុងប្រទេសជាច្រើន ស្ត្រី និងបុរស ប្រើប្រាស់ដីក្នុងលក្ខណៈផ្សេងៗគ្នា ដូច្នេះ អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ ទាមទារឱ្យមានការធ្វើផែនការប្រើប្រាស់ដីធ្លីដែលផ្តោតយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ។

ការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួមនៅថ្នាក់មូលដ្ឋាន គឺជាវិធីមួយដ៏ល្អក្នុងការសម្រេចឱ្យបាននូវគោលបំណងនេះ ដូចឧទាហរណ៍នៃការកំណត់ផែនទីសហគមន៍ពីប្រទេសហ្វីលីពីន ដែលមានរៀបរាប់នៅក្នុងប្រអប់ ៤.៤ បានបញ្ជាក់។ ប្រអប់ ៤.៨ ពន្យល់អំពីការអនុវត្តន៍ល្អដទៃទៀត ពីប្រទេសអេជូពី និងប្រទេសម៉ាលី។ អភិក្រមពជំហាន ដែលមានរៀបរាប់នៅក្នុងករណីប្រទេសអេជូពី អាចចម្លងយកទៅអនុវត្តនៅក្នុងបរិបទ និងប្រទេសដទៃទៀត។

ប្រអប់ ៤.៨ ៖

ការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួមប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ Wehrman, 2011: 156–157.

នៅក្នុង *ប្រទេសអេដូពី* គម្រោងស្តីពីផែនការប្រើប្រាស់ដី និងការគ្រប់គ្រងធនធានធម្មជាតិរបស់ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (GIZ) នៅក្នុងតំបន់អរ៉ូមៀ បានបញ្ចូលការបញ្ជ្រាបយេនឌ័រទៅក្នុងការរៀបចំគម្រោងរបស់ខ្លួន។ នីតិវិធីជ្រើសរើសបុគ្គលិក បានលើកកម្ពស់តុល្យភាពយេនឌ័រ រវាងបុគ្គលិកជាស្ត្រី និងបុរស - ក្នុងករណីដែលសកម្មភាពនេះមិនអាចធ្វើទៅបាន ទីប្រឹក្សា និងអ្នកហាត់ការងារជាស្ត្រីត្រូវបានជួលឱ្យធ្វើការងារជំនួសវិញ។ បុគ្គលិកគម្រោង និងបុគ្គលិកសមភាគី ត្រូវបានបណ្តុះបណ្តាលអំពីការធ្វើសមាហរណកម្មបញ្ហាយេនឌ័រ ទៅក្នុងគ្រប់សកម្មភាពទាំងអស់។ ការធ្វើផែនការប្រើប្រាស់ដីបែបចូលរួម និង សកម្មភាពវាយតម្លៃនៅតំបន់ជនបទបែបចូលរួមពីស្ត្រី និងបុរស មានការចូលរួមពីស្ត្រី និងបុរស ដែលជាក្រុមប្រជាជនគោលដៅ ហើយពេលវេលា និងតំបន់ទីតាំងរបស់ពួកគេ ត្រូវបានរៀបចំផែនការ ដើម្បីជៀសវាងការបាត់បង់ប្រយោជន៍សម្រាប់ស្ត្រី ឬ បុរស។ ឧបករណ៍វិភាគយេនឌ័រ ត្រូវបានប្រើប្រាស់ដើម្បីប្រមូលព័ត៌មានអំពីការទទួលបាន និងការគ្រប់គ្រងទៅលើធនធាន សកម្មភាព និងទម្ងន់ការងាររបស់គ្រប់សមាជិកគ្រួសារទាំងអស់ និង ការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅកម្រិតផ្សេងៗគ្នា។ ការអង្កេតរបស់គម្រោងបានបង្កើតឱ្យមាននូវទិន្នន័យដែលបំបែកព័ត៌មានទៅតាមយេនឌ័រ ដែលត្រូវបានយកមកប្រើប្រាស់ ដើម្បីវិភាគទៅលើការប្រើប្រាស់ដីធ្លីដែលមានស្រាប់ នៅក្នុងស្រុក និង សហគមន៍គោលដៅរបស់គម្រោង។

ឥឡូវនេះ ស្ត្រីចូលរួមពេញលេញនៅក្នុងការធ្វើផែនការប្រើប្រាស់ដីបែបចូលរួម នៅក្នុងតំបន់អរ៉ូមៀ ព្រមទាំងចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តសាធារណៈ និងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងគ្រួសារ។ សកម្មភាពសេដ្ឋកិច្ច ដែលគម្រោងបានផ្តួចផ្តើមឡើង បានបន្តតាមរយៈក្រុមស្ត្រីដែលមានលក្ខណៈប្រពៃណី ដោយមានចំនួនស្ត្រីចូលរួមកាន់តែច្រើនឡើង។

គំនូសផែនទីការងារដោយឡែក ដែលធ្វើឡើងដោយស្ត្រី និងបុរស នៅក្នុងប្រទេសម៉ាលី បានបង្ហាញឱ្យដឹងថា ស្ត្រីផ្តល់វិភាគទានដ៏មានតម្លៃចំពោះការរៀបចំផែនការ និងការគ្រប់គ្រងដីធ្លី ព្រមទាំងធនធានធម្មជាតិដទៃទៀត នៅពេលដែលពួកគេចូលរួមនៅក្នុងការធ្វើផែនការប្រើប្រាស់ដីបែបចូលរួម។ គំនូសផែនទីការងាររបស់ស្ត្រី ផ្តោតលើបញ្ហាប្រើប្រាស់ដី ដែលទាក់ទងទៅនឹងសួនបន្លែរបស់ស្ត្រី វាលស្រែ និងការទទួលបានទឹក។ វាគ្របដណ្តប់ទៅលើតំបន់មួយ ដែលតូចជាងគំនូសផែនទីការងាររបស់បុរស ប៉ុន្តែ វាផ្តល់នូវព័ត៌មានលម្អិតខ្លាំងជាងអំពីតំបន់មួយផ្នែកនៃភូមិនេះ ដែលភាគច្រើនស្ត្រីជាអ្នកប្រើប្រាស់។ គំនូសផែនទីការងាររបស់បុរស ផ្តោតលើតំបន់ដាច់ស្រយាលដែលមានភាពពាក់ព័ន្ធច្រើនជាង ទៅនឹងការងាររបស់ពួកគេ។ ដូច្នេះ គំនូសផែនទីទាំងពីរនេះ បំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ហើយវារួមចំណែកស្មើភាពគ្នាចំពោះរូបភាពរួម នៃស្ថានភាពធនធានក្នុងមូលដ្ឋាន។



ការងារបុរស



ការងារស្ត្រី

បញ្ជីផ្ទៀងផ្ទាត់ ៤.៦ ៖
ការគាំទ្រចំពោះការធ្វើផែនការប្រើប្រាស់ដីប្រកបដោយសមធម៌យេនឌ័រ

- ✓ ជម្រុញឱ្យមានការចូលរួមពីស្ត្រីក្នុងការបញ្ជាក់អំពីសេចក្តីត្រូវការ និង/ឬ ការទាមទារឱ្យមានការធ្វើផែនការប្រើប្រាស់ដី (រាប់បញ្ចូលការធ្វើបច្ចុប្បន្នភាពទៅលើផែនការដែលមានស្រាប់) អាស្រ័យដោយស្ត្រីអាចមើលអំពីការទាមទារ និងសេចក្តីត្រូវការ ដែលបុរសអាចមើលមិនឃើញ។
- ✓ វិភាគទៅលើស្ថានភាពក្នុងមូលដ្ឋាន ៖ សិទ្ធិដីធ្លីដែលមានស្រាប់ ដែលបានចុះបញ្ជី និងមិនបានចុះបញ្ជី ជាពិសេស សិទ្ធិដីធ្លីរបស់ស្ត្រី ការប្រើប្រាស់ និងការទទួលបានប្រយោជន៍ខុសៗគ្នាពីដី។ល។
- ✓ នៅពេលកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធដើម្បីចូលរួមនៅក្នុងសិក្ខាសាលាធ្វើ ផែនការប្រើប្រាស់ដី ត្រូវធានាឱ្យមានការចូលរួមពីជំនាញការជាស្ត្រី សមាជិក នៃសមាគមស្ត្រី និងស្ត្រីដែលតំណាងឱ្យក្រុមសង្គមផ្សេងៗគ្នា។
- ✓ ធ្វើការងារជាមួយស្ត្រីទាំងនេះដោយផ្ទាល់ នៅពេលផ្សព្វផ្សាយ ឬ ជូនដំណឹងដល់អ្នកពាក់ព័ន្ធ។
- ✓ ធានាថាស្ត្រីត្រូវបានទាក់ទងនៅពេលមានកិច្ចសន្ទនាជាមួយអ្នកចូលរួម (អ្នកប្រើប្រាស់ដី)។
- ✓ ធានាឱ្យមានភាពជាតំណាងស្មើភាពគ្នានៅក្នុងកិច្ចសម្ភាសន៍ប្រមូលទិន្នន័យក្រុមពិភាក្សា និងសិក្ខាសាលា។ ពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំ ត្រូវសម្របទៅតាមកាលវិភាគ និងលទ្ធភាពចូលរួមរបស់ស្ត្រី។
- ✓ ទាក់ទងស្ត្រីដោយឡែកពីគ្នាពីបុរស ដើម្បីធានាថាពួកគេលើកឡើងនូវបញ្ហា

ដែលមានសារៈសំខាន់ចំពោះពួកគេ។

- ✓ ជម្រុញឱ្យមានការចូលរួមពីស្ត្រីនៅក្នុងការប្រមូលទិន្នន័យ ដូចជាការវិភាគស្ថានភាព សេចក្តីត្រូវការ សក្តានុពល។ល។ អាស្រ័យដោយពួកគេរមែងតែងមានព័ត៌មានសំខាន់ៗដែលបុរសមិនមាន ឬ បុរសមិនផ្តល់តម្លៃ។
- ✓ បង្កើតឱ្យមានការយល់ដឹងអំពីបញ្ហាយេនឌ័រ ក្នុងការធ្វើផែនការប្រើប្រាស់ដី។
- ✓ កំណត់រកវិធានការដែលអាចអនុវត្តបាន ដើម្បីកាត់បន្ថយវិសមភាពយេនឌ័រ។
- ✓ នៅពេលដែលផែនការកំពុងត្រូវបានរៀបចំបង្កើតឡើង (ជាញឹកញាប់ដោយ អ្នកជំនាញការ) ត្រូវចាត់ទុកថាធាតុចូលរបស់ស្ត្រីមានសារៈសំខាន់ដូចគ្នាទៅនឹងធាតុចូលរបស់បុរសដែរ។
- ✓ ជាមួយនឹងអ្នកជំនាញការផ្នែកផ្សព្វផ្សាយអំពីយេនឌ័រ ចូរពិភាក្សាអំពីផលប៉ះពាល់នៃវិធានការដែលអាចមានទៅលើស្ត្រី និងបុរស។
- ✓ ជម្រុញឱ្យមានការចូលរួមពីស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។
- ✓ ធានាថាផែនការឆ្លើយតបទៅនឹងសេចក្តីត្រូវការ និង ការរំពឹងទុករបស់ស្ត្រីដូចគ្នាទៅនឹងការរំពឹងទុករបស់បុរសផងដែរ។
- ✓ ធានាថាសកម្មភាពអាទិភាពដែលត្រូវបានអនុវត្តដំបូងគេ ផ្តល់ប្រយោជន៍ស្មើភាពគ្នាចំពោះស្ត្រី និង បុរស។
- ✓ ការត្រួតពិនិត្យទៅលើការអនុវត្តន៍ផែនការប្រើប្រាស់ដី ត្រូវផ្អែកលើទិន្នន័យដែលបំបែកព័ត៌មានទៅតាមយេនឌ័រ។

ការច្រប្រាច់បញ្ចូលគ្នា និងការកែសម្រួលដីឡើងវិញ[១៨]

ការប្របាច់កញ្ចប់ដីធ្លីបញ្ចូលគ្នា មិនចំពោះថាជាដីលំនៅដ្ឋាន ឬ ដីកសិកម្ម និងការបែងចែកសិទ្ធិឡើងវិញនៅក្នុងព្រំប្រទល់ថ្មី អាចមានផលប៉ះពាល់ចម្បងៗទៅលើកម្មសិទ្ធិភាពដីធ្លីដែលមានស្រាប់ និងសិទ្ធិប្រើប្រាស់របស់ស្ត្រី និងបុរស។ ដូច្នេះ វាមានសារៈសំខាន់ខ្លាំងណាស់ដែលត្រូវពិចារណាទៅលើសិទ្ធិដែលមានស្រាប់ទាំងនេះ និងសេចក្តីត្រូវការប្រើប្រាស់ដីរបស់ស្ត្រី និងបុរសដែលទទួលរងផលប៉ះពាល់។ អភិក្រមបែបចូលរួមក្នុងការរៀបចំយុទ្ធសាស្ត្រ និងគម្រោងប្របាច់ដីបញ្ចូលគ្នា ផ្តល់នូវជំនួយជាពិសេស។

បញ្ជីផ្ទៀងផ្ទាត់ ៤.៧ ៖
ការគាំទ្រចំពោះការប្របាច់ដីធ្លីបញ្ចូលគ្នាប្រកបដោយសមធម៌យេនឌ័រ

- ✓ វិភាគទៅលើព្រំប្រទល់ដែលមានស្រាប់ និង ស្ថានភាពស្របច្បាប់នៃកញ្ចប់ដីធ្លីដោយផ្តោតទៅលើសិទ្ធិស្ត្រី (បានចុះបញ្ជី និងមិនបានចុះបញ្ជី)។
- ✓ កំណត់រកអ្វីដែលសហគមន៍ត្រូវការ និងចង់បាន ដោយពិគ្រោះយោបល់ជាមួយស្ត្រី និងយុវជនដោយឡែកពីគ្នាពីបុរស និងមនុស្សដែលមានវ័យចំណាស់ជាង។
- ✓ ធានាថាគោលនយោបាយជាតិ ដែលទាក់ទងទៅនឹងការប្របាច់ដីបញ្ចូលគ្នា

ជានា ដល់សិទ្ធិរបស់ស្ត្រី និងបុរស ព្រមទាំងគាំទ្រដល់សិទ្ធិស្នងមរតករបស់ស្ត្រី និងកុមារី។

✓ ផ្តល់ការបណ្តុះបណ្តាលដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ សម្រាប់ មន្ត្រីដែលធ្វើការងារលើបញ្ហាប្រូបាច់ដីបញ្ចូលគ្នា។

✓ ចែករំលែកសេចក្តីព្រាងផែនការគោលគំនិត ដែលចែងអំពីគោលបំណង វិស័យ វិសាលភាព និង ការវិភាគនៃការប្រូបាច់បញ្ចូលគ្នា ជាមួយស្ត្រី និងបុរសនៃសហគមន៍ដែលទទួលរងផលប៉ះពាល់ និង ធានាថាប្រជាពលរដ្ឋគ្រប់រូបដែលពាក់ព័ន្ធ មានលទ្ធភាពទទួលបានព័ត៌មាននេះ (តាមរយៈសារព័ត៌មាន វិទ្យុ អ៊ិនធឺណែត)។

✓ ប្រមូលទិន្នន័យអំពីទ្រព្យសម្បត្តិ ការប្រើប្រាស់ និងគ្រប់គ្រងដី និងសូចនាករសង្គម សេដ្ឋកិច្ចដទៃទៀត (អក្ខរភាព កម្រិតនៃការអប់រំ ប្រភពនៃប្រាក់ចំណូ ល។ល។) នៅក្នុងសហគមន៍ ដោយបំបែកព័ត៌មានទៅតាមយេនឌ័រ។

✓ បញ្ចូលស្ត្រី និង បុរស នៅក្នុងសហគមន៍ទៅក្នុងក្រុមប្រឹក្សាភិបាលប្រូបាច់ដីធ្លីបញ្ចូលគ្នា។ សម្របសម្រួលឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចប្រជុំ និងរៀបចំឱ្យមានការកិច្ចប្រជុំសម្រាប់តែស្ត្រីប៉ុណ្ណោះ។

✓ ធានាឱ្យមានតម្លាភាព ទាក់ទងទៅនឹងការវាយតម្លៃកញ្ចប់ដីធ្លី។

✓ បញ្ចូលគ្រប់ស្ត្រី និងបុរស ដែលកញ្ចប់ដីធ្លីរបស់ពួកគេទទួលរងផលប៉ះពាល់ទៅក្នុងការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត ដោយមិនប្រកាន់ថាម្ចាស់កម្មសិទ្ធិផ្លូវការជានរណាឡើយ។

✓ ចែករំលែកអំពីផែនការប្រូបាច់ដីបញ្ចូលគ្នាលម្អិតមួយ ដែលបង្ហាញអំពីទម្រង់កញ្ចប់ ដីធ្លីថ្មី ទីតាំងផ្លូវថ្មី និង មូលដ្ឋានសេវាសារណៈដទៃទៀត ជាមួយស្ត្រី និងបុរស និង កំណត់រកផ្លូវ និងមូលដ្ឋានសេវាសាធារណៈដែលនឹងត្រូវរុះរើចេញ។

✓ បញ្ចូលមតិយោបល់ទៅក្នុងផែនការ និងផ្តល់ឱកាសជូនដល់ស្ត្រី និងបុរសក្នុងការ លើកឡើងនូវការជំទាស់ ទាក់ទងទៅនឹងព្រំប្រទល់ កម្មសិទ្ធិភាព ការវាយតម្លៃ ។ល។

✓ រៀបចំឱ្យមានការត្រួតពិនិត្យឡើងវិញបែបចូលរួមមួយ ទៅលើជម្រើសប្រូបាច់ដីបញ្ចូលគ្នា។

✓ ជូនដំណឹងដល់សហគមន៍អំពីការអនុម័ត ការអង្កេតទៅលើព្រំប្រទល់ថ្មីនៅមូលដ្ឋាន បច្ចុប្បន្នភាពចុងក្រោយនៃផែនទីសុរិយោដី និង ការផ្តល់ ព្រមទាំងការចុះបញ្ជីប្លង់ដីថ្មី។

✓ បង្កើតឱ្យមានគម្រោងសំណងដែលមានភាពយុត្តិធម៌ និងមានតម្លាភាព ដែលមិន រើសអើងស្ត្រី និង ដែលពាក់ព័ន្ធទៅនឹងការទូទាត់សំណងជូនសហព័ទ្ធទាំងពីរ និង ម្ចាស់ដីគ្រប់រូប។

✓ លើកកម្ពស់ជំនួយផ្នែកច្បាប់ សម្រាប់ស្ត្រីដែលធ្វើការតស៊ូមតិដើម្បីសិទ្ធិស្ត្រី។

ការបែងចែកដីឡើងវិញ និងបដិទាន[១៥]

ប្រអប់ ៤.៩ ៖ ផលប៉ះពាល់នៃការបែងចែកដីធ្លីឡើងវិញទៅលើស្ត្រីនៅអឺរ៉ុបភាគខាងកើត

ប្រភព ៖ World Bank, 2005: 8; Giovarelli and Duncan, 1999.

នៅក្នុងដំណើរការឯកជននីយកម្ម ក្រោយពេលដួលរលំរបបកុំម្មុយនីស្តនៅអឺរ៉ុបខាងកើត បដិទានដីធ្លីត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ដើម្បីប្រគល់ដីទៅឱ្យម្ចាស់ដីដើមវិញ ដែលសិទ្ធិជាម្ចាស់របស់ម្ចាស់ដីទាំងនោះ ត្រូវបានដកហូតក្រោមច្បាប់ដែលបង្កើតឡើងដោយអតីតរដ្ឋាភិបាលកុំម្មុយនីស្ត (Osskó, 2002) (តិច ឬច្រើន រដ្ឋាភិបាលទាំងនេះ បានអនុវត្តតាមការដឹកនាំរបស់សហភាពសូវៀត ដែលធ្វើឱ្យដីធ្លីទាំងអស់ក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ)។

នៅក្នុង*ប្រទេសអាល់បានៀ* ដីធ្លីត្រូវបានចែងចែកឡើងវិញ ជូនដល់គ្រួសារកសិករ និងអតីតសមាជិកសហករ និង កសិដ្ឋានរបស់រដ្ឋ ដោយយោងទៅតាមចំនួនមនុស្សនៅក្នុងគ្រួសារ។ បើទោះជាដូច្នេះក្តី ដីត្រូវបានផ្តល់ប្លង់ និងចុះបញ្ជីក្រោមឈ្មោះមេគ្រួសារប៉ុណ្ណោះ។

នៅក្នុង*ប្រទេសអាហ្សែបៃចាន* ច្បាប់កំណែទម្រង់ដីធ្លី ឆ្នាំ១៩៩៦ តម្រូវឱ្យដីដែលកាន់កាប់ក្រោមកម្មសិទ្ធិសមូហភាពពីមុន ត្រូវបែងចែក និង ចែកចាយទៅឱ្យប្រជាពលរដ្ឋនៅតំបន់ជនបទ។ ស្ថិតក្រោមគម្រោងឯកជននីយកម្មកសិដ្ឋាន របស់ធនាគារពិភពលោក សមាជិកគ្រួសារដែលមានអាយុយ៉ាងហោចណាស់ ១៦ឆ្នាំ ឬ ១៨ឆ្នាំ បានទទួលចំណែកមួយចំនួន ហើយឈ្មោះរបស់ពួកគេត្រូវបានបញ្ចូលទៅក្នុងលិខិតបញ្ជាក់ដីធ្លី បើទោះបីជាមានតែឈ្មោះមេគ្រួសារដែលត្រូវបានបញ្ចូលទៅក្នុងបញ្ជីដីធ្លីក៏ដោយ។ ដីដែលត្រូវបានបែងចែកឡើងវិញនេះ ត្រូវបានកាន់កាប់ក្រោមកម្មសិទ្ធិភាពរួម។ ប្រទេសអាហ្សែបៃចាន បានរក្សាប្រពៃណីដ៏សែនចាស់ ដែលមិនលើកទឹកចិត្តឱ្យមានការបែងចែកប្រភេទនេះឡើយ។ ក្រោមច្បាប់ប្រពៃណីរបស់ប្រទេស ដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិក្រោយពេលរៀបអាពាហ៍ពិពាហ៍ និងការស្នងមរតក ស្ត្រីមិនទទួលបានដីឡើយ បើទោះបីជាស្ថិតក្រោមច្បាប់ឆ្នាំ១៩៩៦ ស្ត្រីមានសិទ្ធិទទួលបានដីកសិកម្មក៏ដោយ។ ជាលទ្ធផល នៅក្នុងផ្ទៃដីកសិកម្មជាច្រើនដែលត្រូវបានបែងចែកឡើងវិញ ស្ត្រីបានទទួលដីតូចជាងបុរស។

បើទោះបីជាផលប៉ះពាល់ផ្សេងៗគ្នាទៅលើយេនឌ័រនៃដំណើរការបដិទាននេះ មិនត្រូវបានសិក្សាទូលំទូលាយក៏ដោយ ប៉ុន្តែ មានសញ្ញាណមួយចំនួននៃការប្រព្រឹត្តមិនស្មើភាពគ្នាទៅលើស្ត្រី និងបុរស ព្រមទាំងមានភស្តុតាង ដែលបញ្ជាក់អំពីការវិលត្រឡប់មកវិញ នៃនិយាមបទដ្ឋាន និងការអនុវត្តន៍បែបបិតុនិយម នៅកម្រិតមូលដ្ឋាន ទាក់ទងទៅនឹងសិទ្ធិដីធ្លីរបស់ស្ត្រី (ប្រអប់ ៤.៩) បើទោះបីជានៅកន្លែងដែលវិធានឯកជននីយកម្មផ្លូវការមិនរើសអើងស្ត្រីក៏ដោយ។

សមធម៌យេនឌ័រមានសារៈសំខាន់ជាពិសេស នៅក្នុងសកម្មភាពបដិទានដីធ្លី ក្រោយពេលគ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស ជម្លោះ និងគ្រោះមហន្តរាយធម្មជាតិ (UNHCS, 1999)។ ស្ត្រីតែងតែជួបប្រទះ

ឧបសគ្គចម្បងៗក្នុងការទទួលបានដីធ្លីក្រោយពេលមានជម្លោះ និងគ្រោះមហន្តរាយ និងនៅពេលដែលអភិបាលកិច្ចលើការកាន់កាប់ដីធ្លីជាទូទៅមានការលំបាកធ្ងន់ធ្ងរ បញ្ហាសមធម៌យេនឌ័រអាចពុំមែនជាអាទិភាពបន្ទាន់ឡើយ។ យ៉ាងណាមិញ នៅក្នុងប្រទេសកូឡុំប៊ី ច្បាប់ស្តីពីជនរងគ្រោះ និងបដិទានដីធ្លី ឆ្នាំ២០១១ មានគោលបំណងកាត់បន្ថយការខាតបង់របស់ជនរងគ្រោះនៃជម្លោះប្រដាប់អាវុធផ្ទៃក្នុងពុំរ៉ែ។ ច្បាប់ថ្មីនេះ ប្រកាន់យកអភិក្រមមួយដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ និងពិចារណាទៅលើចរិកលក្ខណៈពិសេស ដោយផ្អែកលើអាយុ បែបផែនជីវិតផ្លូវភេទ និងពិការភាព។ និយ័តកម្មសម្រាប់ស្ត្រីនៅក្នុងដំណើរការបដិទាន ផ្តល់អាទិភាពដល់ស្ត្រីនៅក្នុងនីតិវិធីបដិទានដីធ្លី និងការផ្តល់ប្លង់ដីជាផ្លូវការចំពោះកម្មសិទ្ធិភាពដែលត្រូវបានធ្វើបដិទានជូន។ ឯកសារកាន់កាប់ដីធ្លីត្រូវបានផ្តល់ជូន និងចុះបញ្ជីរួមគ្នាជាមួយសហព័ទ្ធ ឬ ដៃគូអចិន្ត្រៃយ៍ បើទោះបីជាសហព័ទ្ធ ឬ ដៃគូពុំមានវត្តមាននៅក្នុងអំឡុងពេលនៃនីតិវិធីរដ្ឋបាលក៏ដោយ (Meertens, 2012)។

ការបញ្ជ្រាបបញ្ហាព្រួយបារម្ភអំពីយេនឌ័រ ទៅក្នុងសកម្មភាពត្រៀមកាត់បន្ថយគ្រោះមហន្តរាយ ក៏បង្កើនលទ្ធភាពដែលស្ត្រី និងបុរស អាចអភិវឌ្ឍសមត្ថភាពព្យាករណ៍ និង បន្សាំទៅនឹងឥទ្ធិពលនៃគ្រោះមហន្តរាយធម្មជាតិផងដែរ (World Bank/FOA/IFAD, 2009b: 451)។

គោលការណ៍ពីនហេរ៉ូ ផ្តល់នូវការណែនាំអំពីបញ្ហាបដិទានលំនៅដ្ឋាន និងទ្រព្យសម្បត្តិសម្រាប់ជនភៀសខ្លួន និងបុគ្គលដែលត្រូវបានជម្លៀសក្នុងស្រុក និងមានភាពពាក់ព័ន្ធទៅនឹងអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ អាស្រ័យដោយគោលការណ៍ទាំងនោះលើកកម្ពស់គុណតម្លៃស្នូលនៃការមិនរើសអើង និងការផ្តោតយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ។ ជាពិសេស គោលការណ៍ទី១៤ អំពាវនាវឱ្យមានការពិគ្រោះយោបល់ និងការចូលរួមឱ្យបានគ្រប់គ្រាន់នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត រាប់បញ្ចូល ភាពជាតំណាង និងការបញ្ចូលស្ត្រីទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តអំពីបដិទាន ព្រមទាំងធានាថាស្ត្រីមានមធ្យោបាយ និងព័ត៌មានចាំបាច់ដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាព (FAO et al., 2007)។ គោលការណ៍ទាំងនេះ មានភាពពាក់ព័ន្ធទៅនឹងសកម្មភាពបដិទានដីធ្លីនៅក្នុងរាល់បរិបទក្រោយគ្រោះមហន្តរាយទាំងអស់។

បញ្ជីផ្ទៀងផ្ទាត់ ៤.៨ ៖ ការគាំទ្រចំពោះបដិទានដីធ្លីប្រកបដោយសមធម៌យេនឌ័រ

- ✓ ត្រួតពិនិត្យទៅលើសិទ្ធិដែលមានស្រាប់ ដោយពិចារណាអំពីសិទ្ធិដីធ្លីដែលពុំមានភស្តុតាងបញ្ជាក់ច្បាស់លាស់។
- ✓ ធានាថាគោលនយោបាយជាតិដែលទាក់ទងទៅនឹងបដិទានដីធ្លី លំនៅដ្ឋាន និងទ្រព្យសម្បត្តិ ធានាដល់សិទ្ធិរបស់ស្ត្រី និងបុរស និងគាំទ្រដល់សិទ្ធិស្នងមរតករបស់ស្ត្រី និងកុមារី។
- ✓ កំណត់គោលនយោបាយមួយសម្រាប់បដិទាន រាប់បញ្ចូល តើសិទ្ធិទទួលបានទ្រព្យ សម្បត្តិណាខ្លះ ដែលនឹងត្រូវពង្រឹងឡើងវិញ និងត្រូវផ្តល់ជូនដល់អ្នកទាមទារ ណាខ្លះ៖ ព្រមទាំងទម្រង់នៃបដិទានដែលត្រូវបានយកមកប្រើប្រាស់ ដូចជា ការទទួលបានមកវិញនូវទ្រព្យសម្បត្តិ ឬ ការផ្តល់សំណង។
- ✓ ផ្តល់ការបណ្តុះបណ្តាលអំពីការផ្តោតយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ

សម្រាប់មន្ត្រីដែលធ្វើការងារលើបញ្ហាបដិទាន។

- ✓ ផ្ដល់ព័ត៌មានឱ្យបានទាន់ពេលវេលាអំពីវិធី និងពេលណាដែលត្រូវធ្វើការទាមទារបដិទាន តាមរយៈសារព័ត៌មាន វិទ្យុ អ៊ិនធឺណែត និងកិច្ចប្រជុំសាធារណៈ។
- ✓ រៀបចំកម្មវិធីដើម្បីជួយដល់ស្ត្រី និងកុមារី ក្នុងការទាមទារបដិទាន ឧទាហរណ៍ តាមរយៈការផ្ដល់ទម្រង់ទាមទារដែលមានភាពសាមញ្ញ និង ការផ្ដល់ជំនួយដែលផ្ដោតយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ ក្នុងការបំពេញទម្រង់ទាំងនោះ។
- ✓ ផ្ដល់ធនធានពិសេសជូនដល់គ្រួសារដែលមានស្ត្រីតែម្នាក់ឯងជាមេគ្រួសារ ដើម្បីឱ្យ ពួកគេអាចទទួលបានសិទ្ធិសម្រាប់ខ្លួនឯង ក្នុងករណីគ្រោះអាសន្ន។
- ✓ បញ្ជ្រាបអំពីការផ្ដោតយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ នៅក្នុងកម្មវិធី និងនីតិវិធី នានា ដើម្បីឱ្យស្ត្រី និងបុរសទទួលបានការប្រព្រឹត្តស្មើភាពគ្នានៅក្នុងដំណើរការ បដិទាន រហូតដល់ការផ្ដល់ជូនរួមគ្នានូវសិទ្ធិលំនៅដ្ឋាន សិទ្ធិដីធ្លី ឬ សិទ្ធិទទួលបានទ្រព្យសម្បត្តិ ដែលមានការបញ្ជាក់ច្បាស់លាស់។
- ✓ ត្រួតពិនិត្យទៅលើសិទ្ធិបដិទានលំនៅដ្ឋាន និងទ្រព្យសម្បត្តិរបស់ស្ត្រី ដើម្បីធានាថា ជនភៀសខ្លួនជាស្ត្រី អនុវត្តសិទ្ធិរបស់ពួកគេដោយស្ម័គ្រចិត្ត និងមិនត្រូវបានបង្ខំឱ្យ វិលត្រឡប់ទៅផ្ទះរបស់ពួកគេវិញ ឬ រារាំងមិនឱ្យធ្វើយ៉ាងដូច្នេះ ដោយសុវត្ថិភាព និងភាពថ្លៃថ្នូរ។ អនុវត្តការប៉ះប៉ូវដោយយកចិត្តទុកដាក់ និងឆាប់រហ័ស។ ធានាថា មានជំនួយផ្នែកច្បាប់សម្រាប់ស្ត្រី និងបុរសនៅថ្នាក់មូលដ្ឋាន និងពិចារណាបង្កើតក្រុមការងារផ្នែកច្បាប់ចល័ត។
- ✓ គាំទ្រឱ្យមានវិធានការកាត់បន្ថយគ្រោះមហន្តរាយជាក់លាក់ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់គ្រួសារក្រីក្រ ដែលត្រូវបានជម្លៀស និង មានស្ត្រីជាមេគ្រួសារ។

ចូរចងចាំ!

ស្ត្រី និងបុរសអាចផ្ដោតទៅលើទិដ្ឋភាពផ្សេងៗគ្នានៃដំណើរការបដិទាន ដូច្នេះ គេគួរខិតខំដើម្បីកំណត់ទៅលើទស្សនៈខុសគ្នារបស់ពួកគេ និង របៀបដែលទស្សនៈទាំងនោះអាចត្រូវ បានយកមកពិចារណា និងសម្របសម្រួលនៅក្នុងដំណើរការបដិទានទាំងមូល។

កំណែទម្រង់លើការបែងចែកដីឡើងវិញ[១៦]

ខណៈពេលដែលការប្រមូលបញ្ចូលគ្នា និងការកែសម្រួលដីធ្លីឡើងវិញ ត្រូវបានអនុវត្តដើម្បីធ្វើឱ្យប្រសើរឡើងនូវទំហំទ្រង់ទ្រាយ និងរចនាសម្ព័ន្ធ នៃកញ្ចប់ដីធ្លី កម្មវិធីកំណែទម្រង់លើការបែងចែកដីធ្លីឡើងវិញ មានលក្ខណៈកាន់តែទូលំទូលាយជាងនេះ និងពាក់ព័ន្ធទៅនឹងការដកហូតសិទ្ធិដីធ្លីពីម្ចាស់ដី និងអ្នកប្រើប្រាស់ដីមួយចំនួន

និង ការបែងចែកសិទ្ធិដីធ្លីទាំងនោះទៅឱ្យអ្នកទទួលផលថ្មីទូទាំងប្រទេស។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន កំណែទម្រង់លើការបែងចែកដីធ្លីឡើងវិញ គឺជាផ្នែកមួយដ៏សំខាន់នៃគោលនយោបាយសម្រាប់បង្កើនលទ្ធភាពក្នុងការទទួលបានដី និងជាញឹកញាប់ កំណត់គោលដៅទៅលើអ្នកទទួលផលដែលគ្មានដី ក្រីក្រ និងត្រូវបានគេមើលរំលង រាប់បញ្ចូល ស្ត្រី និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។

បញ្ហាទំនាក់ទំនងមានសារៈសំខាន់ជាពិសេស ក្នុងការធានាឱ្យមានការបែងចែកដីធ្លីឡើងវិញប្រកបដោយសមធម៌យេនឌ័រ ដូចមានពិភាក្សាទាក់ទងទៅនឹងកម្មវិធីបែងចែកដីធ្លីរបស់រដ្ឋាភិបាលខេត្ត Sindh នៅក្នុងប្រទេសប៉ាគីស្ថាន ក្នុងប្រអប់ ៥.៣។

✎បញ្ជីផ្ទៀងផ្ទាត់ ៤.៩ ៖ **ការគាំទ្រចំពោះកំណែទម្រង់លើការបែងចែកដីធ្លីឡើងវិញប្រកបដោយសមធម៌យេនឌ័រ**

✓	រាប់បញ្ចូលស្ត្រី និងបុរសនៅក្នុងការពិភាក្សាវែកញែកថ្នាក់ជាតិអំពីគោលបំណង នៃការបែងចែកដីធ្លីឡើងវិញ។
✓	សម្របសម្រួលឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងក្រុមការងារបច្ចេកទេស និង គណៈកម្មការដែលពាក់ព័ន្ធនៅក្នុងការស្វែងរកការពិត និង ការរៀបចំសេចក្តី ព្រាងអនុសាសន៍ សម្រាប់អភិវឌ្ឍគោលនយោបាយបែងចែកដីធ្លីឡើងវិញ។
✓	លើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការពីក្រសួងពាក់ព័ន្ធដែលអនុវត្តដំណើរការ កំណែទម្រង់ដីធ្លី ក្នុងការផ្តល់កិច្ចគាំទ្ររួមគ្នាជូនដល់អ្នកទទួលផលជាពិសេស គ្រួសារដែលមានស្ត្រីជាមេគ្រួសារ។
✓	ដាក់កម្រិតទៅលើចំនួនវិភាគទានដែលតម្រូវឱ្យអ្នកទទួលផលផ្តល់ជូនក្នុងទម្រង់ ជាសាច់ប្រាក់ សម្ភារៈ ឬ តាមរយៈកម្ចី និង អនុញ្ញាតឱ្យអ្នកទទួលផលធ្វើការដាក់ពាក្យជាក្រុម ដើម្បីធានាឱ្យមានការបញ្ចូលក្រុមប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ព្រមទាំងលើកកម្ពស់ការកាត់បន្ថយភាពក្រីក្រ។
✓	លើកកម្ពស់សមភាពយេនឌ័រនៅក្នុងច្បាប់ និង និយ័តកម្មនានា សម្រាប់ការបែងចែងដីធ្លី។
✓	ធ្វើការប៉ាន់ប្រមាណអំពីតម្រូវការដីសម្រាប់ការងារកសិកម្ម ការចិញ្ចឹមជីវិត ។ល។ និងបែងចែកកញ្ចប់ដីធ្លីទៅតាមភាពជាក់ស្តែង ដោយផ្អែកទៅលើដីជាតិ ទំហំ និងទីតាំងដី។
✓	ជួយដល់ក្រុមងាយរងគ្រោះ ដូចជាអ្នកដែលគ្មានដី និងស្ត្រី ក្នុងការកំណត់រក វាយតម្លៃ និងចរចារទៅលើការទិញដី និងចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍ ស្រែចម្ការ។
✓	ធានាឱ្យមានតម្លាភាព ដើម្បីបង្ការអ្នកដែលមានឥទ្ធិពលពីការចង្អុលទិសទៅលើការជ្រើសរើសអ្នកទទួលផល។
✓	កំណត់ឱ្យបានច្បាស់លាស់អំពីសិទ្ធិទទួលបានទ្រព្យសម្បត្តិ ដែលត្រូវបានបែងចែក ជូនប្រជាពលរដ្ឋតាំងទីលំនៅឡើងវិញ។ គេត្រូវយល់ឱ្យបានច្បាស់អំពីសិទ្ធិ និង ការទទួលខុសត្រូវ ហើយអ្នកដែលត្រូវអនុវត្តតាម ត្រូវតែទទួលយកសិទ្ធិ និង

	ការទទួលខុសត្រូវទាំងនោះ ដែលរដ្ឋត្រូវពង្រឹងឱ្យបានរឹងមាំ ហើយត្រូវឱ្យគេយល់ឃើញថាមានសន្តិសុខសុវត្ថិភាពល្អ។
✓	បង្កើតយន្តការសម្រាប់ទប់ស្កាត់ និង ដោះស្រាយវិវាទទាក់ទងទៅនឹងព្រំដែន ឬការប្រើប្រាស់ធនធានធម្មជាតិដែលទទួលបានពីការបែងចែកដីធ្លីឡើងវិញ ឬ សម្របសម្រួលឱ្យមានការធ្វើសមាហរណកម្មប្រជាពលរដ្ឋ ដែលតាំងទីលំនៅឡើងវិញដោយរលូន ទៅក្នុងសហគមន៍ជុំវិញ យន្តការសម្រុះសម្រួល តុលាការដីធ្លី។ល។
✓	ជ្រើសរើសអ្នកទទួលផលដែលមានបទពិសោធន៍ជាកសិករ ឬ ពលករ និង គាំទ្រអ្នកដែលគ្មានបទពិសោធន៍បែបនេះ តាមរយៈការផ្តល់ការបណ្តុះបណ្តាលជំនាញកសិកម្ម អំពីការប្រើប្រាស់ដីដោយសមស្រប និង ប្រកបដោយនិរន្តរភាព។
✓	សម្របសម្រួលឱ្យមានការទទួលបានទីផ្សារសម្ភារៈ និង ផលិតផលកសិកម្ម សេវាឥណទាន និងសេវាប្រឹក្សាយោបល់សម្រាប់ស្ត្រី និងបុរស។
✓	មានប្រព័ន្ធត្រួតពិនិត្យមួយដ៏ល្អសម្រាប់កំណត់រកការប្រែប្រួលនៅក្នុងលទ្ធផល ការកែលម្អកម្មវិធី និង ការរៀបចំផែនការវិធានការកាត់បន្ថយ សម្រាប់ព្រឹត្តិការណ៍ និងផលប៉ះពាល់អវិជ្ជមាននានា។

សំណង[១៧]

ជាទូទៅ សំណងត្រូវផ្តល់ក្នុងករណីអស្សាមិករណ៍ ដែលត្រូវបានធ្វើឡើងដើម្បីប្រយោជន៍សាធារណៈ និងជួនកាលគឺសម្រាប់អ្នកដែលបាត់បង់សិទ្ធិកាន់កាប់ក្នុងអំឡុងពេលនៃដំណើរការបេជិទាន ប្រមាច់បញ្ចូលគ្នា និង បែងចែកដីធ្លីឡើងវិញ។ សំនួរដែលសួរថា តើនរណាទទួលបានសំណងសម្រាប់ដីដែលស្ថិតក្រោមកម្មសិទ្ធិភាពរួមគ្នាអាចមានភាពស្មុគស្មាញខ្លាំង នៅពេលដែលកម្មសិទ្ធិភាពដីធ្លីស្ថិតក្រោមវិវាទ។ ដូច្នេះ ច្បាប់ដែលទាក់ទងទៅនឹងសំណង គួរទាមទារឱ្យមានការស៊ើបអង្កេត ថាតើនរណានឹងរងគ្រោះពីការខាតបង់ដែលបណ្តាលមកពីការយកដីដោយបង្ខំ ឬ អស្សាមិករណ៍ ដោយយកចិត្តទុកដាក់ជាពិសេស ចំពោះសិទ្ធិប្រើប្រាស់ដីរបស់ស្ត្រី និងកុមារដែលអាច ពុំមែនជាម្ចាស់ដីផ្លូវការ ព្រមទាំងសិទ្ធិរបស់កតិកៈ។ យន្តការផ្តល់សំណង គួរត្រូវបានរៀបចំឡើងដើម្បីធានាឱ្យមានការធ្វើសេចក្តីសម្រេចចិត្តរួមគ្នានៅក្នុងគ្រួសារ អំពីការប្រើប្រាស់ថវិកាសំណង (FAO, 2008a: 33-34)។

✎បញ្ជីផ្ទៀងផ្ទាត់៤.១០ ៖ ការគាំទ្រចំពោះការផ្តល់សំណង ប្រកបដោយសមធម៌យេនឌ័រ

✓	ពិនិត្យថាតើនរណាជាម្ចាស់ដី ឬ មានសិទ្ធិទៅលើដីនោះ ដោយធានាថាម្ចាស់ដីគ្រប់រូបទទួលបានការជូនដំណឹងសមស្រប មិនចំពោះថាពួកគេរស់នៅលើដី ឬ មិនរស់នៅលើដី ដែលកំពុងត្រូវបានធ្វើអស្សាមិករណ៍ឡើយ។
✓	ពិនិត្យថាម្ចាស់ប្លង់ដីដែលស្ថិតក្រោមកម្មសិទ្ធិរួមគ្នា ទទួលបានចំណែកនៃសំណង ប្រកបដោយសមធម៌។
✓	ធានាថាសំណងប្រកបដោយភាពយុត្តិធម៌ ត្រូវបានផ្តល់ជូនដល់ម្ចាស់ដី។ ក្នុងករណី ដែលអាចធ្វើទៅបាន ត្រូវពិចារណាផ្តល់ដីមួយកន្លែងទៀតជាសំណងសម្រាប់ក្រុម ងាយរងគ្រោះដែលពុំមានប្រាក់ចំណូលដទៃទៀត។
✓	យន្តការផ្តល់សំណង គួរធានាឱ្យមានការធ្វើសេចក្តីសម្រេចចិត្តរួមគ្នានៅក្នុងគ្រួសារ អំពីការប្រើប្រាស់ថវិកាសំណង។

ចូរចងចាំ!
ដើម្បីធានាថាស្ត្រីទទួលបានប្រយោជន៍ពីសំណង វាមានសារៈសំខាន់ខ្លាំងណាស់ដែលសិទ្ធិកាន់កាប់របស់ពួកគេត្រូវបានទទួលស្គាល់ និងចុះបញ្ជី។

កំណត់សម្គាល់

7 Dalal Alnaggar, Marianna Bicchieri, Kate Dalrymple, Nigel Edmead, Neil Pullar and Rebecca Sittie បានផ្តល់ធាតុចូលសំខាន់ៗនៅក្នុងម៉ូឌុលនេះ ក្នុងអំឡុងពេលនៃសិក្ខាសាលាបច្ចេកទេស ដែលប្រព្រឹត្តធ្វើឡើងក្នុងខែឧសភា ឆ្នាំ២០១១ នៅឯការិយាល័យកណ្តាល របស់អង្គការ FAO រាប់បញ្ចូលក្នុងអំឡុងពេលនៃការពិភាក្សា របស់ក្រុមការងារស្តីពីបញ្ហាបច្ចេកទេស។

8 World Bank/FAO/IFAD. The Gender and Agriculture Sourcebook, 2009. http://siteresources.worldbank.org/INTGENAGRLIVSOUBOOK/Resources/CompleteBook.pdf

9 Ibid.

10 Nigel Edmead's presentation on "Gender issues in designing and setting up land information systems and databases: experiences from Ghana, Zambia and Uganda" at the May 2011 technical workshop.

11 Mends, 2006: 5ff; Ambaye, 2009: 13 ff.

12 www.fig.net/commission9/wgroups/sg9_1_1_11_14.htm; Barnett and Grown, 2004.

13 Wehrman, 2011.

14 FAO, 2003b: 22.

15 Grover and Flores-Bórquez, 2004; Osskó, 2002.

16 Binswanger-Mkhize, Bourguignon and van den Brink, 2009: 14ff.

17 Binswanger-Mkhize, Bourguignon and van den Brink, 2009: 23ff; Ambaye, 2009: 18ff.

សង្ខេបអំពីសារសំខាន់ៗ

ស្ដីពីបញ្ហាបច្ចេកទេស

មុនពេលចាប់ផ្ដើមសកម្មភាពរដ្ឋបាលដីធ្លីណាមួយ គេគួរវិភាគទៅលើស្ថានភាពនៅមូលដ្ឋាន រាប់បញ្ចូលរចនាសម្ព័ន្ធគ្រួសារ អំណាចក្នុងការធ្វើសេចក្ដីសម្រេចចិត្តរបស់ស្ត្រី គំរូនៃការស្វែងមរតក ការរៀបអាពាហ៍ពិពាហ៍ និងការលែងលះ ភាពជាតំណាងរបស់ស្ត្រីនៅក្នុងកិច្ចការមូលដ្ឋាន ការប្រើប្រាស់ និងការទទួលបានប្រយោជន៍ផ្សេងៗគ្នាពីដី ព្រមទាំងព្រំប្រទល់ និង សិទ្ធិដីធ្លីដែលមានស្រាប់ (បានចុះបញ្ជី និងមិនបានចុះបញ្ជី) ជាពិសេស សិទ្ធិស្ត្រី។
យន្តការគួរបង្កលក្ខណៈឱ្យមានការចុះបញ្ជីសិទ្ធិដីធ្លីជាក់លាក់របស់ស្ត្រី ដូចជា សិទ្ធិប្រើប្រាស់ សិទ្ធិបន្ទាប់បន្សំ ឬ សិទ្ធិក្នុងការមានកម្មសិទ្ធិភាពរួមគ្នា។ ស្ត្រីគួរអាចមានលទ្ធភាពប្រើប្រាស់សិទ្ធិក្នុងការមានកម្មសិទ្ធិភាពផ្ដាច់មុខទៅលើទ្រព្យសម្បត្តិ ជាលក្ខណៈបុគ្គល ឬ ជាក្រុម។
វិធីសាស្ត្រ និងឧបករណ៍បែបចូលរួម ដែលបង្កលក្ខណៈឱ្យស្ត្រីចូលរួម គួរត្រូវបានលើកកម្ពស់។ គួររៀបចំឱ្យមានកិច្ចប្រជុំដាច់ដោយឡែកសម្រាប់ស្ត្រី ដើម្បីធានាថាស្ត្រីលើកឡើងនូវបញ្ហាដែលមានសារៈសំខាន់ចំពោះពួកគេ ដែលពួកគេអាចមិនធ្វើដូច្នេះនៅពេលដែលមានវត្តមានបុរស ដោយសារតែមូលហេតុទាក់ទងនឹងវប្បធម៌។
ស្ត្រីដែលតំណាងឱ្យក្រុមសង្គមផ្សេងៗគ្នា គួរត្រូវបានកំណត់ថាជាអ្នកពាក់ព័ន្ធសំខាន់ និងគួរសម្របសម្រួលឱ្យមានការចូលរួមសកម្មរបស់ពួកគេនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត។ គួរពិចារណាទៅលើបញ្ហាអនក្ខរភាព កង្វះព័ត៌មាន និងមធ្យោបាយធ្វើដំណើរ ហើយទីតាំង និងពេលវេលានៃកិច្ចប្រជុំ គួរសម្របទៅតាមកាលវិភាគ និងលទ្ធភាពក្នុងការធ្វើដំណើររបស់ស្ត្រី។
គួរយកចិត្តទុកដាក់ចំពោះបញ្ហាសមធម៌យេនឌ័រ ក្នុងការរៀបចំប្រព័ន្ធ និងមូលដ្ឋានទិន្នន័យថ្មីៗអំពីព័ត៌មានដីធ្លី។
គេអាចត្រូវការឱ្យមានកំណែទម្រង់ច្បាប់ និងនីតិវិធី ដើម្បីគាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យា និងប្រព័ន្ធដែលសម្របសម្រួលឱ្យមានភាពប្រសើរឡើងនូវសមធម៌យេនឌ័រ ក្នុងរដ្ឋបាលដីធ្លី។
ឧបករណ៍ដីធ្លីគួរវាយតម្លៃតាមរយៈទស្សនៈវិស័យយេនឌ័រ។
បញ្ហាសមធម៌យេនឌ័រ គួរបញ្ជ្រាបទៅក្នុងការរៀបចំ ការអនុវត្តន៍ និងការត្រួតពិនិត្យគម្រោង និងសកម្មភាពរដ្ឋបាលដីធ្លីទាំងអស់។ គេត្រូវការឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រ នៅក្នុងទិដ្ឋភាពផ្នែកបច្ចេកទេសនៃអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ដូចជាសកម្មភាព បច្ចេកវិទ្យា និងប្រព័ន្ធរដ្ឋបាលដីធ្លី ដើម្បីបញ្ចូលប្រយោជន៍របស់ប្រជាពលរដ្ឋគ្រប់រូប ទាំងស្ត្រី និងបុរស។
បុគ្គលិក មន្ត្រីរដ្ឋាភិបាល និងសហគមន៍ គួរទទួលបានការបណ្ដុះបណ្ដាលអំពីការផ្ដោតយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ ហើយយុទ្ធនាការចុះផ្ទាល់តាមមូលដ្ឋានជាសាធារណៈគួរត្រូវបានធ្វើឡើង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសកម្មភាពរដ្ឋបាលដីធ្លីដែលមានសមធម៌យេនឌ័រ។
នីតិវិធី និងលទ្ធផលនៃសកម្មភាពរដ្ឋបាលដីធ្លី ត្រូវមានភាពងាយយល់ ផ្ដល់ជូនសម្រាប់សាធារណជន និងមានតម្លៃទាប ដើម្បីជៀសវាងអំពើពុករលួយ និងការមិនរាប់បញ្ចូល។
ផលប៉ះពាល់ផ្សេងៗគ្នានៃវិធានការទៅលើស្ត្រី និងបុរស គួរត្រូវបានយកមកពិចារណា ដើម្បីធានាថាសកម្មភាពរដ្ឋបាលដីធ្លីផ្ដល់ប្រយោជន៍ស្មើភាពគ្នាចំពោះស្ត្រី និង បុរស។

សូចនាករត្រួតពិនិត្យជាអនុសាសន៍ សម្រាប់បញ្ហាបច្ចេកទេស

- ចំនួនភាគរយនៃស្ត្រី និង បុរសដែលធ្វើការងារនៅក្នុងវិជ្ជាជីវៈបច្ចេកទេសនៃរដ្ឋបាលដីធ្លី (ការអង្កេត ការវាយតម្លៃ វិភាគផែនដី GPS ។ល។)។
- ចំនួនស្ត្រីដែលបានចុះឈ្មោះ និង បញ្ចប់ការសិក្សាវគ្គបច្ចេកទេសកម្រិតឧត្តមសិក្សា និង មុខវិជ្ជាវិទ្យាសាស្ត្រ នៅឯមធ្យមសិក្សា។
- ចំនួនភាគរយនៃស្ត្រី និង បុរស ដែលទទួលបានការបណ្តុះបណ្តាលអំពីការតស៊ូមតិ និង អក្ខរកម្មផ្នែកច្បាប់ ដែលផ្តោតលើបញ្ហាដីធ្លី។
- ចំនួនបច្ចេកវិទ្យាដែលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ ដែលត្រូវបានយកមកប្រើប្រាស់នៅក្នុងសកម្មភាពរដ្ឋបាលដីធ្លី។
- ចំនួនភាគរយនៃស្ត្រី និង បុរស ដែលចូលរួមវគ្គបណ្តុះបណ្តាលអំពីការប្រើប្រាស់បច្ចេកវិទ្យាថ្មីដែលទាក់ទងទៅនឹងដីធ្លី។

ឯកសារយោង

Ambaye, D. W. 2009. Land valuation for expropriation in Ethiopia: Valuation methods and adequacy of compensation. Paper presented at the 7th FIG Regional Conference on Spatial Data Serving People: Land Governance and the Environment – Building the Capacity, Hanoi, 19–22 October 2009.

Aristazabal, N. & Gomez, A. 2004. Improving security without titles in Bogotá. Habitat International, 28(2): 245–258.

Augustinus, C. & Benschop, M. 2003: Security of tenure – best practices. Nairobi, UN-HABITAT. http://www.unhabitat.org/downloads/docs/10784_1_594339.pdf

Barnett, K. & Grown, C. 2004. Gender impacts of government revenue collection: The case of taxation. Economic Paper No. 62. London, Commonwealth Secretariat.

Binswanger-Mkhize, H. P., Bourguignon, C. & van den Brink, R. 2009. Agricultural land redistribution: toward greater consensus. Washington, DC, World Bank.

FAO. 2003b. The design of land consolidation pilot projects in Central and Eastern Europe. Land Tenure Studies No. 6. Rome. ftp://ftp.fao.org/docrep/fao/006/y4954e/y4954e00.pdf

FAO. 2008a. Compulsory acquisition of land and compensation. Land Tenure Studies No. 10. Rome. ftp://ftp.fao.org/docrep/fao/011/i0506e/i0506e00.pdf

FAO. 2009c. "We all inherited this earth", inheritance rights of widows and children in the context of AIDS: legal overview. Rome. (final draft)

FAO. 2012b. Voluntary Guidelines on the Responsible Governance of Tenure of Land, Fisheries and Forests in the Context of National Food Security.Rome. http://www.fao.org/docrep/016/i2801e/i2801e.pdf

FAO, Norwegian Refugee Council, UNHCR, UN-HABITAT, OHCHR & OCHA. 2007. Handbook on housing and property restitution for refugees and displaced persons – implementing the "Pinheiro Principles". www.ohchr.org/Documents/Publications/pinheiro_principles.pdf

FAO. 2012a. Improving Gender Equality in Territorial Issues (IGETI).Land and Water Division Working Paper No. 3. Rome. www.fao.org/docrep/016/me282e/me282e.pdf

Farfan, F. 2002. In G. Payne, ed. Land rights and innovation: improving tenure security for the urban poor. London, ITDG Publishing.

Giovarelli, R. & Duncan, J. 1999. Women and land in Eastern Europe and Central Asia. Washington, DC, USAID. http://pdf.usaid.gov/pdf_docs/pnacl400.pdf

Giovarelli, R. & Lastarria-Cornhiel, S. 2006. Study on women and property rights: project best practices. Washington, DC, USAID. http://pdf.usaid.gov/pdf_docs/pnadj420.pdf

Grover, R. & Flores-Bórquez, M. 2004. Restitution and land markets. Paper presented at the FIG Working Week, Athens, 22–27 May 2004.

Meertens, D. 2012. Colombia's law on victims and restitution: a challenge for gender-sensitive transitional justice. Paper presented at the Expert Group Meeting on Good Practices in Realizing Women's Rights to Productive Resources, with a Focus on Land, UN Women in collaboration with the United Nations Office of the High Commissioner for Human Rights, Geneva, 25–27 June 2012.

Osskó, A. 2002. Land restitution and compensation procedures in Central Eastern Europe. Paper Presented at the FIG Commission 7 Annual Meeting, Pretoria, 4–9 November 2002.

South Africa Department of Land Affairs.1997. White Paper on South African Land Policy. Pretoria.

Teklu, A. 2005. Research report 4 – land registration and women's land rights in Amhara Region, Ethiopia. London, IIED.

Undeland, A. 2012.Lessons learned and good practices in realizing women's rights to productive resources with a focus on land: Kyrgyzstan and Tajikistan. Paper prepared for the Expert Group Meeting on Good Practices in Realizing Women's Rights to Productive Resources, with a Focus on Land, organized by UN Women in collaboration with the United Nations Office of the High Commissioner for Human Rights, Geneva, 25–27 June 2012.

UNCHS. 1999. Women's rights to land, housing and property in post-conflict situations and during reconstruction: A global overview. Nairobi, United Nation Centre for Human Settlements.www.unhabitat.org/downloads/docs/1504_59744_Land.pdf2.pdf

UN-HABITAT. 2007. Gendering land tool development. Nairobi, GLTN Secretariat.

UN-HABITAT. 2007b. Policy makers guide to women's land, property and housing rights across the world. Nairobi.

UN-HABITAT. 2008a. Secure Land Rights for All.Nairobi.

UN-HABITAT. 2009. Gender evaluation criteria for largescale land tools. Nairobi.

UN-HABITAT. 2011. Designing and evaluating land tools with a gender perspective: training package for land professionals. Nairobi.

Wehrmann, B. 2003. Women's access to and control over land in African and South Asian countries. Landnutzung und Landentwicklung [Land Use and Development], 44: 83–89.

Wehrman, B. 2011. Land use planning. Concept, tools and applications. Eschborn, Germany, GIZ. www2.gtz.de/dokumente/bib-2011/giz2011-0041en-landuse-planning.pdf

World Bank. 2005. Gender issues and best practices in land administration projects: A synthesis report. Washington, DC. http://siteresources.worldbank.org/intard/resources/gender_land_fulltxt.pdf

World Bank/FAO/IFAD. 2009. Gender in agriculture sourcebook. Washington, DC and Rome.

World Bank/FAO/IFAD. 2009a. Module 4: Gender issues in land policy and administration. In Gender in agriculture sourcebook. Washington, DC and Rome.

World Bank/FAO/IFAD. 2009b. Module 10: Gender and natural resources management. In Gender in agriculture sourcebook. Washington, DC and Rome.

ម៉ូឌុល

ការបញ្ជូនសារ

បញ្ជីរាយនាមប្រអប់ និង តារាងរូបភាព

ប្រអប់

132
ប្រអប់ ៥.១ ៖
ការបញ្ជូនសារ
និងគោលការណ៍ណែនាំ
133
ប្រអប់ ៥.២ ៖
ការអនុវត្តន៍ល្អក្នុងការលើកកម្ពស់
ការយល់ដឹង
136
ប្រអប់ ៥.៣ ៖
ការផ្សព្វផ្សាយអំពីយេនឌ័រ
ដើម្បីគាំទ្រដល់អភិបាលកិច្ច
លើការកាន់កាប់ដីធ្លីប្រកប
ដោយសមធម៌យេនឌ័រ
140
ប្រអប់ ៥.៤ ៖
ការគាំទ្រអក្ខរកម្មផ្នែកច្បាប់
145
ប្រអប់ ៥.៥ ៖
ការរៀបចំសារតាមរយៈ
កិច្ចសន្ទនាសហគមន៍
147
ប្រអប់ ៥.៦ ៖
ការគាំទ្រឱ្យមានការចូលរួម
របស់ស្ត្រីនៅក្នុងកិច្ចប្រជុំ
148
ប្រអប់ ៥.៧ ៖
វិទ្យុសហគមន៍ក្នុងលក្ខណៈ
ជាឧបករណ៍ទំនាក់ទំនងមួយ
ដើម្បីឱ្យមានការផ្លាស់ប្តូរ -
គម្រោងឌីមីត្រា
149
ប្រអប់ ៥.៨ ៖
វិធីសាស្ត្រទំនាក់ទំនង និង
ប្រព័ន្ធផ្សព្វផ្សាយប្រកបដោយ
សមធម៌យេនឌ័រ
150
ប្រអប់ ៥.៩ ៖
ការផ្លាស់ប្តូរឥរិយាបថ តាមរយៈ
អភិក្រមមួយដែលផ្តោត
លើគ្រួសារ

បញ្ជីផ្ទៀងផ្ទាត់

135
បញ្ជីផ្ទៀងផ្ទាត់ ៥.១ ៖
ការគាំទ្រដល់ការទទួលបាន
ព័ត៌មានដីធ្លីប្រកបដោយសមធម៌
យេនឌ័រ
138
បញ្ជីផ្ទៀងផ្ទាត់ ៥.២ ៖
ការផ្សព្វផ្សាយអំពីយេនឌ័រ
139
បញ្ជីផ្ទៀងផ្ទាត់ ៥.៣ ៖
ការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនង
សម្រាប់ការតស៊ូមតិ
142
បញ្ជីផ្ទៀងផ្ទាត់ ៥.៤ ៖
ការរៀបចំយុទ្ធសាស្ត្រ និង
វិធីសាស្ត្រទំនាក់ទំនង និង
លើកកម្ពស់ការយល់ដឹង
146
បញ្ជីផ្ទៀងផ្ទាត់ ៥.៥ ៖
ការអភិវឌ្ឍន៍សារ
153
សូចនាករត្រួតពិនិត្យ
ជាអនុសាសន៍សម្រាប់
ការបញ្ជូនសារ

តារាង និង រូបភាព

143
រូបភាព ៥.១ ៖
ការរៀបចំយុទ្ធសាស្ត្រទំនាក់ទំនង
និងលើកកម្ពស់ការយល់ដឹង

ម៉ូឌុល ៥ ៖ ការបញ្ជូនសារ

យុទ្ធសាស្ត្រ និងវិធីសាស្ត្រទំនាក់ទំនង និងលើកកម្ពស់ការយល់ដឹង សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លី ប្រកបដោយសមធម៌យេនឌ័រ

សេចក្តីផ្តើម[១៨]

ទំនាក់ទំនង និងការលើកកម្ពស់ការយល់ដឹង មានសារៈសំខាន់ខ្លាំងណាស់ក្នុងការផ្លាស់ប្តូរគុណតម្លៃ និងឥរិយាបថ រាប់បញ្ចូល គុណតម្លៃ និងឥរិយាបថអំពីយេនឌ័រ និងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។ ទំនាក់ទំនង អាចគៀងគរ ប្រជាពលរដ្ឋឱ្យចូលរួមក្នុងសកម្មភាពអភិវឌ្ឍ ដូចជា ការទាមទារសិទ្ធិដីធ្លីរបស់ពួកគេ ហើយស្របពេលជាមួយគ្នា នោះដែរ ក៏ជួយកសាងឱ្យមានការឯកភាពជារួមទៅលើបញ្ហា និង ដំណោះស្រាយដែលអាចធ្វើទៅបាន តាមរយៈ ការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ (FAO/GTZ, 2006)។

គោលការណ៍មួយក្នុងចំណោមគោលការណ៍ស្នូលទាំង១០ នៃការអនុវត្តន៍គោលការណ៍ណែនាំ ដែលនោះគឺជា គោលការណ៍ស្តីពីតម្លាភាព កំណត់អំពីរបៀបដែលទំនាក់ទំនង និងការលើកកម្ពស់ការយល់ដឹង អាចគាំទ្រដល់ អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ។ គោលការណ៍ណែនាំ ក៏បានសង្កត់ធ្ងន់ផងដែរ អំពីសេចក្តីត្រូវការឱ្យមានសារដែលផ្តោតយកចិត្តទុកដាក់ខ្ពស់លើបញ្ហាយេនឌ័រ និង កំណត់គោលដៅទៅលើយេនឌ័រ (ប្រអប់ ៥.១)។

ប្រអប់ ៥.១ ៖ ការបញ្ជូនសារ និង គោលការណ៍ណែនាំ

៣.ខ.៨ តម្លាភាព៖ ការកំណត់និយមន័យច្បាស់លាស់ និង ការផ្សព្វផ្សាយទូលំទូលាយ អំពី គោលនយោបាយ ច្បាប់ និង នីតិវិធីនានា ជាភាសាសមស្រប និង ការផ្សព្វផ្សាយទូលំ ទូលាយអំពីសេចក្តីសម្រេចនានា ជាភាសាសមស្រប និង ក្នុងទម្រង់ដែលអាចប្រើប្រាស់ បានគ្រប់គ្នា។
៨.៩ រដ្ឋគប្បីបែងចែកសិទ្ធិកាន់កាប់ និង ធ្វើប្រតិភូកម្មអភិបាលកិច្ចលើការកាន់កាប់ ប្រកបដោយតម្លាភាព និងមានការចូលរួម ដោយប្រើប្រាស់នីតិវិធីសាមញ្ញដែលមាន លក្ខណៈច្បាស់លាស់ អាចរកប្រើប្រាស់បាន និង ងាយយល់សម្រាប់មនុស្សគ្រប់រូប ជាពិសេសជនជាតិដើមភាគតិច និង សហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់ បែបប្រពៃណី។ ព័ត៌មានជាភាសាសមស្រប គប្បីផ្តល់ជូនគ្រប់មុខសញ្ញាចូលរួម រាប់បញ្ចូលតាមរយៈសារដែលគិតគូរដល់យេនឌ័រ។
១៥.៩ រដ្ឋគប្បីអនុវត្តកំណែទម្រង់លើការបែងចែកដីឡើងវិញ តាមរយៈអភិក្រម និង នីតិវិធីមានតម្លាភាព មានការចូលរួម និង មានគណនេយ្យភាព។ .... ភាគីរងផលប៉ះពាល់ទាំងអស់ រួមទាំងក្រុមជនជួបការលំបាក គប្បីទទួលបានព័ត៌មាន ពេញលេញ និង ច្បាស់លាស់អំពីកំណែទម្រង់ រួមទាំងតាមរយៈសារដែលផ្តោត គោលដៅលើយេនឌ័រ។

ប្រភព ៖ FAO, 2012b.

ការលើកកម្ពស់ការយល់ដឹង ការបញ្ជ្រាបយេនឌ័រ និងការតស៊ូមតិ

ប្រជាពលរដ្ឋត្រូវដឹងអំពីបញ្ហា និងសិទ្ធិ ដើម្បីឱ្យពួកគេអាចអនុវត្តប្រើប្រាស់ទាំងសម្លេង និងជម្រើសរបស់ពួកគេប្រកបដោយប្រសិទ្ធភាព (FAO, 2011a: 20)។ ដូច្នេះ ព័ត៌មានត្រូវមានជាភាសាក្នុងមូលដ្ឋាន (ព័ត៌មានលាយលក្ខណ៍អក្សរ និងការផ្តល់ព័ត៌មានផ្ទាល់មាត់) ព្រមទាំងផ្តល់ជូនដល់ប្រជាពលរដ្ឋគ្រប់កម្រិតទាំងអស់ ចាប់ពីអ្នកបង្កើតគោលនយោបាយនៅកម្រិតថ្នាក់ជាតិ រហូតដល់សហគមន៍មូលដ្ឋាន ដែលអាចមានគំនិតទស្សនៈវិស័យ បទពិសោធន៍ និងប្រើប្រាស់ភាសាខុសគ្នា។

ការលើកកម្ពស់ការយល់ដឹង ដើរតួនាទីមួយដ៏សំខាន់ក្នុងការជួយលុបបំបាត់ឧបសគ្គដែលរាំងស្ទះចំពោះលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានព័ត៌មានដីធ្លី នៅក្នុងគម្រោង និងកំណែទម្រង់វិស័យដីធ្លី ព្រមទាំងនៅក្នុងគ្រប់ដំណើរការ និងស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។

ការលើកកម្ពស់ការយល់ដឹងមានប្រសិទ្ធភាពបំផុត នៅពេលដែលអ្នកពាក់ព័ន្ធផ្សេងៗគ្នាជាច្រើន រាប់បញ្ចូលទាំងអ្នកពាក់ព័ន្ធពីខាងភាគីរដ្ឋាភិបាល និងសង្គមស៊ីវិល សហការគ្នា និងនៅពេលដែលសហគមន៍ទាំងមូលចូលរួមនៅក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹង។ សកម្មភាពនេះ ទាមទារឱ្យមានយុទ្ធសាស្ត្រដែលត្រូវបានគិតគូដោយប្រុងប្រយ័ត្ន សម្រាប់ប្រាស្រ័យទាក់ទងជាមួយស្ត្រី និងបុរស និងធ្វើការងារជាមួយអ្នកពាក់ព័ន្ធផ្សេងៗគ្នានៅកម្រិតខុសៗគ្នា។

ការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាដីធ្លី និងយេនឌ័រ មានសារៈសំខាន់ជាពិសេសនៅក្នុងការអនុវត្តន៍គម្រោង និងកំណែទម្រង់វិស័យដីធ្លី។ ឧទាហរណ៍នៃការអនុវត្តន៍ល្អ មានរៀបរាប់នៅក្នុងប្រអប់ ៥.២។ កត្តាសំខាន់ៗដើម្បីទទួលបានជោគជ័យ រួមមានការប្រើប្រាស់អន្តរាគមន៍កំណត់គោលដៅដោយប្រុងប្រយ័ត្ន ដោយសហការជាមួយអង្គការសង្គមស៊ីវិល ដែលសម្របសម្រួលឱ្យមានការដឹកនាំច្បាស់លាស់របស់ស្ត្រី នៅក្នុងកិច្ចប្រជុំលើកកម្ពស់ការយល់ដឹង និងអនុម័តទៅលើអភិក្រមបែបចូលរួមមួយដែលអាចអនុវត្តទៅបានជាមួយសហគមន៍អ្នកទទួលផលក្នុងមូលដ្ឋាន។

ប្រអប់ ៥.២ ៖ ការអនុវត្តន៍ល្អក្នុងការលើកកម្ពស់ការយល់ដឹង

នៅក្នុង*ប្រទេសឥណ្ឌា* គម្រោងលើកកម្ពស់ការយល់ដឹងមួយរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋានដែលមានឈ្មោះថា ស្វាឌីណា ក្នុងស្រុកមីដណាផរ ភាគខាងលិច នៃខេត្តវែសប៊ែងហ្គល បានប្រើប្រាស់សកម្មភាពលើកកម្ពស់ការយល់ដឹងមួយចំនួន ដើម្បីជម្រុញឱ្យមានការចូលរួមពីសមាជិកសហគមន៍គ្រប់កម្រិត ជាមួយនឹងព្រឹត្តិការណ៍កំណត់គោលដៅដើម្បីបង្កើនកម្រិតចំណេះដឹង ទំនុកចិត្ត និងអត្ថភាពរបស់ស្ត្រី។ គម្រោងមានគោលបំណងបង្កើនការយល់ដឹងអំពីសិទ្ធិដីធ្លី និងលើកកម្ពស់សមធម៌យេនឌ័រ ក្នុងចំណោមគ្រួសារកុលសម្ព័ន្ធ និងគ្រួសារជនបទដែលត្រូវបានគេមើលរំលង។ សកម្មភាពរួមមានជាអាទិ៍ ៖

- កិច្ចប្រជុំរយៈពេល១ថ្ងៃ ចំនួន ១០ដង នៅក្នុងសហគមន៍ចំនួន១០ កិច្ចប្រជុំថ្នាក់ស្រុក និងថ្នាក់ប្លុកសម្រាប់ស្ត្រី និងបុរស ព្រមទាំងការសម្តែងល្ខោនតាមផ្លូវចំនួន១៦ដង ដើម្បីលើកកម្ពស់ការយល់ដឹង។

ប្រភព ៖ Renée Giovarelli's presentation on "Gender-equitable awareness raising" and Rebecca Sittie's presentation on "Gender issues in managing and implementing land registration in Ghana" at the May 2011 technical workshop; ILC, 2010e.

- ការផលិតសម្ភារៈទំនាក់ទំនងសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋាន និង ទូទាំងប្រទេស រាប់បញ្ចូលខ្សែភាពយន្តខ្លីជាភាសាក្នុងមូលដ្ឋាន អំពីការផ្តល់ភាពអង់អាចដល់ស្ត្រី និង សិទ្ធិដីធ្លី ផ្ទាំងបដារ និងកូនសៀវភៅគំនូរជីវចល។
- ការបណ្តុះបណ្តាលអំពីការដឹកនាំសង្គម និងការដឹកនាំតាមផ្លូវច្បាប់ សម្រាប់ស្ត្រី និង បុរស នៅក្នុងសហគមន៍ទាំង១០ និងជំរុំហត្ថលេខាចំនួន១៤ ដែលស្ត្រីអនក្ខរកម្ម ចំនួន៣៥៤នាក់ បានរៀនសូត្រអំពីរបៀបចុះហត្ថលេខាលើឈ្មោះរបស់ពួកគេ។
- ពិធីបុណ្យផែនដីនៅក្នុងសហគមន៍ចំនួន២ ដែលប្រារព្ធអំពីវិភាគទានរួមចំណែករបស់ ស្ត្រីចំពោះវិស័យកសិកម្មក្នុងមូលដ្ឋាន និងមានការចូលរួម ព្រមទាំងការគៀងគរពី សហគមន៍ទាំងមូល។

នៅក្នុង*សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ* បើទោះបីជាគោលការណ៍សមធម៌យេនឌ័រ ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីគ្រួសារ ច្បាប់ស្តីពីការស្នងមរតក និងទ្រព្យសម្បត្តិ ហើយសង្គមភាគច្រើនមានលក្ខណៈមាតាធិបតេយ្យជាប្រពៃណី ដោយពុំមានការរិតបន្តឹងទៅលើស្ត្រីកាន់កាប់ដីធ្លីក៏ដោយ ប៉ុន្តែ គម្រោងមួយដែលទទួលបានមូលនិធិគាំទ្រពីធនាគារពិភពលោក សម្រាប់ការចុះបញ្ជីប្លង់ដីនៅតំបន់ទីក្រុង អនុវត្តការងារមិនបានល្អប្រសើរឡើយលើបញ្ហាសមធម៌យេនឌ័រនៅក្នុងរយៈពេល២ឆ្នាំដំបូង ៖ នៅពេលដែលស្ត្រីស្នងមរតកដីធ្លី ស្វាមីរបស់ពួកគេគឺជាអ្នកចុះបញ្ជីដីធ្លីនោះ។ មានស្ត្រីតិចតួចណាស់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គម្រោង និងសកម្មភាពដទៃទៀត ហើយទម្រង់ដែលគេបានប្រើប្រាស់ ពុំមានផ្តល់ការរៀបចំឱ្យមានសហកម្មសិទ្ធិភាពរួមគ្នាឡើយ និងគ្រាន់តែស្នើសុំឱ្យបំពេញឈ្មោះមេគ្រួសារ ដែលជាទូទៅគឺជាបុរសដែលមានវ័យចំណាស់ជាងគេនៅក្នុងគ្រួសារ ដោយឡែក ឯកសារដែលគេត្រូវការដើម្បីគាំទ្រដល់ការទាមទារ កម្មសិទ្ធិភាពជាទូទៅត្រូវបានចុះបញ្ជីក្រោមឈ្មោះរបស់មេគ្រួសារ។

ដើម្បីដោះស្រាយបញ្ហានេះ សហភាពស្ត្រីឡាវបានរៀបចំវគ្គផ្តល់ព័ត៌មានអំពីយេនឌ័រចំនួន២នៅក្នុងសហគមន៍គម្រោងនីមួយៗ - វគ្គផ្តល់ព័ត៌មានមួយ គឺសម្រាប់បុរស និងស្ត្រី និងមួយវគ្គទៀត គឺសម្រាប់តែស្ត្រីប៉ុណ្ណោះ។ ការបណ្តុះបណ្តាលសហគមន៍ ផ្តោតទៅលើសិទ្ធិក្រោមច្បាប់ និង ប្រយោជន៍នៃការចូលរួមនៅក្នុងការផ្តល់ប្លង់ដី ហើយសមាជិកសហភាពស្ត្រីឡាវ បានចាប់ផ្តើមចូលរួមនៅក្នុងសកម្មភាពផ្តល់ប្លង់ដីរបស់គម្រោង នៅថ្នាក់មូលដ្ឋាន។ ករណីនេះ បង្ហាញឱ្យឃើញអំពីសារៈសំខាន់នៃការត្រួតពិនិត្យគម្រោង ដើម្បីកំណត់រកបញ្ហា និងការប្រឈមនានា ក្នុងការសម្រេចឱ្យបាននូវសមធម៌យេនឌ័រ និងអភិក្រមដែលមានភាពបត់បែនសម្រាប់ដោះស្រាយបញ្ហាទាំងនោះ។

នៅក្នុង*ប្រទេសហ្គាណា* គម្រោងផ្តល់ប្លង់ដីជនបទជាប្រព័ន្ធ របស់អាជ្ញាធរអភិវឌ្ឍន៍សហសវត្សរ៍ ដែលទទួលបានមូលនិធិគាំទ្រពីសារជីវកម្ម ស្តីពីការប្រឈមសហសវត្សរ៍ រួមមានសមាសភាពសំខាន់ៗស្តីពីការលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ និងដីធ្លី ដែលជួយបង្កើនផលប៉ះពាល់របស់វា ៖

- ការចូលរួមពីអ្នកពាក់ព័ន្ធ និងការអប់រំសាធារណៈនៅក្នុងសហគមន៍បានជានាឱ្យមាន លទ្ធភាព និងឱកាសស្មើភាពគ្នាសម្រាប់ស្ត្រី និង បុរស។ ឈ្មោះរបស់សហម្ចាស់ កម្មសិទ្ធិទាំងអស់ត្រូវបានចុះបញ្ជីលើលិខិតបញ្ជាក់ដីធ្លី។
- គម្រោងបានអនុម័តជ្រើសរើសយកវិធីសាស្ត្របែបចូលរួមមួយ ៖
  - ដើម្បីជ្រាបទៅដល់សហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍ដែលគម្រោងបានប្រើប្រាស់ បានណែនាំអំពីសកម្មភាពអង្កេត និងសកម្មភាពសារពើភ័ណ្ឌជូនដល់សហគមន៍។
  - សិទ្ធិកាន់កាប់ដីធ្លីត្រូវបានចងក្រង និង ពន្យល់ជូនដល់សហគមន៍បានយ៉ាងប្រសើរ។
  - សហគមន៍បានចូលរួមនៅក្នុងលំហាត់កំណត់ផែនទីតាមមូលដ្ឋាន។
  - សមាជិកសហគមន៍ដែលត្រូវបានជ្រើសរើស ទទួលបានការបណ្តុះបណ្តាលអំពីបច្ចេកទេសដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីដោះស្រាយវិវាទដីធ្លីរបស់ពួកគេ។
  - វគ្គបន្តត្រួតពិនិត្យទៅលើការផ្តល់ព័ត៌មានជាសាធារណៈ បានបញ្ជាក់ឱ្យបានច្បាស់លាស់អំពីបញ្ហាសំខាន់ៗមួយចំនួន។
- ស្ត្រីបានដឹកនាំសកម្មភាពផ្សព្វផ្សាយយេនឌ័រ និង លើកកម្ពស់ការយល់ដឹងរបស់គម្រោងនៅក្នុងសហគមន៍ដែលទទួលបានការគាំទ្រពីស្ត្រី និងបុរសដទៃទៀត។

ឥរិយាបថអំពីយេនឌ័រ និងដីធ្លី ដែលបានចាក់ឫសយ៉ាងជ្រៅ អាចមានការពិបាកក្នុងការផ្លាស់ប្តូរ ដូច្នេះ គេត្រូវរៀបចំផែនការ និងធ្វើសមាហរណកម្មកិច្ចខិតខំផ្សព្វផ្សាយជាក់លាក់អំពីបញ្ហាយេនឌ័រ ទៅក្នុងយុទ្ធសាស្ត្រទំនាក់ទំនង និងលើកកម្ពស់ការយល់ដឹងទូលំទូលាយ។

បញ្ជីផ្ទៀងផ្ទាត់ ៥.១ ៖
ការគាំទ្រដល់ការទទួលបានព័ត៌មានដីធ្លីប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ FIG, 2001.

ការផ្សព្វផ្សាយយេនឌ័រប្រកបដោយប្រសិទ្ធភាព គួរកំណត់គោលដៅទាំងស្ត្រី និងបុរសគ្រប់អាយុ វណ្ណៈ សាសនា ជាតិពន្ធ ឋានៈសង្គម ។ល។ ការផ្សព្វផ្សាយយេនឌ័រផ្តល់ភាពអង់អាចដល់ស្ត្រី តាមរយៈព័ត៌មាន និងជំនាញក្នុងការនិយាយអះអាង ប៉ុន្តែ វាក៏មានសារៈសំខាន់ផងដែរ ដែលបុរសត្រូវជានាឱ្យមានឱកាសសម្រាប់ស្ត្រីក្នុងការចរចាអំពីសេចក្តីត្រូវការរបស់ពួកគេ។ ការសម្រេចឱ្យបាននូវចំណុចនេះ អាចទាមទារឱ្យមានការដោះស្រាយបញ្ហា ដែលទាក់ទងទៅនឹងអត្ថន័យនៃភាពជាបុរស ឬ ស្ត្រី នៅក្នុងវប្បធម៌ដែលពាក់ព័ន្ធ (WOLREC, 2011)។

ការផ្សព្វផ្សាយយេនឌ័រអំពីការកាន់កាប់ដីអាចមានទម្រង់ជាច្រើនផ្សេងៗគ្នា ដូចជាកម្មវិធីលើកកម្ពស់ការយល់ដឹងសាធារណៈ និងសហគមន៍ អំពីសិទ្ធិកាន់កាប់របស់ស្ត្រី វិធានការអប់រំមូលដ្ឋានសម្រាប់ជូនដំណឹងដល់ស្ត្រី និង បុរស អំពីសិទ្ធិរបស់ពួកគេ សកម្មភាពដែលគាំទ្រដល់អក្ខរកម្មផ្នែកច្បាប់ និង សកម្មភាពគាំទ្រសិទ្ធិដីធ្លី ព្រមទាំងកម្មវិធីដែលលើកទឹកចិត្តឱ្យមានការចូលរួមសកម្មពីស្ត្រី និង ក្រុមស្ត្រីនៅក្នុងការងារអភិបាលកិច្ច និងគ្រប់គ្រងធនធាន (FAO, 2000: 10)។

ប្រអប់ ៥.៣ ផ្តល់ឧទាហរណ៍អំពីការអនុវត្តន៍ល្អ ដែលរាល់ការអនុវត្តន៍ទាំងនោះបានឱ្យដឹងថា ការផ្សព្វផ្សាយអំពីយេនឌ័រប្រកបដោយប្រសិទ្ធភាព ពឹងផ្អែកទៅលើការប្រើប្រាស់កម្រងឧបករណ៍ និងសម្ភារៈទំនាក់ទំនងផ្សេងៗគ្នា ប្រកបដោយភាពច្នៃប្រឌិត។

- ✓ ពន្យល់ទៅកាន់ស្ត្រីអំពីសិទ្ធិ និងកាតព្វកិច្ច ដែលទាក់ទងទៅនឹងការ កាន់កាប់ប្លង់ដី។
- ✓ ពិភាក្សាអំពីអត្ថន័យនៃពាក្យរដ្ឋបាលដីធ្លី និង ការគ្រប់គ្រងដីធ្លីជាមួយស្ត្រី។
- ✓ ពិគ្រោះយោបល់ជាមួយស្ត្រី ថាតើនរណានឹងទទួលរងផលប៉ះពាល់ ដោយផ្ទាល់ពីគម្រោង និងលទ្ធផលកំណែទម្រង់វិស័យដីធ្លី។
- ✓ ធានាថាមានយន្តការទំនាក់ទំនងទ្វេទិសមួយ រវាងស្ត្រី និងអ្នកអង្កេត ព្រមទាំងអ្នកបច្ចេកទេសវិស័យដីធ្លីនៅមូលដ្ឋាន។
- ✓ បញ្ចូលអ្នកវិជ្ជាជីវៈផ្នែកអង្កេតជាស្ត្រី ទៅក្នុងក្រុមដែលធ្វើការងារ ជាមួយសហគមន៍មូលដ្ឋាន។
- ✓ គាំទ្រដល់សមាជិកភាពរបស់ស្ត្រីនៅក្នុងស្ថាប័នដីធ្លីគ្រប់កម្រិត។

ចូរចងចាំ!

ត្រូវលុបបំបាត់ឧបសគ្គដែលរាំងស្ទះលទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបានព័ត៌មានដីធ្លី ដើម្បីបង្កើតឱ្យមាននូវការទទួលបានព័ត៌មានដីធ្លីប្រកបដោយសមធម៌យេនឌ័រ នៅក្នុងគម្រោង និងកំណែទម្រង់វិស័យដីធ្លី។

ប្រអប់ ៥.៣ ៖

ការផ្សព្វផ្សាយអំពីយេនឌ័រ ដើម្បីគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ ILC, 2010c; ULA, 2010; World Bank/FAO/IFAD, 2009a: 159–161.

នៅក្នុង*ប្រទេសប៉ាគីស្ថាន* ក្នុងឆ្នាំ២០០៩-២០១០ គម្រោងមួយដែលទទួលបានមូលនិធិគាំទ្រពីសម្ព័ន្ធភាពដីធ្លីអន្តរជាតិ (ILC) បានត្រួតពិនិត្យផលប៉ះពាល់ទៅលើលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានដីធ្លី នៃកម្មវិធីបែងចែកដីធ្លី (LDP) របស់រដ្ឋាភិបាលខេត្ត Sindh និង បានផ្តល់ជំនួយផ្នែកច្បាប់ជូនដល់ស្ត្រី ដែលពាក់ព័ន្ធនៅក្នុងវិវាទដីធ្លី។ សមាសធាតុមួយដ៏សំខាន់របស់គម្រោង គឺជាការបញ្ជ្រាបប្រព័ន្ធផ្សព្វផ្សាយអំពីបញ្ហាដីធ្លី និងយេនឌ័រ ដោយបង្កើនការយកចិត្តទុកដាក់របស់ប្រព័ន្ធផ្សព្វផ្សាយ ចំពោះកម្មវិធីបែងចែកដីធ្លី ដែលបានរួមចំណែកធ្វើឱ្យរដ្ឋាភិបាលថ្នាក់ខេត្តទទួលស្គាល់ អំពីចន្លោះប្រហោងនៅក្នុងដំណើរការបែងចែកដី។ សកម្មភាពផ្សព្វផ្សាយ រួមមាន កិច្ចសន្ទនាជាមួយប្រព័ន្ធផ្សព្វផ្សាយអំពីកម្មវិធីបែងចែកដីធ្លី និង បញ្ហាពាក់ព័ន្ធ ទស្សនៈកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយទៅកាន់បណ្តាស្រុក និង ប្រជាពលរដ្ឋដែលទទួលបានដីធ្លី អត្ថបទសម្រាប់ប្រព័ន្ធផ្សព្វផ្សាយធ្វើការបោះពុម្ព វីដេអូ និង ឯកសារអំពីករណីសិក្សា និងករណីជោគជ័យ ព្រមទាំងការផ្សព្វផ្សាយអំពីការសិក្សាលើបញ្ហាកម្មវិធីបែងចែកដីធ្លី។

ចលនាដីធ្លី និងសមធម៌នៅក្នុង*ប្រទេសយូហ្គាន់ដា* (LEMU) កំពុងផ្សព្វផ្សាយជូនដល់សហគមន៍អំពីបញ្ហាដីធ្លី និងយេនឌ័រ ព្រមទាំងផ្តល់ព័ត៌មានជូនដល់សាធារណជន

រាប់បញ្ចូលព័ត៌មានអំពីជម្រើសសម្រាប់គ្រួសារ ដែលកំពុងសម្រេចចិត្ត ថាតើពួកគេគួរ ឬមិនគួរចុះបញ្ជីប្លង់ដីបែបប្រពៃណីរបស់ពួកគេ ឬ គ្រួសារដែលកំពុងជួបប្រទះបញ្ហាការទិញដីរបស់ពួកគេដោយបង្ខំ។ ចលនាដីធ្លី និងសមធម៌នៅក្នុងប្រទេសយូហ្គាន់ដាប្រើប្រាស់ខិត្តប័ណ្ណ កម្មវិធីជជែកតាមទូរស័ព្ទនៅក្នុងវិទ្យុ និងការផ្តល់ដំបូន្មានផ្នែកច្បាប់លក្ខណៈបុគ្គល ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិដីធ្លីរបស់ស្ត្រី ស្ថិតក្រោមច្បាប់បែបប្រពៃណី និងបែបគតិយុត្តិ ព្រមទាំងអំពីជំហានដែលសហគមន៍អាចអនុវត្ត ដើម្បីកាត់បន្ថយជម្លោះដីធ្លី និង ដើម្បីជម្រុញឱ្យមានការផ្សព្វផ្សាយ និង ពិភាក្សាវែកញែកអំពីបញ្ហាយេនឌ័រ។

នៅក្នុង*ប្រទេសនេប៉ាល់* គម្រោងជួលភ្នំដើម្បីអភិវឌ្ឍន៍ព្រៃឈើ និងការចិញ្ចឹមសត្វ របស់មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម (IFAD) បានជួលសិទ្ធិអ្នកប្រើប្រាស់លើដីព្រៃ ទៅឱ្យគ្រួសារក្រីក្រដែលមានសមាជិកចន្លោះពី ៥គ្រួសារ ទៅ ១០គ្រួសារក្នុងមួយក្រុម។ ដើម្បីធានាថា គម្រោងនេះឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងប្រយោជន៍របស់ស្ត្រីជនបទ គម្រោងបានជួលក្រុមការងារយេនឌ័រមួយក្រុម ដែលមានសមាសភាពស្ត្រីចំនួន៣រូប ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រផ្សព្វផ្សាយយេនឌ័រមួយប្រកបដោយភាពច្នៃប្រឌិត។ សកម្មភាព រួមមាន ការជ្រើសរើស និងការបណ្តុះបណ្តាលក្រុមស្ត្រីធ្វើការងារលើកកម្ពស់ ដើម្បីផ្សព្វផ្សាយដល់អ្នកទទួលផលជាស្ត្រី និង បុរសអំពីគម្រោង កំណត់អត្តសញ្ញាណ ផ្តល់ការបណ្តុះបណ្តាល និងបង្រៀនជនបង្គោលយេនឌ័រនៅក្នុងទីភ្នាក់ងារអនុវត្តគម្រោង ដែលបុគ្គលិកភាគច្រើនជាបុរស និងការផលិត និងចែកចាយទស្សនាវដ្តីចំនួនពីរ ៖ ទស្សនាវដ្តីមួយសម្រាប់ជនបង្គោលយេនឌ័រនៅថ្នាក់ស្រុក និងទស្សនាវដ្តីមួយទៀតសម្រាប់ក្រុមអ្នកលើកកម្ពស់នៅថ្នាក់មូលដ្ឋាន។

ក្រោយពេលអនុវត្តបាន៩ឆ្នាំ ជោគជ័យរួមមាន ការចូលរួម និងតួនាទីដឹកនាំរបស់ស្ត្រីមានចំនួនកាន់តែច្រើន - អ្នកចូលរួមចំនួន២៥% នៅក្នុងកិច្ចប្រជុំក្រុមជួលព្រៃ គឺជាស្ត្រី និងមានក្រុមស្ត្រីសុទ្ធសាធចំនួន៧៤ក្រុម និងប្រធានក្រុមស្ត្រីចំនួន ១១២នាក់ ទំនុកចិត្ត លើខ្លួនឯងមានការកើនឡើងសម្រាប់ស្ត្រីវ័យក្មេងដែលចូលរួមនៅក្នុងគម្រោង ហើយ ការផ្តល់ប្លង់ដីជូនដល់ស្ត្រីមានការកើនឡើង ជាមួយនឹងរបាយការណ៍ឱ្យដឹងថា បុរស មានការទទួលយកកាន់តែច្រើនឡើង ចំពោះសិទ្ធិស្ត្រីក្នុងការកាន់កាប់ដីកសិកម្ម ក្រោម ឈ្មោះផ្ទាល់ខ្លួនរបស់ពួកគេ។ ស្ត្រីដែលធ្លាប់បានចូលរួមក្នុងក្រុមទាំងនេះ យ៉ាងហោច រយៈពេល៥ឆ្នាំ បានរាយការណ៍ឱ្យដឹងថា ឥឡូវនេះ ៩០% នៃរាល់សេចក្តីសម្រេចចិត្តនៅក្នុងគ្រួសារ ត្រូវបានធ្វើឡើងរួមគ្នា។

✎បញ្ជីផ្ទៀងផ្ទាត់ ៥.២ ៖
ការផ្សព្វផ្សាយ អំពីយេនឌ័រ

ប្រភព ៖ FAO, 2002c: 27.

✓	ផ្សព្វផ្សាយជូនដល់ស្ត្រី និង បុរសឱ្យផ្លាស់ប្តូរគុណតម្លៃ និងឥរិយាបថដែលបានចាក់ឫសយ៉ាងជ្រៅ។
✓	ផ្សព្វផ្សាយជូនដល់មេដឹកនាំថ្នាក់ជាតិ ថ្នាក់ស្រុក និងថ្នាក់មូលដ្ឋានអំពីយេនឌ័រ និង បញ្ហាដីធ្លី។
✓	លើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងគម្រោង និង កំណែទម្រង់វិស័យដីធ្លីតាមរយៈការផ្តល់ការផ្សព្វផ្សាយ និង ការបណ្តុះបណ្តាលសមស្របអំពីយេនឌ័រជូនដល់បុគ្គលិកគម្រោងគ្រប់រូបទាំងអស់ និង សមាជិករបស់សហគមន៍មូលដ្ឋានដែលពាក់ព័ន្ធ។
✓	ជម្រុញឱ្យមានការពិភាក្សាអំពីបញ្ហាយេនឌ័រ និងបញ្ហាដីធ្លីក្នុងវេទិកាមួយដែលមាន លក្ខណៈអព្យាក្រឹត្យ និងធានាឱ្យមានយន្តការប្រកបដោយប្រសិទ្ធភាព និង មាន ភាពសមស្របទៅតាមបរិបទវប្បធម៌ សម្រាប់ការកំណត់អត្តសញ្ញាណ និង ការពិភាក្សា ការចរចារ និងការដោះស្រាយជម្លោះចំពោះបញ្ហា។
✓	ផ្តល់ឱកាសស្មើភាពគ្នាសម្រាប់ស្ត្រី និងបុរស នៅក្នុងការផ្សព្វផ្សាយ ការអប់រំ និង ការបណ្តុះបណ្តាលអំពីយេនឌ័រ (រាប់បញ្ចូលទស្សនៈកិច្ចសិក្សា) នៅក្នុងគ្រប់គម្រោង និងកំណែទម្រង់វិស័យដីធ្លីទាំងអស់។
✓	សម្របសម្រួលឱ្យមានការតែងតាំងស្ត្រី ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឱ្យចូលកាន់តួនាទីដឹកនាំ និង ធ្វើសេចក្តីសម្រេចចិត្តក្នុងបញ្ហាដីធ្លី។
✓	ផ្តល់ការបណ្តុះបណ្តាលពិសេសអំពីបញ្ហាយេនឌ័រជូនដល់ស្ត្រី ដើម្បីជម្រុញឱ្យមាន ជំនាញ និងធនធានថ្មីៗសម្រាប់ប្រឆាំងទៅនឹងតួនាទីបែបប្រពៃណីរបស់ពួកគេ និង ចូលរួមឱ្យបានពេញលេញនៅក្នុងដំណើរការ និង ស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។
✓	ផ្តល់ការបណ្តុះបណ្តាលពិសេសអំពីបញ្ហាយេនឌ័រជូនដល់បុរស ដើម្បីលើកទឹកចិត្ត ពួកគេក្នុងការធានាឱ្យមានឱកាសសម្រាប់ស្ត្រីចូលរួមនៅក្នុងការងារអភិបាលកិច្ចលើការកាន់កាប់ដីធ្លី តាមរយៈការដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងអត្តន័យនៃភាពជាបុរស ឬ ស្ត្រី នៅក្នុងវប្បធម៌ដែលពាក់ព័ន្ធ។
✓	ធ្វើការបញ្ជ្រាបដល់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីសម្របសម្រួលឱ្យមានការផ្លាស់ប្តូរប្រកបដោយនិរន្តរភាព នៅកម្រិតសហគមន៍ រដ្ឋាភិបាលមូលដ្ឋាន និងកម្រិតថ្នាក់ជាតិ។

ចូរចងចាំ!

ការផ្សព្វផ្សាយអំពីយេនឌ័រ គឺជាផ្នែកមួយដែលចាំបាច់នៃយុទ្ធសាស្ត្រទំនាក់ទំនងប្រកបដោយជោគជ័យ ប៉ុន្តែ ផ្នែកនេះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ សម្រាប់កសាងឱ្យមានការគាំទ្រប្រកបដោយនិរន្តរភាព ចំពោះអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ និងមានសមធម៌យេនឌ័រ។ អង្គការអន្តរជាតិ មានតួនាទីមួយដ៏សំខាន់នៅក្នុងសកម្មភាពអប់រំ និងផ្សព្វផ្សាយ ដើម្បីលើកកម្ពស់សមាហរណកម្មយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងសមធម៌យេនឌ័រ នៅក្នុងដំណើរការ និង ស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។

បើទោះបីជាការងារតស៊ូមតិ រមែងតែងសំដៅដោយផ្ទាល់ចំពោះអ្នកបង្កើតគោលនយោបាយនៅក្នុងជួររដ្ឋាភិបាល និងអង្គភាពធ្វើសេចក្តីសម្រេចចិត្តដទៃទៀតក៏ដោយ ប៉ុន្តែ ការលើកកម្ពស់ការយល់ដឹងនៅក្នុងចំណោមអ្នកពាក់ព័ន្ធទូលំទូលាយ និង ក្រុមដែលទទួលបានប្រយោជន៍ អាចគាំទ្រដល់កិច្ចខិតខំតស៊ូមតិ តាមរយៈការអភិវឌ្ឍន៍ឱ្យមានសម្ពាធសាធារណៈ សំដៅជម្រុញឱ្យមានការផ្លាស់ប្តូរ និង កំណែទម្រង់។

បញ្ជីផ្ទៀងផ្ទាត់ ៥.៣ ៖
ការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងសម្រាប់ការតស៊ូមតិ

ប្រភព ៖ Sabine Pallas's presentation on "Developing communication and advocacy tools through action-oriented research in Africa" at the May 2011 technical workshop; ILC, 2011.

- ✓ ផ្តល់ការអភិវឌ្ឍន៍សមត្ថភាព និងកិច្ចគាំទ្រហិរញ្ញវត្ថុជូនដល់អង្គការសង្គមស៊ីវិល ដែលធ្វើការងារនៅមូលដ្ឋាន និង/ឬ ក្រោមភាពជាដៃគូជាមួយអង្គការសហគមន៍ អាស្រ័យដោយពួកគេអាចជួយលុបបំបាត់ចន្លោះប្រហោង (ដូចជា របាំងឧបសគ្គផ្នែកភាសា) រវាងសហគមន៍មូលដ្ឋាន និងរដ្ឋាភិបាល។
- ✓ ជម្រុញឱ្យមានការចូលរួមពីសហគមន៍ទាំងមូលនៅក្នុងគ្រប់យុទ្ធសាស្ត្រទំនាក់ទំនង ទាំងអស់ ដើម្បីឱ្យអភិបាលកិច្ចលើការកាន់កាប់ដីធ្លីមានសមធម៌យេនឌ័រ និង សង្កត់ធ្ងន់អំពីប្រយោជន៍នៃសមធម៌យេនឌ័រ ជូនដល់ជនគ្រប់រូប ៖
  - ជាជាងការជម្រុញទាមទារសិទ្ធិស្ត្រីដាច់ដោយឡែកតែឯង ត្រូវលើកទឹកចិត្តឱ្យមានការគាំទ្រពីប្រជាជនដែលត្រូវបានគេមើលរំលង និង ងាយរងគ្រោះបំផុតនៅក្នុងសហគមន៍ ដើម្បីជៀសវាងការប្រឈមដោយផ្ទាល់ទៅនឹងឥរិយាបថដែលបានចាក់ឫសយ៉ាងជ្រៅអំពីទំនាក់ទំនងយេនឌ័រ។
- ✓ ធានាថាគ្រប់ផលិតផល និងឧបករណ៍ទំនាក់ទំនងទាំងអស់ សង្កត់ធ្ងន់ទៅលើបញ្ហា សមធម៌យេនឌ័រ។ ពិចារណាប្រើប្រាស់ផលិតផល និង ឧបករណ៍ផ្សេងៗគ្នា សម្រាប់ប្រាស្រ័យទាក់ទងជាមួយបុរស និងស្ត្រី ដោយយោងទៅតាមប្រភេទ ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗគ្នា ដែលពួកគេអាចមានលទ្ធភាពប្រើប្រាស់ និងមាន ចំណាប់អារម្មណ៍។
- ✓ ផ្តោតការយកចិត្តទុកដាក់ពិសេស ចំពោះការដោះស្រាយបញ្ហាអនក្ខរភាពរបស់ ស្ត្រីជនបទ និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ទាំងមូល ដែលស្ត្រី

	អាចមានលទ្ធភាពប្រើប្រាស់ រាប់បញ្ចូលទាំងទូរស័ព្ទចល័តផងដែរ។
✓	ជម្រុញឱ្យមានការចូលរួមពីស្ត្រី និងកសាងទំនុកចិត្តរបស់ពួកគេក្នុងការនិយាយ ដើម្បីប្រយោជន៍ខ្លួនឯងជាសាធារណៈ។
✓	ពិចារណាទៅលើទម្ងន់ការងាររបស់ស្ត្រី និងពេលវេលាដែលពួកគេមានសម្រាប់ ចូលរួមកិច្ចប្រជុំ។

ចូរចងចាំ!

ការប្រាស្រ័យទាក់ទងមានសារៈសំខាន់ខ្លាំងណាស់ចំពោះការងារតស៊ូមតិ។ យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងដែលត្រូវបានរៀបចំ និង អនុវត្តបានល្អ អាចជួយលើកកម្ពស់បុព្វហេតុមួយបាន ផ្ទុយទៅវិញ ភាពទន់ខ្សោយក្នុងការប្រាស្រ័យទាក់ទង អាចបំផ្លាញវាទៅវិញ។

អក្ខរកម្មផ្នែកច្បាប់

អក្ខរកម្មផ្នែកច្បាប់សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ ទាមទារឱ្យស្ត្រី និងបុរស ដឹងអំពីអ្វីដែលអាចទៅរួចតាមផ្លូវច្បាប់ និង ទាមទារឱ្យពួកគេមានព័ត៌មានអំពីរបៀបចុះបញ្ជីសិទ្ធិដីធ្លី ចូលរួមនៅក្នុងប្រតិបត្តិការដីធ្លី និង ចូលរួមក្នុងដំណើរការ ព្រមទាំងស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី។ ពួកគេក៏ត្រូវយល់ផងដែរអំពីភាពស្មុគស្មាញនៃបញ្ហាដីធ្លី ភាពមានកម្រិតនៃច្បាប់ និងសមត្ថភាពអនុវត្តរបស់ស្ថាប័នរដ្ឋបាល និងគ្រប់គ្រងដីធ្លី ព្រមទាំងជម្រើស យន្តការ និងបរិយាកាសផ្នែកច្បាប់បែបផ្លូវការ និងមិនផ្លូវការផ្សេងៗគ្នាដែលអាចមាន ដើម្បីបន្តធ្វើការទាមទារដីធ្លីរបស់ពួកគេ។ បុគ្គលដែលមានបន្ទុកអនុវត្តច្បាប់ភូមិបាល និងគ្រប់គ្រងដំណើរការស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ដូចជា មេដឹកនាំក្នុងមូលដ្ឋាន អាជ្ញាធរយុត្តិធម៌ និងរដ្ឋបាល ព្រមទាំងអ្នកបច្ចេកទេសវិស័យដីធ្លី ក៏ត្រូវយល់អំពីច្បាប់ និងអត្ថន័យនៃច្បាប់ផងដែរ (FAO, 2011a: 18-19; World Bank/FAO/IFAD, 2009a: 144)។

ការប្រាស្រ័យទាក់ទង និងកិច្ចគាំទ្រដើម្បីធ្វើឱ្យប្រសើរឡើងនូវអក្ខរកម្មផ្នែកច្បាប់ ត្រូវដោះស្រាយការរើសអើងបែបប្រពៃណី ដែលរមែងតែងកើតឡើងយូរអង្វែង និង ដែលបណ្ដាលឱ្យស្ត្រីមួយចំនួនបោះបង់សិទ្ធិដីធ្លីតាមផ្លូវច្បាប់របស់ពួកគេ បើទោះបីជាពួកគេដឹងថាពួកគេមានសិទ្ធិទាំងនោះក៏ដោយ។

ការអនុវត្តន៍ល្អក្នុងការបង្កើត និងគាំទ្រដល់អក្ខរកម្មផ្នែកច្បាប់ សម្រាប់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ រួមមាន អភិក្រមបែបចូលរួមដែលត្រូវបានប្រើប្រាស់នៅក្នុងប្រទេសកូឡុំប៊ី និងយុទ្ធនាការយល់ដឹងអំពីច្បាប់ ដោយប្រើប្រាស់បទចំរៀង របាំ និងឧបករណ៍ទស្សនីយភាព ដែលងាយស្រួលក្នុងការចម្លងយកលំនាំតាម នៅក្នុងសហគមន៍ជនជាតិដើមភាគតិចដែលមានកម្រិតអនក្ខរភាពខ្ពស់ និង ងាយរងគ្រោះខ្លាំងនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ភាគខាងកើត ដូចមានរៀបរាប់នៅក្នុងប្រអប់ ៥.៤។

ប្រអប់ ៥.៤ ៖ **នៅក្នុងប្រទេសកូឡុំប៊ី គម្រោងអក្ខរកម្មផ្នែកច្បាប់មួយ ដែលអនុវត្តដោយអង្គការ**

ការគាំទ្រអន្តរកម្ម ផ្នែកច្បាប់

ប្រភព ៖
ILC, 2010a; 2010b.

មិនមែនរដ្ឋាភិបាល ដែលមានឈ្មោះ Centro de Investigación y Educación Popular ក្នុងឆ្នាំ២០១០ បានបណ្តុះបណ្តាលស្ត្រីចំនួន ៣០នាក់ ពីអង្គការជនបទ ដើម្បីបង្កើនការយល់ដឹងរបស់សហគមន៍អំពីសិទ្ធិដីធ្លី និង យន្តការសម្រាប់ទាមទារសិទ្ធិទាំងនោះ។ អភិក្រមបែបចូលរួម មានជាអាទិ៍ ៖

- ការស្រាវជ្រាវ និងវិភាគដោយមានការចូលរួម ដែលនាំឱ្យមានការផលិតឯកសារអំពី បញ្ហាប្រឈមដែលស្ត្រីជួបប្រទះក្នុងការទទួលបានដីធ្លី ក្នុងប្រទេសកូឡុំប៊ី។
- វគ្គបណ្តុះបណ្តាលចំនួន៣ ដែលត្រូវបានធ្វើឡើងនៅក្នុងភូមិនីមួយៗក្នុងចំណោមភូមិ ទាំង៥ បូករួមជាមួយកិច្ចប្រជុំចុងក្រោយមួយសម្រាប់រៀនសូត្រ និង ចែករំលែកបទពិសោធន៍ក្នុងចំណោមស្ត្រីទាំង៣០នាក់។
- ការផលិតសម្ភារៈប្រាស្រ័យទាក់ទង រាប់បញ្ចូលព្រឹត្តិប័ត្រ និងផ្ទាំងបដាអំពីស្ត្រី និង ការទទួលបានដីធ្លី និងការផ្សាយវិទ្យុតាមប៉ុស្តិ៍វិទ្យុក្នុងតំបន់ចំនួន៣។
- ការរៀបចំសេចក្តីព្រាង និងការផ្តល់សុក្រឹត្យភាពទៅលើយុទ្ធសាស្ត្រច្បាប់មួយ សម្រាប់ ការពារ និងទាមទារសិទ្ធិដីធ្លីរបស់ស្ត្រី ការអនុម័តទៅលើសេចក្តីប្រកាស និងការ ផ្សព្វផ្សាយកញ្ចប់ឧបករណ៍ដោយសិក្ខាកាមជាស្ត្រីទាំង ៣០ នាក់។

សកម្មភាពទាំងនេះ មានផលប៉ះពាល់គួរឱ្យកត់សម្គាល់ទៅលើទំនុកចិត្តរបស់សិក្ខាកាម ក្នុងការនិយាយ និងទាមទារសិទ្ធិរបស់ពួកគេ និង ការលើកទឹកចិត្តរបស់ពួកគេ ក្នុងការសហការសំដៅសម្រេចគោលដៅរួមមួយ។

នៅក្នុង*សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ* ក្នុងឆ្នាំ២០០៩-២០១០ Union pour l'Emancipation de la Femme Autochtone (UEFA) បានអនុវត្តធ្វើយុទ្ធនាការយល់ដឹងអំពី ច្បាប់មួយដែលទទួលបានមូលនិធិគាំទ្រពីសម្ព័ន្ធភាពដីធ្លីអន្តរជាតិ (ILC) ដោយផ្តោតយកចិត្តទុកដាក់ទៅលើសិទ្ធិដីធ្លីរបស់ស្ត្រីនៅក្នុងសហគមន៍មនុស្សតឿ ក្នុងខេត្តគីវូភាគខាងជើង និងភាគខាងត្បូង។ សកម្មភាពរួមមាន ៖

- ការកសាងសមត្ថភាពសម្រាប់អ្នកលើកកម្ពស់ការយល់ដឹង ("sensibilisateurs") ចំនួន ១០នាក់ អំពីជំនាញ និងបច្ចេកទេសទំនាក់ទំនងច្បាប់ភូមិបាល និងច្បាប់ ព្រៃឈើ សិទ្ធិស្ត្រី យេនឌ័រ និងការអភិវឌ្ឍន៍។
- ការផលិតសម្ភារៈលើកកម្ពស់ការយល់ដឹងអំពីច្បាប់ រាប់បញ្ចូលកូនសៀវភៅគំនូរជីវចល និងចំរៀងជាភាសាក្នុងមូលដ្ឋាន ដែលត្រូវបានរៀបចំឡើងសម្រាប់សហគមន៍ដែលមានកម្រិតអនក្ខរភាពខ្ពស់ ដែលមានវប្បធម៌សម្បូរបែបអំពីចំរៀង ដែលទទួលស្គាល់អំពីសិទ្ធិ និងឋានៈរបស់ស្ត្រី ប៉ុន្តែ ត្រូវគេបំភ្លេចចោល។

- ការរៀបចំយុទ្ធនាការសកម្មភាពដែលជ្រាបទៅដល់ប្រជាជនជិត ៩.០០០នាក់ និង មេដឹកនាំក្នុងមូលដ្ឋានចំនួន ២០នាក់ ហើយបើយោងតាមការប៉ាន់ប្រមាណរបស់ UEFA ចំនួននេះ តំណាងឱ្យ ១៥% នៃមនុស្សតឿក្នុងមូលដ្ឋាន។
- ការតស៊ូមតិជាមួយមេដឹកនាំក្នុងមូលដ្ឋាន ដោយប្រើប្រាស់អនុស្សរណៈមួយស្តីពីសិទ្ធិ ដីធ្លីរបស់ស្ត្រី ដែលរៀបចំឡើងដោយប្រតិភូពីសហគមន៍គម្រោង ជាមូលដ្ឋានសម្រាប់សកម្មភាពនៅពេលអនាគត។

យុទ្ធនាការនេះ បានបង្កើនការយល់ដឹងរបស់សហគមន៍អំពីសិទ្ធិដីធ្លី ក្នុងចំណោមសហគមន៍មនុស្សតឿ និង ការយល់ដឹងរបស់មេដឹកនាំក្នុងមូលដ្ឋាន អំពីសិទ្ធិដីធ្លីរបស់មនុស្សតឿជាស្ត្រី។ ការប្រើប្រាស់ចំរៀង របាំ និងឧបករណ៍ទស្សនីយភាពបែបប្រពៃណី មានតម្លៃជាពិសេស ក្នុងការលើកកម្ពស់អក្ខរកម្មផ្នែកច្បាប់ ក្នុងចំណោមប្រជាជនដែលត្រូវបានគេមើលរំលង និងងាយរងគ្រោះខ្លាំងទាំងនេះ ព្រមទាំងផ្តល់នូវគំរូមួយនៃការអនុវត្តន៍។

យុទ្ធសាស្ត្រ និងវិធីសាស្ត្រប្រាស្រ័យទាក់ទង និង លើកកម្ពស់ការយល់ដឹង

នៅពេលរៀបចំយុទ្ធសាស្ត្រ និង វិធីសាស្ត្រប្រាស្រ័យទាក់ទង និងលើកកម្ពស់ការយល់ដឹង វាមានសារៈសំខាន់ក្នុងការកំណត់រកវិធីផ្សេងៗគ្នាដែលស្ត្រី និងបុរស ចូលរួមជាមួយពិភពលោក និងទទួលបានព័ត៌មាន ព្រមទាំងកែច្នៃ ព័ត៌មាននៅក្នុងប្រទេស គម្រោង និង/ឬ កំណែទម្រង់ដែលពាក់ព័ន្ធ។

✎បញ្ជីផ្ទៀងផ្ទាត់ ៥.៤ ៖ ការរៀបចំយុទ្ធសាស្ត្រ និងវិធីសាស្ត្រ ទំនាក់ទំនង និង លើកកម្ពស់ការយល់ដឹង

✓ តើស្ត្រី និងបុរសជាទូទៅទទួលបានព័ត៌មានពីកន្លែងណា?
- ឧទាហរណ៍ ជារឿយៗ គ្រូបង្រៀនគឺជាប្រភពព័ត៌មានមួយដ៏សំខាន់សម្រាប់ស្ត្រី ប៉ុន្តែ ពួកគេមិនសូវជាប្រភពព័ត៌មានសំខាន់សម្រាប់បុរសឡើយ។

✓ តើប្រព័ន្ធផ្សព្វផ្សាយណាខ្លះដែលប្រសើរបំផុតសម្រាប់ជ្រាបទៅដល់ស្ត្រី?

✓ តើអ្វីខ្លះជាសញ្ញាណផ្នែកសង្គម និង វប្បធម៌នៃសិទ្ធិដីធ្លីសម្រាប់យេនឌ័រនីមួយៗ? តើកំណែទម្រង់លើការកាន់កាប់ដីធ្លីអាចមានផលប៉ះពាល់ខុសគ្នាអ្វីខ្លះ សម្រាប់ ស្ត្រី និងបុរស?

✓ តើប្រជាពលរដ្ឋផ្សេងៗគ្នាចូលរួមនៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លីដោយ របៀបណា និង នៅពេលណា? តើពួកគេអាចមានចំណេះដឹងកម្រិតណារួចទៅហើយ?

✓ តើគេត្រូវផ្តល់សារអ្វីខ្លះជូនដល់ស្ត្រី និងបុរសនៅដំណាក់កាលផ្សេងៗគ្នា និងអំពី ដំណាក់កាលផ្សេងៗគ្នានៃគម្រោង ឬ កំណែទម្រង់វិស័យដីធ្លី? តើគេគួររៀបចំ សារទាំងនេះ ដោយរបៀបណា?

ចូរចងចាំ!

កិច្ចខិតខំប្រាស្រ័យទាក់ទង និងលើកកម្ពស់ការយល់ដឹង ប្រឈមទៅនឹងការដែលមានផលប៉ះពាល់មិនគ្រប់គ្រាន់ ប្រសិនបើសំនួរទាំងនេះ មិនត្រូវបានឆ្លើយតបពីដំបូងនៅក្នុងដំណាក់កាលរៀបចំយុទ្ធនាការព័ត៌មានមួយ។

ការរៀបចំ និងការអនុវត្តន៍សកម្មភាពប្រាស្រ័យទាក់ទង គួរឆ្លើយតបទៅនឹងទិដ្ឋភាពផ្នែកយុទ្ធសាស្រ្ត ដូចជាការផ្លាស់ប្តូររយៈពេលវែងទៅលើគុណតម្លៃ និងឥរិយាបថ ទិដ្ឋភាពផ្នែកវិធីសាស្រ្ត ដូចជាជម្រើសនៃវិធីសាស្រ្ត ឧបករណ៍ និងសារ សម្រាប់ក្រុមគោលដៅផ្សេងៗគ្នា និងទិដ្ឋភាពផ្នែកស្ថាប័ន ដូចជា សមធម៌យេនឌ័រនៅក្នុងអង្គការ ឬ ស្ថាប័នដែលលើកកម្ពស់សកម្មភាព (FAO-Demitra, 2011b)។

រូបភាព ៥.១ បង្ហាញអំពីជំហានក្នុងការរៀបចំយុទ្ធសាស្រ្ត និងវិធីសាស្រ្តប្រាស្រ័យទាក់ទង និងលើកកម្ពស់ការយល់ដឹង ដើម្បីគាំទ្រដល់អភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ។

រូបភាព ៥.១ ៖
ការរៀបចំយុទ្ធសាស្រ្តទំនាក់ទំនង និងលើកកម្ពស់ការយល់ដឹង

ការចាប់ផ្តើមនៅកម្រិតកំពូល

ការប្រាស្រ័យទាក់ទង និងការលើកកម្ពស់ការយល់ដឹងដោយជោគជ័យ អាស្រ័យទៅលើការទទួលបានកិច្ចគាំទ្រ និងការប្តេជ្ញាចិត្តពីបុគ្គលនៅកម្រិតកំពូលនៃការធ្វើសេចក្តីសម្រេចចិត្ត និងការបង្កើតគោលនយោបាយ។ ដូច្នេះ រាល់យុទ្ធសាស្រ្តប្រាស្រ័យទាក់ទងទាំងអស់ គួរចាប់ផ្តើមពីការផ្សព្វផ្សាយ និងបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល និង មន្ត្រីរដ្ឋបាល ព្រមទាំងអ្នកបច្ចេកទេសវិស័យដីធ្លី ស្តីពី ៖

- ហេតុអ្វីបានជាយេនឌ័រគឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់
- តើគម្រោង និងកំណែទម្រង់វិស័យដីធ្លីនីមួយៗបង្កឱ្យមានផលប៉ះពាល់ទៅលើស្ត្រី និងបុរស លើផ្នែកវប្បធម៌ សង្គម និងសេដ្ឋកិច្ច ដោយរបៀបណា
- ជំនឿទៅលើអភិបាលកិច្ចលើការកាន់កាប់ដីធ្លីប្រកបដោយសមធម៌យេនឌ័រ និងជំនឿក្នុងការជម្រុញឱ្យមានការចូលរួមពីស្ត្រី និងបុរស នៅក្នុងគ្រប់ដំណើរការ និងស្ថាប័នអភិបាលកិច្ចលើការកាន់កាប់ដីធ្លីទាំងអស់ រាប់បញ្ចូល ស្ថាប័នរដ្ឋបាល និងគ្រប់គ្រងដីធ្លី និងសកម្មភាពអនុវត្តគម្រោង និងកំណែទម្រង់
- ការអនុវត្តន៍ល្អ សម្រាប់លើកកម្ពស់សមធម៌យេនឌ័រ។

ជំហានដំបូងនេះ ក៏ទាមទារឱ្យមានការយល់ច្បាស់អំពីបរិបទ និងគោលបំណងនៃការប្រាស្រ័យការទាក់ទង និងការលើកកម្ពស់ការយល់ដឹងផងដែរ។ ទាក់ទងទៅនឹងក្របខ័ណ្ឌបង្កើតគោលនយោបាយ ដែលមានរៀបរាប់នៅក្នុង*ម៉ូឌុល១* វាមានសារៈប្រយោជន៍ក្នុងការកសាងឱ្យមាននូវអាណត្តិការងារមួយ ដើម្បីឱ្យមានការផ្លាស់ប្តូរតាមរយៈសម្ព័ន្ធភាពពហុភាគីអ្នកពាក់ព័ន្ធ ដោយកំណត់រកបុគ្គលផ្ទើម និង ក្រុមអ្នកត្រួសត្រាយផ្លូវមួយក្រុមដើម្បីលើកកម្ពស់សមធម៌យេនឌ័រ នៅក្នុងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី និង ធ្វើការដឹកនាំក្នុងការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង និងលើកកម្ពស់ការយល់ដឹងជារួម។

លំដាប់លំដោយ និងពេលវេលា

ការផ្តល់ឱ្យសាធារណជននូវព័ត៌មានឱ្យបានឆាប់រហ័សពីដំបូងនៅក្នុងដំណើរការ អាចជួយកែតម្រូវទៅលើការសន្និដ្ឋានមិនត្រឹមត្រូវ និងជៀសវាងការភាន់ច្រឡំ។ បើទោះជាដូច្នេះក្តី ប្រសិនបើស្ថាប័នដីធ្លីបំពេញមុខងារមិនបានល្អ ឬ ពុករលួយ ព័ត៌មានដែលផ្តល់ជូន អាចបង្កឱ្យមានអំពើហិង្សា និងភាពខ្វែងគំនិតគ្នាក្នុងចំណោមប្រជាពលរដ្ឋ។ នេះគឺជាហានិភ័យជាក់លាក់មួយនៅក្នុងស្ថានភាពក្រោយជម្លោះ ដែលបញ្ហាដី និងធនធានអាចជាកត្តារួមចំណែកមួយនៅក្នុងជម្លោះ។

ជំហានទី២ នៅក្នុងដំណើរការរៀបចំយុទ្ធសាស្ត្រ ក៏ទាមទារឱ្យមានការប្រុងប្រយ័ត្នក្នុងការរៀបចំផែនការ និង ថវិកាសម្រាប់អនុវត្តសកម្មភាពប្រាស្រ័យទាក់ទង និងលើកកម្ពស់ការយល់ដឹងផងដែរ។

ការកំណត់និយមន័យ និងការជ្រើសរើសជនគោលដៅ

នៅក្នុងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជារួម គេត្រូវអភិវឌ្ឍសារផ្សេងៗគ្នាសម្រាប់ជនគោលដៅផ្សេងៗគ្នា។ ដូច្នេះព័ត៌មានដូចគ្នាអាចត្រូវបង្ហាញក្នុងលក្ខណៈខុសគ្នា ដោយផ្តោតទៅលើសមាសធាតុដែលគេចាប់អារម្មណ៍ និងពាក់ព័ន្ធទៅនឹងក្រុមប្រជាជនផ្សេងៗគ្នា។

វាក៏មានសារៈសំខាន់ខ្លាំងផងដែរ ក្នុងការប៉ាន់ប្រមាណទៅលើកម្រិតចំណេះដឹង និងការយល់ដឹងដែលមានស្រាប់របស់ជនគោលដៅទាំងពីរភេទជាទូទៅ និងបញ្ហាការកាន់កាប់ដីធ្លីជាក់លាក់ដែលកំពុងមានការប្រឈម។ ចំណុចនេះអាចសម្រេចទៅបានតាមរយៈការកំណត់ផែនទីជនគោលដៅ ដើម្បីកំណត់ថា តើវាមានភាព

បើកចំហក្នុងការ ពិភាក្សាអំពីបញ្ហាយេនឌ័រ ប្រភេទសកម្មភាព និងសារទំនាក់ទំនងដែលអាចមានភាពសមស្រប បំផុត និងក្របខ័ណ្ឌពេលវេលាប្រហាក់ប្រហែល។ ការកំណត់ផែនទីជនគោលដៅក៏ត្រូវពិចារណាអំពីបណ្តាញ និងទីតាំងដែលមានសារៈប្រយោជន៍បំផុតសម្រាប់ការប្រាស្រ័យទាក់ទង សកម្មភាពប្រាស្រ័យទាក់ទង និង ការលើកកម្ពស់ការយល់ដឹង អំពីសមធម៌យេនឌ័រ និងបញ្ហាដីធ្លី ដែលអង្គការ និងស្ថាប័នដទៃទៀតកំពុងអនុវត្ត ព្រមទាំងវិធីសាស្រ្ត និង ឧបករណ៍ដែលកំពុងត្រូវបានប្រើប្រាស់រួចទៅហើយ ដែលគេអាចពង្រឹងបន្ថែមទៅលើ វិធីសាស្រ្ត និងឧបករណ៍ទាំងនោះបាន។

ការកំណត់ជនគោលដៅ រាប់បញ្ចូលការសួរសំនួរអំពី តើនរណា/ស្ថាប័នណាដែលមានអាណត្តិការងារកសាង ការយល់ដឹងអំពីបញ្ហាយេនឌ័រ និងអភិបាលកិច្ចលើការកាន់កាប់ដីធ្លី និងការធានាថាបុគ្គល និងស្ថាប័នទាំងនេះ ត្រូវបានបញ្ចូលជាជនគោលដៅ និងជាតួអង្គនៅក្នុងការផ្តល់សារ។

ការរៀបចំសារ

គេត្រូវអភិវឌ្ឍ និងរៀបចំសារឱ្យបានប្រុងប្រយ័ត្ន ដោយពិចារណាអំពីជនគោលដៅ និងមាតិកានៃសារ ព្រមទាំង តើសារទាំងនោះនឹងត្រូវផ្តល់ជូនដោយរបៀបណា និងដោយនរណា ក៏ដូចជាបរិបទរបស់ប្រទេស និងគម្រោង ផងដែរ។

ប្រអប់ ៥.៥ ៖ ការរៀបចំសារតាមរយៈកិច្ចសន្ទនាសហគមន៍

សារកាន់តែមានភាពខ្លាំងក្លានៅពេលដែលអ្នកផ្តល់សារទាំងនោះ មានអារម្មណ៍ ថាពួកគេគឺជាម្ចាស់សារ ដូច្នេះ វាមានសារៈសំខាន់ក្នុងការអនុវត្តន៍អភិក្រម បែបចូលរួមមួយ ដើម្បីអភិវឌ្ឍសារ។ បច្ចេកទេសក៏មានសារៈសំខាន់ផងដែរ ដូចជា ការបង្ហាញអំពីការផ្លាស់ប្តូរថាជាការអភិវឌ្ឍន៍មួយបែបវិជ្ជមាន ដែល នាំមកនូវប្រយោជន៍សម្រាប់សហគមន៍ទាំងមូល ទំនងនឹងទទួលបានជោគជ័យ ច្រើនជាងការបង្ហាញថា វាមានពាក់ព័ន្ធទៅនឹងការបាត់បង់អំណាចរបស់អ្នក កាន់អំណាចដែលមានស្រាប់។ ដូច្នេះការវិភាគដែលគេត្រូវការសម្រាប់រៀបចំ សារគួរបញ្ចូលការពិចារណាអំពីបញ្ហាដែលសមធម៌យេនឌ័រ នៅក្នុងអភិបាលកិច្ច លើការកាន់កាប់ដីធ្លីបង្កឱ្យមានឡើងនាពេលបច្ចុប្បន្ន។

ភាពលម្អិតតូចមួយ ក៏អាចធ្វើឱ្យមានភពខុសគ្នាគួរឱ្យកត់សម្គាល់ចំពោះ របៀបដែលប្រជាពលរដ្ឋបកស្រាយសារផងដែរ។ ឧទាហរណ៍ គំនូរជីវចល ដែលបង្ហាញរូបភាពបុរស និងស្រ្តីម្នាក់ចុះបញ្ជីដីធ្លីរបស់ពួកគេ ដែលនៅក្នុង រូបភាពនោះ បុរសត្រូវបានបង្ហាញថា កំពុងចុះហត្ថលេខាទៅលើទម្រង់ ខណៈ ពេលដែលស្រ្តីឈរញញឹមនៅក្បែរគាត់ ពុំបញ្ជូនសារអំពីសមធម៌យេនឌ័រ ដូចការ ដែលរូបភាពបង្ហាញអំពីស្រ្តីចុះហត្ថលេខា

ប្រភព ៖ Renée Giovarelli's presentation on "Gender-equitable awareness raising" at the May 2011 technical workshop.

គម្រោងមួយដែលទទួលបានថវិកាគាំទ្រពីមូលនិធិ Nike និងអនុវត្ត ដោយអង្គការមិនមែនរដ្ឋាភិបាលរបស់សហរដ្ឋអាមេរិក ដែលមានឈ្មោះ ថា លែនដេសា នៅវេសប៊ែងហ្គាល ប្រទេសឥណ្ឌា បានអនុម័តប្រើប្រាស់ អភិក្រមសន្ទនាសហគមន៍មួយ ដើម្បីលើកកម្ពស់សន្តិសុខលើការកាន់កាប់ ដីធ្លីសម្រាប់កុមារី និង ដើម្បីត្រួតពិនិត្យទៅលើបញ្ហាស្នងមរតករបស់

ទៅលើទម្រង់ឡើយ។

វិធីសាស្រ្តសន្ទនាសហគមន៍ ដែលមានរៀបរាប់នៅក្នុងប្រអប់ ៥.៥ គឺជាឧបករណ៍មួយ ដែលមានឥទ្ធិពលខ្លាំងក្លា ដើម្បីជម្រុញឱ្យមានការផ្លាស់ប្តូរ ដែលបង្កលក្ខណៈឱ្យសហគមន៍ទាំងមូលស្តាប់ឮអំពីទស្សនៈរបស់សហគមន៍ដទៃទៀត។ កិច្ចសន្ទនារបស់សហគមន៍ ត្រូវបានអភិវឌ្ឍឡើងដោយអ្នកដែលធ្វើការងារលើបញ្ហាមេរោគអេដស៍/ជំងឺអេដស៍ និងបញ្ហាកាត់ច្រិបប្រដាប់ភេទស្រ្តីនៅអាហ្រ្វិក ដើម្បីប្រើប្រាស់ជាឧបករណ៍មួយសម្រាប់សម្របសម្រួលឱ្យមានការផ្លាស់ប្តូរផ្នែកវប្បធម៌ ហើយវាក៏មានសារៈប្រយោជន៍ដូចគ្នានៅក្នុងបញ្ហាដីធ្លីផងដែរ។ បើទោះជាដូច្នេះក្តី ការអនុវត្តន៍វិធីសាស្រ្តនៅក្នុងបរិបទដទៃទៀត ទាមទារឱ្យមានការយកលំនាំតាម ដូចជានៅក្នុងប្រទេសឥណ្ឌា ដែលគំនិតរបស់សហគមន៍មានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីអ្វីដែលបានរកឃើញនៅអាហ្វ្រិក ដោយសារតែការដែលគេត្រូវពិចារណាទៅលើវណ្ណៈ និងសាសនាព្រមទាំងយេនឌ័រ។ ដូច្នេះ វាពុំរមែងតែងតែអាចធ្វើទៅបានឡើយ ក្នុងការធ្វើការងារជាមួយសហគមន៍ទាំងមូល និងផ្តួចផ្តើមឱ្យមានប្រភេទកិច្ចសន្ទនាសហគមន៍ ដែលអាចធ្វើទៅបាននៅក្នុងបរិបទមួយចំនួន។

កុមារី ដែលមានលក្ខណៈកាន់តែទូលំទូលាយ។ អង្គការ លែនដេសា បានរៀបចំកិច្ចប្រជុំមួយចំនួន ដែលសហគមន៍ និង ក្រុមកុមារា និង កុមារីផ្សេងៗគ្នាពិភាក្សាអំពីបញ្ហាដែលធ្វើឱ្យកុមារីមានការលំបាកក្នុងការគ្រប់គ្រងទៅលើទ្រព្យសម្បត្តិ ដូចជាភាពក្រីក្រ ការទាមទារឱ្យផ្តល់ជំនូនអាពាហ៍ពិពាហ៍ទៅខាងបុរស ការឆាប់រៀបអាពាហ៍ពិពាហ៍។ ដោយសារតែការរិតបន្តឹងផ្នែកវប្បធម៌ទៅលើការប្រូបាច់បញ្ចូលគ្នានូវក្រុមប្រជាជនផ្សេងៗគ្នា គម្រោងត្រូវរៀបចំកិច្ចប្រជុំដោយឡែក ជាមួយក្រុមវណ្ណៈសាសនា និងក្រុមផ្សេងៗគ្នាដទៃទៀត មុនពេលដែលសហគមន៍ទាំងមូលអាចជួបគ្នា។

នៅពេលសន្ទនាជាមួយក្រុមដោយឡែកពីគ្នា អង្គការ លែនដេសា បានដឹងថាគោលបំណងរបស់គម្រោង ក្នុងការកាត់បន្ថយជំនូនអាពាហ៍ពិពាហ៍ដែលផ្តល់ជូនដោយគ្រួសារក្រីក្រ មានភាពផ្ទុយគ្នាទៅនឹងទស្សនៈរបស់សហគមន៍ថា ជំនូនតិចតួចធ្វើឱ្យកូនស្រីបាក់មុខ។ កុមារីពីគ្រួសារក្រីក្ររមែងតែងរៀបអាពាហ៍ពិពាហ៍ក្នុងវ័យក្មេង ដើម្បីឱ្យគ្រួសាររបស់ពួកគេអាចផ្តល់ជំនូនតិច។ ទីបំផុត សមាជិកសហគមន៍បានឈានដល់ការឯកភាពគ្នាថា ជាជាងការលុបបំបាត់ ឬ កាត់បន្ថយការផ្តល់ជំនូន គេអាចចាត់ទុកថាជំនូនមួយផ្នែក គឺជាទ្រព្យសម្បត្តិសម្រាប់កូនស្រីរបស់ពួកគេ។ កិច្ចសន្ទនាសហគមន៍ក៏បាននាំឱ្យមានការទាមទារពីម្តាយ និងកូនស្រីឱ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានមូលដ្ឋានផ្អែកលើដីធ្លី ដើម្បីអភិវឌ្ឍជំនាញដែលពួកគេអាចរកប្រាក់ចំណូលបានពីជំនាញទាំងនោះ។ ជាលទ្ធផលនៃអភិក្រមនេះ គម្រោងអាចផ្តល់កិច្ចគាំទ្ររបស់ខ្លួន ជូនដល់កុមារីជំទង់នៃគ្រួសារដែលគ្មានផ្ទះសម្បែង និងគ្មានដី ដើម្បីធ្វើការផ្លុះបញ្ចាំងអំពីប្រយោជន៍ និង សេចក្តីត្រូវការរបស់ពួកគេនៅក្នុងសហគមន៍។

✎បញ្ជីផ្ទៀងផ្ទាត់ ៥.៥ ៖
ការអភិវឌ្ឍន៍សារ

✓	កំណត់រកប្រព័ន្ធផ្សព្វផ្សាយដែលល្អបំផុតដើម្បីជ្រាបទៅដល់ស្រ្តី។
✓	ដឹងអំពីបរិយាកាសនយោបាយ តាមរយៈការធ្វើផែនទីអ្នកមានសិទ្ធិអំណាចមួយ

ប្រភព ៖ Sabine Pallas's presentation on "Developing communication and advocacy tools through action-oriented research in Africa" at the May 2011 technical workshop; ILC, 2011.

ដើម្បីកំណត់រកអ្នកពាក់ព័ន្ធសំខាន់ៗ។

- ✓ ស្គាល់អំពីជនគោលដៅ តាមរយៈការអនុវត្តន៍កំណត់ផែនទីរកជនគោលដៅ។
- ✓ សារត្រូវមានភាពសាមញ្ញ និងខ្លី។
- ✓ ត្រូវមានលក្ខណៈជាការបញ្ចុះបញ្ចូល ពុំមែនជាការបង្ខិតបង្ខំឡើយ។
- ✓ ប្រើប្រាស់រឿងរ៉ាវ និងការដកស្រង់ពីជីវិតពិត។
- ✓ ប្រើប្រាស់អង្គហេតុឱ្យបានច្បាស់លាស់ និង តួលេខប្រកបដោយភាពច្នៃប្រឌិត។

ចូរចងចាំ!

ជនគោលដៅខុសៗគ្នា មានសេចក្តីត្រូវការក្នុងការប្រាស្រ័យទាក់ទងខុសៗគ្នា។ គេត្រូវធ្វើការកែសម្រួលទៅលើភាសា និងផ្តល់សារទៅតាមប្រភេទអតិថិជនផ្សេងៗគ្នា ដើម្បីឱ្យពួកគេយល់ និងទទួលយកបានប្រសើរបំផុត។

ការជម្រុញឱ្យមានការចូលរួមពីស្ត្រី

ទីតាំង និងពេលវេលានៃកិច្ចប្រជុំមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីបង្កលក្ខណៈឱ្យស្ត្រីចូលរួម។ ឧទាហរណ៍ ស្ត្រីមែងតែងមានការងារធ្វើជាច្រើននៅឯផ្ទះ ដូច្នេះវាអាចមានភាពសមស្របក្នុងការរៀបចំកិច្ចប្រជុំក្រុមតូចៗ ដែលមានការចូលរួមពីស្ត្រីដែលរស់នៅជិតគ្នា នៅក្នុងផ្ទះរបស់ស្ត្រីណាម្នាក់។ ការអញ្ជើញស្ត្រីឱ្យយកអាហារសម្រាប់គ្រួសាររបស់ពួកគេទៅកាន់កន្លែងប្រជុំ ដើម្បីឱ្យពួកគេអាចដាំស្លរួមគ្នាក្នុងអំឡុងពេលនៃកិច្ចប្រជុំ ក៏អាចជួយបង្កើនការចូលរួមរបស់ស្ត្រីបានផងដែរ ដូចមានបញ្ជាក់នៅក្នុងឧទាហរណ៍ពីប្រទេសយូហ្គាន់ដា នៅក្នុងប្រអប់ ៥.៦។

វាអាចមានភាពប្រសើរបំផុតក្នុងការរៀបចំកិច្ចប្រជុំសម្រាប់ស្ត្រី នៅល្ងាចនោះ ក្រោយពេលដែលពួកគេបានបញ្ចប់ការងារប្រចាំថ្ងៃរបស់ពួកគេ។ បើទោះជាដូច្នេះក្តី កិច្ចប្រជុំនៅពេលល្ងាច អាចពុំមានភាពសមស្របនៅពេលដែលស្ត្រីរស់នៅឆ្ងាយពីគ្នា អាស្រ័យដោយសុវត្ថិភាព និងសន្តិសុខរបស់ពួកគេ អាចមានគ្រោះថ្នាក់នៅពេលដែលពួកគេដើរត្រឡប់ទៅផ្ទះវិញនៅពេលងងឹត។ វាមានសារៈសំខាន់ដែលត្រូវផ្តល់សារឱ្យមានភាពសាមញ្ញ និងច្បាស់លាស់នៅក្នុងកិច្ចប្រជុំពេលល្ងាច ដើម្បីឱ្យ កិច្ចប្រជុំអាចចប់មុនពេលដែលអ្នកចូលរួមគ្រប់រូបមានភាពនឿយហត់។

វាក៏មានសារៈសំខាន់ផងដែរ ដែលត្រូវរៀបចំ

ប្រអប់ ៥.៦ ៖ ការគាំទ្រឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចប្រជុំ

ប្រភព ៖ Rachael Knight's presentation on "Genderequitable participation in land governance: community land titling in Liberia, Mozambique and Uganda", and discussions of the communication working group at the May 2011 technical workshop; World Bank/FAO IFAD, 2009b: 441.

គម្រោងកសិរុក្ខកម្មមួយ នៅតំបន់ហ្គូឌីបានដា នៃខេត្តកាណាតាកា *ប្រទេសឥណ្ឌា* ដែលអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលមានឈ្មោះថា ស្ត្រីសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព គាំទ្រដល់កសិករជាស្ត្រី និងបុរសក្នុងមូលដ្ឋាន ក្នុងការធ្វើចម្ការសម្រាប់ប្រមូលផល និង ការយកកាបូន។ គម្រោងសម្រប

សម្រួលឱ្យមានការចូលរួមពីស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដោយពិចារណាទៅលើពេលវេលារបស់ស្ត្រី និង ឧបសគ្គផ្នែកវប្បធម៌នៅពេលរៀបចំបង្កើតវេទិកាសាធារណៈ។
ក្នុងអំឡុងពេលនៃការអនុវត្តន៍គម្រោងផ្តល់ប្លង់ដីសហគមន៍ របស់អង្គការច្បាប់អភិវឌ្ឍន៍អន្តរជាតិ នៅក្នុងតំបន់អូកេរ៉េ នៃ*ប្រទេសយូហ្គាន់ដា* ស្ត្រីបានរាយការណ៍ឱ្យដឹងថា ពួកគេត្រូវខកខានចូលរួមកិច្ចប្រជុំជាច្រើន អាស្រ័យដោយពួកគេត្រូវធ្វើការងារ និងពុំមានពេលវេលា។ ដូច្នេះ អ្នកគាំទ្រសហគមន៍ម្នាក់ បានស្នើសុំឱ្យស្ត្រីធ្វើម្ហូបអាហាររបស់ពួកគេទៅកន្លែងប្រជុំ បន្ទាប់មក ចំអិនអាហារទាំងអស់ ដើម្បីធានាថាស្ត្រីបានចូលរួមកិច្ចប្រជុំ។
គម្រោងមួយរបស់អង្គការអាកសិនអេដ ដែលទទួលបានពានរង្វាន់ នៅក្នុងប្រទេសម៉ាឡាវី បានបញ្ចូលការពិភាក្សាអំពីបញ្ហាយេនឌ័រ និងបញ្ហាដីធ្លី ទៅក្នុងថ្នាក់អក្ខរកម្មប្រចាំសប្តាហ៍សម្រាប់ស្ត្រី។

កិច្ចប្រជុំនៅកន្លែងដែលស្ត្រី អាចចូលរួមប្រកបដោយសុខុមាលភាព។ កិច្ចប្រជុំរបស់គម្រោងអាចច្របាច់បញ្ចូលគ្នាជាមួយកិច្ចប្រជុំដែលមានស្រាប់ ដែលមានការចូលរួមពីស្ត្រី ឬ រៀបចំនៅកន្លែងដែលស្ត្រីរមែងតែងជួបជុំគ្នា ដូចជាចំណុចប្រភពទឹករបស់រដ្ឋាភិបាល កន្លែងលក់ទឹកតែ ឬ មណ្ឌលអក្ខរកម្ម ដូចក្នុងករណីប្រទេសម៉ាឡាវី (ប្រអប់ ៥.៦)។

ការប្រើប្រាស់វិធីសាស្ត្រប្រាស្រ័យទាក់ទងប្រកបដោយសមធម៌យេនឌ័រ

វិធីសាស្ត្រប្រាស្រ័យទាក់ទង និងប្រព័ន្ធផ្សព្វផ្សាយមួយចំនួន មានប្រសិទ្ធភាពជាងវិធីសាស្ត្រ និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត ក្នុងការឈោងចាប់ជនគោលដៅផ្សេងៗគ្នា អាស្រ័យទៅលើការមានធនធាន ពេលវេលា និងការគ្រប់គ្រងទៅលើលទ្ធភាពទទួលបាន និងការប្រើប្រាស់។

ឧទាហរណ៍ វិទ្យុគឺជាឧបករណ៍មួយដ៏សំខាន់សម្រាប់លើកកម្ពស់ការយល់ដឹង ការផ្សព្វផ្សាយកសិកម្ម និងការផ្សព្វផ្សាយព័ត៌មាននៅតំបន់ជនបទ និងសហគមន៍ដែលស្ថិតនៅដាច់ដោយឡែកពីគេ។ គេក៏អាចប្រើប្រាស់វិទ្យុនៅក្នុងអភិក្រមបែបចូលរួមផងដែរ ដូចដែលគម្រោងឌីមីត្រារបស់អង្គការ FAO មានរៀបរាប់នៅក្នុងប្រអប់ ៥.៧។ អភិក្រមរបស់គម្រោងឌីមីត្រា គឺជាការអនុវត្តន៍ល្អមួយសម្រាប់ប្រើប្រាស់នៅតំបន់ជនបទ ដើម្បីលើកទឹកចិត្តឱ្យមានការជែកញែក និងការពិភាក្សា។ បើទោះជាដូច្នេះក្តី នៅក្នុងករណីមួយចំនួន បុរសគឺជាអ្នកគ្រប់គ្រងទៅលើការប្រើប្រាស់ និង លទ្ធភាពប្រើប្រាស់វិទ្យុគ្រួសារ។

ប្រអប់ ៥.៧ ៖

វិទ្យុសហគមន៍ក្នុងលក្ខណៈជាឧបករណ៍ទំនាក់ទំនងមួយដើម្បីឱ្យមានការផ្លាស់ប្តូរ - គម្រោងឌីមីត្រា

ប្រភព ៖ FAO-Dimitra, 2008; 2010a; 2010b; 2011a; 2011b; 2011c; Eliane Najros, personal

ឌីមីត្រា គឺជាគម្រោងមួយរបស់អង្គការ FAO ព្រមទាំងជាបណ្តាញស្តីពីសមភាពយេនឌ័រ ព័ត៌មាន ទំនាក់ទំនង និងសន្តិសុខស្បៀងនៅតំបន់ជនបទ។ ជាមួយនឹងដៃគូនៅក្នុង*ប្រទេសណៃជឺ និង សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ* (DRC) ក្នុងឆ្នាំ២០០៦ គម្រោងឌីមីត្រា បានអភិវឌ្ឍឱ្យមានក្លឹបអ្នកស្តាប់សហគមន៍ ដែលបច្ចុប្បន្នមានសមាជិកប្រមាណ ៨.០០០នាក់ នៅក្នុងប្រទេសទាំងពីរនេះ។

ក្រុមដោយឡែកពីគ្នា និងក្រុមចម្រុះ ដែលមានអ្នកភូមិជាស្ត្រី និងបុរស ជួបប្រជុំគ្នាជាទៀងទាត់ ដើម្បីពិភាក្សាអំពីបញ្ហាកង្វល់ និងឧបសគ្គរបស់ពួកគេ ព្រមទាំងចាត់វិធានការសមូហភាពដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ស្ថានីយវិទ្យុជនបទបញ្ជូនបន្ត និងផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក ដោយផ្តល់លទ្ធភាពកាន់តែទូលំទូលាយចំពោះ

communication.

ការទទួលបានចំណេះដឹង និងការលើកកម្ពស់ការយល់ដឹងអំពីប្រធានបទ ដែលសមាជិកក្លឹបបានកំណត់រកឃើញ ដូចជា ការអនុវត្តន៍នៅក្នុងវិស័យកសិកម្ម សន្តិសុខស្បៀង ការទទួលបានដីធ្លី អនាម័យ។ល។ សមាជិកក្លឹបប្រើប្រាស់វិទ្យុដែលប្រើថាមពលពន្លឺព្រះអាទិត្យ និង វិទ្យុវ៉ៃ និង (ជូនកាល) ទូរស័ព្ទដៃ ដើម្បីទាក់ទងជាមួយគ្នាទៅវិញទៅមក និង ក្លឹបដទៃទៀត។ តាមរយៈកិច្ចសន្ទនា និងសកម្មភាព ប្រជាពលរដ្ឋជនបទទទួលបានព័ត៌មានកាន់តែប្រសើរ ចែករំលែកចំណេះដឹង ទទួលបានទំនុកចិត្តលើខ្លួនឯង និងហ៊ាននិយាយ។ ដំណើរការនេះ ក៏លើកទឹកចិត្តឱ្យពួកគេចូលរួមសកម្មនៅក្នុងជីវិតសហគមន៍ផងដែរ។

លទ្ធផលមួយចំនួនក្នុងចំណោមលទ្ធផលទាំងនេះ មានសារៈប្រយោជន៍ជាពិសេសក្នុងការលើកកម្ពស់សមធម៌យេនឌ័រ។ ឧទាហរណ៍ នៅក្នុងប្រទេសណៃជឺ ស្ត្រីនៅក្នុងភូមិបានីហ្សូមប៊ូ បានចរចារជាមួយបុរសជាម្ចាស់ដីក្នុងមូលដ្ឋាន ដើម្បីទទួលបានការជួលដី ២,៧៥ហិកតា ដែលមានគុណភាពល្អសម្រាប់ដាំបន្លែ រយៈពេល ៩៩ឆ្នាំ។ នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ តាមរយៈការពិភាក្សាក្នុងចំណោមក្លឹបអ្នកស្ដាប់នៅប៊ូហ្គោប៊ី (កាបារី) គេឃើញថា បុរសកាន់កាប់តំបន់ដីសើមដែលមានជីជាតិដើម្បីដាំអំពៅ។ ចំណុចនេះ មានផលប៉ះពាល់គួរឱ្យកត់សម្គាល់ទៅលើស្ថានភាពស្បៀងអាហាររបស់គ្រួសារ អាស្រ័យដោយវាធ្វើឱ្យស្ត្រីខ្វះដីសម្រាប់ដាំដំណាំដទៃទៀត។ ក្លឹបអ្នកស្ដាប់បានផ្ដល់ព័ត៌មានដល់អាជ្ញាធររដ្ឋបាល និង អាជ្ញាធរបែបប្រពៃណី ដែលបានកំណត់ពន្ធខ្ពស់ខ្លាំងទៅលើអ្នកដាំអំពៅ។ ជាលទ្ធផល ដីប្រមាណ ៧០% បានវិលត្រឡប់មកជាការដាំបន្លែ និងផ្លែឈើវិញ។

ឧទាហរណ៍ទាំងនេះ បង្ហាញអំពីរបៀបដែលការទទួលបានព័ត៌មាន និងការប្រាស្រ័យទាក់ទងកាន់តែប្រសើរ អាចជម្រុញឱ្យមានការសួរសំនួរចំពោះការអនុវត្តន៍ដែលពុំមានសមធម៌យេនឌ័រ និងការពិភាក្សាអំពីបញ្ហាអភិវឌ្ឍសហគមន៍សំខាន់ៗ ទាក់ទងទៅនឹងវិស័យកសិកម្ម សន្តិសុខស្បៀង សិទ្ធិស្ត្រី។ល។ ដែលនាំឱ្យមានការធ្វើចលនាសង្គម និងការផ្ដល់ភាពអង់អាចដល់សមាជិកសហគមន៍ ជាពិសេសស្ត្រី។ បុរសម្នាក់បានរៀបរាប់អំពីរបៀបដែលការចូលរួមរបស់គាត់នៅក្នុងក្លឹបអ្នកស្ដាប់ ក្នុងតំបន់កាឡេហេនៃខេត្តគីវូភាគខាងត្បូង សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ថាវាគឺជាលើកដំបូងដែលគាត់បានចូលរួមនៅក្នុងការពិភាក្សាវែកញែកស្ដីពីការយល់ដឹងអំពីយេនឌ័រ។ "ខ្ញុំតែងតែគិតថា នេះគឺជាប្រធានបទដែលលម្អៀងទៅលើស្ត្រី និង ប្រឆាំងចំពោះបុរស!"។

ស្ត្រីជនបទរមែងតែងមានលទ្ធភាពមានកម្រិតខ្លាំង ក្នុងការទទួលបានប្រព័ន្ធផ្សព្វផ្សាយក្នុងទម្រង់បោះពុម្ព និងព័ត៌មានបោះពុម្ព ដូច្នេះ គេគួរផ្ដោតយកចិត្តទុកដាក់ជាពិសេសទៅលើឧបករណ៍ប្រាស្រ័យទាក់ទងផ្ទាល់មាត់ និងឧបករណ៍ប្រាស្រ័យទាក់ទងបែបទស្សនីយភាព។ គេក៏អាចត្រូវបកប្រែសារ និងព័ត៌មានជាភាសាក្នុងមូលដ្ឋានផងដែរ និងគួរជៀសវាងប្រើប្រាស់ពាក្យបច្ចេកទេស ឬ ភាសាច្បាប់។ ការសម្ដែងល្ខោនតាមសហគមន៍ សៀវភៅគំនូរជីវចល ចំរៀង ផ្ទាំងបដារ និងវីដេអូ គឺជាឧបករណ៍បន្ថែម ដូចមានរៀបរាប់នៅក្នុងប្រអប់ ៥.៨ អំពីគម្រោងមួយនៅក្នុងប្រទេសម៉ាឡាវី។

សកម្មភាពជាមួយមេដឹកនាំបែបប្រពៃណី ដែលអាចមានប្រសិទ្ធភាពខ្លាំងក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរសង្គម នៅពេលដែលពួកគេដឹង និង ទទួលស្គាល់អំពីធម្មានុរូបនៃបញ្ហាយេនឌ័រ។
ការចងក្រងឯកសារវីដេអូដែលរួមមានបទចំរៀង កំណាព្យ ល្ខោន និង សម្លេងផ្សេងៗគ្នា ប៉ុន្តែ ជួនកាល ប្រជាជនមិនចង់បង្ហាញមុខនៅក្នុងម៉ាស៊ីនថត និងបង្ហាញអត្តសញ្ញាណរបស់ពួកគេឡើយ។
ល្ខោនសម្រាប់ការអភិវឌ្ឍន៍ផ្តោតលើបញ្ហាដីធ្លី ដែលមានវិសមភាពយេនឌ័រ និងការផ្សព្វផ្សាយអំពីគំហើញនៃការស្រាវជ្រាវនៅក្នុងសហគមន៍ ដែលផ្តល់ឱកាសជូនដល់ជនគោលដៅ ដើម្បីពិភាក្សាអំពីតថភាពជាក់ស្តែងរបស់ពួកគេ និង ស្វែងរកដំណោះស្រាយ ដើម្បីធ្វើការតស៊ូមតិទាក់ទងទៅនឹងបញ្ហាដីធ្លី។
ការផ្លាស់ប្តូរទស្សនៈកិច្ចគ្នាទៅវិញទៅមក រវាងសហគមន៍បិតាធិបតេយ្យ និងមាតាធិបតេយ្យ ដើម្បីប្រៀបធៀបប្រព័ន្ធកាន់កាប់ដីធ្លីរបស់ពួកគេ ដែលនេះគឺជាវិធីសាស្រ្តទំនាក់ទំនងមួយដែលត្រូវប្រើធនធានច្រើន។
លំហាត់ទស្សនៈវិស័យសហគមន៍ ដែលស្ត្រី និងបុរសក្នុងសហគមន៍គូរផែនទីអំពីរូបភាពនៃកម្មសិទ្ធិភាព និង ការគ្រប់គ្រងដីធ្លីរបស់ស្ត្រី។

ប្រអប់ ៥.៨ ៖
វិធីសាស្រ្តទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយ ប្រកបដោយសមធម៌យេនឌ័រ

ប្រភព ៖ WOLREC, 2011.

